رئاسة الشؤون الدينية
بالمسجد الحرام والمسجد النبوي

التَّحْقِيقُ وَالإِيضَاحُ لِكَثِيرٍ مِنْ مَسَائِلِ الحَجِّ وَالعُمْرَةِ وَالزِّيَارَةِ عَلَى ضَوءِ الكِتَابِ وَالسُّنَّةِ

ភាសាខ្មែរ

خميري

# ការស្រាវជ្រាវបញ្ជាក់ និងការពន្យល់លម្អិតអំពីបញ្ហាជាច្រើននៃហាជ្ជី អុំរ៉ោះ និងហ្ស៊ីយ៉ារ៉ោះ(ការទស្សនកិច្ច) យោងតាមគម្ពីរគួរអាន និងសុណ្ណ

របស់អ្នកប្រាជ្ញឥស្លាម ស្ដេខ អាល់ឡើម៉ាស់
អាប់ទុលអាហ្ស៊ីស កូន អាប់ទុលឡោះ ពិន ហ្បាហ្ស

ⓒجمعية خدمة المحتوى الإسلامي باللغات ، ١٤٤٧هـ

بن باز ، عبدالعزيز
التحقيق والإيضاح لكثير من مسائل الحج والعمرة والزيارة على ضوء الكتاب والسنة - خميري. / عبدالعزيز بن باز - ط١. .- الرياض ، ١٤٤٧هـ
١٩٤ ص ؛ ..سم

رقم الإيداع: ١٤٤٧/١٧٩٩٥
ردمك: ٩-٢٤٧-٥١٧-٦٠٣-٩٧٨

# التَّحْقِيقُ وَالإِيضَاحُ
# لِكَثِيرٍ مِنْ مَسَائِلِ الحَجِّ وَالعُمْرَةِ وَالزِّيَارَةِ
# عَلَى ضَوءِ الكِتَابِ وَالسُّنَّةِ

# ការស្រាវជ្រាវបញ្ជាក់
# និងការពន្យល់លម្អិតអំពីបញ្ហាជាច្រើននៃហជ្ជី អំ្ុរ៉េាះ និងហ្សីយ៉ារ៉ោះ(ការទស្សនកិច្ច)
# យោងតាមគម្ពីរគួរអាន និងសុណ្ណ


سَمَاحَةُ الشَّيْخِ

عَبْدِ الْعَزِيزِ بْنِ عَبْدِ اللَّهِ بْنِ بَازٍ رَحِمَهُ اللَّهُ

របស់អ្នកប្រាជ្ញឥស្លាម ស្ហេខ អាល់ឡើម៉ាស់
អាប់ទុលអាហ្ស៊ីស កូន អាប់ទុលឡោះ ពិន ហ្គាហ្ស

بِسْمِ اللهِ الرَّحْمَنِ الرَّحِيمِ

# ការស្រាវជ្រាវបញ្ជាក់ និងការពន្យល់លម្អិតអំពីបញ្ហាជាច្រើននៃហាជ្ជី អំ្រោះ និងហ្ស៊ីយ៉ារ៉ោះ(ការទស្សនកិច្ច) យោងតាមគម្ពីរគួរអាន និងសុណ្ណះ

របស់អ្នកប្រាជ្ញឥស្លាម ស្ហេខ អាល់ឡើម៉ាស់ អាប់ទុលអាហ្ស៊ីស កូន អាប់ទុលឡោះ ពិន ហ្បាហ្ស

## អារម្ភកថា អ្នកនិពន្ធ

រាល់ការសរសើរតម្កើង សម្រាប់អល់ឡោះជាម្ចាស់នៃពិភពទាំងអស់ ហើយទីបញ្ចប់ដ៏ល្អគឺសម្រាប់បណ្ដាអ្នកដែលកោតខ្លាចអល់ឡោះ សូមទ្រង់ប្រទានពរជ័យ និងសុខសន្តិភាពពេញលេញដល់ខ្ញុំបម្រើ និងរ៉សូល(អ្នកនាំសារ)របស់ទ្រង់ គឺមូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារ ហើយនិងសហការី(សហាហ្បាត់)របស់លោកទាំងអស់គ្នា។

បន្ទាប់មកទៀត៖

នេះគឺជាសារសង្ខេបអំពីហាជ្ជី និងការបកស្រាយអំពីភាពប្រសើរ និងសុជីវធម៌របស់វា ក៏ដូចជាអ្វីដែលអ្នកដែលមានបំណងធ្វើដំណើរទៅបំពេញវាគួរតែដឹង

ព្រមទាំងការបកស្រាយអំពីបញ្ហាសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងហាជ្ជី អំុរ៉ោះ និងការទស្សនកិច្ចដោយសង្ខេបនិងច្បាស់លាស់ ដែលនៅក្នុងនោះខ្ញុំបានខិតខំស្រាវជ្រាវយ៉ាងហ្មត់ចត់នូវអ្វីដែលត្រូវបានចង្អុលបង្ហាញនៅក្នុងគម្ពីររបស់អល់ឡោះ និងសុណ្ណះរបស់រ៉សូល ﷺ ហើយខ្ញុំបានចងក្រងវាឡើងដើម្បីជាការដាស់តឿនសម្រាប់បណ្តាមូស្លីម និងដើម្បីអនុវត្តតាមព្រះបន្ទូលរបស់អល់ឡោះជ៏ខ្ពង់ខ្ពស់ដែលទ្រង់មានព្រះបន្ទូលថា៖

﴿وَذَكِّرْ فَإِنَّ الذِّكْرَىٰ تَنفَعُ الْمُؤْمِنِينَ ﴿٥٥﴾﴾

ហើយចូរអ្នកដាស់រំឭកគ្នាចុះ ព្រោះការដាស់រំឭកគ្នានោះ ពិតជាផ្តល់ផលប្រយោជន៍ដល់បណ្តាអ្នកដែលមានជំនឿ។ [គម្ពីរគួរអាន ៥១:៥៥] ទ្រង់បានមានបន្ទូលទៀតថា៖

﴿وَإِذْ أَخَذَ اللَّهُ مِيثَاقَ الَّذِينَ أُوتُوا الْكِتَابَ لَتُبَيِّنُنَّهُ لِلنَّاسِ وَلَا تَكْتُمُونَهُ...﴾

ហើយ(ចូរចងចាំ)នៅពេលដែលអល់ឡោះបានយកកិច្ចសន្យាពីពួកដែលគេបានផ្តល់គម្ពីរឱ្យ(យ៉ាហ៊ូទី និងណាសរ៉នី) ដើម្បីឱ្យពួកអ្នកបំភ្លឺវាដល់មនុស្សលោក ហើយកុំឱ្យពួកអ្នកលាក់បាំងវា...... [គម្ពីរគួរអាន ៣:១៨៧] ទ្រង់បានមានបន្ទូលទៀតថា៖

﴿...وَتَعَاوَنُوا عَلَى الْبِرِّ وَالتَّقْوَىٰ...﴾

...ហើយចូរពួកអ្នកសហការគ្នាក្នុងការធ្វើអំពើល្អ និងកោតខ្លាចអល់ឡោះ... [គម្ពីរគួរអាន ៥:២]

ហើយនៅក្នុងហាទីស្ហ សហ៊ើស របស់ព្យាការីមូហាំម៉ាត់ﷺ លោកបានមានប្រសាសន៍ថា៖

«الدِّينُ النَّصِيحَةُ، ثَلَاثًا، قِيلَ: لِمَنْ يَا رَسُولَ اللَّهِ؟ قَالَ: لِلَّهِ وَلِكِتَابِهِ وَلِرَسُولِهِ وَلِأَئِمَّةِ الْمُسْلِمِينَ وَعَامَّتِهِمْ».

"សាសនា គឺជាការអប់រំទូន្មានទៅកាន់អ្នកដទៃ" (ចំនួនបីដង)។ មានគេសួរថា៖ ឱរ៉ស៊ូលុលឡោះ! តើការទូន្មាននោះសម្រាប់អ្នកណា? លោកបានឆ្លើយថា៖ "សម្រាប់អល់ឡោះ សម្រាប់គម្ពីររបស់ទ្រង់ សម្រាប់រ៉សូលរបស់ទ្រង់ សម្រាប់អ្នកដឹកនាំ(អ៊ីម៉ាំ) របស់បណ្តាមូស្លីម និងសម្រាប់មហាជនទូទៅរបស់ពួកគេ"[1]។

អាត់-តប់រ៉នី បានរាយការណ៍អំពី ហ៊ូហៃហ្វះ ថា៖ពិតណាស់ ព្យាការីមូាំម៉ាត់ ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ لَمْ يَهْتَمَّ بِأَمْرِ الْمُسْلِمِينَ فَلَيْسَ مِنْهُمْ، وَمَنْ لَمْ يُصْبِحْ وَيُمْسِ نَاصِحًا لِلَّهِ وَلِرَسُولِهِ وَلِكِتَابِهِ وَلِإِمَامِهِ وَلِعَامَّةِ الْمُسْلِمِينَ فَلَيْسَ مِنْهُمْ».

"«ជនណាដែលមិនយកចិត្តទុកដាក់ចំពោះកិច្ចការរបស់បណ្តាអ្នកមូស្លីម នោះរូបគេមិនមែនជាក្រុមរបស់ពួកគេឡើយ,

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម៖៥៥

ហើយជនណាដែលមិនមានចិត្តស្មោះត្រង់ចំពោះអល់ឡោះ, ចំពោះរ៉សូលរបស់ទ្រង់, ចំពោះគម្ពីររបស់ទ្រង់, ចំពោះមេដឹកនាំរបស់ខ្លួន និងចំពោះបណ្ដាមូស្លីមទូទៅ នោះរូបគេមិនមែនជាមនុស្សម្នាក់ក្នុងក្រុមរបស់ពួកគេដែរ»[1]។"

យើងសូមបួងសួងពីអល់ឡោះជាម្ចាស់ សូមទ្រង់មេត្តាផ្ដល់ជាប្រយោជន៍ដល់ខ្ញុំបាទ និងបណ្ដាជនមូស្លីមតាមរយៈកិច្ចការនេះ និងសូមទ្រង់ធ្វើឱ្យការខិតខំប្រឹងប្រែងនេះមានភាពបរិសុទ្ធជ្រះថ្លាសម្រាប់ទ្រង់ ហើយជាមូលហេតុនៃការទទួលបានជោគជ័យនៅចំពោះទ្រង់ក្នុងឋានសួគ៌ណាអ៊ីម។ ពិតប្រាកដណាស់ ទ្រង់មហាឮ ជាអ្នកទទួលយកការបួងសួង ហើយទ្រង់គឺគ្រប់គ្រាន់សម្រាប់យើង ហើយទ្រង់គឺជាអ្នកចាត់ចែងដ៏ប្រសើរបំផុត។

## ជំពូក

## ភស្ដុតាងនានានៃការដាក់កាតព្វកិច្ចហាជ្ជី និងអ៊ុំរ៉ោះ និងការរួសរាន់ក្នុងការបំពេញអ៊ីហ្ពាទាត់ទាំងពីរនេះ។

នៅពេលដែលបានជ្រាបរឿងនេះហើយ

1 រាយការណ៍ដោយ អាត់តប់រ៉នីក្នុងសៀវភៅ អាល់អៅសត់៖៧៤៦៩

សូមពួកអ្នកដឹងថា -
សូមអល់ឡោះជាម្ចាស់ប្រទានការចង្អុលបង្ហាញដល់ខ្ញុំនិងពួកអ្នក
ដើម្បីឱ្យស្គាល់សច្ចធម៌និងប្រតិបត្តិតាមវា -
ពិតប្រាកដណាស់
អល់ឡោះជាម្ចាស់ទ្រង់បានដាក់កាតព្វកិច្ចឱ្យខ្ញុំបម្រើរបស់ទ្រង់ធ្វើហាជ្ជីទៅកាន់ពៃតុលហារ៉មរបស់ទ្រង់ ហើយទ្រង់បានចាត់ទុកវាជាសសរគ្រឹះមួយនៃសាសនាឥស្លាម។ ទ្រង់បានមានព្រះបន្ទូលថា៖

﴿...وَلِلَّهِ عَلَى النَّاسِ حِجُّ الْبَيْتِ مَنِ اسْتَطَاعَ إِلَيْهِ سَبِيلًا وَمَنْ كَفَرَ فَإِنَّ اللَّهَ غَنِيٌّ عَنِ الْعَالَمِينَ﴾

ហើយអល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចទៅលើមនុស្សឱ្យធ្វើធម្មយាត្រាហាជ្ជីនៅឯពៃទុលឡោះចំពោះជនណាដែលមានលទ្ធភាពទៅដល់ទីនោះ។ ហើយជនណាដែលប្រឆាំងនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់មិនត្រូវការអ្វីមួយពីពិភពទាំងអស់ឡើយ។ [គម្ពីរគួរអាន ៣:៩៧]

នៅក្នុងសហ៊ីសទាំងពីរ អំពី អ៊ិបនូអ៊ូមើរ رضي الله عنهما ពិតណាស់ ព្យាការីមូហាំម៉ាត់ ﷺ លោកបានមានប្រសាសន៍ថា៖

«بُنِيَ الإِسْلَامُ عَلَى خَمْسٍ: شَهَادَةِ أَنْ لَا إِلَهَ إِلَّا اللَّهُ، وَأَنَّ مُحَمَّدًا رَسُولُ اللَّهِ، وَإِقَامِ الصَّلَاةِ، وَإِيتَاءِ الزَّكَاةِ، وَصَوْمِ رَمَضَانَ، وَحَجِّ بَيْتِ اللَّهِ الحَرَامِ».

“គេបានស្ថាបនាឥស្លាមលើមូលដ្ឋានគ្រឹះប្រាំយ៉ាងគឺៈ ការធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះ ហើយមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ ប្រតិបត្តិសឡាត បរិច្ចាគហ្សាកាត់ បួសខែរ៉ម៉ាទន និងធ្វើធម្មយាត្រាហាជ្ជីនៅពៃតុលហារ៉ម(ម៉ាក្កះ)”[1]។

ហើយសាអុ៊ីតបានរាយការណ៍នៅក្នុងស៊ូណាន់របស់គាត់ថា៖ អំពី អ៊ូមើរ ពិន អាល់ខត្តប رضي الله عنه ថាគាត់បាននិយាយថាៈ “ពិតណាស់ ខ្ញុំមានបំណងថានឹងបញ្ជូនបុរសមួយចំនួនទៅកាន់ទីក្រុងទាំងនេះ(តំបន់ផ្សេងៗនៅក្នុងរដ្ឋឥស្លាម) ដើម្បីឲ្យពួកគេពិនិត្យមើលគ្រប់អ្នកដែលមានលទ្ធភាព( សេដ្ឋកិច្ច រទេះ និងលុយសម្រាប់ធ្វើដំណើរ )តែមិនបានធ្វើហាជ្ជីទេ ដើម្បីដាក់ជីសយ៉ះទៅលើពួកគេ។ ពួកគេមិនមែនជាជនមូស្លីមឡើយ, ពួកគេមិនមែនជាជនមូស្លីមឡើយ”។[2][3]

គេបានរាយការណ៍អំពី អាលី رضي الله عنه ថាលោកបាននិយាយថាៈ៥

"ជនណាដែលមានសមត្ថភាពធ្វើធម្មយាត្រាហាជ្ជី

---

1 រាយការណ៍ដោយ អាល់ពូខរីៈ៨, និងមូស្លីមៈ១៦

2 បានបញ្ជាក់ប្រភពនៅក្នុងសៀវភៅ ហ្វាមីអ៊ុលអាហាទីស្ចៈ៣១២២១ ថារាយកចេញពីសៀវភៅ ស៊ូណាន់ សាអ៊ីត កូន ម៉ាន់ស៊ួរ ប៉ុន្តែខ្ញុំមិនបានរកឃើញវានៅក្នុងច្បាប់ដែលខ្ញុំមានឡើយ។

3 ពោលគឺ ទ្រព្យសម្បត្តិដ៏ច្រើនសន្ធឹកសន្ធាប់។

ប៉ុន្តែគេបានបោះបង់វាចោល(មិនទៅធ្វើ) នោះគ្មានអ្វីដែលត្រូវខ្វល់ខ្វាយឡើយថាគេនឹងស្លាប់ទៅក្នុងសភាពជាជនជាតិយូដា ឬជាគ្រិស្ទាន"[1]។

វ៉ាជិប(កាតព្វកិច្ចចាំបាច់)លើអ្នកដែលមិនទាន់បានធ្វើហាជ្ជី ទាំងដែលរូបគេមានលទ្ធភាព ត្រូវរួសរាន់ទៅធ្វើវា ដោយយោងតាមអ្វីដែលត្រូវបានរាយការណ៍ពីលោក អ៊ិបនូ អាប់ហ្គាស់ رضي الله عنه ថា ព្យាការី មូហាំម៉ាត់ﷺ បានមានប្រសាសន៍ថា៖

«تَعَجَّلُوا إِلَى الحَجِّ - يَعْنِي الفَرِيضَةَ - فَإِنَّ أَحَدَكُمْ لَا يَدْرِي مَا يَعْرِضُ لَهُ».

"ចូរពួកអ្នករួសរាន់ទៅធ្វើហាជ្ជី ព្រោះម្នាក់ៗនៃពួកអ្នកមិនដឹងថា អ្វីនឹងកើតឡើងចំពោះគេនោះឡើយ"។[2]

ដោយសារតែការធ្វើហាជ្ជីគឺជាកាតព្វកិច្ចដែលត្រូវតែប្រតិបត្តិជាបន្ទាន់ចំពោះអ្នកដែលមានលទ្ធភាព ដោយផ្អែកលើជាក់ស្តែកស្តុតាងនៃបន្ទូលរបស់អល់ឡោះជាម្ចាស់ថា៖

﴿...وَلِلَّهِ عَلَى النَّاسِ حِجُّ الْبَيْتِ مَنِ اسْتَطَاعَ إِلَيْهِ سَبِيلًا وَمَنْ كَفَرَ فَإِنَّ اللَّهَ غَنِيٌّ عَنِ الْعَالَمِينَ﴾

ហើយអល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចលើមនុ

---

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី៖៨១២

2 រាយការណ៍ដោយ អាពូហ្ទើវូទ៖១៧៣២

ស្សលោកឱ្យធ្វើបុណ្យហាជ្ជីនៅផ្ទះរបស់អល់ឡោះ(ម៉ាក្កះ) ចំពោះអ្នកដែលមានលទ្ធភាពទៅដល់ទីនោះ។ ហើយជនណាដែលប្រឆាំងនោះ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់មហាមានលើសលប់មិនត្រូវការអ្វីមួយពីពិភពទាំងអស់ឡើយ។ [គម្ពីរគួរអាន ៣:៩៧]
ព្យាការីមូហាំម៉ាត់ ﷺ លោកបានមានប្រសាសន៍នៅក្នុងសុន្នរកថា(យុតហ្គ្លះ) របស់លោកថា៖

«أَيُّهَا النَّاسُ، إِنَّ اللَّهَ فَرَضَ عَلَيْكُمُ الْحَجَّ فَحُجُّوا».

«ឱមនុស្សលោក!៖ ពិតណាស់ អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចហាជ្ជីលើពួកអ្នកហើយ ដូច្នេះ ចូរពួកអ្នកធ្វើហាជ្ជីចុះ»។1

មានហាទីសជាច្រើនដែលបញ្ជាក់អំពីកាតព្វកិច្ចនៃការធ្វើអ៊ុំរ៉ោះផងដែរ ក្នុងនោះមាន៖

ប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ ﷺ នៅក្នុងចម្លើយរបស់លោកទៅកាន់ជីព្រីល នៅពេលដែលគាត់បានសាកសួរលោកអំពីឥស្លាម, លោកបានមានប្រសាសន៍ថា៖

«الإِسْلَامُ أَنْ تَشْهَدَ أَنْ لَا إِلَهَ إِلَّا اللَّهُ وَأَنَّ مُحَمَّدًا رَسُولُ اللَّهِ، وَتُقِيمَ الصَّلَاةَ، وَتُؤْتِيَ الزَّكَاةَ، وَتَحُجَّ الْبَيْتَ وَتَعْتَمِرَ، وَتَغْتَسِلَ مِنَ الْجَنَابَةِ، وَتُتِمَّ الْوُضُوءَ، وَتَصُومَ رَمَضَانَ».

«ឥស្លាមគឺ ការដែលអ្នកធ្វើសាក្សីថា គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ពិតប្រាកដ

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម (1337)។

លើកលែងតែអល់ឡោះម្នាក់គត់ ហើយមូហាំម៉ាត់គឺជាអ្នកនាំសាររបស់អល់ឡោះ, បញ្ឈរសឡាត, បរិច្ចាគហ្សាកាត់, ធ្វើធម្មយាត្រាហាជ្ជី និងធ្វើអ៊ុំរ៉ោះ, ងូតទឹកជូនូប, បំពេញវូហ្ចូឲ្យបានពេញលេញ និងបួសខែរ៉ម៉ាទន»[1] រាយការណ៍ដោយ អ៊ិបនូឃូហ្សៃម៉ះ និង អាត់ទើរ៉ូកុតនី ពីហាទីស្ទរបស់ អ៊ូមើរ កូន អាល់ខត្តប رضي الله عنه, ហើយលោក អាត់ទើរ៉ូកុតនី បានមានប្រសាសន៍ថា៖ នេះគឺជាអ៊ីសណាទ(បណ្តាញរាយការណ៍) ដែលរឹងមាំ និងសហើស។

ហើយនិង សេចក្តីរាយការណ៍អំពី អាអ៊ីស្ហះ رضي الله عنها ពិតណាស់ គាត់បាននិយាយថា៖

«يَا رَسُولَ اللَّهِ، هَلْ عَلَى النِّسَاءِ مِنْ جِهَادٍ؟ قَالَ: عَلَيْهِنَّ جِهَادٌ لَا قِتَالَ فِيهِ: الحَجُّ وَالعُمْرَةُ».

«ឱរ៉ស៊ូលុលឡោះ! តើសម្រាប់ស្ត្រីមានការតស៊ូ(ជីហាទ)ដែរឬទេ?» លោកបានឆ្លើយថា៖ «សម្រាប់ពួកនាងមានការតស៊ូ(ជីហាទ)ដែលគ្មានការប្រយុទ្ធនៅក្នុងនោះ គឺការធ្វើហាជ្ជី និងការធ្វើអ៊ុំរ៉ោះ»[2] រាយការណ៍ដោយ អះម៉ាត់ និងអ៊ិបនូម៉ាហ្ជះ ដោយបណ្តាញរាយការណ៍សហើស។

---

1 រាយការណ៍ដោយ អ៊ិបនូឃូហ្សៃម៉ះ ៖១

2 រាយការណ៍ដោយ អាល់ពូខរី៖១៥២០

ហើយកាតព្វកិច្ចហាជ្ជីនិងអ៊ុមរ៉ោះគឺតម្រូវឲ្យធ្វើតែ ១ដងប៉ុណ្ណោះក្នុងមួយជីវិត យោងតាមប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ ﷺ នៅក្នុងហាទីស្ហដែលត្រឹមត្រូវថា៖

«الحَجُّ مَرَّةٌ، فَمَنْ زَادَ فَهُوَ تَطَوُّعٌ».

«ការធ្វើហាជ្ជីគឺមានតែម្តងគត់(ដែលជាកាតព្វកិច្ច), ដូច្នេះ អ្នកណាដែលធ្វើលើសពីនេះ នោះគឺជាទង្វើស្ម័គ្រចិត្តប៉ុណ្ណោះ»[1]

ហើយវាជាប្រការស៊ូណាត់ក្នុងបង្កើនការធ្វើហាជ្ជី និងអ៊ុមរ៉ោះឲ្យបានច្រើន នរយោងតាមអ្វីដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៅក្នុងសៀវភៅសហីសទាំងពីរ, អាពូហ៊ូរ៉ាយរ៉ោះ رضي الله عنه ថា រ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖

«العُمْرَةُ إِلَى العُمْرَةِ كَفَّارَةٌ لِمَا بَيْنَهُمَا، وَالحَجُّ المَبْرُورُ لَيْسَ لَهُ جَزَاءٌ إِلَّا الجَنَّةُ».

(ពីអ៊ុំរ៉ោះមួយ ទៅអ៊ុំរ៉ោះមួយទៀត គឺជាការលុបចោលនូវបាបកម្មដែលបានកើតឡើងរវាងអ៊ុំរ៉ោះទាំងពីរនោះ។ ហើយចំពោះហាជ្ជីដែលអល់ឡោះទទួលយក គ្មានអ្វីតបស្នងចំពោះវាក្រៅពីឋានសួគ៌ឡើយ)[2]

---

1 រាយការណ៍ដោយ អាន់ណាសាអ៊ី៖២៦២០]

2 រាយការណ៍ដោយ អាល់ពូខរី៖១៧៧៣, មូស្លីម៖១៣៤៩

# ជំពូក

# កាតព្វកិច្ចត្រូវសារភាពកំហុសពីអំពើ និងបាបទាំងឡាយ និងការដោះស្រាយរាល់អំពើអយុត្តិធម៌ដែលបានប្រព្រឹត្តលើអ្នកដទៃ

នៅពេលដែលមូស្លីមប្តេជ្ញាចិត្តធ្វើដំណើរទៅធ្វើហាជ្ជី ឬអ៊ុំរ៉ោះ គប្បីឱ្យគាត់ផ្តែផ្តាំក្រុមគ្រួសារ និងមិត្តភក្តិរបស់គាត់ឱ្យមានការកោតខ្លាចចំពោះអល់ឡោះ ដែលវាគឺជាការប្រតិបត្តិតាមបទបញ្ជារបស់ទ្រង់ និងការចៀសវាងពីបម្រាមទាំងឡាយរបស់ទ្រង់។

ហើយគេគប្បីកត់ត្រានូវអ្វីដែលជាកម្មសិទ្ធិរបស់ខ្លួន និងបំណុលដែលខ្លួនជំពាក់ ហើយមានសាក្សីដឹងឮលើរឿងនោះ ហើយតម្រូវឲ្យគេរួសរាន់សារភាពកំហុស(តាវហ្ពាត់)ឲ្យបានត្រឹមត្រូវពីអំពើបាបទាំងអស់ ព្រោះអល់ឡោះជាម្ចាស់មានបន្ទូលថា៖

﴿...وَتُوبُوا إِلَى اللَّهِ جَمِيعًا أَيُّهَ الْمُؤْمِنُونَ لَعَلَّكُمْ تُفْلِحُونَ﴾

ហើយចូរពួកអ្នកសារភាពកំហុសចំពោះអល់ឡោះទាំងអស់គ្នាចុះ ឱបណ្តាអ្នកដែលមានជំនឿទាំងឡាយ សង្ឃឹមថាពួកអ្នកនឹងទទួលបានជោគជ័យ។ [គម្ពីរគួរអាន ២៤:៣១]

ខ្លឹមសារពិតនៃការសារភាពកំហុសគឺៈ ការលះបង់ចោលនូវអំពើបាប, សោកស្តាយចំពោះអ្វីដែលបានសាង, និងប្តេជ្ញាចិត្តថានឹងមិនត្រឡប់ទៅប្រព្រឹត្តវាម្តងទៀតឡើយ។ ហើយប្រសិនបើមានការបំពានទៅលើសិទ្ធិរបស់អ្នកដទៃទាក់ទងនឹងអាយុជីវិត, ទ្រព្យសម្បត្តិ ឬកិត្តិយស គឺត្រូវតែបង្វិលសិទ្ធិទាំងនោះត្រឡប់ទៅម្ចាស់ដើមវិញ ឬដោះស្រាយសុំការអភ័យទោសពីពួកគេមុនពេលធ្វើដំណើរ ដូចដែលមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីព្យាការី ﷺ ថា លោកបានមានប្រសាសន៍ថាៈ

«مَنْ كَانَتْ عِنْدَهُ مَظْلَمَةٌ لِأَخِيهِ مِنْ مَالٍ أَوْ عِرْضٍ فَلْيَتَحَلَّلِ اليَوْمَ قَبْلَ أَنْ لَا يَكُونَ دِينَارٌ وَلَا دِرْهَمٌ، إِنْ كَانَ لَهُ عَمَلٌ صَالِحٌ أُخِذَ مِنْهُ بِقَدْرِ مَظْلَمَتِهِ، وَإِنْ لَمْ تَكُنْ لَهُ حَسَنَاتٌ أُخِذَ مِنْ سَيِّئَاتِ صَاحِبِهِ فَحُمِلَ عَلَيْهِ».

«អ្នកណាដែលធ្លាប់បានប្រព្រឹត្តអំពើអយុត្តិធម៌ (បង្កកំហុស) លើបងប្អូនរបស់គេ នោះជាពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ឬកិត្តិយសក្តី ចូរគេប្រញាប់សុំការអភ័យទោស (ដោះស្រាយឱ្យជ្រះស្រឡះ) នៅថ្ងៃនេះឱ្យហើយចុះ មុននឹងថ្ងៃមួយមកដល់ (ថ្ងៃបរលោក) ដែលលែងមានប្រាក់ឌីណើរ ឬឌៀរហាំ (សម្រាប់សង) ទៀតហើយ។ ប្រសិនបើគេ (អ្នកធ្វើខុស) មានអំពើល្អ អំពើល្អនោះនឹងត្រូវដកយកទៅសងតាមទំហំនៃកំហុ

សដែលគេបានសាង។ ប៉ុន្តែប្រសិនបើគេគ្មានអំពើល្អសោះទេនោះ គេនឹងត្រូវយកអំពើអាក្រក់របស់អ្នកដែលរងគ្រោះមកដាក់លើខ្លួនគេវិញ។»[1]

ហើយវាគឺជាការចាំបាច់ (ឬជារឿងដែលគួរគប្បីបំផុត) ដែលគេត្រូវតែជ្រើសរើសសម្រាប់ការធ្វើហាជ្ជី និងអ៊ុំរ៉ោះរបស់គេ នូវការចំណាយដ៏ល្អស្អាតស្អំ ដែលបានមកពីប្រភពទ្រព្យសម្បត្តិដ៏ហាឡាល (ត្រឹមត្រូវតាមច្បាប់សាសនា)។ នេះយោងតាមអ្វីដែលបានបញ្ជាក់យ៉ាងត្រឹមត្រូវពីព្យាការីមូហាំម៉ាត់ ﷺ ថា ៖

«إِنَّ اللَّهَ تَعَالَى طَيِّبٌ لَا يَقْبَلُ إِلَّا طَيِّبًا».

"ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់មហាស្អាតស្អំ ទ្រង់មិនទទួលយកអ្វីឡើយ លើកលែងតែអ្វីដែលស្អាតស្អំ។"[2]

រាយការណ៍ដោយអ៊ីម៉ាំ អាត់តប់រ៉នី អំពីអាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«إِذَا خَرَجَ الرَّجُلُ حَاجًّا بِنَفَقَةٍ طَيِّبَةٍ وَوَضَعَ رِجْلَهُ فِي الغَرْزِ فَنَادَى: لَبَّيْكَ اللَّهُمَّ

---

1 រាយការណ៍ដោយ អាល់ពូខរី៖២៤៤៩

2 រាយការណ៍ដោយ មូស្លីម៖១០១៥

لَبَّيْكَ، نَادَاهُ مُنَادٍ مِنَ السَّمَاءِ: لَبَّيْكَ وَسَعْدَيْكَ، زَادُكَ حَلَالٌ، وَرَاحِلَتُكَ حَلَالٌ، وَحَجُّكَ مَبْرُورٌ غَيْرُ مَأْزُورٍ، وَإِذَا خَرَجَ الرَّجُلُ بِالنَّفَقَةِ الْخَبِيثَةِ فَوَضَعَ رِجْلَهُ فِي الْغَرْزِ فَنَادَى: لَبَّيْكَ اللَّهُمَّ لَبَّيْكَ، نَادَاهُ مُنَادٍ مِنَ السَّمَاءِ: لَا لَبَّيْكَ وَلَا سَعْدَيْكَ، زَادُكَ حَرَامٌ، وَنَفَقَتُكَ حَرَامٌ، وَحَجُّكَ غَيْرُ مَبْرُورٍ».

«នៅពេលដែលបុរសម្នាក់ចេញទៅធ្វើបុណ្យហាជ្ជីដោយប្រើប្រាស់នូវការចំណាយដ៏ល្អបរិសុទ្ធ (ហាឡាល់) ហើយគាត់បានដាក់ជើងរបស់គាត់នៅលើឈ្នាន់ (ដើម្បីឡើងជិះសត្វជំនិះ) រួចគាត់បានស្រែកអំពាវនាវថា៖ "ឡាប់ពៃកុលឡោះហ៊ុមម៉ាឡាប់ពៃ" (ទូលបង្គំនៅទីនេះហើយ ឱអល់ឡោះ ទូលបង្គំនៅទីនេះដើម្បីឆ្លើយតបតាមបញ្ជារបស់ទ្រង់)។ ខណៈនោះ មានអ្នកស្រែកម្នាក់ពីលើមេឃបានស្រែកតបទៅគាត់វិញថា៖ "ឡាប់ពៃកា វ៉ាសាក់ទៃកា" (ការមកដល់របស់អ្នកត្រូវបានទទួលយក និងប្រកបដោយសេចក្តីសុខ) ស្បៀងអាហាររបស់អ្នកគឺហាឡាល់ យានជំនិះរបស់អ្នកគឺហាឡាល់ ហើយបុណ្យហាជ្ជីរបស់អ្នកត្រូវបានទទួលយកយ៉ាងល្អប្រសើរ (ម៉ាប់រ៉ូរ) និងមិនមានបាបឡើយ។ ផ្ទុយទៅវិញ ប្រសិនបើបុរសម្នាក់ចេញទៅធ្វើបុណ្យហាជ្ជី ដោយប្រើប្រាស់នូវការចំណាយដ៏អាក្រក់ (ហារ៉ាម) ហើយគាត់បានដាក់ជើងរបស់គាត់នៅលើឈ្នាន់

រួចស្រែកអំពាវនាវថា៖ "ឡាប់ពៃកុលឡោះ ហ៊ុមម៉ាឡាប់ពៃ"។

ខណ:នោះ មានអ្នកស្រែកម្នាក់ពីលើមេឃបានស្រែកតបទៅគាត់វិញថា៖ "ឡាប់ពៃការ វ៉ា ឡើ សាក់ទៃកា" (ការមកដល់របស់អ្នកមិនត្រូវបានទទួលយក និងមិនមានសេចក្តីសុខឡើយ) ស្បៀងអាហាររបស់អ្នកគឺហារ៉ាម ការចំណាយរបស់អ្នកគឺហារ៉ាម ហើយបុណ្យហាជ្ជីរបស់អ្នកមិនត្រូវបានទទួលយកឡើយ។»[1]

អ្នកដែលធ្វើហាជ្ជី គប្បីធ្វើខ្លួនឲ្យមានភាពគ្រប់គ្រាន់ មិនត្រូវពឹងផ្អែកលើអ្វីដែលមាននៅក្នុងដៃរបស់អ្នកដទៃឡើយ និងត្រូវរក្សាកិត្តិយសដោយការមិនដើរសុំទានពីពួកគេ ដោយស្របតាមប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ ﷺ ថា៖

«وَمَنْ يَسْتَعْفِفْ يُعِفَّهُ اللَّهُ، وَمَنْ يَسْتَغْنِ يُغْنِهِ اللَّهُ».

“ហើយអ្នកណាដែលព្យាយាមរក្សាកិត្តិយស(ដោយមិនដើរសុំគេ អល់ឡោះនឹងប្រទានឲ្យគេនូវកិត្តិយសនិងភាពស្អាត

---

1 រាយការណ៍ដោយ អាត់តប់រ៉នី នៅក្នុងសៀវភៅ អាល់កាពៀរ៖២៩៨៩

ស្ងំ ហើយអ្នកណាដែលស្វែងរកភាពគ្រប់គ្រាន់(ដោយពឹងផ្អែកលើអល់ឡោះ) អល់ឡោះនឹងប្រទានឲ្យគេនូវភាពគ្រប់គ្រាន់និងបរិបូរណ៍”[1]។

លោកបានមានប្រសាសន៍ទៀតថា៖

«لَا يَزَالُ الرَّجُلُ يَسْأَلُ النَّاسَ حَتَّى يَأْتِيَ يَوْمَ الْقِيَامَةِ وَلَيْسَ فِي وَجْهِهِ مُزْعَةُ لَحْمٍ».

“មនុស្សម្នាក់នៅតែបន្តដើរសុំទានពីគេ(ដោយគ្មានភាពចាំបាច់) រហូតដល់ថ្ងៃបរលោក គេនឹងបង្ហាញខ្លួនក្នុងស្ថានភាពដែលនៅលើផ្ទៃមុខរបស់គេ គ្មានសាច់សូម្បីតែមួយដុំឡើយ (គឺនៅសល់តែឆ្អឹងមុខ)។”[2]។

វាគឺជាកាតព្វកិច្ចសម្រាប់អ្នកធ្វើហាជ្ជី និងអ៊ុំរ៉ោះ ដែលត្រូវតម្រង់គោលបំណង (នៀត) របស់ខ្លួនដើម្បីអល់ឡោះតែមួយគត់ និងដើម្បីថ្ងៃបរលោក។ ត្រូវខិតខំស្វែងរកការខិតជិតទៅរកអល់ឡោះ តាមរយៈពាក្យសម្ដី និងទង្វើទាំងឡាយណាដែលទ្រង់ពេញចិត្ត នៅក្នុងទីកន្លែងដ៏ពិសិដ្ឋទាំងនោះ។

ជាមួយគ្នានេះដែរ ត្រូវប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុត

---

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖១៤២៧, មូស្លីម៖១០៣៥

2 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖១៤៧៤, មូស្លីម៖៤០៤០

មិនត្រូវធ្វើហាជ្ជីក្នុងគោលបំណងចង់បានផលប្រយោជន៍លោកិយ ឬរបស់របរលោកិយឡើយ ហើយក៏មិនត្រូវធ្វើដើម្បីបង្អួតគេ (រីយ៉ាក់) ដើម្បីកេរ្តិ៍ឈ្មោះ ឬដើម្បីអំនួតសម្តែងនោះដែរ។ ព្រោះថានេះគឺជាបំណងប្រាថ្នាដ៏អាក្រក់បំផុត ដែលជាមូលហេតុធ្វើឱ្យរលាយបាត់ផលបុណ្យ និងមិនត្រូវបានទទួលយក (ពីអល់ឡោះ) ឡើយ ដូចដែលអល់ឡោះជាម្ចាស់បានមានបន្ទូលថា៖»

﴿مَن كَانَ يُرِيدُ الْحَيَاةَ الدُّنْيَا وَزِينَتَهَا نُوَفِّ إِلَيْهِمْ أَعْمَالَهُمْ فِيهَا وَهُمْ فِيهَا لَا يُبْخَسُونَ ﴿١٥﴾ أُولَٰئِكَ الَّذِينَ لَيْسَ لَهُمْ فِي الْآخِرَةِ إِلَّا النَّارُ وَحَبِطَ مَا صَنَعُوا فِيهَا وَبَاطِلٌ مَّا كَانُوا يَعْمَلُونَ ﴿١٦﴾﴾

ជនណាដែលប្រាថ្នាចង់បានការរស់នៅក្នុងលោកិយ និងភាពស្រស់បំព្រងរបស់វា នោះយើងនឹងប្រទានឱ្យពួកគេយ៉ាងពេញលេញតាមទង្វើរបស់ពួកគេនៅក្នុងលោកិយ ហើយពួកគេនៅក្នុងលោកិយនេះនឹងមិនត្រូវគេកាត់បន្ថយផលឡើយ។

ពួកទាំងនោះហើយគឺជាពួកដែលនៅថ្ងៃបរលោកគ្មានអ្វី សម្រាប់ពួកគេក្រៅពីភ្លើងនរកនោះ។ ហើយអ្វីដែលពួកគេបានសាង នៅក្នុងលោកិយនេះបានរលាយសាបសូន្យអស់។ ហើយអ្វីដែលពួក

គេធ្លាប់បានប្រព្រឹត្តកន្លងមកទុកជាមោឃៈ។ [គម្ពីរគួរអាន ១១:១៥-១៦]

អល់ឡោះបានមានបន្ទូលទៀតថា ៖

﴿مَّن كَانَ يُرِيدُ الْعَاجِلَةَ عَجَّلْنَا لَهُ فِيهَا مَا نَشَاءُ لِمَن نُّرِيدُ ثُمَّ جَعَلْنَا لَهُ جَهَنَّمَ يَصْلَاهَا مَذْمُومًا مَّدْحُورًا ﴿١٨﴾ وَمَنْ أَرَادَ الْآخِرَةَ وَسَعَىٰ لَهَا سَعْيَهَا وَهُوَ مُؤْمِنٌ فَأُولَٰئِكَ كَانَ سَعْيُهُم مَّشْكُورًا ﴿١٩﴾﴾

អ្នកណាហើយប្រាថ្នាចង់បានការសប្បាយរីករាយនៅលើលោកិយភ្លាមៗ យើងនឹងផ្តល់ឱ្យគេវិញភ្លាមៗដែរនូវអ្វីដែលយើងមានចេតនាចំពោះអ្នកណាដែលយើងមានចេតនា។ បន្ទាប់មកយើងបានរៀបចំនរកជើហាន់ណាំឱ្យគេដែលគេនឹងចូលទៅក្នុងនោះដោយ ការស្តីបន្ទោសឃ្លាតឆ្ងាយពីការសន្តោសប្រណីរបស់អល់ឡោះ។

រីឯនរណាហើយដែលប្រាថ្នាចង់បានថ្ងៃបរលោក(ឋានសួគ៌) ហើយគេតស៊ូប្រឹងប្រែងធ្វើវាសម្រាប់វា(ថ្ងៃបរលោក) ដោយគេជាអ្នកមានជំនឿ គឺអ្នកទាំងនោះហើយដែលការខំប្រឹងប្រែងរបស់ពួកគេត្រូវទទួលបានការថ្លែងអំណរគុណ(ពីអល់ឡោះ) [គម្ពីរគួរអាន ១៧:១៨-១៩]

ហើយមានភាពត្រឹមត្រូវពីព្យាការី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«قَالَ اللَّهُ تَعَالَى: أَنَا أَغْنَى الشُّرَكَاءِ عَنِ الشِّرْكِ، مَنْ عَمِلَ عَمَلًا أَشْرَكَ مَعِي فِيهِ غَيْرِي تَرَكْتُهُ وَشِرْكَهُ».

"អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖ យើងមិនត្រូវការស្ហ៊ីរិក(ដៃគូ)ឡើយ។ ហេតុនេះ បុគ្គលណាធ្វើទង្វើអ្វីមួយដោយស្ហ៊ីរិកមកចំពោះយើង (ដើម្បីយើងផង និងអ្នកផ្សេងផង) យើងនឹងបោះបង់គេ និងទង្វើស្ហ៊ីរិករបស់គេចោល(យើងមិនផ្តល់ផលបុណ្យឲ្យឡើយ)"។[1]

ហើយគេគប្បីផងដែរ ក្នុងការធ្វើដំណើររបស់គេ ឲ្យរាប់អានមនុស្សល្អ ដែលជាអ្នកគោរពប្រតិបត្តិ មានការគោរពកោតខ្លាច និងមានចំណេះដឹងខាងសាសនា ហើយត្រូវប្រុងប្រយ័ត្នពីការរាប់អានមនុស្សល្ងង់ខ្លៅ និងពួកប្រព្រឹត្តអំពើល្មើស។

«គាត់គប្បីរៀនសូត្រនូវអ្វីដែលត្រូវបានកំណត់ក្នុងច្បាប់សាសនាសម្រាប់ការធ្វើបុណ្យហាជ្ជី និងអ៊ុំរ៉ោះរបស់គាត់ ហើយត្រូវស្វែងយល់ឱ្យបានច្បាស់លាស់ និងសាកសួរនូវរាល់ចំណុចណាដែលគាត់មានការងឿងឆ្ងល់ ដើម្បីឱ្យការអនុវត្តរបស់គាត់ផ្អែកលើចំណេះដឹងពិតប្រាកដ (ហ្វាស៊ីរ៉ោះ)។

---

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម៖២៩៨៥

នៅពេលដែលគាត់ឡើងជិះសត្វជំនិះ រថយន្ត យន្តហោះ ឬមធ្យោបាយធ្វើដំណើរផ្សេងៗទៀត វាគឺជាការប្រសើរ (មូស្ដាហាប់) ក្នុងការរំលឹកនាមអល់ឡោះ (ពោលពីសមីលឡើ) និងសរសើរតម្កើងទ្រង់ (ពោល អាល់ហាំទូលិលឡើ) រួចពោល "អល់ឡោះហ៊ូអឹកពើរ" ចំនួនបីដង ហើយបន្ទាប់មកពោលថា៖»

﴿...سُبْحَانَ الَّذِى سَخَّرَ لَنَا هَذَا وَمَا كُنَّا لَهُ مُقْرِنِينَ ۝١٣ وَإِنَّا إِلَى رَبِّنَا لَمُنْقَلِبُونَ۝١٤﴾

ទ្រង់មហាស្អាតស្អំដែលបានសម្រួលដល់ពួកយើងនូវប្រការនេះ ហើយពួកយើងពុំមែនជាអ្នកដែលមានសមត្ថភាព(ក្នុងការទទួលបានវានោះឡើយ)។ ហើយពិតណាស់ ពួកយើងពិតជានឹងត្រូវវិលត្រឡប់ទៅកាន់ព្រះជាម្ចាស់របស់ពួកយើង(តែមួយគត់)។ 14﴾ [គម្ពីរគួរអាន ៤៣:១៣-១៤]

«اللَّهُمَّ إِنِّي أَسْأَلُكَ فِي سَفَرِي هَذَا البِرَّ وَالتَّقْوَى، وَمِنَ العَمَلِ مَا تَرْضَى، اللَّهُمَّ هَوِّنْ عَلَيْنَا سَفَرَنَا هَذَا، وَاطْوِ عَنَّا بُعْدَهُ، اللَّهُمَّ أَنْتَ الصَّاحِبُ فِي السَّفَرِ، وَالخَلِيفَةُ فِي الأَهْلِ، اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ وَعْثَاءِ السَّفَرِ، وَكَآبَةِ المَنْظَرِ، وَسُوءِ المُنْقَلَبِ فِي المَالِ وَالأَهْلِ».

ឱ!អល់ឡោះជាម្ចាស់!

ទូលបង្គំសុំពរជ័យពីទ្រង់ក្នុងដំណើរនេះ នូវរាល់អំពើល្អ និងការកោតខ្លាច
ចំពោះទ្រង់ក៏ដូចជាកិច្ចការទាំងឡាយណាដែលទ្រង់ពេញចិត្ត។ ឱ! អល់ឡោះ! សូមទ្រង់មេត្តាសម្រាលភាពលំបាកក្នុងដំណើររបស់ពួកយើងមួយនេះ
ហើយសូមទ្រង់មេត្តាបង្រួញចម្ងាយផ្លូវដ៏វែងឆ្ងាយឱ្យមកនៅជិតវិញ។ ឱ! អល់ឡោះ! ទ្រង់ជាអ្នកការពារក្នុងពេលធ្វើដំណើរ
ហើយទ្រង់គឺជាអ្នកថែរក្សាជំនួសទូលបង្គំចំពោះក្រុមគ្រួសារ។

ឱ! អល់ឡោះ! ទូលបង្គំសូមការការពារពីទ្រង់ឱ្យចៀសផុតពីភាពហត់នឿយខ្លាំងនៃការធ្វើដំណើរ ចៀសផុតពីទិដ្ឋភាពដែលនាំឱ្យមានទុក្ខសោក និងចៀសផុតពីវាសនាអាក្រក់ (ការជួបគ្រោះថ្នាក់) នៅពេលត្រឡប់មកវិញទាំងចំពោះទ្រព្យសម្បត្តិ និងក្រុមគ្រួសារ។"[1]

ហាទីស្ហនេះគឺត្រឹមត្រូវពីព្យាការីមូហាំម៉ាត់ ﷺ រាយការណ៍ដោយមូស្លីម ពីហាទីស្ហរបស់ អ៊ីបនូអ៊ូមើរ رضي الله عنهما។

ក្នុងអំឡុងពេលធ្វើដំណើរគេគប្បីបង្កើនការរឭកដល់អល់ឡោះការសុំអភ័យទោស
ការបួងសួងសុំពរជ័យពីទ្រង់

1 រាយការណ៍ដោយ មូស្លីម៖១៣៤២

ការបន្ទាបខ្លួនចំពោះទ្រង់ ការសូត្រគម្ពីរគួរអាន និងពិចារណាលើអត្ថន័យនៃគម្ពីរគួរអានឲ្យបានស៊ីជម្រៅ លើសពីនេះ គេគប្បីរក្សានូវការថ្វាយបង្គំ(សឡាត)ហ្ជាម៉ាអះ និងរក្សាអណ្តាត(សម្តី) ឲ្យចៀសផុតពីការនិយាយដើមគ្នាដែលគ្មានប្រយោជន៍ ការលូកដៃក្នុងរឿងដែលមិនមែនជាកិច្ចការរបស់ខ្លួន និងការលេងសើចហួសប្រមាណ។ ទន្ទឹមនឹងនេះ គេក៏ត្រូវការការពារអណ្តាតឲ្យចៀសផុតពីការនិយាយកុហស ការនិយាយដើមបង្កាច់បង្ខូច ការនិយាយចាក់រុក និងការសើចចំអកឲ្យមិត្តភក្តិក៏ដូចជាបងប្អូនមូស្លីមដទៃទៀតផងដែរ។

ហើយវាជាការគប្បីសម្រាប់អ្នកធ្វើដំណើរ ក្នុងការផ្តល់នូវសេចក្តីល្អដល់មិត្តភក្តិរួមដំណើររបស់ខ្លួន ការបញ្ឈប់នូវរាល់ការរំខាន ឬការផ្តល់ផលវិបាកដល់ពួកគេ ការណែនាំពួកគេឲ្យធ្វើអំពើល្អ និងការហាមឃាត់ពួកគេពីអំពើអបាយមុខ ដោយប្រើប្រាស់នូវប្រាជ្ញាស្មារតី និងការទូន្មានដ៏ល្អប្រពៃ ទៅតាមលទ្ធភាព និងសមត្ថភាពដែលអាចធ្វើបាន។

## ជំពូក

## កិច្ចការរបស់អ្នកធ្វើហាជ្ជី នៅពេលពួកគេទៅដល់មីកត

ដូច្នេះ នៅពេលដែលគេទៅដល់មីកត គេត្រូវបានណែនាំ(ស៊ូណាត់) ឲ្យងូតទឹកសម្អាតកាយ និងលាបគ្រឿងក្រអូប ដោយសារតែមានសេក្តីរាយការណ៍ថា ព្យាការីមូហាំម៉ាត់ ﷺ បានដោះសម្លៀកបំពាក់ថ្មេរដេរភ្ជាប់គ្នាហើយចេញ នៅពេលអៀសរ៉ម ហើយបានងូតទឹក យោងតាមអ្វីដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅសាហ៊ីសទាំងពីរ ពីអ្នកស្រី អាអ៊ីស្សះ رضي الله عنها បានមានប្រសាសន៍ថា៖

«كُنْتُ أُطَيِّبُ رَسُولَ اللَّهِ ﷺ لِإِحْرَامِهِ قَبْلَ أَنْ يُحْرِمَ، وَلِحِلِّهِ قَبْلَ أَنْ يَطُوفَ بِالبَيْتِ».

«ខ្ញុំធ្លាប់បានលាបគ្រឿងក្រអូបជូនរ៉សូលរបស់អល់ឡោះ ﷺ សម្រាប់អៀហរ៉មរបស់លោក មុនពេលដែលលោកចាប់ផ្តើមតាំងចិត្ត(នៀត) ចូលអៀហរ៉ម, និងសម្រាប់ការចេញពីអៀហរ៉មរបស់លោក មុនពេលដែលលោកធ្វើតវ៉ាហ្វនៅនឹងពៃទុលឡោះ(កា

ក់ហ្គ»[1]៖ "ហើយព្យាការីមូហាំម៉ាត់ ﷺ បានបញ្ជាទៅកាន់អ្នកស្រី អាអ៊ីស្ះ នៅពេលដែលនាងមានរដូវ ក្នុងខណៈដែលនាងបានគ្របដណ្ដប់អៀសរ៉ម ដើម្បីធ្វើអ៊ុំរ៉ោះរួចទៅហើយនោះ ឱ្យនាងងូតទឹកសម្អាតកាយ ហើយតាំងចិត្តចូល(នៀត) អៀសរ៉មដើម្បីធ្វើហាជ្ជី (បញ្ចូលគ្នា)វិញ។" "ហើយព្យាការី មូហាំម៉ាត់ﷺ បានបញ្ជាទៅកាន់អ្នកស្រី អាស្មាស់ កូនស្រី អ៊ូមែស៍ នៅពេលដែលនាងបានសម្រាលកូននៅទីតាំង ហ៊្សុល ហ៊ូលៃហ្វះ ឱ្យនាងងូតទឹកសម្អាតកាយ ប្រើប្រាស់ក្រណាត់ទ្រនាប់បិទបាំងឱ្យជិត (ដើម្បីការពារឈាម) រួចហើយចូលក្នុងសភាពអៀសរ៉ម។

ហេតុការណ៍នេះបានសបញ្ជាក់ថា៖ កាលណាស្ត្រីដែលបានធ្វើដំណើរមកដល់មីកត ក្នុងខណៈដែលនាងកំពុងមានរដូវ ឬឈាមរដូវក្រោយសម្រាលកូន គឺនាងត្រូវងូតទឹកសម្អាតកាយ និងតាំងចិត្ត(នៀត)ចូលអៀសរ៉មជាមួយមនុស្សដទៃទៀតដែរ។ ហើយនាងអាចបំពេញកិច្ចការគ្រប់យ៉ាងដូចដែលអ្នកសាងបុណ្យហាជ្ជីដទៃទៀតធ្វើដែរ លើកលែងតែការ

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១៥៣៩, មូស្លីមៈ១១៨៩

តវ៉ាហ្វ (ការដើរប្រទក្សិណជុំវិញ) នៅឯកាក់ហ្ពះប៉ុណ្ណោះ ដូចអ្វីដែលលោកព្យាការីមូហាំម៉ាត់ ﷺ បានបញ្ជាទៅកាន់អ្នកស្រី អាអ៊ីស្សះនិងអ្នកស្រីអាស្មាស់ ដូច្នោះដែរ។[1]

ហើយវាជាការគប្បី (ស៊ូណាត់) សម្រាប់អ្នកដែលចង់ចូលក្នុងសភាពអៀសរ៉មក្នុងការត្រួតពិនិត្យសម្អាតពុកមាត់ ក្រចក រោមអវយវះភេទ និងរោមក្រោមឃ្លៀករបស់ខ្លួន ដោយកាត់ ឬដកចេញនូវអ្វីដែលចាំបាច់ត្រូវដកចេញ។

ទាំងនេះគឺដើម្បីកុំឱ្យគេមានតម្រូវការក្នុងការកាត់ ឬដកវាចេញ បន្ទាប់ពីបានចូលក្នុងសភាពអៀសរ៉មហើយ ដែលវានឹងក្លាយជាបម្រាម (ហាមឃាត់) សម្រាប់គេ។ ម្យ៉ាងវិញទៀត គឺដោយសារលោកព្យាការី ﷺ បានកំណត់ជាច្បាប់ឱ្យមូស្លីមទាំងអស់ ត្រួតពិនិត្យសម្អាតនូវវត្ថុទាំងនេះជាប្រចាំគ្រប់ពេលវេលា ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងសៀវភៅសាហ៊ីសទាំងពីរ ពី អាពូ ហ៊ូរ៉ុយរ៉ោះ (សូមអល់ឡោះពេញចិត្តដល់គាត់) ដែលបាននិយាយថា៖ ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖

---

1 រាយការណ៍ដោយ មូស្លីមៈ១២១៨

«الفِطْرَةُ خَمْسٌ: الخِتَانُ، وَالِاسْتِحْدَادُ، وَقَصُّ الشَّارِبِ، وَقَلْمُ الأَظْفَارِ، وَنَتْفُ الإِبْطِ».

“ស៊ុណាត់ហ្វិតត្រោះមានប្រាំ(សភាវៈដើមនៃភាពស្អាតស្អំ)៖ ការកាត់ចុងស្បែកអង្គជាតិ (ខតាន់) ការកោររោមប្រដាប់ភេទ ការកាត់តម្រឹមពុកមាត់ កាត់ក្រចក និងដករោមឃ្លៀក”។[1]

នៅក្នុង សហ៊ើសមូស្លីម، អំពី អាណាស (សូមអល់ឡោះពេញចិត្តដល់គាត់) បាននិយាយថា៖

«وَقَّتَ لَنَا فِي قَصِّ الشَّارِبِ، وَقَلْمِ الأَظْفَارِ، وَنَتْفِ الإِبْطِ، وَحَلْقِ العَانَةِ: أَنْ لَا نَتْرُكَ ذَلِكَ أَكْثَرَ مِنْ أَرْبَعِينَ لَيْلَةً».

"លោកព្យាការី ﷺ បានកំណត់គោលការណ៍ដល់ពួកយើង ក្នុងការកាត់តម្រឹមពុកមាត់ កាត់ក្រចក ដករោមក្រោមឃ្លៀក និងកោររោមអវយវៈភេទ ដោយមិនត្រូវទុកឱ្យលើសពីសែសិបយប់ឡើយ។"[2]

ហើយ អាន់-ណាសាអ៊ី បាននិយាយវាតាមឃ្លាថា៖

«وَقَّتَ لَنَا رَسُولُ اللَّهِ ﷺ».

«អ្នកនាំសាររបស់អល់ឡោះ ﷺ បានកំណត់ពេលវេលាឱ្យពួកយើង»،[3]

---

1 រាយការណ៍ដោយ អាល់ពូខរី៖៥៨៨៩, មូស្លីម៖២៥៧

2 រាយការណ៍ដោយ មូស្លីម៖២៥៨

3 រាយការណ៍ដោយ អាន់ណាសាអ៊ី៖១៤]

ហាទីស្ទនេះត្រូវបានរាយការណ៍ដោយលោក អះម៉ាត់, អាពូ ហ្មើវូទ និងតៀរមីហ្សី ដោយប្រើប្រាស់ពាក្យពេចន៍ដូចនឹងលោក ណាសាអ៊ី។ ចំពោះការកាត់សក់ក្បាលវិញ គឺពុំត្រូវបានកំណត់ក្នុងច្បាប់សាសនាឱ្យធ្វើការកាត់ ឬកោរចេញ ក្នុងអំឡុងពេលត្រៀមខ្លួនគ្រប់ដណ្ដប់អៀសរ៉មឡើយ ទោះបីជាចំពោះបុរស ឬស្ត្រីក៏ដោយ។"

"ដោយឡែកចំពោះពុកចង្ការ ការកោរឬការកាត់តម្រឹមយកផ្នែកណាមួយចេញ ត្រូវបានហាមឃាត់ជាដាច់ខាតក្នុងគ្រប់កាលៈទេសៈ។ ផ្ទុយទៅវិញ កាតព្វកិច្ចរបស់អ្នកមូស្លីមគឺត្រូវទុកពុកចង្ការឱ្យវែង និងថែរក្សាវាឱ្យដុះច្រើន។ នេះយោងតាមសេចក្ដីដកស្រង់ដែលមានបញ្ជាក់ក្នុងសៀវភៅសាហ៊ើសពូខរី និងមូស្លីម តាមរយៈ អ៊ិបនូ អ៊ូមើរ ដែលលោកដែលព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖"

«خَالِفُوا الْمُشْرِكِينَ، وَفِّرُوا اللِّحَى، وَأَحْفُوا الشَّوَارِبَ».

“ចូរអ្នករាល់គ្នាធ្វើឲ្យខុសប្លែកពីពួកមូស្ហរីគីន (អ្នកពហុទេវនិយម) ដោយការរក្សាទុកពុកចង្ការឱ្យបានវែង និងច្រើន ព្រមទាំងធ្វើការកាត់តម្រឹម

ឬដកពុកមាត់ឱ្យបានខ្លីបំផុត។"[1]
"ហើយមានសេចក្ដីរាយការណ៍បន្ថែម ដែលត្រូវបានកត់ត្រាទុកដោយ អ៊ីម៉ាំមូស្លីម នៅក្នុងសៀវភៅសាហ៊ីសរបស់លោក តាមរយៈលោក អាពូ ហ៊ូរ៉ុយរ៉ោះថា ព្យាការីមូហាំម៉ាត់ ﷺ បានមានប្រសាសន៍ថា៖"

«جُزُّوا الشَّوَارِبَ، وَأَرْخُوا اللِّحَى، خَالِفُوا المَجُوسَ».

“ចូរអ្នករាល់គ្នាធ្វើការកាត់តម្រឹមពុកមាត់ឱ្យបានខ្លីបំផុត និងរក្សាទុកពុកចង្ការឱ្យដុះវែងចុះមកក្រោម ដើម្បីធ្វើឱ្យខុសប្លែកពីពួកម៉ាជូស៊ី (អ្នកថ្វាយបង្គំភ្លើង)។។"
[2]

ហើយសេចក្ដីទុក្ខសោក (គ្រោះភ័យ) បានរីករាលដាលយ៉ាងធំធេងក្នុងសម័យកាលនេះ ដោយសារមានមនុស្សជាច្រើនបានធ្វើផ្ទុយនឹងស៊ុណ្ណះ និងការប្រឆាំង (ការស្អប់ខ្ពើម) របស់ពួកគេចំពោះពុកចង្ការនិងការពេញចិត្តរបស់ពួកគេក្នុងការធ្វើត្រាប់តាមពួកកាហ្វៀរ និងស្ត្រីជាពិសេសអ្នកដែលជាប់ពាក់ព័ន្ធនឹងចំណេះដឹង និងការអប់រំ (អ្នកចេះដឹង)ពិតប្រាកដណាស់ពួកយើងជាកម្មសិទ្ធរបស់អល់ឡោះ

---

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖២៨៩២, មូស្លីម៖២៥៩

2 រាយការណ៍ដោយ មូស្លីម៖២៦០

ហើយពួកយើងនឹងត្រឡប់ទៅរកទ្រង់វិញហើយពួកយើងសុំចំពោះអល់ឡោះឱ្យមេត្តាបង្ហាញផ្លូវដល់យើង និងមូស្លីមទាំងអស់ឱ្យស្របតាមផ្លូវស៊ុនណះ និងការប្រកាន់ខ្ជាប់នូវផ្លូវនោះនិងការអំពាវនាវទៅកាន់ផ្លូវនោះ ទោះបីជាមនុស្សភាគច្រើនមិនពេញចិត្តក៏ដោយអល់ឡោះគឺគ្រប់គ្រាន់សម្រាប់យើង ហើយទ្រង់គឺជាអ្នកគ្រប់គ្រងដ៏ប្រសើរបំផុត ព្រោះគ្មានកម្លាំង និងអំណាចណាឡើយ លើកលែងតែដោយសារអល់ឡោះដ៏ខ្ពង់ខ្ពស់បំផុត

បន្ទាប់មក បុរសត្រូវស្លៀកនូវក្រណាត់អៀហរ៉ម(អ៊ុហ្សៀរ និង រីហ្ទើក) ផ្នែកខាងក្រោម និងផ្នែកខាងលើហើយវាជាការគប្បី (ស៊ុណ្ណះ) ដែលក្រណាត់ទាំងពីរនោះមានពណ៌ស និងស្អាតបាត ហើយក៏ជាការគប្បីផងដែរ ក្នុងការចូលអៀហរ៉មដោយពាក់ស្បែកជើងផ្ទាត់ឃោងតាមសេចក្តីណែនាំរបស់លោកព្យាការី មូហាំម៉ាត ﷺ ថា៖

«وَلْيُحْرِمْ أَحَدُكُمْ فِي إِزَارٍ وَرِدَاءٍ وَنَعْلَيْنِ، فَإِنْ لَمْ يَجِدْ نَعْلَيْنِ فَلْيَلْبَسْ خُفَّيْنِ وَلْيَقْطَعْهُمَا حَتَّى يَكُونَا أَسْفَلَ مِنَ الكَعْبَيْنِ».

«ចូរឲ្យនរណាម្នាក់ក្នុងចំណោមពួកអ្នកនីយ៉ាត់អ៊ីហ្រម ដោយស្លៀកសារ៉ុង ស្បៃដណ្តប់ និងស្បែកជើងផ្ទាត់។ ប្រសិនបើគេរកស្បែកជើងផ្ទាត់មិនឃើញទេ

ចូរឲ្យគេពាក់ស្បែកជើងឃ្លុប
និងកាត់វារហូតទាល់តែវាស្ថិតនៅក្រោមភ្នែកគោល»1

"ព្យាការី ﷺ បានបង្គាប់ថា៖ ចូរអ្នករាល់គ្នាគ្របដណ្តប់អៀហរ៉មដោយប្រើប្រាស់ក្រណាត់សម្រាប់ស្លៀកភាគខាងក្រោម ក្រណាត់ដណ្តប់ភាគខាងលើ និងពាក់ស្បែកជើង។ ក្នុងករណីដែលរកស្បែកជើងធម្មតា (ប្រភេទស្បែកជើងសឹក ឬស្បែកជើងផ្ទាត់) មិនបាន នោះគេអនុញ្ញាតឱ្យពាក់ស្បែកជើងឃ្លុបបាន ប៉ុន្តែត្រូវកាត់តម្រឹមវាឱ្យនៅត្រឹមក្រោមភ្នែកគោ ដើម្បីកុំឱ្យវាបិទបាំងភ្នែកគោទាំងសងខាង។" រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់(សូមឲ្យអល់ឡោះអាណិតស្រឡាញ់ដល់គាត់)

ចំណែកស្ត្រី គឺអាចចូលសភាពអៀហរ៉មដោយស្លៀកសម្លៀកបំពាក់ពណ៌ខ្មៅ ឬបៃតង ឬពណ៌ផ្សេងទៀតតាមតែនាងពេញចិត្ត ដោយគ្រាន់តែត្រូវប្រយ័ត្នកុំឱ្យដូចទៅនឹងសម្លៀកបំពាក់របស់បុរស។ ប៉ុន្តែនាងមិនត្រូវពាក់នីកប និងស្រោមដៃឡើយក្នុងពេលស្ថិតក្នុងសភាពអៀហរ៉ម ហើយត្រូវគ្របមុខ

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម៖១១៧៧

និងដៃរបស់នាងដោយប្រើអ្វីផ្សេងទៀត។
ដោយសារព្យាការី ﷺ
បានហាមស្ត្រីដែលស្ថិតក្នុងសភាពអៀហរ៉មពីការពាក់
នីកប និងស្រោមដៃ។
ចំណែកឯការដែលមនុស្សទូទៅមួយចំនួនកំណត់ជាពិសេសថា
សម្លៀកបំពាក់អៀហរ៉មរបស់ស្ត្រីត្រូវតែជាពណ៌បៃតង
ឬខ្មៅ ដោយមិនយកពណ៌ផ្សេងនោះ
គឺជារឿងដែលគ្មានមូលដ្ឋានគ្រឹះឡើយ។

ក្រោយងូតទឹកសម្អាតកាយ
និងគ្របដណ្តប់អៀហរ៉មរួច គេត្រូវតាំងចិត្ត (នៀត)
ក្នុងចិត្តឱ្យច្បាស់នូវប្រភេទកិច្ចបុណ្យ (ហាជ្ជី ឬអ៊ុំរ៉ោះ)
ដែលត្រូវបំពេញ
ស្របតាមប្រសាសន៍របស់លោកព្យាការី ﷺ ថា៖

«إِنَّمَا الأَعْمَالُ بِالنِّيَّاتِ، وَإِنَّمَا لِكُلِّ امْرِئٍ مَا نَوَى».

"ពិតប្រាកដណាស់
ទង្វើ(អាម៉ាល់)ទាំងឡាយអាស្រ័យទៅតាមគោលបំណង(នៀត)
ហើយបុគ្គលគ្រប់រូបនឹងទទួលបានផល(ការតបស្នង)
តាមអ្វីដែលខ្លួនប៉ងប្រាថ្នា"។[1]

អ្នកសាងបុណ្យត្រូវបានលើកទឹកចិត្តឱ្យបន្លឺសម្លេង
នូវអ្វីដែលខ្លួនបានតាំងចិត្តក្នុងចិត្ត។ បើធ្វើអ៊ុំរ៉ោះ
ត្រូវពោលថា ឡាប់ពៃកៈ អ៊ុំរ៉ាតាន់ ហើយបើធ្វើហាជ្ជី

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១, មូស្លីមៈ១៩០៧

ត្រូវពោលថា ឡាប់ពៃក: ហាដ្ឋាន់ស្របតាមទង្វើរបស់លោកព្យាការី ﷺ។ ចំណែកពេលវេលាដែលប្រសើរបំផុតសម្រាប់ការបន្លឺសម្លេងនេះ គឺនៅពេលដែលសាមីខ្លួនបានឡើងអង្គុយលើមធ្យោបាយធ្វើដំណើរ (ដូចជារថយន្ត ឬយន្តហោះ) រួចរាល់ហើយត្រៀមចេញដំណើរចាកចេញពីមីកត។ នេះគឺជាការយល់ឃើញដែលត្រឹមត្រូវបំផុតរបស់បណ្ដាអ្នកប្រាជ្ញឥស្លាម។

ហើយច្បាប់មិនអនុញ្ញាតឲ្យបញ្ចេញសំលេងនូវអ្វីដែលបាននៀតឡើយ លើកលែងតែនៅក្នុងអៀហរ៉មតែប៉ុណ្ណោះ ដោយសារវាមានការរាយការណ៍មកពីព្យាការី ﷺ។

ចំពោះកិច្ចការបុណ្យផ្សេងៗ ដូចជាការថ្វាយបង្គំស(សឡាត) ឬការដើរប្រទក្សិណ(តវ៉ាហ្វ) គឺមិនត្រូវបានអនុញ្ញាតឱ្យបន្លឺសម្លេងតាំងចិត្តចេញមកក្រៅឡើយ។ ការពោលចេញនូវបំណងក្នុងចិត្ត (ដូចជាពោលថា ខ្ញុំតាំងចិត្តថ្វាយបង្គំ...) គឺជាទង្វើដែលបង្កើតឡើងថ្មី (ពិតអះ) ដែលពុំមានមូលដ្ឋានក្នុងសាសនា ហើយការបន្លឺសម្លេងឱ្យឮខ្លាំងៗក្នុងរឿងនេះ គឺកាន់តែមិនសមរម្យ។ ប្រសិនបើវាជាទង្វើដែលត្រឹមត្រូវ ម្ល៉េះសមលោកព្យាការី ﷺ និងពួកសឡាហ្វសឡេះ

(អ្នកជំនាន់ដើម) បានអនុវត្ត និងណែនាំយើងឱ្យធ្វើតាមតាំងពីដំបូងមកម្ល៉េះ។

ដោយសារតែរឿងនោះមិនត្រូវបានគេរាយការណ៍ពីព្យាការី ﷺ ហើយក៏មិនមែនពីសហាការីរបស់លោក (សូមអល់ឡោះទ្រង់យល់ព្រមពីពួកគេ) ដែរ ទើបគេដឹងថាវាគឺជាពិតអះ។ ពិតណាស់ ព្យាការី ﷺ លោកបានមានប្រសាសន៍ថា៖

«وَشَرُّ الأُمُورِ مُحْدَثَاتُهَا، وَكُلُّ بِدْعَةٍ ضَلَالَةٌ».

“ហើយកិច្ចការដែលអាក្រក់បំផុតនោះគឺប្រការដែលគេបង្កើតថ្មីៗក្នុងសាសនា ហើយរាល់ប្រការពិតអះទាំងអស់នោះគឺសុទ្ធតែវង្វេង”[1] រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម នៅក្នុងសៀវភៅសហេសរបស់គាត់, លោកបានមានប្រសាសន៍ទៀតថា៖

«مَنْ أَحْدَثَ فِي أَمْرِنَا هَذَا مَا لَيْسَ مِنْهُ فَهُوَ رَدٌّ».

បុគ្គលណាដែលបង្កើតថ្មីក្នុងកិច្ចការសាសនាដែលពុំមានមូលដ្ឋានគ្រឹះ ឬការណែនាំពីច្បាប់ដើម គឺត្រូវបានចាត់ទុកជាមោឃៈ និងមិនត្រូវបានទទួលយកជាផលបុណ្យក្នុងកិច្ចការសក្ការៈឡើយ។[2]

---

1 រាយការណ៍ដោយ មូស្លីម៖៨៦៧

2 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖២៦៩៧, មូស្លីម៖១៧១៨

រាយការណ៍ដោយ អ៊ីម៉ាំពូខរី និងមូស្លីម។ ចំណែកឯក្នុងពាក្យពេចន៍របស់មូស្លីមវិញ៖

«مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ».

“ជនណាធ្វើទង្វើអ្វីមួយដែលមិនមែនជាកិច្ចការ(សាសនា)របស់យើងទេនោះ វានឹងត្រូវគេបដិសេធចោល”។[1]

## ជំពូក
## ស្តីពីទីតាំងកំណត់ (មីកត) និងការកំណត់ព្រំដែននៃទីតាំងទាំងនោះ

ទីតាំង(មីកត) កំណត់សម្រាប់ចាប់ផ្តើមគ្របដណ្តប់អៀហរ៉ូម មានចំនួន ៥ កន្លែង៖

ទីមួយ៖ ហ៊្សុលហ៊ូឡៃហ្វះ(គឺសម្រាប់អ្នកស្រុកម៉ាទីណះ) ហើយដែលគេនិយមហៅនៅសព្វថ្ងៃនេះថា៖ អាប់យ៉ារអាលី។

ទីពីរ៖ អាល់ជុះហ្វះ (សម្រាប់អ្នកមកពីតំបន់សាម) ដែលជាមីកតរបស់អ្នករស់នៅតំបន់សាម (ស៊េរីឡីបង់ ហ្សកដានី ប៉ាឡេស្ទីន)ហើយបច្ចុប្បន្នមនុស្សទូទៅបានគ្របដណ្តប់អៀហរ៉ូមពីតំបន់រ៉ាប៊ីរ

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖២៥៥០, មូស្លីម៖១៧១៨

"អ្នកដែលគ្របដណ្ដប់អៀហរ៉មពីតំបន់ រ៉ាប៊ិរ គឺចាត់ទុកថាត្រឹមត្រូវតាមច្បាប់មីកត ព្រោះរ៉ាប៊ិរស្ថិតនៅដល់មុនតំបន់អាល់ជុះហ្វះបន្តិចបន្តួចប៉ុណ្ណោះ។

ទីបីៈ ក័រនុល ម៉ាណាសុិល ជាមីកតរបស់អ្នកតំបន់ណាចជ៍ ដែលបច្ចុប្បន្នហៅថាៈ អាស់សៃល។

ទីបួនៈ យ៉ាឡាំឡាំ ដែលជាមីកតរបស់អ្នករស់នៅប្រទេសយេម៉ែន។

ទីប្រាំៈ ហ្សាតុ អៀតរ៉ក ដែលជាមីកត់របស់អ្នករស់នៅប្រទេសអុីរ៉ាក់។

ហើយទីតាំងមីកត់ទាំងនេះ ត្រូវបានកំណត់ដោយលោកព្យាការី ﷺសម្រាប់អ្នកដែលយើងបានរៀបរាប់ឈ្មោះ (អ្នកស្រុកតំបន់នោះ)និងសម្រាប់អ្នកដទៃទៀតដែលបានធ្វើដំណើរឆ្លងកាត់ទីតាំងទាំងនោះក្នុងចំណោមអ្នកដែលប្រាថ្នាចង់បំពេញកិច្ចការ ធ្វើហាជ្ជី ឬអុំរ៉ោះ។

អ្នកដែលធ្វើដំណើរទៅសាងបុណ្យហាជ្ជី ឬអុំរ៉ោះ ត្រូវតែគ្របដណ្ដប់អៀហរ៉មនៅមីកត ហើយហាមដាច់ខាតការធ្វើដំណើរហួសទីតាំងនោះដោយគ្មានអៀហរ៉ម ទោះតាមផ្លូវគោក ឬផ្លូវអាកាសក៏ដោយ។ នេះជាច្បាប់ទូទៅដែលព្យាការី ﷺ បានកំណត់ទុក។"

«هُنَّ لَهُنَّ، وَلِمَنْ أَتَى عَلَيْهِنَّ مِنْ غَيْرِ أَهْلِهِنَّ، مِمَّنْ أَرَادَ الحَجَّ وَالعُمْرَةَ».

“ទីតាំងមីកត់ទាំងនោះ

គឺសម្រាប់អ្នកដែលរស់នៅទីនោះ (អ្នកស្រុកតំបន់នោះ) និងសម្រាប់អ្នកដទៃ (អ្នកក្រៅតំបន់) ដែលបានធ្វើដំណើរឆ្លងកាត់ទីនោះក្នុងចំណោមអ្នកដែលប្រាថ្នាចង់បំពេញកិច្ចការហាជ្ជី និងអ៊ុំរ៉ោះ។”[1]។

ហើយវាជាច្បាប់កំណត់សម្រាប់អ្នកដែលឆ្ពោះទៅម៉ាក្កុះតាមផ្លូវអាកាសក្នុងគោលបំណងសាងបុណ្យហជ្ជ ឬអ៊ុមរ៉ោះ គឺត្រូវត្រៀមលក្ខណៈឱ្យរួចរាល់ដោយការងូតទឹកសម្អាតកាយ និងកិច្ចដទៃទៀត មុនពេលឡើងយន្តហោះហើយនៅពេលជិតដល់មីកត គេត្រូវស្លៀកក្រណាត់អៀហរ៉ម( អ៊ីហ្សែរនិងរីហ្តីអះ)រួចបន្លឺសម្លេងតាំងចិត្ត(នៀត)ធ្វើអ៊ុំរ៉ោះ ប្រសិនបើមានពេលវេលាគ្រប់គ្រាន់តែបើពេលវេលាប្រកៀកខ្លាំង (ខ្លាចមិនទាន់ហាជ្ជី) គេត្រូវតាំងចិត្តធ្វើហាជ្ជីបើគេស្លៀកក្រណាត់អៀហរ៉មតាំងពីមុនឡើងយន្តហោះ... គឺមិនអីឡើយប៉ុន្តែមិនត្រូវតាំងចិត្ត(នៀត)ចូលកិច្ចបុណ្យ ឬបន្លឺវាចាតល់ពីយ៉ះឡើយលុះត្រាតែនៅពេល (យន្តហោះ) ស្របនឹងមីកត ឬខិតជិតដល់ទីនោះពីព្រោះព្យាការី ﷺ មិនបានធ្វើអៀហរ៉មពីកន្លែងណាផ្សេងក្រៅពីមីកតឡើយ ហើយកាតព្វកិច្ចលើសហគមន៍មូស្លីម

---

[1] រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១៥២៤, មូស្លីមៈ១១៨១

គឺត្រូវធ្វើតាមគំរូរបស់ព្យាការីមូហាំម៉ាត់ ﷺ យោងតាមបន្ទូលរបស់អល់ឡោះជាម្ចាស់ដ៏មហាបរិសុទ្ធថា៖

﴿لَقَدْ كَانَ لَكُمْ فِي رَسُولِ اللَّهِ أُسْوَةٌ حَسَنَةٌ...﴾

ជាការពិតណាស់ ពួកអ្នកមានអ្នកនាំសាររបស់អល់ឡោះ(ព្យាការីមូហាំម៉ាត់) គឺជាគំរូដ៏ល្អសម្រាប់អ្នក... [គម្ពីរគួរអាន ៣៣:២១] ហើយដោយព្យាការី ﷺ បានមានប្រសាសន៍ក្នុងពេលធ្វើហាជ្ជីលាដំណើរ(ហាជ្ជីវ៉ាហ្ទាក)ថា៖

«خُذُوا عَنِّي مَنَاسِكَكُمْ».

“ចូរអ្នករាល់គ្នា យកគំរូ ពីខ្ញុំ”នូវរាល់វិន័យ និងកិច្ចការសាងបុណ្យ (ហាជ្ជី និងអ៊ុំរ៉ោះ) របស់អ្នករាល់គ្នា។[1]

រីឯអ្នកដែលធ្វើដំណើរទៅកាន់ម៉ាក្កះ ហើយមិនមានបំណងធ្វើហាជ្ជី ឬអ៊ុំរ៉ោះ ដូចជាអ្នកជំនួញ អ្នកកាប់អុស អ្នកនាំសំបុត្រ និងអ្នកផ្សេងទៀតជាដើមនោះ គឺមិនតម្រូវឱ្យគាត់ចូលនៀតអៀហរ៉ាមឡើយ លើកលែងតែគាត់មានបំណងចង់ធ្វើដូច្នេះ ដោយយោងតាមចម្រូលរបស់ព្យាការី ﷺ នៅក្នុងហាទីស្ហដែលបានពោលពីមុនមក

---

1 រាយការណ៍ដោយមូស្លីម លេខ (1297)។

នៅពេលដែលលោកបានមានប្រសាសន៍អំពីបណ្ដាមីកគថា៖

«هُنَّ لَهُنَّ، وَلِمَنْ أَتَى عَلَيْهِنَّ مِنْ غَيْرِ أَهْلِهِنَّ، مِمَّنْ أَرَادَ الحَجَّ وَالعُمْرَةَ».

«(ទីកន្លែងមីកគ)ទាំងនោះគឺសម្រាប់អ្នកស្រុករបស់វា និងសម្រាប់អ្នកផ្សេងទៀតដែលធ្វើដំណើរឆ្លងកាត់ដែលមានបំណងធ្វើហាជ្ជី និងអ៊ុំរ៉ោះ»[1]، អត្ថន័យរបស់វាគឺថា ជនណាដែលឆ្លងកាត់មីកគ ហើយគ្មានបំណងធ្វើហាជ្ជី ឬអ៊ុំរ៉ោះ គឺគ្មានការអៀហរ៉មលើគាត់ឡើយ។

ហើយនេះគឺជាក្ដីមេត្តាករុណារបស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់និងជាការបង្កលក្ខណៈងាយស្រួលដល់ពួកគេដូច្នេះ រាល់ការសរសើរ និងអំណរគុណគឺចំពោះទ្រង់លើកិច្ចការនោះហើយចំណុចដែលបញ្ជាក់រឿងនេះ គឺនៅពេលដែលលោកព្យាការី ﷺបានមកដល់ម៉ាក្កះក្នុងឆ្នាំរំដោះ លោកមិនបានធ្វើអៀហរ៉មទេប៉ុន្តែលោកបានចូលទៅ ដោយមានពាក់មួកដែកការពារ (មួកទាហាន) នៅលើក្បាលមកពីនៅពេលនោះ លោកមិនមានបំណងធ្វើហាជ្ជី ឬអ៊ុំរ៉ោះឡើយគឺលោកគ្រាន់តែចង់រំដោះទីក្រុង និងកម្ចាត់រាល់ការធ្វើស្ហ៊ីរិក (ការសក្ការៈរូបបដិមា) ចេញ។

---

1 បានបញ្ជាក់ប្រភពរួចហើយ

ចំពោះបុគ្គលណាដែលទីលំនៅរបស់គេស្ថិតនៅចន្លោះបន្ទាត់មីកត ដូចជាអ្នករស់នៅក្រុងជិតដះ, អ៊ីមុលសាឡាំ, បាហ្ររ៉ោះ... ជាដើមគឺគេមិនចាំបាច់ធ្វើដំណើរទៅកាន់មីកតទាំង ៥ ដែលបានរៀបរាប់ខាងលើឡើយ ផ្ទុយទៅវិញលំនៅឋានរបស់គេ គឺជាមីកតរបស់គេ ហើយគេត្រូវធ្វើអៀហរ៉មពីទីនោះនូវរាល់កិច្ចការបុណ្យដែលគេប្រាថ្នា ទោះជាហាជ្ជី ឬអ៊ុំរ៉ោះក្តីប្រសិនបើគេមានលំនៅឋានមួយទៀត នៅខាងក្រៅខ្សែបន្ទាត់មីកតឬបើគេចង់ គឺអាចធ្វើអៀហរ៉មពីលំនៅឋានរបស់គេដែលនៅជិតម៉ាក្កះបំផុតយោងតាមអត្ថន័យទូទៅនៃប្រសាសន៍របស់ព្យាការី ﷺ... ដែលលោកមានប្រសាសន៍ថា៖

«فَمَنْ كَانَ دُونَهُنَّ، فَمُهَلُّهُ مِنْ أَهْلِهِ، وَكَذَلِكَ حَتَّى أَهْلُ مَكَّةَ يُهِلُّونَ مِنْ مَكَّةَ».

“ចំណែកឯអ្នកដែលនៅខាងក្នុង(ព្រំដែន)ទាំងនោះ គឺត្រូវចាប់ផ្តើម ពីផ្ទះរបស់ខ្លួន ហើយដូចគ្នានេះដែររហូតដល់អ្នកក្រុងម៉ាក្កះគឺពួកគេចាប់ផ្តើមពីក្រុងម៉ាក្កះ”។12 រាយការណ៍ដោយ អ៊ីម៉ាំពូខរី និងមូស្លីម។

---

1 ផ្នែកមួយនៃហាទីស្ទមុន។

2 ពាក្យថា "ម:ហាំឡ្លះ" របស់គេ គឺមានន័យថា៖ ការបន្លឺសម្លេងតាល់ពីយ៉ះរបស់គេចេញពីទីតាំងដែលគេបានគ្របដណ្តប់អៀហរ៉មនោះឯង។

ប៉ុន្តែបុគ្គលណាដែលប្រាថ្នាធ្វើអ៊ុំរ៉ោះ ហើយគេកំពុងស្ថិតក្នុងតំបន់ហារ៉មគឺកាតព្វកិច្ចលើគេត្រូវតែចេញទៅកាន់តំបន់ "ហ៊ិល" (ក្រៅព្រំដែនហារ៉ម) ហើយត្រូវគ្របដណ្តប់អៀរ៉មសម្រាប់អ៊ុំរ៉ោះចេញពីទីនោះពីព្រោះនៅពេលដែលលោកស្រី អៃអ៊ីស្ហះ សុំលោកព្យាការី ﷺ ធ្វើអ៊ុំរ៉ោះលោកបានបង្គាប់ឱ្យបងប្រុសនាងគឺ អាប់ទុលរ៉ោះម៉ាន នាំនាងចេញទៅតំបន់ហ៊ិលនេះបញ្ជាក់ថា អ្នកធ្វើអ៊ុំរ៉ោះមិនត្រូវធ្វើអៀហរ៉ាមចេញពីក្នុងតំបន់ហារ៉មឡើយពោលគឺត្រូវតែធ្វើអៀហរ៉ាមចេញពីតំបន់ហ៊ិល (ក្រៅព្រំដែនហារ៉ម)។

ហើយហាទិស្ហនេះបញ្ជាក់លម្អិតទៅលើហាទីស្ហរបស់ អ៊ិនូអាប់ហ្គាសដែលបានរៀបរាប់កន្លងមក ហើយវាបង្ហាញឱ្យឃើញថា ពិតណាស់គោលបំណងរបស់ណាពី ﷺ នៅក្នុងប្រសាសន៍របស់លោកដែលថា៖

«حَتَّى أَهْلُ مَكَّةَ يُهِلُّونَ مِنْ مَكَّةَ».

“សូម្បីតែអ្នកស្រុកដែលរស់នៅក្នុងទីក្រុងម៉ាក្កះផ្ទាល់ ក៏ពួកគាត់ត្រូវបន្លឺសម្លេងតាំងចិត្ត (សម្រាប់ធ្វើហាជ្ជី) ចេញពីក្នុងទីក្រុងម៉ាក្កះដែរ។”‹1

1 បានដកស្រង់រួចហើយ

"ការអនុញ្ញាតឱ្យតាំងចិត្តចេញពីក្នុងម៉ាក្កះ គឺសម្រាប់តែការធ្វើហាជ្ជីប៉ុណ្ណោះ។ ចំពោះអ៊ុំរ៉ោះ អ្នកត្រូវតែចេញទៅតាំងចិត្តនៅក្រៅព្រំដែនហារ៉ម (តំបន់ហ៊ីល) ដូចដែលលោកព្យាការី ﷺ បានបង្គាប់ដល់លោកស្រី អាអ៊ីស្សះ។ នេះជាមតិរបស់មហាជនអ្នកប្រាជ្ញឥស្លាម ហើយវាក៏ជាការប្រុងប្រយ័ត្នបំផុតសម្រាប់អ្នកមានជំនឿ ពីព្រោះវាជាការអនុវត្តតាមហាទីស្ហទាំងពីរក្នុងពេលតែមួយហើយអល់ឡោះគឺជាអ្នកផ្តល់នូវភាពជោគជ័យ និងការចង្អុលបង្ហាញ។

ចំពោះអ្វីដែលមនុស្សមួយចំនួនតែងតែធ្វើ គឺការធ្វើអ៊ុំរ៉ោះច្រើនដងបន្ទាប់ពីហាជ្ជី ដោយចេញទៅតាំងចិត្តនៅតំបន់ តានអ៊ីម, ជៀករ៉ាណះ ឬកន្លែងផ្សេងទៀតគឺពុំមានភស្តុតាងណាមួយបញ្ជាក់ថាវាជាច្បាប់កំណត់ឡើយ ផ្ទុយទៅវិញ ភស្តុតាងបង្ហាញថាការលះបង់ (មិនធ្វើវា) គឺប្រសើរជាងព្រោះលោកព្យាការី ﷺ និងសហាហ្ពាត់របស់លោក មិនដែលធ្វើអ៊ុំរ៉ោះឡើយក្រោយចប់ហាជ្ជី ចំណែកឯអ្នកស្រី អាអ៊ីស្សះ ដែលបានធ្វើអ៊ុំរ៉ោះពីតំបន់ តានអ៊ីមនោះគឺដោយសារនាងមិនបានធ្វើអ៊ុំរ៉ោះជាមួយគេឯងកាលមកដល់ម៉ាក្កះដំបូង ព្រោះមានរដូវទើបព្យាការី ﷺ អនុញ្ញាតឱ្យនាងធ្វើ

(ដើម្បីបង្គ្រប់ចិត្តនាង)ដូច្នេះ
បុគ្គលណាដែលមានករណី (ឧបសគ្គ) ដូចអ្នកស្រីអាអ៊ីស្ហះគឺគ្មានបញ្ហាឡើយដើម្បីអនុវត្តតាមភស្តុតាងផង និងជាការផ្តល់ភាពទូលំទូលាយដល់មូស្លីមផង។
ហើយពិតជាមិនមានការសង្ស័យឡើយថា
ការដែលអ្នកធ្វើហាជ្ជីរលល់នឹងការធ្វើអ៊ុំរ៉ោះបន្ថែមទៀត
បន្ទាប់ពីពួកគេបានបញ្ចប់កិច្ចការហាជ្ជីរួចរាល់ហើយនោះគឺបង្កឱ្យមានការលំបាកដល់មនុស្សគ្រប់គ្នានិងបង្កឱ្យមានភាពកកកុញខ្លាំង
ក៏ដូចជាគ្រោះថ្នាក់ផ្សេងៗព្រមទាំងជាការធ្វើខុសនឹងគំរូបង្ហាញ របស់លោកព្យាការី ﷺហើយអល់ឡោះគឺជាអ្នកផ្តល់នូវភាពជោគជ័យ
និងការចង្អុលបង្ហាញ។

## ជំពូក
## ក្បួនច្បាប់ចំពោះអ្នកទៅដល់មីកតនៅក្រៅខែហាជ្ជី

ចូរដឹងថា អ្នកដែលទៅដល់មីកត
គឺមានពីរស្ថានភាព៖
ក្នុងករណីដែលគេទៅដល់មីកត
ក្នុងខែដែលមិនមែនជាខែហាជ្ជីដូចជាក្នុងខែរ៉ម៉ាទននិងខែស្ហាក់ពាន ជាដើមគឺស៊ុណ្ណះ សម្រាប់បុគ្គលនេះគឺត្រូវគ្រប់ដណ្តប់អៀហរ៉មសម្រាប់អ៊ុំរ៉ោះដោយតាំងចិត្តក្នុងចិត្ត

និងបន្លឺសម្លេងតាមរយៈអណ្ដាតថា៖"ឡាប់ពៃកា អ៊ុំរ៉តាន់" ឬ "អល់ឡហ៊ុម៉ា ឡាប់ពៃកា អ៊ុំរ៉តាន់"បន្ទាប់មក ត្រូវបន្តបន្លឺសម្លេងតល់ពីយ៉ះ តាមរបៀបព្យាការី ﷺ គឺ៖

«لَبَّيْكَ اللَّهُمَّ لَبَّيْكَ، لَبَّيْكَ لَا شَرِيكَ لَكَ لَبَّيْكَ، إِنَّ الحَمْدَ وَالنِّعْمَةَ لَكَ وَالمُلْكَ، لَا شَرِيكَ لَكَ».

«ទូលបង្គំសូមឆ្លើយតបចំពោះទ្រង់ ឱអល់ឡោះ! ទូលបង្គំសូមឆ្លើយតបចំពោះទ្រង់ ទូលបង្គំសូមឆ្លើយតបចំពោះទ្រង់ ទ្រង់គ្មានដៃគូ (សក្ការៈ) ឡើយ ទូលបង្គំសូមឆ្លើយតបពិតប្រាកដណាស់ រាល់ការសរសើរ ភាពសុខសប្បាយ និងអំណាចទាំងពួង គឺជាកម្មសិទ្ធិរបស់ទ្រង់ទ្រង់មិនមានដៃគូ (សក្ការៈ) ឡើយ។ »[1]
ហើយគេត្រូវសូត្រតាល់ពីយ៉ះនេះឱ្យបានច្រើន និងរំលឹកនាមអល់ឡោះរហូតទាល់តែគេធ្វើដំណើរទៅដល់កាក់ពះ នៅពេលទៅដល់កាក់ពះ គេត្រូវបញ្ឈប់ការសូត្រតាល់ពីយ៉ះរួចធ្វើ "តវ៉ាហ្វ" (ដើរប្រទក្សិណ) ជុំវិញកាក់ពះចំនួន ៧ ជុំ ហើយសឡាត(ថ្វាយបង្គំ) ២ រ៉ក្អាត់ នៅខាងក្រោយម៉ាកមអ៊ីប្រាហ៊ីម បន្ទាប់មកចេញទៅភ្នំសហ្វា ដើម្បីដើរ "សាអ៊ី" ទៅមក

---

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖១៥៤៩, មូស្លីម៖១១៨៤

៧ ជុំ បន្ទាប់មកត្រូវកោរសក់ក្បាល ឬកាត់ឱ្យខ្លីតាមរយៈកិច្ចការនេះ អ៊ុំរ៉ោះរបស់គេត្រូវបានបញ្ចប់ ហើយរាល់ការហាមឃាត់ទាំងឡាយត្រូវបានអនុញ្ញាតឡើងវិញ។

ករណីទី២៖ គឺការដែលគេទៅដល់មីកត់ក្នុងអំឡុងខែទាំងឡាយនៃហាជ្ជីដែលខែទាំងនោះរួមមាន៖ ខែស្ហាវ៉ាល់ និងខែហ្ស៊ុលកក់ដះនិងរយៈពេល ១០ ថ្ងៃដំបូង នៃខែហ្ស៊ុលហិជ្ជះ។

សម្រាប់បុគ្គលបែបនេះ គឺមានសិទ្ធិជ្រើសរើសរវាងជម្រើស ៣ យ៉ាង គឺ៖ ហាជ្ជីតែម្តង, អ៊ុំរ៉ោះតែម្តង, ឬការធ្វើរួមគ្នាទាំងពីរ ព្រោះព្យាការី ﷺ បានផ្តល់ជម្រើសដល់សហាហ្បាត់នូវកិច្ចការទាំង ៣ នេះ ប៉ុន្តែស៊ុណ្ណះសម្រាប់អ្នកដែលគ្មានសត្វជំនូន គឺត្រូវធ្វើអ៊ុំរ៉ោះ (មុន) ព្រោះ ﷺ បានបង្គាប់សហាហ្បាត់ឱ្យប្តូរការតាំងចិត្តទៅជាអ៊ុំរ៉ោះវិញ ពួកគេក៏បានតវ៉ាហ្វ សាអ៊ី កាត់សក់ និងដោះអៀហរ៉ាមតាមបញ្ជារបស់លោក លើកលែងតែអ្នកដែលមានសត្វជំនូន ទើបលោកបង្គាប់ឱ្យរក្សាអៀហរ៉ាមរហូតដល់ថ្ងៃបុណ្យ(រ៉យ៉ា)។ ហើយស៊ុណ្ណះសម្រាប់បុគ្គលដែលបានដឹកនាំសត្វជំនូនសក្ការៈមកជាមួយ គឺត្រូវគ្រប់ដណ្តប់អៀហរ៉ាមសម្រាប់ទាំងហាជ្ជី

និងអុំរ៉ោះរួមគ្នា ពីព្រោះព្យាការី ﷺ បានអនុវត្តបែបនោះ ដោយសារកាលនោះលោកបាននាំយកសត្វជំនូនមកជាមួយដែរ ហើយលោកបានបង្គាប់ដល់សហាហ្ពាត់ណាដែលនាំសត្វមកជាមួយ ឱ្យបន្លឺសម្លេងតាំងចិត្តធ្វើហាជ្ជីរួមជាមួយអុំរ៉ោះរបស់គេ និងមិនត្រូវដោះអៀហរ៉មឡើយ រហូតដល់ថ្ងៃបុណ្យ(ថ្ងៃរ៉យ៉ា) ទោះបីជាគេតាំងចិត្តធ្វើតែហាជ្ជីម្យ៉ាង ក៏ត្រូវរក្សាសភាពអៀហរ៉មរហូតដល់ថ្ងៃបុណ្យដែរ ដូចគ្នាទៅនឹងអ្នកដែលធ្វើហាជ្ជីបែប "គីរ៉ន" (រួមបញ្ចូលគ្នា) ដូច្នោះឯង។

តាមរយៈចំណុចនេះ គេដឹងថាៈ បុគ្គលណាដែលគ្របដណ្តប់អៀហរ៉មធ្វើហាជ្ជីម្យ៉ាង ឬធ្វើហាជ្ជីរួមជាមួយអុំរ៉ោះ ប៉ុន្តែគ្មានសត្វសក្ការៈ(សត្វជំនូន) មកជាមួយ គឺមិនគប្បីឱ្យគេរក្សាសភាពអៀហរ៉ម (រហូតដល់ថ្ងៃរ៉យ៉ា) នោះឡើយ ផ្ទុយទៅវិញ ស៊ុណ្ណៈសម្រាប់គេ គឺត្រូវប្តូរការតាំងចិត្តមកជាអុំរ៉ោះវិញ រួចធ្វើតវ៉ាហ្វ សាអ៊ី កាត់សក់ និងដោះអៀហរ៉មចេញ ដូចដែលលោកព្យាការី ﷺ បានបង្គាប់ដល់អ្នកដែលមិនបាននាំសត្វមកជាមួយ លើកលែងតែបុគ្គលនោះបារម្ភថាខ្លាចមិនទាន់ពេលវេលាធ្វើហាជ្ជី ដោយសារគេមកដល់យឺតពេក

ក្នុងករណីនេះ មិនអីឡើយក្នុងការរក្សាអៀហរ៉ម ហើយអល់ឡោះគឺជាអ្នកដែលដឹងបំផុត។

ប្រសិនបើអ្នកគ្របដណ្តប់អៀហរ៉ម បារម្ភថាមិនអាចបំពេញកិច្ចការបុណ្យបានចប់សព្វគ្រប់ ដោយសារតែគេមានជំងឺ ឬបារម្ភពីសត្រូវ និងបញ្ហាផ្សេងៗជាដើម គឺស៊ុណ្ណះត្រូវឱ្យគេពោលនៅពេលតាំងចិត្តអៀហរ៉មថា៖

"فَإِنْ حَبَسَنِي حَابِسٌ فَمَحِلِّي حَيْثُ حَبَسْتَنِي"

"ប្រសិនបើមានឧបសគ្គណាមួយមករារាំងខ្ញុំ នោះកន្លែងដែលខ្ញុំដោះអៀហរ៉ម គឺនៅត្រង់កន្លែងដែលទ្រង់បានរារាំងខ្ញុំនោះឯង" យោងតាមហាទីស្ហរបស់អ្នកស្រី ទូហ្អា អះ កូនស្រីអាល់ហ្ស៊ូបៃរ៍ ដែលនាងបានជម្រាបថា៖ ឱរ៉សូលុលឡោះ! នាងខ្ញុំចង់ធ្វើហាជ្ជី ប៉ុន្តែនាងខ្ញុំកំពុងមានជំងឺពេលនោះព្យាការី ﷺ បានមានប្រសាសន៍ទៅកាន់នាងថា៖

«حُجِّي وَاشْتَرِطِي أَنَّ مَحِلِّي حَيْثُ حَبَسْتَنِي».

«ចូរនាងធ្វើហជ្ជទៅ ហើយចូរដាក់លក្ខខណ្ឌ (ក្នុងចិត្ត និងពាក្យសម្តី) ថា៖ពិតប្រាកដណាស់ កន្លែងដែលនាងខ្ញុំត្រូវដោះអៀហរ៉ម គឺនៅត្រង់កន្លែងដែលទ្រង់ (អល់ឡោះ) បានរារាំងនាងខ្ញុំនោះឯង។ »[1] រាយការណ៍ដោយអ៊ីម៉ាំ

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖៥០៨៩, មូស្លីម៖១២០៧

ពួខរី និងមូស្លីម

នៅពេលដែលអ្នកគ្របដណ្ដប់អៀហរ៉ាម ជួបប្រទះនូវអ្វីដែលមករារាំងគេ មិនឱ្យបំពេញកិច្ចការបុណ្យបានចប់សព្វគ្រប់ ដូចជាជំងឺ ឬការរារាំងពីសត្រូវ គឺគេត្រូវបានអនុញ្ញាតឱ្យ "តាហាលុល" (ដោះអៀហរ៉ាម) បាន ដោយមិនចាំបាច់បង់ការផាកពិន័យ (ហ្វីឌយ៉ះ) ឬសងសត្វសក្ការៈ (ឌាំ) នោះឡើយ។"

## ជំពូក

## នៅក្នុងហ៊ូកុម(ច្បាប់) នៃការធ្វើហាជ្ជីរបស់កុមារតូច តើវាគ្រប់គ្រាន់សម្រាប់គាត់ជំនួសឱ្យហាជ្ជីនៃឥស្លាមដែរឬទេ?

ការធ្វើហាជ្ជីរបស់កុមារា និងកុមារីតូចៗ គឺមានភាពត្រឹមត្រូវ (ទទួលបានបុណ្យ) យោងតាមការសេចក្ដីរាយការណ៍ របស់មូស្លីម ពីលោក អ៊ិបនូ អាហ្គាស់ មានស្ត្រីម្នាក់បានលើកកុមារតូចម្នាក់បង្ហាញដល់ព្យាការី ﷺ រួចនាងសួរថា៖ ឱរ៉សូលុលឡោះ! តើកុមារម្នាក់នេះអាចធ្វើហាជ្ជីបានដែរឬទេ? លោកក៏តបថា៖ "បាទ បាន! ហើយនាងក៏នឹងទទួលបានផលបុណ្យដែរ"

«نَعَمْ، وَلَكِ أَجْرٌ».

«បាទ បាន! ហើយនាងក៏នឹងទទួលបានផលបុណ្យដែរ"»1

នៅក្នុងសហេីស អ៊ីម៉ាំពូខរី, អំពី សាអ៊ិប កូន យ៉ាហ្សិត رضي الله عنه បាននិយាយថា៖ “គេបាននាំខ្ញុំទៅធ្វើហាជ្ជី រួមជាមួយព្យាការីﷺ ខណៈពេលដែលខ្ញុំមានអាយុត្រឹមតែ ៧ ឆ្នាំប៉ុណ្ណោះ”2។ "ប៉ុន្តែ ការធ្វើហាជ្ជី (កាលពីក្មេង) នេះ មិនទាន់គ្រប់គ្រាន់សម្រាប់ពួកគេទាំងពីរឡើយ ជំនួសឱ្យការធ្វើហាជ្ជីដែលជាកាតព្វកិច្ចគ្រឹះនៃឥស្លាម (ហ្វាជាតុលឥស្លាម )នោះទេ។"

ហើយដូចគ្នាដែរ ចំពោះអ្នកបម្រើបុរស និងអ្នកបម្រើស្ត្រី (ដែលស្ថិតក្រោមការគ្រប់គ្រង) ការធ្វើហាជ្ជីរបស់ពួកគេ គឺទទួលបានផលបុណ្យប៉ុន្តែវាមិនទាន់គ្រប់គ្រាន់ស ម្រាប់ពួកគេ ជំនួសឱ្យហាជ្ជីកាតព្វកិច្ចគ្រឹះឡើយ យោងតាមភស្តុតាងច្បាស់លាស់ពីហាទីស្ហរបស់លោក អ៊ិបនូ អាហ្គាស់ ដែលព្យាការីﷺ មានប្រសាសន៍ថា៖

«أَيُّمَا صَبِيٍّ حَجَّ، ثُمَّ بَلَغَ الحِنْثَ، فَعَلَيْهِ أَنْ يَحُجَّ حَجَّةً أُخْرَى، وَأَيُّمَا عَبْدٍ حَجَّ، ثُمَّ أُعْتِقَ، فَعَلَيْهِ حَجَّةٌ أُخْرَى».

“កុមារណាក៏ដោយដែលបានធ្វើហាជ្ជី

1 រាយការណ៍ដោយ មូស្លីម៖១៣៣៦

2 រាយការណ៍ដោយ អ៊ីម៉ាំអាល់ពូខរី៖១៨៥៨

បន្ទាប់មកគេបានឈានចូលដល់វ័យពេញវ័យ គឺគេមានកាតព្វកិច្ចត្រូវធ្វើហាជ្ជីម្ដងទៀត ហើយអ្នកបម្រើ (ទាសករ) ណាក៏ដោយដែលបានធ្វើហាជ្ជី បន្ទាប់មកគេត្រូវបានរំដោះឱ្យមានសេរីភាព គឺគេមានកាតព្វកិច្ចត្រូវធ្វើហាជ្ជីម្ដងទៀត"[1] រាយការណ៍ដោយ អ៊ីបនូ អាពីស្ហៃពះ និង អាល់ពៃហាគី ដោយមានខ្សែរាយការណ៍ល្អ។

ប្រសិនបើកុមារនោះស្ថិតក្នុងវ័យមិនទាន់ដឹងក្ដី (តូចខ្លាំង) គឺអាណាព្យាបាល (វ៉ាលី) ត្រូវតាំងចិត្ត(នៀត) អៀហរ៉មជំនួសគេ ដោយត្រូវដោះសម្លៀកបំពាក់ដែលមានថ្នេរចេញ និងស្លូត្រតាល់ពីយ៉ះជំនួសគេ តាមរយៈសកម្មភាពនេះ កុមារនោះនឹងក្លាយជាអ្នកស្ថិតក្នុងសភាពអៀហរ៉ម ហើយរាល់ការហាមឃាត់សម្រាប់មនុស្សធំ ក៏ត្រូវអនុវត្តលើកុមារនោះដែរ ហើយពួកគេគប្បីមានភាពស្អាតស្អំ ទាំងសម្លៀកបំពាក់ និងរាងកាយ នៅពេលធ្វើតវ៉ាហ្វ ពីព្រោះការធ្វើតវ៉ាហ្វ គឺប្រៀបដូចជាការថ្វាយបង្គំ (សឡាត) ដែរ។

ហើយប្រសិនបើកុមារា និងកុមារីនោះ គឺជាអ្នកដែលដឹងក្ដី (មានអាយុចាប់ពី ៧ ឆ្នាំឡើងទៅ) ពួកគេទាំងពីរត្រូវគ្របដណ្ដប់អៀហរ៉ម

---

1 រាយការណ៍ដោយ អ៊ីបនូ អាពីស្ហៃពះ៖៤/៤៤៤

(តាំងចិត្ត) ដោយមានការអនុញ្ញាតពីអាណាព្យាបាលរបស់ពួកគេ ហើយពួកគេទាំងពីរត្រូវអនុវត្តនៅពេលចាប់ផ្ដើមអៀហរ៉ម នូវអ្វីដែលមនុស្សធំបានអនុវត្ត រួមមានការងូតទឹក (សម្អាតកាយ) ការប្រើទឹកអប់ និងអ្វីផ្សេងទៀតដែលប្រហាក់ប្រហែលនឹងការងារទាំងនេះ ហើយអាណាព្យាបាលរបស់ពួកគេទាំងពីរ គឺជាអ្នកដែលទទួលបន្ទុកចាត់ចែងរាល់កិច្ចការងាររបស់ពួកគេ ទោះបីជា (អាណាព្យាបាលនោះ) គឺជាឪពុករបស់ពួកគេ ឬម្ដាយរបស់ពួកគេ ឬអ្នកដទៃក្រៅពីពួកគេទាំងពីរនាក់នេះក៏ដោយ ហើយអាណាព្យាបាលត្រូវអនុវត្តជំនួសពួកគេទាំងពីរ នូវអ្វីដែលពួកគេទាំងពីរមិនមានសមត្ថភាពធ្វើបាន ដូចជាការគប់គ្រាប់ក្រួស និងកិច្ចការផ្សេងទៀតដែលប្រហាក់ប្រហែលនេះ ហើយជាកាតព្វកិច្ចលើពួកគេទាំងពីរ ក្នុងការអនុវត្តកិច្ចការផ្សេងទៀតក្រៅពីនោះ នៃកិច្ចការបុណ្យ (ហាជ្ជី/អ៊ុំរ៉ោះ) ដូចជាការឈរនៅវាលអារ៉ហ្វះ ការស្នាក់នៅពេលយប់នៅមីណា និងមូសដាលីហ្វះ ការធ្វើតវ៉ាហ្វ (ដើរប្រទក្សិណជុំវិញកាក់ពះ) និងការធ្វើសាអ៊ី (ដើរទៅមករវាងភ្នំសហ្វានិងម៉ារវ៉ោះ)។ ប្រសិនបើពួកគេទាំងពីរ (កុមារា និងកុមារី) មិនមានសមត្ថភាព (ទន់ខ្សោយ) ក្នុងការធ្វើតវ៉ាហ្វ

និងសាអ៊ី គេត្រូវនាំពួកគេទាំងពីរទៅធ្វើតវ៉ាហ្វ និងសាអ៊ី ក្នុងសភាពដែលត្រូវបានគេពរ (ឬសែង) ហើយអ្វីដែលប្រសើរបំផុតសម្រាប់អ្នកដែលពរពួកគេ គឺមិនត្រូវធ្វើតវ៉ាហ្វ និងសាអ៊ី រួមគ្នា (ក្នុងពេលតែមួយ) រវាងខ្លួនឯង និងរវាងពួកគេទាំងពីរនោះទេ ពោលគឺ គេត្រូវតាំងចិត្តធ្វើតវ៉ាហ្វ និងសាអ៊ី សម្រាប់ពួកគេទាំងពីរ (សិន) ហើយគេត្រូវធ្វើតវ៉ាហ្វសម្រាប់ខ្លួនឯងនូវតវ៉ាហ្វដាច់ដោយឡែកមួយ និងធ្វើសាអ៊ីសម្រាប់ខ្លួនឯងនូវសាអ៊ីដាច់ដោយឡែកមួយ ដើម្បីជាការប្រុងប្រយ័ត្ន (ឱ្យបានហ្មត់ចត់បំផុត) សម្រាប់កិច្ចការគោរពសក្ការៈ និងដើម្បីអនុវត្តតាមហាទីស្ហ៍ខ្ពង់ខ្ពស់។

«دَعْ مَا يَرِيبُكَ إِلَى مَا لَا يَرِيبُكَ».

“ចូរអ្នកបោះបង់ចោលអ្វីដែលធ្វើឲ្យអ្នកមន្ទិលសង្ស័យ រួចងាកទៅរកអ្វីដែលមិនធ្វើឲ្យអ្នកមន្ទិលសង្ស័យ”។[1]

ប៉ុន្តែប្រសិនបើអ្នកដែលពរ (កូន) គេបានតាំងចិត្ត(នៀត)ធ្វើតវ៉ាហ្វសម្រាប់ខ្លួនឯងផង និងសម្រាប់អ្នកដែលត្រូវបានគេពរ (កុមារ) នោះផងដែរ គឺវាគ្រប់គ្រាន់ សម្រាប់គេនូវទង្វើនោះ យោងតាមមតិដែលត្រឹមត្រូវបំផុតក្នុងចំណោមមតិទាំងពីរ (របស់អ្នកប្រាជ្ញ) ពីព្រោះព្យាការី ﷺ

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ីៈ២៥១៨

មិនបានបង្គាប់ទៅកាន់ស្ត្រីដែលបានសួរលោកអំពីការធ្វើហាជ្ជីរបស់កុមារ (មុននេះ) នោះឡើយ ឱ្យនាងធ្វើតវ៉ាហ្វសម្រាប់កុមារនោះ ដាច់ដោយឡែកតែម្នាក់ឯងនោះទេ ហើយប្រសិនបើកិច្ចការនោះ (ការបែងចែកតវ៉ាហ្វ) គឺជាកាតព្វកិច្ច (វ៉ាជិប) នោះព្យាការី ﷺ ពិតជាបានបកស្រាយវាយ៉ាងច្បាស់លាស់រួចទៅហើយ ហើយអល់ឡោះគឺជាអ្នកផ្តល់នូវភាពជោគជ័យ (និងការដឹកនាំដ៏ត្រឹមត្រូវ)។

ហើយកុមារាដែលដឹងក្តី និងកុមារីដែលដឹងក្តី (អាយុ ៧ ឆ្នាំឡើង) ត្រូវតែទទួលបានការបង្គាប់ (ឱ្យអនុវត្ត) នូវភាពស្អាតស្អំពី "ហាដាស់" និង "ណាជិស" (ភាពកខ្វក់ផ្សេងៗ) មុនពេលចាប់ផ្តើមធ្វើតវ៉ាហ្វ ដូចគ្នាទៅនឹងអ្នកគ្របដណ្តប់អៀហរ៉ាមដែលជាមនុស្សធំដែរ ហើយការធ្វើអៀហរ៉ាម (ការតាំងចិត្តសាងបុណ្យ) ជំនួសឱ្យកុមារា និងកុមារីតូចៗនោះ មិនមែនជាកាតព្វកិច្ច (វ៉ាជិប) លើអាណាព្យាបាលរបស់ពួកគេឡើយ ប៉ុន្តែ វាគឺជាការស្ម័គ្រចិត្ត (ស៊ូណាត់) តែប៉ុណ្ណោះ ដូច្នេះ ប្រសិនបើគេ (អាណាព្យាបាល) អនុវត្តកិច្ចការនោះ គេនឹងទទួលបានផលបុណ្យ ហើយប្រសិនបើគេបោះបង់ (មិនបានធ្វើអៀហរ៉ាមឱ្យកូនតូច) នោះក៏មិនមានទោសពៃរ៍អ្វីដល់រូបគេដែរ

ហើយអស់ឡោះគឺជាអ្នកដែលដឹងបំផុត។

## ជំពូក

## ការបកស្រាយអំពីបម្រាមទាំងឡាយនៃអៀហរ៉ម

## និងកិច្ចការដែលអនុញ្ញាតសម្រាប់អ្នកអៀហរ៉ម

មិនត្រូវបានអនុញ្ញាតឡើយ សម្រាប់អ្នកដែលស្ថិតក្នុងសភាពអៀហរ៉ូម បន្ទាប់ពីបានតាំងចិត្តគ្របដណ្តប់អៀហរ៉មរួចរាល់ហើយ ទោះបីជា អ្នកសាងបុណ្យនោះគឺជាភេទប្រុស ឬក៏ជាភេទស្រីក៏ដោយ ក្នុងការយកចេញនូវអ្វីមួយ (កាត់/ដក) ពីសក់របស់គេ ឬក្រចករបស់គេ ឬការប្រើប្រាស់ទឹកអប់។

ហើយមិនត្រូវបានអនុញ្ញាតឡើយ សម្រាប់មនុស្សប្រុសជាពិសេស (ដោយឡែកពីភេទស្រី) ក្នុងការស្លៀកពាក់នូវអ្វីដែលមាន "ថ្នេរ" (សម្លៀកបំពាក់កាត់ដេរ) គ្របដណ្តប់លើរាងកាយទាំងមូលរបស់គេ មានន័យថាៈ (សម្លៀកបំពាក់) ដែលមានរូបរាងត្រូវបានគេវាស់កាត់ និងដេរតម្រូវតាមរូបរាងកាយ ដូចជាអាវវែង (ក៏មីស) ជាដើម ឬគ្របលើផ្នែកណាមួយនៃរាងកាយ ដូចជាអាវយឺត ខោវែង ស្បែកជើងឃ្លុប (ហ៊្សហ្វេន) និងស្រោមជើង លើកលែងតែក្នុងករណីដែលគេរក "អ៊ីហ៊្សើរ" (ក្រណាត់រុំចង្កេះ) មិនបាន

នោះគេត្រូវបានអនុញ្ញាតឱ្យស្លៀកខោវែងបាន ហើយដូចគ្នាដែរ បុគ្គលណាដែលរកស្បែកជើងផ្ទាត់ (ណាក់លែន) មិនបាន គេត្រូវបានអនុញ្ញាតឱ្យពាក់ស្បែកជើងឃ្លុបបាន ដោយមិនចាំបាច់កាត់ (ផ្នែកកជើង) ចេញឡើយ យោងតាមហាទីស្ហរបស់ អ៊ិបនូ អាហ្គាស់ ដែលមានចែងយ៉ាងច្បាស់ក្នុងសៀវភៅពូខរី និងមូស្លីម ដែលថា លោកព្យាការី ﷺ បានមានប្រសាសន៍ថាៈ

«مَنْ لَمْ يَجِدْ نَعْلَيْنِ، فَلْيَلْبَسِ خُفَّيْنِ، وَمَنْ لَمْ يَجِدْ إِزَارًا، فَلْيَلْبَسْ سَرَاوِيلَ».

"ជនណាដែលគ្មានស្បែកជើងផ្ទាត់ ចូរឲ្យគេពាក់ស្បែកជើងឃ្លុប ហើយជនណាដែលគ្មានសារុង ចូរឲ្យគេស្លៀកខោ"[1]។

ចំពោះអ្វីដែលមានចែងក្នុងហាទីស្ហរបស់លោក អ៊ិបនូ អ៊ូមើរ អំពីបទបញ្ជាឱ្យកាត់ស្បែកជើងឃ្លុប (ត្រង់កជើង) ប្រសិនបើចាំបាច់ត្រូវពាក់វាដោយសាររកស្បែកជើងស៊កមិនបាននោះ គឺត្រូវបាន "លុបចោល" (ដោយច្បាប់ថ្មី) ហើយ ពីព្រោះព្យាការី ﷺ បានបង្គាប់បែបនោះនៅទីក្រុងម៉ាទីណះ នៅពេលដែលគេបានសួរលោកអំពីអ្វីដែលអ្នកអៀហ្រាំមត្រូវស្លៀកពាក់ បន្ទាប់មក នៅពេលដែលលោកបានថ្លែងសុន្ទរកថា (ឃុតពះ)

1 រាយការណ៍ដោយ អាល់ពូខរីៈ ១៨៤១, មូស្លីមៈ១១៧៩

ទៅកាន់មនុស្សលោកនៅវាលអារ៉ហ្វះ
លោកបានអនុញ្ញាតឱ្យពាក់ស្បែកជើងឃ្លុបនៅពេល
បាត់ស្បែកជើងស៊ក
ដោយលោកមិនបានបង្គាប់ឱ្យកាត់វាឡើយ
ហើយការពន្យារពេលក្នុងលាតត្រដាងការពិត (ច្បាប់)
លើសពីពេលវេលាដែលចាំបាច់
គឺមិនត្រូវបានអនុញ្ញាតឡើយ
ដូចដែលត្រូវបានដឹងនៅក្នុងមុខវិជ្ជាគ្រឹះនៃហាទីស្ហ
(អ៊ុសូល ហាទីស្ហ) និងច្បាប់ (ហ្វិកោះ) ដូច្នេះ
វាបានក្លាយជាភស្តុតាងច្បាស់លាស់ក្នុងការលុបចោល
នូវបទបញ្ញាឱ្យកាត់នោះ
ហើយប្រសិនបើវាជាកាតព្វកិច្ច (ឱ្យកាត់) ព្យាការី ﷺ
ពិតជាបានបកស្រាយវារួចទៅហើយ
ហើយអល់ឡោះគឺជាអ្នកដែលដឹងបំផុត។

គេអនុញ្ញាតឱ្យអ្នកដែលកំពុងនៅក្នុងសភាពអៀហរ៉ម
ពាក់ស្បែកជើងឃ្លុបដែលទាបជាងកជើងទាំងពីរបាន ព្រោះវាប្រៀបដូចទៅនឹងស្បែកជើងស៊កដែរ។

ហើយវាត្រូវបានអនុញ្ញាតសម្រាប់មួសរ៉ម
ក្នុងការចងក្រណាត់រុំចង្កេះ
និងការចងបង្រឹងវាជាមួយនឹងខ្សែ
ឬអ្វីផ្សេងទៀតដែលប្រហាក់ប្រហែលនឹងវា
(ដូចជាខ្សែក្រវាត់)

ហើយវាត្រូវបានអនុញ្ញាតសម្រាប់អ្នកមួសរ៉ម
ក្នុងការងូតទឹក និងការលាងសម្អាតក្បាលរបស់គេ។

និងការអេះ (ក្បាល) ប្រសិនបើគេមានតម្រូវការចំពោះការងារនោះ ដោយភាពថ្នមៗ និងដោយភាពស្រាលៗ។ ដូច្នេះប្រសិនបើមានអ្វីមួយ (សក់) ជ្រុះចេញពីក្បាលរបស់គេ ដោយសារមូលហេតុនៃទង្វើនោះ គឺមិនមានទោសពៃរ៍ (ឬខុសឆ្គង) អ្វីដល់រូបគេឡើយ។

ហើយត្រូវបានហាមឃាត់ (ហារ៉ាម) លើស្ត្រី ក្នុងការស្លៀកពាក់នូវអ្វីដែលត្រូវបានគេកាត់ដេរ (មានថ្នេរ) សម្រាប់មុខរបស់នាង។ ដូចជា បួរកក(ស្បៃបិទមុខ) និងនីកប (ស្បៃបិទមុខទុកតែភ្នែក) ឬ (របស់ដែលមានថ្នេរ) សម្រាប់ដៃទាំងពីររបស់នាង ដូចជាស្រោមដៃជាដើម។ យោងតាមប្រសាសន៍របស់ព្យាការីថាៈ

«وَلَا تَنْتَقِبِ الْمَرْأَةُ الْمُحْرِمَةُ، وَلَا تَلْبَسِ الْقُفَّازَيْنِ».

«ហើយស្ត្រីដែលស្ថិតក្នុងសភាពអៀហរ៉ម មិនត្រូវប្រើប្រាស់ស្បៃបិទមុខ (នីកប)ឡើយ ហើយនាងក៏មិនត្រូវពាក់ស្រោមដៃទាំងពីរ (របស់នាង) ផងដែរ»។[1] រាយការណ៍ដោយ អ៊ីម៉ាំពូខរី។ ហើយស្រោមដៃទាំងពីរ គឺជាៈ អ្វីដែលត្រូវបានគេកាត់ដេរ ឬត្រូវបានគេត្បាញឡើង ពីវត្ថុធាតុដើមដូចជា រោមសត្វ ឬកប្បាស ឬវត្ថុធាតុដទៃទៀតក្រៅពីរបស់ទាំងពីរនេះ

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១៨៣៨

ដែលត្រូវបានធ្វើឡើង ទៅតាមទំហំ និងរូបរាងនៃដៃទាំងពីរ

ហើយត្រូវបានអនុញ្ញាតសម្រាប់នាង នូវរាល់សម្លៀកបំពាក់ដែលមានថ្នេរ (កាត់ដេរ) ក្រៅពីរបស់ (ដែលបានហាមឃាត់) ទាំងនោះ ដូចជា អាវវែង (ក៏មីស) ខោវែង ស្បែកជើងឃ្លុប ស្រោមជើង និងអ្វីផ្សេងទៀតដែលប្រហាក់ប្រហែលនឹងរបស់ទាំងនេះ។

ហើយដូចគ្នាដែរ វាត្រូវបានអនុញ្ញាតសម្រាប់នាងក្នុងការទម្លាក់ស្បៃគ្របក្បាល (ឃិម៉ារ) របស់នាង ចុះមកលើផ្ទៃមុខរបស់នាង ប្រសិនបើមាងមានតម្រូវការចំពោះការងារនោះ (ដូចជាដើម្បីបិទបាំងពីបុរសដទៃ) ដោយមិនចាំបាច់ប្រើដងទប់ (ឬឧបករណ៍ជំនួយឱ្យស្បៃប៉ោងចេញពីមុខ) ឡើយ ហើយទោះបីជាស្បៃនោះ ប៉ះនឹងផ្ទៃមុខរបស់នាងក៏ដោយ ក៏មិនមានទោសពៃរ៍ (ឬកាតព្វកិច្ចផាកពិន័យ) អ្វីលើរូបនាងដែរ យោងតាមហាទីស្ហរបស់លោកស្រី អាអ៊ីស្ហះ (សូមអល់ឡោះពេញចិត្តនឹងអ្នកស្រី) បាននិយាយថាៈ « ក្រុមអ្នកជិះសត្វជំនិះ (អ្នកដំណើរជាបុរសដទៃ) តែងតែធ្វើដំណើរឆ្លងកាត់ពួកយើង ខណៈពេលដែលពួកយើងកំពុងនៅជាមួយរ៉សូលុលអល់ឡោះ ﷺ ក្នុងសភាពគ្របដណ្តប់អៀហរ៉មនៅពេលដែលពួកគេ (ក្រុមអ្នកដំណើរនោះ)

មកដល់ទន្ទឹមនឹងពួកយើង ពួកយើងម្នាក់ៗបានទម្លាក់អាវធំ (ជិលប៉ាប) ឬស្បៃរបស់នាង ចុះពីលើក្បាលរបស់នាងមកបិទលើផ្ទៃមុខរបស់នាង លុះត្រាតែពួកគេបានធ្វើដំណើរហួសពីពួកយើងទៅ ទើបពួកយើងបើក (ស្បៃ) ផ្ទៃមុខនោះឡើងវិញ។»1 រាយការណ៍ដោយ អាពូហ្ទើវូទ និងអ៊ិបនូម៉ាហ្ជះ ហើយរាយការណ៍ដោយ អាត់ហ្ទើរ៉ាកុឧនី ពីហាទីស្ហរបស់អ៊ុម្មូសឡាម៉ះ ស្រដៀងគ្នានេះ។

ហើយដូចគ្នាដែរ គឺមិនមានបញ្ហាអ្វីឡើយ ក្នុងការដែលនាង គ្របដណ្តប់ដៃទាំងពីររបស់នាង ជាមួយនឹងសម្លៀកបំពាក់របស់នាង ឬអ្វីផ្សេងទៀត (ដែលគ្មានថ្នេរសម្រាប់ម្រាមដៃ) ហើយវាគឺជាកាតព្វកិច្ច (វ៉ាជិប) លើនាង ក្នុងការបិទបាំងផ្ទៃមុខ និងបាតដៃរបស់នាង នៅពេលដែលនាងស្ថិតនៅចំពោះមុខបុរសដទៃ (បុរសដែលអាចរៀបការជាមួយនាងបាន) ពីព្រោះថាផ្នែកទាំងនោះ (មុខ និងដៃ) គឺជាអៅរ៉ាត់ (ផ្នែកដែលត្រូវបិទបាំង) យោងតាមបន្ទូលរបស់អល់ឡោះជ៏មហាខ្ពង់ខ្ពស់ដែលថា៖

﴿...وَلَا يُبْدِينَ زِينَتَهُنَّ إِلَّا لِبُعُولَتِهِنَّ...﴾

---

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖១៨៣៣

ហើយពួកនាងមិនត្រូវបង្ហាញសម្រស់របស់ពួកនាងនោះឡើយ លើកលែងតែចំពោះស្វាមីរបស់ពួកនាង [គម្ពីរគួរអាន ២៤:៣១] ហើយគ្មានការសង្ស័យឡើយថា ផ្ទៃមុខ និងបាតដៃទាំងពីរ គឺជាការតុបតែងមួយដ៏ធំជេងបំផុត។

ហើយចំណុចនេះគឺកាន់តែធ្ងន់ធ្ងរ និងសំខាន់បំផុត៖ ទ្រង់បានមានបន្ទូលទៀតថា៖

﴿...وَإِذَا سَأَلْتُمُوهُنَّ مَتَاعًا فَاسْأَلُوهُنَّ مِنْ وَرَاءِ حِجَابٍ ذَلِكُمْ أَطْهَرُ لِقُلُوبِكُمْ وَقُلُوبِهِنَّ...﴾

...ហើយនៅពេលពួកអ្នកសុំរបស់របរប្រើប្រាស់អ្វីមួយពីពួកនាង(ភរិយាព្យាការី) ចូរពួកអ្នកសុំពីពួកនាង ពីខាងក្រោយបាំង។ ទាំងនោះគឺជាការស្អាតស្អំបំផុតចំពោះចិត្តពួកអ្នក និងចិត្តពួកនាង។... [គម្ពីរគួរអាន ៣៣:៥៣]

ចំពោះអ្វីដែលស្ត្រីជាច្រើនបានទម្លាប់អនុវត្ត (ជាទម្លាប់ផ្ទាល់ខ្លួន) នូវការដាក់ដងទប់ (ឬក្រណាត់រុំក្បាលឱ្យប៉ោង) នៅក្រោមស្បៃគ្របក្បាល ដើម្បីឱ្យវា (ដងទប់នោះ) ទប់ស្បៃឱ្យងើបឡើងចេញពីផ្ទៃមុខរបស់នាង គឺវាគ្មានមូលដ្ឋានគ្រឹះណាមួយឡើយ នៅក្នុងច្បាប់សាសនា (ស្ហារីអាត់) តាមអ្វីដែលពួកយើងបានដឹង ហើយប្រសិនបើកិច្ចការនោះ (ការប្រើដងទប់ស្បៃ) គឺជាអ្វីដែលត្រូវបានបញ្ញត្តិមកមែននោះ

ព្យាការីមូហាំម៉ាត់ ﷺពិតជាបានបកស្រាយវាដល់ប្រជាជនរបស់លោករួចទៅហើយ ។ ហើយវាមិនមែនជាការត្រឹមត្រូវឡើយសម្រាប់លោកក្នុងការនៅស្ងៀម (មិនប្រាប់) ចំពោះរឿងនោះ (ប្រសិនបើវាជាច្បាប់មែន)។

អ្នកដែលស្ថិតក្នុងសភាពអៀហរ៉ម ទាំងបុរសនិងស្ត្រី អាចបោកសម្អាតសម្លៀកបំពាក់អៀហរ៉មរបស់ខ្លួនពីភាពកខ្វក់ ឬអ្វីផ្សេងៗបាន ហើយក៏អាចផ្លាស់ប្តូរវាជាមួយសម្លៀកបំពាក់ផ្សេងទៀតបានផងដែរ។

ហើយគេមិនត្រូវបានអនុញ្ញាតឱ្យស្លៀកពាក់សម្លៀកបំពាក់ដែលប្រឡាក់ដោយហ្សាក់ហ្វារ៉ន ឬ វ៉ារស៊ុឡើយ ពីព្រោះព្យាការី ﷺ លោកបានហាមឃាត់អំពីប្រការនោះនៅក្នុងហាទីស្សរបស់លោកអ៊ិបនូអូមើរ (សូមអល់ឡោះពេញចិត្តដល់គាត់)។

ហើយវាគឺជាកាតព្វកិច្ច (វ៉ាជិប) លើអ្នកអៀហរ៉មក្នុងការបោះបង់ចោលនូវ ការនិយាយអាក្រក់ ការប្រព្រឹត្តអំពើបាប និងការឈ្លោះប្រកែកគ្នា យោងតាមបន្ទូលរបស់អល់ឡោះជាម្ចាស់ខ្ពង់ខ្ពស់ដែលថា៖

﴿الْحَجُّ أَشْهُرٌ مَّعْلُومَاتٌ فَمَنْ فَرَضَ فِيهِنَّ الْحَجَّ فَلَا رَفَثَ وَلَا فُسُوقَ وَلَا جِدَالَ

﴿فِي الْحَجِّ...﴾

(ពេលវេលានៃ)ការធ្វើធម្មយាត្រាហាជ្ជី គឺស្ថិតក្នុងបណ្តាខែដែលត្រូវបានគេដឹងយ៉ាងច្បាស់ ។ ដូចនេះ ចំពោះអ្នកដែលមានកាតព្វកិច្ចធ្វើហាជ្ជីនៅអំឡុងខែទាំងនេះ (ក្រោយពេលកាន់គំណមអៀហរ៉មរួចហើយ) គឺមិនត្រូវរួមដំណេក មិនត្រូវប្រព្រឹត្តអំពើល្មើស(ចំពោះអល់ឡោះ) ហើយក៏មិនត្រូវឈ្លោះប្រកែកគ្នាក្នុងអំឡុងពេលនៃការធ្វើហាជ្ជីនោះដែរ។ [គម្ពីរគួរអាន ២:១៩៧]

ហើយមានការរាយការណ៍ដ៏ត្រឹមត្រូវពីព្យាការី ﷺ ថា លោកបានមានប្រសាសន៍ថា៖

«مَنْ حَجَّ، فَلَمْ يَرْفُثْ، وَلَمْ يَفْسُقْ، رَجَعَ كَيَوْمِ وَلَدَتْهُ أُمُّهُ».

“ជនណាដែលបានធ្វើធម្មយាត្រាហាជ្ជី ហើយគេមិនបានរួមមេត្រី និងមិនបានប្រព្រឹត្តអំពើល្មើសទេនោះ គេនឹងវិលត្រឡប់មកវិញដូចជាថ្ងៃដែលគេប្រសូត្រពីផ្ទៃម្តាយរបស់ខ្លួនដូច្នោះដែរ(ពោលគឺជ្រះស្អាតពីបាបកម្ម)”[1]។ ហើយ "រ៉ហ្វ" ៖ ត្រូវបានប្រើសំដៅលើការរួមដំណេក និងសំដៅលើរាល់សម្តី ឬសកម្មភាពទាំងឡាយណាដែលអាសអាភាស

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១៥២១, មូស្លីមៈ១៣៥០

(មិនសមរម្យ) ហើយ "ហ្វូស៊ូក"៖ គឺសំដៅលើរាល់អំពើបាប ឬការប្រព្រឹត្តល្មើស (នឹងបញ្ញត្តិសាសនា) ហើយ "ជីទើល" ៖ គឺការឈ្លោះប្រកែកគ្នាលើរឿងដែលខុស (មិនពិត) ឬក្នុងរឿងរ៉ាវទាំងឡាយណាដែលគ្មានប្រយោជន៍ ប៉ុន្តែចំពោះការពិភាក្សា (តតាំងមតិ) ដោយវិធីសាស្ត្រដែលល្អបំផុត ដើម្បីបង្ហាញនូវការពិត និងដើម្បីបដិសេធនូវអ្វីដែលខុសឆ្គង នោះគឺមិនមានបញ្ហាអ្វីឡើយ ផ្ទុយទៅវិញ វាគឺជាអ្វីដែលត្រូវបានគេបង្គាប់ឱ្យធ្វើផងដែរ យោងតាមបន្ទូលរបស់អល់ឡោះជាម្ចាស់ដ៏មហាខ្ពង់ខ្ពស់ដែលថា៖

﴿ادْعُ إِلَى سَبِيلِ رَبِّكَ بِالْحِكْمَةِ وَالْمَوْعِظَةِ الْحَسَنَةِ وَجَادِلْهُمْ بِالَّتِي هِيَ أَحْسَنُ...﴾

ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)អំពាវនាវទៅកាន់មាគ៌ានៃព្រះជាម្ចាស់របស់អ្នក(សាសនាអ៊ីស្លាម)ដោយគតិបណ្ឌិត និងការណែនាំដែលល្អ។ ហើយចូរអ្នកជជែកវែកញែកជាមួយពួកគេតាមមធ្យោបាយណាដែលល្អបំផុត... [គម្ពីរគួរអាន ១៦:១២៥]

គេហាមឃាត់ចំពោះអ្នកអៀហរ៉ាមជាបុរស មិនឱ្យគ្របក្បាលរបស់គេជាមួយនឹងអ្វីដែលជាប់នឹងក្បាល ដូចជា៖ មួក សាល់ ក្រណាត់ ឬអ្វីផ្សេងពីនេះ ហើយផ្ទៃមុខរបស់គេក៏ដូចគ្នាដែរ

ដោយយោងទៅតាមប្រសាសន៍របស់ព្យាការី ﷺ អំពីបុរសម្នាក់ដែលបានធ្លាក់ពីលើសត្វជំនិះរបស់គាត់នៅថ្ងៃអារ៉ហ្វះ ហើយបានស្លាប់៖

«اغْسِلُوهُ بِمَاءٍ وَسِدْرٍ، وَكَفِّنُوهُ فِي ثَوْبَيْهِ، وَلَا تُخَمِّرُوا رَأْسَهُ، وَلَا وَجْهَهُ، فَإِنَّهُ يُبْعَثُ يَوْمَ القِيَامَةِ مُلَبِّيًا».

«ចូរពួកអ្នកងូតទឹកឲ្យសពគេដោយទឹក និងស្លឹកពុទ្រា ហើយចូររុំសពគេនឹងសម្លៀកបំពាក់ទាំងពីររបស់គេ ហើយចូរកុំគ្របក្បាលរបស់គេ និងផ្ទៃមុខរបស់គេ ព្រោះពិតប្រាកដណាស់ រូបគេនឹងត្រូវបានគេបង្កើតឲ្យរស់ឡើងវិញនៅថ្ងៃបរលោកដោយកំពុងសូត្រតាល់ប៊ីយ៉ះ»[1] រាយការណ៍ដោយអាល់ពូខរី និងមូស្លីម ហើយនេះគឺជាសម្ដីរបស់អ៊ីម៉ាំមូស្លីម។

ចំណែកឯការជ្រកក្រោមដំបូលឡាន ឬឆត្រ ឬរបស់អ្វីផ្សេងទៀតដែលស្រដៀងគ្នានេះ គឺគ្មានបញ្ហានោះឡើយ ដូចជាការជ្រកនៅក្នុងតង់ និងក្រោមម្លប់ដើមឈើដែរ។ នេះដោយសារតែមានភស្តុតាងត្រឹមត្រូវដែលបញ្ជាក់ថា ព្យាការី ﷺ ត្រូវបានគេយកសម្លៀកបំពាក់មកបាំងជូនលោក នៅពេលដែលលោកគប់ដុំរ៉េះអាល់អាក៏ហ្គះ

---

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖១៥២១, មូស្លីម៖១៣៥០

ហើយក៏មានភស្តុតាងត្រឹមត្រូវពីព្យាការី ﷺ ដែរថា គេបានដំឡើងតង់មួយជូនលោកនៅឯ ណាមីរ៉ោះ ហើយលោកក៏បានស្នាក់នៅពីក្រោមវារហូតដល់ថ្ងៃជ្រេនាថ្ងៃអារ៉ហ្វះ។

ហើយត្រូវបានហាមឃាត់សម្រាប់អ្នកមួសរ៉ិម ទាំងបុរសនិងស្ត្រី នូវការសម្លាប់សត្វព្រៃ និងការជួយជ្រោមជ្រែងក្នុងការងារនោះ និងការបណ្តេញវាចេញពីកន្លែងរបស់វា និងការរៀបអាពាហ៍ពិពាហ៍ និងការរួមភេទ និងការចូលស្ដីដណ្ដឹងស្ត្រី និងការប៉ះពាល់ពួកនាងដោយចំណង់តណ្ហា៖ យោងតាមហាទីស្ហរបស់អ៊ូស្មាន (សូមអល់ឡោះពេញចិត្តដល់គាត់) ដែលថាព្យាការី ﷺ មានប្រសាសន៍ថា៖

«لَا يَنْكِحُ الْمُحْرِمُ وَلَا يُنْكِحُ وَلَا يَخْطُبُ».

“អ្នកដែលស្ថិតក្នុងសភាពអៀហរ៉ាម មិនត្រូវរៀបការ (សម្រាប់ខ្លួនឯង) ឡើយ ហើយគេក៏មិនត្រូវរៀបការឱ្យអ្នកដទៃ (ក្នុងនាមជាអាណាព្យាបាល(វ៉ាលី ឬសាក្សី) ឡើយ ហើយគេក៏មិនត្រូវធ្វើការចូលដណ្តឹង (ឬសុំរៀបការ) នោះដែរ។”។[1] រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម

ហើយប្រសិនបើអ្នកអៀហរ៉ាមស្លៀកសម្លៀកបំពាក់ដែលដេរ ឬបិទបាំងក្បាលរបស់ខ្លួន

1 រាយការណ៍ដោយ មូស្លីម៖១៤០៩

ឬប្រើប្រាស់ទឹកអប់ ដោយភ្លេចភ្លាំង ឬមិនដឹង គឺគ្មានការពិន័យអ្វីឡើយលើគាត់ ហើយគាត់ត្រូវដកចេញនូវអ្វីដែលខុសនោះភ្លាម នៅពេលដែលគាត់នឹកឃើញ ឬបានដឹង។ ហើយដូចគ្នានេះដែរ អ្នកដែលបានកោរសក់របស់ខ្លួន ឬកាត់សក់របស់ខ្លួន ឬកាត់ក្រចករបស់ខ្លួន ដោយភ្លេចភ្លាំង ឬមិនដឹង គឺគ្មានបាបអ្វីឡើយលើគាត់ យោងតាមទស្សនៈដែលត្រឹមត្រូវ។

ហើយជនមូស្លីម - ទោះបីជាគេស្ថិតក្នុងតំណមអៀហរ៉ម ឬមិនស្ថិតក្នុងតំណមអៀហរ៉មក្តី ទោះបីជាបុរស ឬស្ត្រីក៏ដោយ - ត្រូវបានហាមឃាត់ពីការសម្លាប់សត្វនៅក្នុងទឹកដីពិសិដ្ឋ និងការជួយក្នុងការសម្លាប់សត្វនោះ ដោយប្រើប្រាស់ឧបករណ៍ ឬតាមរយៈការធ្វើកាយវិការ ឬអ្វីផ្សេងៗទៀតដែលស្រដៀងនឹងនោះ។

ហើយត្រូវបានហាមឃាត់មិនឱ្យបណ្តេញសត្វ(ព្រៃ) ឱ្យរត់ចេញពីកន្លែងរបស់វា ហើយការកាប់ដើមឈើ និងរុក្ខជាតិបៃតងស្រស់នៅតំបន់ហារ៉ម និងការរើសរបស់ដែលជ្រុះនៅទីនោះក៏ត្រូវបានហាមឃាត់ផងដែរ លើកលែងតែសម្រាប់អ្នកដែលប្រកាសរកម្ចាស់របស់វា ដោយសារការមានប្រសាសន៍របស់ព្យាការីមូហាំម៉ាត់ ﷺ ថា៖

«فَإِنَّ هَذَا البَلَدَ - يَعْنِي مَكَّةَ - حَرَامٌ بِحُرْمَةِ اللَّهِ إِلَى يَوْمِ القِيَامَةِ، لَا يُعْضَدُ شَوْكُهُ، وَلَا يُنَفَّرُ صَيْدُهُ، وَلَا يُلْتَقَطُ لُقَطَتُهُ إِلَّا مَنْ عَرَفَهَا، وَلَا يُخْتَلَى خَلَاهَا».

«ពិតប្រាកដណាស់ ទឹកដីនេះ - មានន័យថា ទីក្រុងម៉ាក្កះ - គឺជាតំបន់ពិសិដ្ឋដោយសារការកំណត់របស់អល់ឡោះរហូតដល់ថ្ងៃជំនុំជំរះ, មិនត្រូវកាប់បន្លារបស់វា, ហើយក៏មិនត្រូវបណ្តេញសត្វព្រៃរបស់វា, ហើយក៏មិនត្រូវរើសយករបស់ដែលជ្រុះបាត់របស់វា លើកលែងតែអ្នកដែលប្រកាស(រកម្ចាស់)វា, ហើយក៏មិនត្រូវកាត់ស្មៅស្រស់របស់វាដែរ»[1] បានយល់ព្រម

ហើយ "អាល់មុនស្ហ៊ីទ"៖ គឺជាអ្នកដែលប្រកាសស្វែងរក (ម្ចាស់របស់ដែលបាត់) ហើយ "អាល់ឃុឡា"៖ គឺជាស្មៅដែលនៅស្រស់ (ស្មៅដែលដុះដោយធម្មជាតិ) ហើយតំបន់មីណា និងមូហ្សហ្ទើលីហ្វះ គឺស្ថិតនៅក្នុងតំបន់ហារ៉ាំ (តំបន់ហាមឃាត់) ប៉ុន្តែចំពោះវាលអារ៉ាហ្វាត វិញ គឺស្ថិតនៅក្នុងតំបន់ហ៊ិល (តំបន់ទូទៅដែលមិនមែនជាហារ៉ាំ)។

---

1 រាយការណ៍ដោយ អ៊ីមុាំពូខរី៖១៨៣៤, មូស្លីម៖១៣៥៣

## ជំពូក
## អំពីកិច្ចការដែលអ្នកធ្វើហាជ្ជីត្រូវធ្វើនៅពេលចូលក្រុងម៉ាក្កះ
## និងការបកស្រាយអំពីអ្វីដែលត្រូវធ្វើបន្ទាប់ពីចូលក្នុងម៉ាស្ជិតហារ៉ម អំពីការតវ៉ាហ្វ និងរបៀបរបស់វា។

នៅពេលដែលគេបានទៅដល់ទីក្រុងម៉ាក្កះ ស៊ូណាត់ឲ្យគេងូតទឹកមុននឹងចូលទៅកាន់ទីក្រុងនោះ ពីព្រោះព្យាការី ﷺ លោកបានធ្វើដូច្នោះដែរ។ នៅពេលដែលទៅដល់ម៉ាស្ជិតអាល់ហារ៉ម គេគប្បីឈានជើងស្តាំចូលមុន ហើយសូត្រថា៖

بِسْمِ اللهِ، وَالصَّلَاةُ وَالسَّلَامُ عَلَى رَسُولِ اللهِ، أَعُوذُ بِاللهِ العَظِيمِ وَبِوَجْهِهِ الْكَرِيمِ وَسُلْطَانِهِ القَدِيمِ مِنَ الشَّيْطَانِ الرَّجِيمِ، اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ

ហើយគេត្រូវសូត្រទូអានេះនៅពេលចូលម៉ាស្ជិតទាំងឡាយផងដែរ ហើយមិនមានពាក្យរំលឹក (ហ្ស៊ីកៀរ) ណាមួយដែលជារឿងដាច់ដោយឡែកសម្រាប់តែការចូលម៉ាស្ជិត អាល់ហារ៉ម ដែលមានចែងច្បាស់លាស់ពីលោកព្យាការី ﷺ តាមអ្វីដែលខ្ញុំបានដឹងនោះទេ។

នៅពេលដែលគេបានទៅដល់វិហារកាក់ពះ គេត្រូវបញ្ឈប់ការសូត្រតាល់ពីយ៉ះ មុននឹងចាប់ផ្តើមធ្វើតវ៉ាហ្វ

ប្រសិនបើគេជាអ្នកដែលបំពេញហាជ្ជីប្រភេទតាំម៉ាត់តក់ ឬជាអ្នកដែលបំពេញអ៊ុំរ៉ោះ។ បន្ទាប់មកត្រូវដើរឆ្ពោះទៅកាន់ហាជើរ៉ុលអាសវ៉ាត់(ថ្មខ្មៅ) ហើយបែរមុខទៅកាន់វា។ រួចឱ្យសាឡាមដោយយកដៃស្តាំប៉ះលើវា ហើយថើបវា ប្រសិនបើមានភាពងាយស្រួល ហើយមិនត្រូវប្រជ្រៀតគ្នាដែលបង្កការលំបាកដល់អ្នកដទៃឡើយ។ ហើយនៅពេលឱ្យសាឡាមនោះ គឺគប្បីសូត្រថា៖

(بِسْمِ اللهِ وَاللهُ أَكْبَرُ)

(ពិសមិល្លាហិ វ៉ល់ឡហ៊ូអឹកពើរ) ឬសូត្រថា៖

(الله أكبر)

(អល់ឡហ៊ូអឹកពើរ)។ ដូច្នេះ ប្រសិនបើការថើបវាមានការលំបាក (ដោយសារមនុស្សកកកុញ) គឺត្រូវស្ទាបវាដោយដៃ ឬដោយដំបង ឬអ្វីដែលប្រហាក់ប្រហែលនឹងរបស់ទាំងនេះ ហើយ (បន្ទាប់មក) ត្រូវថើបលើអ្វីដែលខ្លួនបានយកទៅស្ទាបនោះ (ដូចជាថើបបាតដៃ ឬថើបចុងដំបង) ហើយប្រសិនបើការស្ទាបនោះនៅតែមានការលំបាកទៀត គឺត្រូវធ្វើសញ្ញា (លើកដៃ) សំដៅទៅកាន់វា ហើយពោលថា៖ "អល់ឡហ៊ូអឹកពើរ" (អល់ឡោះមហាអស្ចារ្យបំផុត) ប៉ុន្តែ

មិនត្រូវថើបលើអ្វីដែលខ្លួនបានធ្វើសញ្ញានោះឡើយ (ឧទាហរណ៍៖ បើគ្រាន់តែលើកដៃជម្រាបសួរពីចម្ងាយ គឺមិនបាច់ថើបបាតដៃខ្លួនឯងវិញទេ)។

លក្ខខណ្ឌដើម្បីឱ្យការតវ៉ាហ្វត្រឹមត្រូវគឺ៖ អ្នកដែលធ្វើតវ៉ាហ្វត្រូវតែមានភាពស្អាតស្អំពីភាពមិនហាទេសតូចនិងធំ ព្រោះថាការតវ៉ាហ្វគឺប្រៀបដូចជាការសឡាតដែរ គ្រាន់តែគេអនុញ្ញាតឱ្យនិយាយនៅក្នុងនោះ។ ហើយគេត្រូវដាក់កាក់ហ្ពះនៅខាងឆ្វេងរបស់គេក្នុងពេលកំពុងតវ៉ាហ្វ។ ហើយប្រសិនបើនៅពេលចាប់ផ្ដើមតវ៉ាហ្វ គេបានបួងសួងថា «ឱអល់ឡោះ! ដោយការជឿជាក់លើទ្រង់ និងជឿលើគម្ពីររបស់ទ្រង់ និងបំពេញតាមកិច្ចសន្យារបស់ទ្រង់ និងអនុវត្តតាមស៊ុនណះរបស់ណាពីមូហាំម៉ាត់ ﷺ របស់ទ្រង់» នោះគឺជារឿងល្អ ព្រោះថាការបួងសួងនោះត្រូវបានរ៉ាយការណ៍ពីណាពី ﷺ។ ហើយគេត្រូវតវ៉ាហ្វចំនួនប្រាំពីរជុំ ហើយគេត្រូវដើរញាប់ៗនៅក្នុងបីជុំដំបូងនៃការតវ៉ាហ្វលើកទីមួយ ដែលជាការតវ៉ាហ្វដែលគេធ្វើនៅពេលទៅដល់ម៉ាក្កះដំបូងគេ ទោះបីជាគេជាអ្នកធ្វើអុំរ៉ោះ ឬអ្នកធ្វើហាជ្ជីតាម៉ាត់តួក ឬអ្នកគ្រងអៀហរ៉មសម្រាប់តែហាជ្ជី ឬអ្នកដែលរួមបញ្ចូលគ្នារវាងហាជ្ជីនិងអុំរ៉ោះក៏ដោយ។

ហើយដើរជម្មតានៅក្នុងបួនជុំដែលនៅសល់ ដោយចាប់ផ្ដើមគ្រប់ជុំនីមួយៗពីហាជើរ៉ុលអាស្វាត (ជុំថ្មខ្មៅ) ហើយបញ្ចប់នៅទីនោះដែរ។

ការរត់តិចៗ គឺជាការដើរឲ្យលឿនៗព្រមទាំងបោះជំហានឲ្យញាប់និងជិតៗគ្នា ហើយគេគប្បីបើកស្មាស្ដាំនៅក្នុងតវ៉ាហ្វនេះទាំងអស់ មិនមែនក្នុងកិច្ចការផ្សេងពីនេះឡើយ។ ការបើកស្មាស្ដាំ គឺត្រូវដាក់ក្រណាត់អៀហរ៉មពីក្រោមក្លៀកខាងស្ដាំ និងដាយអៀហរ៉មពីលើស្មាឆ្វេង។

ហើយប្រសិនបើមានការសង្ស័យចំពោះចំនួនជុំ គឺត្រូវយកតាមអ្វីដែលប្រាកដច្បាស់ក្នុងចិត្ត ដែលជាចំនួនតិចជាង។ ដូចច្នេះ ប្រសិនបើគេសង្ស័យថាតើខ្លួនបានដើរចំនួនបីជុំ ឬបួនជុំ គេត្រូវចាត់ទុកថាវាជាបីជុំ ហើយគេត្រូវធ្វើដូច្នេះដែរនៅក្នុងការធ្វើសាអ៊ី។

បន្ទាប់ពីគេបញ្ចប់តវ៉ាហ្វនេះរួច គេត្រូវគ្របស្មាវិញដោយដាក់ដាយទាំងពីររបស់វានៅលើទ្រូង មុននឹងគេសឡាតតវ៉ាហ្វចំនួនពីររ៉ក្អាត់។

ហើយក្នុងចំណោមប្រការដែលត្រូវហាមឃាត់ស្ត្រី និងព្រមានដល់ពួកនាងអំពីវានោះគឺ ការដើរតវ៉ាហ្វរបស់ពួកនាងដោយតុបតែងខ្លួន និងប្រើប្រាស់ទឹកអប់ ហើយនិងការមិនបិទបាំងខ្លួនប្រាណ

ខណៈដែលពួកនាងគឺជារឿងកេរខ្មាស់។ ហេតុនេះ ចាំបាច់លើពួកនាងត្រូវបិទបាំងខ្លួនប្រាណ ហើយត្រូវបោះបង់ចោលការតុបតែង(សម្រស់)នៅពេលធ្វើតវ៉ាហ្វ និងករណីផ្សេងៗទៀតដែលពួកនាងនៅលាយឡំជាមួយនឹងបុរស ពីព្រោះពួកនាងគឺជារឿងកេរខ្មាស់ និងជាប្រភពនៃភាពវឹកវរ។ ហើយផ្ទៃមុខរបស់ស្ត្រីគឺជាការតុបតែង(សម្រស់)ដែលបង្ហាញឲ្យឃើញច្បាស់ជាងគេបំផុតរបស់នាង ដូចនេះ នាងមិនត្រូវបានអនុញ្ញាតឲ្យបង្ហាញវាឡើយ លើកលែងតែចំពោះបណ្តាមូហរ៉មរបស់នាង ដោយយោងទៅតាមបន្ទូលរបស់អល់ឡោះជាម្ចាស់ដ៏ខ្ពង់ខ្ពស់ដែលទ្រង់មានបន្ទូលថាៈ

﴿...وَلَا يُبْدِينَ زِينَتَهُنَّ إِلَّا لِبُعُولَتِهِنَّ...﴾

ហើយពួកនាងមិនត្រូវបង្ហាញសម្រស់របស់ពួកនាងនោះឡើយ លើកលែងតែចំពោះស្វាមីរបស់ពួកនាង

[គម្ពីរគួរអាន ២៤:៣១] មិនអនុញ្ញាតឱ្យស្ត្រីទាំងនោះបើកផ្ទៃមុខរបស់ពួកគេនៅពេលថើបហាជើរ៉ុលអាសវ៉ាត់(ថ្មខ្មៅ) ប្រសិនបើមានបុរសណាម្នាក់មើលឃើញពួកនាងឡើយ។ ហើយប្រសិនបើមិនមានភាពងាយស្រួលសម្រាប់ពួកនាងក្នុងការប៉ះថ្មនិងថើបវាទេ

គឺមិនអនុញ្ញាតឱ្យពួកនាងប្រជ្រៀតជាមួយបុរសឡើយ ផ្ទុយទៅវិញ ពួកនាងត្រូវតរ៉ាវ៉ីហ្វនៅពីក្រោយពួកគេ ហើយនោះគឺប្រសើរជាងសម្រាប់ពួកនាង និងទទួលបានផលបុណ្យច្រើនជាងការតវ៉ាហ្វនៅក្បែរកាក់បះក្នុងពេលដែលពួកនាងប្រជ្រៀតជាមួយបុរស។ ច្បាប់មិនបានអនុញ្ញាតឱ្យធ្វើរ៉ម៉ាល់(ដើរញាប់ៗ) និងអ៊ិតទីបាក(បង្ហាញស្មាស្តាំ) នៅក្នុងការតវ៉ាហ្វផ្សេងទៀត ឬនៅក្នុងការសៃអៀឡើយ ហើយក៏មិនមែនសម្រាប់ស្ត្រីដែរ ព្រោះព្យាការី ﷺ បានធ្វើរ៉ម៉ាល់ និងអ៊ិតទីបាកតែនៅក្នុងការតវ៉ាហ្វលើកដំបូងរបស់គាត់នៅពេលដែលគាត់បានមកដល់ម៉ាក្កះប៉ុណ្ណោះ។ ក្នុងអំឡុងពេលតវ៉ាហ្វ គេត្រូវតែស្ថិតក្នុងភាពស្អាតស្អំពីភាពមិនបរិសុទ្ធទាំងឡាយ មានភាពចុះចូល និងបន្ទាបខ្លួនចំពោះម្ចាស់របស់ខ្លួន។

នៅក្នុងពេលតវ៉ាហ្វ ស៊ូណាត់ឲ្យគេបង្កើននូវការហ្សិកៀររំលឹកទៅចំពោះអល់ឡោះ និងការសុំទូអា ហើយការសូត្រគម្ពីរគួរអានខ្លះៗក្នុងពេលនោះក៏ជាការល្អដែរ។ នៅក្នុងការតវ៉ាហ្វនេះ និងតវ៉ាហ្វផ្សេងៗទៀត ក៏ដូចជាការដើរសាអ៊ី គឺគ្មានការហ្សិកៀរ ឬទូអាណាមួយដែលជាវ៉ាជិបជាក់លាក់នោះឡើយ។

ចំណែកឯអ្វីដែលមនុស្សមួយចំនួនបានបង្កើតឡើ

ងថ្មី នូវការកំណត់ការរំឭកជាក់លាក់ ឬទូអាជាក់លាក់សម្រាប់ជុំនីមួយៗនៃការធ្វើតវ៉ាហ្វ ឬការធ្វើសាអ៊ី គឺគ្មានគោលការណ៍ច្បាស់លាស់ទេ។ ផ្ទុយទៅវិញ អ្វីក៏ដោយដែលងាយស្រួលពីការរំឭក និងទូអាគឺគ្រប់គ្រាន់ហើយ។ នៅពេលដែលទៅដល់ជ្រុងយ៉ាម៉ានី គាត់ត្រូវប៉ះវាដោយដៃស្តាំរបស់គាត់ ហើយសូត្រថា៖

"بِسْمِ اللهِ وَاللّٰهُ أَكْبَرُ"

ហើយមិនត្រូវថើបវាទេ។ ប្រសិនបើគាត់ពិបាកក្នុងការប៉ះវា គាត់ត្រូវទុកវាចោល ហើយបន្តការធ្វើតវ៉ាហ្វរបស់គាត់។ ហើយមិនត្រូវចង្អុលទៅវាទេ ហើយក៏មិនត្រូវតឹកពៀរនៅពេលទៅដល់ស្របនឹងវាដែរ ព្រោះថារឿងនោះមិនមានបញ្ជាក់ពីព្យាការី ﷺ ទេ តាមដែលយើងដឹង។ ហើយស៊ូណិតលើគេគប្បីសូត្រនៅចន្លោះជ្រុងយ៉ាម៉ានី និងហាជើរ៉ុលអាសវ៉ាត(ថ្មខ្មៅ)ថា៖

﴿...رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا عَذَابَ النَّارِ ﴿٢٠١﴾﴾

ឱអល់ឡោះជាម្ចាស់របស់យើង! សូមទ្រង់មេត្តាប្រទានដល់យើងខ្ញុំនូវប្រការល្អក្នុងលោកិយ និងប្រការល្អនៅថ្ងៃបរលោក ព្រមទាំងការពារយើងខ្ញុំពីទណ្ឌកម្មនៃភ្លើងនរកផង។ [គម្ពីរគួរអាន ២:២០១]

រាល់ពេលដែលគេឆ្លងកាត់ហាជើរ៉ុលអាសវ៉ាត់
គឺត្រូវឱ្យសាទ្បាមដោយយកដៃស្តាំប៉ះលើវា និងថើបវា
ហើយសូត្រថា៖ (أكبر الله)(អល់ឡហ៊ូអឹកពើរ)។
ប្រសិនបើមិនមានភាពងាយស្រួលក្នុងការធ្វើដូច្នេះទេ
គឺត្រូវលើកដៃតម្រង់ទៅកាន់វារាល់ពេលដែលឆ្លងកាត់ ហើយសូត្រ(أكبر الله)(អល់ឡហ៊ូអឹកពើរ)។

គ្មានបញ្ហាអ្វីទេក្នុងការធ្វើតវ៉ាហ្វពីក្រោយអណ្តូងហ្សាំហ្សាំនិងម៉ាកម
ជាពិសេសនៅពេលមានមនុស្សច្រើន
ហើយម៉ាស្ជិតទាំងមូលគឺជាទីកន្លែងសម្រាប់តវ៉ាហ្វ។
ប្រសិនបើគេធ្វើតវ៉ាហ្វនៅក្នុងរបងម៉ាស្ជិតក៏ត្រឹមត្រូវដែរ
ប៉ុន្តែការតវ៉ាហ្វនៅជិតកាក់ហ្ពះគឺប្រសើរជាងប្រសិនបើអាចធ្វើទៅបាន។

នៅពេលដែលតវ៉ាហ្វរួច
គេត្រូវសទ្បាតពីររ៉ក្អាត់ខាងក្រោយម៉ាកមអ៊ីព្រហ៊ីម
ប្រសិនបើមានភាពងាយស្រួល
ប៉ុន្តែប្រសិនបើមានការលំបាកដោយសារការចង្អៀតជាដើម
គឺអាចសទ្បាតនៅកន្លែងណាក៏បានក្នុងម៉ាស្ជិត។
ហើយជាស៊ូណាត់ដែលត្រូវសូត្រនៅក្នុងរ៉ក្អាត់ទាំងពីរនោះ បន្ទាប់ពីសូត្រអាល់ហ្វាទីហះ

﴿قُلْ يَٰٓأَيُّهَا ٱلْكَٰفِرُونَ ١﴾

ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថាៈ ឱពួកដែលគ្មានជំនឿ! (អាល់កាហ្វិរូនៈ១) នៅរ៉ក្អាត់ទីមួយ និង

﴿قُلْ هُوَ ٱللَّهُ أَحَدٌ ۝١﴾

ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលចុះថាៈ អល់ឡោះគឺជាព្រះជាម្ចាស់(ដែលគេត្រូវគោរពសក្ការៈ)តែមួយគត់។ (អាល់អៀខ្លើសៈ១) នៅក្នុងរ៉ក្អាត់ទីពីរ នេះគឺជាការល្អប្រសើរ ហើយប្រសិនបើគេសូត្រ(ជំពូក)ផ្សេងពីនេះក៏មិនមានបញ្ហាអ្វីដែរ។ បន្ទាប់មក ត្រូវឆ្ពោះទៅកាន់ហាជើរ៉ុលអាសវ៉ាត់(ថ្មខ្មៅ) ហើយយកដៃស្ទាំប៉ះវាប្រសិនបើមានភាពងាយស្រួល ដើម្បីអនុវត្តតាមព្យាការី ﷺ ។

បន្ទាប់មក ត្រូវចេញទៅកាន់ភ្នំសហ្វា រួចឡើងលើវា ឬឈរនៅត្រង់នោះ ហើយការឡើងគឺប្រសើរជាងប្រសិនបើមានភាពងាយស្រួល។ នៅពេលចាប់ផ្ដើមជុំទីមួយ គេត្រូវសូត្រថាៈ

﴿إِنَّ الصَّفَا وَالْمَرْوَةَ مِنْ شَعَائِرِ اللَّهِ...﴾

ជាការពិតណាស់ ភ្នំសហ្វា និងភ្នំម៉ារវ៉ាស់ គឺជាអត្តសញ្ញាណមួយក្នុងចំណោមអត្តសញ្ញាណរបស់អល់ឡោះជាម្ចាស់... (អាល់ហ្គាក៏រ៉ោះៈ១៥៨)

ហើយជាការប្រសើរដែលត្រូវបែរមុខទៅកាន់ទិសគីបឡាត់នៅលើភ្នំសហ្វា ហើយសរសើរដល់អល់ឡោះ និងតឹកពៀរ ហើយសូត្រថាៈ

لَا إِلَهَ إِلَّا اللهُ، وَاللهُ أَكْبَرُ، لَا إِلَهَ إِلَّا اللهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ الْمُلْكُ وَلَهُ الْحَمْدُ، يُحْيِي وَيُمِيتُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، لَا إِلَهَ إِلَّا اللهُ وَحْدَهُ، أَنْجَزَ وَعْدَهُ، وَنَصَرَ عَبْدَهُ، وَهَزَمَ الأَحْزَابَ وَحْدَهُ"

បន្ទាប់មក គេត្រូវធ្វើការទូអាទៅតាមអ្វីដែលងាយស្រួល ដោយលើកដៃទាំងពីរឡើង ហើយពោលឡើងវិញនូវការរំឭកដល់អល់ឡោះ និងការទូអានេះ (ចំនួនបីដង)។ បន្ទាប់មក ត្រូវចុះដើរទៅកាន់ភ្នំម៉ារវ៉ះរហូតដល់បង្គោលទីមួយ ពេលនោះបុរសត្រូវរត់តិចៗរហូតដល់បង្គោលទីពីរ។ ចំណែកឯស្ត្រីវិញ មិនត្រូវបានអនុញ្ញាតឱ្យរត់នៅចន្លោះបង្គោលទាំងពីរឡើយ ពីព្រោះនាងគឺជាអៅរ៉ោះ ហើយអ្វីដែលតម្រូវសម្រាប់នាង គឺការដើរធម្មតានៅក្នុងការសាអ៊ីទាំងមូល។ បន្ទាប់មក គេត្រូវដើររហូតដល់ឡើងទៅលើភ្នំម៉ារវ៉ះ ឬក៏ឈរនៅត្រង់នោះ។ ហើយការឡើងទៅលើភ្នំនោះគឺប្រសើរជាង ប្រសិនបើគេអាចធ្វើបាន។ ហើយគេត្រូវសូត្រ និងធ្វើនៅលើភ្នំម៉ារ៉ា ដូចដែលគេបានសូត្រ និងធ្វើនៅលើភ្នំសហ្វាដែរ លើកលែងតែការសូត្រអាយ៉ាត់ ដែលជាបន្ទូលរបស់អល់ឡោះជាម្ចាស់:

﴿إِنَّ الصَّفَا وَالْمَرْوَةَ مِنْ شَعَائِرِ اللَّهِ...﴾

ជាការពិតណាស់ ភ្នំសហ្វា និងភ្នំម៉ារវ៉ាស់ គឺជាអត្តសញ្ញាណមួយក្នុងចំណោមអត្តសញ្ញាណរបស់អល់ឡោះជាម្ចាស់... (អាល់ហ្គាក៏រ៉ោះ៖១៥៨) ការអនុវត្តនេះគឺសម្រាប់តែពេលឡើងភ្នំសហ្វានៅក្នុងជុំទីមួយប៉ុណ្ណោះ ដើម្បីអនុវត្តតាមព្យាការី ﷺ។ បន្ទាប់មក គេត្រូវចុះដើរនៅកន្លែងដែលត្រូវដើរ ហើយរត់តិចៗនៅកន្លែងដែលត្រូវរត់តិចៗ រហូតដល់ទៅដល់ភ្នំសហ្វា។ គេត្រូវធ្វើបែបនេះឱ្យបានប្រាំពីរជុំ ដោយការចេញទៅរាប់ថាមួយជុំ ហើយការត្រឡប់មកវិញរាប់ថាមួយជុំ។ ពីព្រោះព្យាការី ﷺ បានធ្វើដូចដែលបានរៀបរាប់ ហើយលោកបានមានប្រសាសន៍ថា៖

«خُذُوا عَنِّي مَنَاسِكَكُمْ».

“ចូរអ្នករាល់គ្នារៀនសូត្រ យកគំរូពីខ្ញុំ”។នូវរាល់វិន័យ និងកិច្ចការសាងបុណ្យ (ហាជ្ជី និងអ៊ុំរ៉ោះ) របស់អ្នករាល់គ្នា”។[1] ហើយជាប្រការស៊ូណាត់ (មូស្ដាហាប់) ឱ្យរូបគេបង្កើនការរំលឹកនឹកគុណ (ហ្ស៊ីកៀរ) និងការបួងសួង (ទូអា) តាមអ្វីដែលងាយស្រួល ក្នុងកំឡុងពេលដើរសាអ៊ីរបស់គេ។ និងឱ្យរូបគេស្ថិតក្នុងសភាពស្អាតស្អំ ផុតពី "ហាដាសធំ" (ការរួមដំណេក/មករដូវ) និង "ហាដាសតូច"

1 បានបញ្ជាក់ប្រភពរួចហើយ

(ការមិនមានវូហ្គុ)។ ប៉ុន្តែ ប្រសិនបើគេបានដើរសាអ៊ីដោយមិនមានវូហ្គុ (សភាពមិនស្អាតស្អំ) ក៏វាត្រូវបានចាត់ទុកថាត្រឹមត្រូវ (គ្រប់គ្រាន់) សម្រាប់គេដែរ។ ហើយដូចគ្នាដែរ ប្រសិនបើស្ត្រីមានមករដូវ ឬឈាមក្រោយសម្រាលកូន បន្ទាប់ពីនាងបានដើរតវ៉ាហ្វរួចរាល់ នោះនាងអាចបន្តដើរសាអ៊ីបាន ហើយវាត្រូវបានចាត់ទុកថាត្រឹមត្រូវសម្រាប់នាង។ ពីព្រោះថាភាពស្អាតស្អំ (វូហ្គុ) មិនមែនជាលក្ខខណ្ឌដាច់ខាត នៅក្នុងការដើរសាអ៊ីឡើយ គឺវាគ្រាន់តែជាប្រការស៊ូណាត់ (មូស្តាហាប់) ដូចដែលបានរៀបរាប់ខាងលើប៉ុណ្ណោះ។

នៅពេលដែលបានបញ្ចប់សាអ៊ី គេត្រូវកោរសក់ ឬកាត់សក់របស់គេ។ ការកោរសម្រាប់បុរសគឺប្រសើរជាង។ ប្រសិនបើគេកាត់សក់ ហើយទុកការកោរសម្រាប់ធ្វើហាជ្ជី នោះគឺជាការល្អ។ ហើយប្រសិនបើគេទៅដល់ក្រុងម៉ាក្កះខិតជិតនឹងថ្ងៃធ្វើហាជ្ជី នោះការកាត់សក់ខ្លីគឺប្រសើរជាងសម្រាប់គេ ដើម្បីទុកសក់សម្រាប់កោរនៅពេលធ្វើហាជ្ជី។ ពីព្រោះព្យាការី ﷺ នៅពេលដែលលោក និងសហការីរបស់លោកបានទៅដល់ក្រុងម៉ាក្កះនៅថ្ងៃទីបួន ខែហ្ស៊ុលហិជ្ជះ លោកបានបញ្ជាឱ្យអ្នកដែលមិនបាននាំសត្វជំនូន-

យកមកជាមួយ ឱ្យចេញពីអៀហរ៉ម និងកាត់សក់ខ្លី ហើយលោកមិនបានបញ្ជាឱ្យពួកគេកោរសក់ឡើយ។ ក្នុងការកាត់សក់ ត្រូវតែកាត់ឱ្យសព្វពេញក្បាល ហើយការកាត់ត្រឹមតែផ្នែកខ្លះគឺមិនគ្រប់គ្រាន់ឡើយ ដូចគ្នានឹងការកោរត្រឹមតែផ្នែកខ្លះដែរ។ ចំណែកឯស្ត្រីវិញ គឺតម្រូវឱ្យកាត់សក់ ដោយមិនតម្រូវឱ្យកោរឡើយ។ ដោយតម្រូវឱ្យនាងកាត់សក់ដែលចងក្រងរបស់នាង ប្រវែងមួយថ្នាំងដៃ ឬតិចជាងនេះ។ ពាក្យថា ថ្នាំងដៃ គឺសំដៅលើចុងម្រាមដៃ។ ស្ត្រីមិនត្រូវកាត់លើសពីនេះឡើយ។

ដូច្នេះ នៅពេលដែលអ្នកស្ថិតក្នុងអៀហរ៉ម បានអនុវត្តនូវអ្វីៗដែលបានរៀបរាប់រួចមកហើយនោះ នោះកិច្ចការអ៊ុំរ៉ោះរបស់គេត្រូវបានបញ្ចប់ជាស្ថាពរ ហើយវាត្រូវបានអនុញ្ញាត (ហាឡាល) សម្រាប់រូបគេវិញនូវរាល់អ្វីៗទាំងអស់ដែលធ្លាប់ត្រូវបានហាមឃាត់ (ហារ៉ាំ) លើរូបគេក្នុងកំឡុងពេលអៀហរ៉ម លើកលែងតែក្នុងករណីដែលរូបគេបាននាំយកសត្វជំនូន មកជាមួយតាំងពីក្រៅតំបន់ហរ៉ាំ (តំបន់ហ៊ីល) នោះរូបគេត្រូវតែបន្តស្ថិតក្នុងសភាពអៀហរ៉មដដែល រហូតទាល់តែរូបគេបានបញ្ចប់ (តាហាលុល) ទាំងកិច្ចការហាជ្ជី និងអ៊ុំរ៉ោះ ជាមួយគ្នា។

រីឯអ្នកអៀហរ៉មធ្វើហាជ្ជីអ៊ិហ្វរ៉ាទ ឬហាជ្ជីគីរ៉ន គឺគេគប្បីប្តូរអៀហរ៉មរបស់ខ្លួនទៅជាអ៊ុំរ៉ោះ

ហើយត្រូវធ្វើដូចអ្នកធ្វើហាជ្ជីតាម៉ាត់តួកដែរ លើកលែងតែគេបាននាំសត្វជំនូនមកជាមួយ។ ពីព្រោះព្យាការី ﷺ បានបញ្ជាពួកសហាការីរបស់លោកឲ្យធ្វើដូច្នេះ ហើយលោកបានមានប្រសាសន៍ថា៖

«لَوْلَا أَنِّي سُقْتُ الهَدْيَ لَأَحْلَلْتُ مَعَكُمْ».

«ប្រសិនបើមិនមែនមកពីខ្ញុំបាននាំយកសត្វជំនូនមកជាមួយទេនោះ ខ្ញុំពិតជាបានដោះអៀហរ៉ម (តាហាលុល) ជាមួយពួកអ្នកបាត់ទៅហើយ។»[1]

នៅពេលដែលស្ត្រីម្នាក់មករដូវ ឬមានឈាមនិហ្វាស(ឈាមក្រោយសម្រាល) បន្ទាប់ពីនាងបាននៀត(ប៉ង)អៀហរ៉មសម្រាប់អ៊ុំរ៉ោះ នាងមិនត្រូវធ្វើការតវ៉ាហ្វ ហើយក៏មិនត្រូវរត់រវាងភ្នំសហ្វា និងម៉ារវ៉ះដែរ រហូតទាល់តែនាងជ្រះស្អាតសិន។ នៅពេលដែលនាងជ្រះស្អាត នាងត្រូវធ្វើការតវ៉ាហ្វ រត់រវាងភ្នំសហ្វា និងម៉ារវ៉ះ ហើយកាត់សក់ក្បាលរបស់នាង នោះអ៊ុំរ៉ោះរបស់នាងក៏ត្រូវបានបញ្ចប់។ ប្រសិនបើនាងមិនទាន់ជ្រះស្អាតមុនថ្ងៃតារវីយ៉ះ(ថ្ងៃទី៨នៃខែហ្ស៊ុលហីជ្ជះ)ទេនោះ នាងត្រូវនៀត(ប៉ង)អៀហរ៉មសម្រាប់ហាជ្ជីពីកន្លែង

---

1 រាយការណ៍ដោយ អាល់ពូខរីៈ១៥៦៨

ដែលនាងកំពុងស្នាក់នៅនោះ ហើយចេញដំណើរជាមួយប្រជាជនទៅកាន់មីណា ហើយដោយសារតែបែបនេះ នាងនឹងក្លាយជាអ្នកធ្វើហាជ្ជីប្រភេទគីរ៉ន ដែលរួមបញ្ចូលគ្នារវាងហាជ្ជីនិងអ៊ុំរ៉ោះ។ ហើយនាងត្រូវធ្វើអ្វីដែលអ្នកធ្វើហាជ្ជីធ្វើ ដូចជាការឈរនៅអារ៉ហ្វះ, នៅមូសដាលីហ្វះ, ការគប់ដុំថ្មនៅកន្លែងជម៉ារ៉ត់, ការស្នាក់នៅមួយយប់នៅមូសដាលីហ្វះ និងមីណា, ការសំឡេះសត្វជំនួននិងការកាត់សក់។ នៅពេលដែលនាងជ្រះស្អាត នាងត្រូវធ្វើការតវ៉ាហ្វ និងរត់រវាងភ្នំសហ្វា និងម៉ារវ៉ះ ដោយធ្វើតវ៉ាហ្វតែម្តង និងរត់រវាងភ្នំសហ្វានិងម៉ារវ៉ះតែម្តងគត់ ហើយការធ្វើបែបនេះគឺគ្រប់គ្រាន់សម្រាប់ហាជ្ជី និងអ៊ុំរ៉ោះរបស់នាងទាំងពីរ។ នេះបើយោងទៅតាមហាទីស្ហរបស់អ្នកស្រី អាអ៊ីស្សះ ដែលអ្នកស្រីបានមករដូវបន្ទាប់ពីអ្នកស្រីបាននៀត(ប៉ង)អៀហរ៉មសម្រាប់អ៊ុំរ៉ោះ ហើយព្យាការី(សូមសុខសន្តិភាពមានដល់លោក)បានមានប្រសាសន៍ទៅកាន់អ្នកស្រីថា៖

«افْعَلِي مَا يَفْعَلُ الحَاجُّ غَيْرَ أَنْ لَا تَطُوفِي بِالبَيْتِ حَتَّى تَطْهُرِي».

«ចូរធ្វើអ្វីៗដែលអ្នកធ្វើហាជ្ជីធ្វើ លើកលែងតែការដើរតវ៉ាហ្វជុំវិញកាក់ហ្ពះប៉ុណ្ណោះ

រហូតដល់អ្នកបានជ្រះស្អាត»។[1] រាយការណ៍ដោយអ៊ីមុាំពូខរី និង មូស្លីម។

នៅពេលស្ត្រីមករដូវ ឬមានឈាមក្រោយសម្រាលកូន បានគប់គោលនៅថ្ងៃនៃការសំឡេះសត្វ និងកាត់សក់របស់ខ្លួនរួច អ្វីៗទាំងអស់ដែលត្រូវបានហាមឃាត់លើនាងដោយសារការអៀសរ៉ម គឺត្រូវបានអនុញ្ញាតឡើងវិញដូចជាទឹកអប់ជាដើម លើកលែងតែស្វាមីរហូតទាល់តែនាងបំពេញកិច្ចការហជ្ជីបានរួចរាល់ដូចស្ត្រីដែលជ្រះស្អាតដទៃទៀតដែរ។ ដូច្នេះ នៅពេលដែលនាងបានដើរតវ៉ាហ្វ និងដើរសាច់អ៊ុ◌ិបន្ទាប់ពីជ្រះស្អាតហើយ នោះនាងអាចរួមមេត្រីជាមួយស្វាមីរបស់នាងបានវិញ។

## ជំពូក
## ស្តីពីហ៊ូកុមនៃការនៀតអៀហរ៉មហាជ្ជីនៅថ្ងៃទីប្រាំបីនៃខែហ្ស៊ុលហ៊ិជ្ជះ និងការចាកចេញទៅកាន់មីណា

នៅពេលដែលចូលមកដល់ថ្ងៃតើរវីយ៉ះ ដែលជាថ្ងៃទីប្រាំបីនៃខែហ្ស៊ុលហ៊ិជ្ជះ ជាការគប្បីសម្រាប់អ្នកដែលមិនស្ថិតក្នុងតំណមអៀ

1 រាយការណ៍ដោយ អ៊ីមុាំពូខរីៈ៣០៥, មូស្លីមៈ១២១១

ហរ៉មនៅម៉ាក្កះ
និងអ្នកក្រុងម៉ាក្កះដែលមានបំណងធ្វើហាជ្ជី
គឺត្រូវនៀតអៀហរ៉មហាជ្ជីពីលំនៅដ្ឋានរបស់ពួកគេ។
ព្រោះថាបណ្ដាសាហាហ្ពាត់របស់ព្យាការី ﷺ
បានស្នាក់នៅតំបន់អាប់តហ៍
ហើយពួកគេបាននៀតអៀហរ៉មហាជ្ជីពីទីនោះនៅថ្ងៃ
តើរវីយ៉ះតាមបទបញ្ជារបស់លោក ﷺ។ ហើយព្យាការី ﷺ
មិនបានបញ្ជាឱ្យពួកគេទៅកាន់កាក់ហ្ពះដើម្បីនៀត
អៀហរ៉មនៅទីនោះ ឬនៅក្បែរមីហ្សាបនោះឡើយ។
ដូចគ្នានេះដែរ
លោកមិនបានបញ្ជាឱ្យពួកគេធ្វើតវ៉ាហ្វវ៉ាហ្ទាកនៅពេ
លពួកគេចាកចេញទៅកាន់មីណានោះឡើយ។
ប្រសិនបើកិច្ចការនោះត្រូវបានបញ្ញត្តិនៅក្នុងសាស
នា
លោកពិតជាបានបង្រៀនដល់ពួកគេជាក់ជាមិនខា
ន។
ហើយរាល់គ្រប់អំពើល្អទាំងអស់គឺស្ថិតនៅក្នុងការធ្វើ
តាមព្យាការី ﷺ និងបណ្ដាសាហាហ្ពាត់របស់លោក
សូមអល់ឡោះស្រឡាញ់ពេញចិត្តចំពោះពួកគេ។
ស៊ូណាត់ត្រូវងូតទឹក សម្អាតកាយ
និងប្រើគ្រឿងក្រអូបនៅពេលអៀហរ៉មហាជ្ជី
ដូចដែលគេអនុវត្តនៅពេលអៀហរ៉មនៅមីកតដែរ។
ក្រោយពីពួកគេបានកាន់អៀហរ៉មធ្វើហាជ្ជីរួច
គប្បីឲ្យពួកគេតម្រង់ទៅកាន់មីណាក្នុងថ្ងៃតារវីយ៉ះ
មុនថ្ងៃត្រង់ ឬក្រោយពីនោះ

ហើយត្រូវពោលពាក្យតាល់ពីយ៉ះឲ្យបានច្រើនរហូតទាល់តែពួកគេបានគប់ជុំរ៉ោះអាស់កហ្ពាះ។
ពួកគេត្រូវសឡាតហ្ស៊ូហោរ អាសើរ ម៉ាហ្គ្រិប អ៊ីស្ហា និងស៊ូពូសនៅមីណា
ហើយតាមសុណ្ណះគឺត្រូវសឡាតរាល់សឡាតនីមួយៗតាមពេលវេលារបស់វាដោយបង្រួមសឡាត(កសើរ) ដោយមិនបូករួមបញ្ចូលគ្នាសឡាត(ជម៉ក់)ឡើយ លើកលែងតែសឡាតម៉ាហ្គ្រិប និងស៊ូពូស គឺមិនត្រូវបង្រួមចំនួននោះទេ។

ហើយមិនមានភាពខុសគ្នារវាងអ្នកក្រុងម៉ាក្កះ និងអ្នកផ្សេងទៀតឡើយ ព្រោះថា ព្យាការី ﷺ លោកបានដឹកនាំអ្នកក្រុងម៉ាក្កះ និងអ្នកផ្សេងទៀតសឡាតនៅមីណា អារ៉ហ្វះ និងមូហ្សដាលីហ្វះ ដោយសឡាត ហើយលោកបង្រួមខ្លី មិនបានបង្គាប់ឲ្យអ្នកក្រុងម៉ាក្កះសឡាតឲ្យបានពេញលេញនោះឡើយ។ ប្រសិនបើវាជាកាតព្វកិច្ចលើពួកគេ លោកច្បាស់ជាបានបញ្ជាក់ប្រាប់ពួកគេហើយ។

ក្រោយមក បន្ទាប់ពីថ្ងៃរះនាថ្ងៃអារ៉ហ្វះ អ្នកធ្វើហាជ្ជីត្រូវធ្វើដំណើរពីមីណាឆ្ពោះទៅកាន់អារ៉ហ្វះ ដោយស៊ូណាត់ឱ្យស្នាក់នៅឯណាមីរ៉ោះរហូតដល់ថ្ងៃជ្រេ ប្រសិនបើអាចធ្វើបាន
ព្រោះវាជាសកម្មភាពរបស់ព្យាការី ﷺ។

ហើយនៅពេលថ្ងៃជ្រេ គឺស៊ុនណះសម្រាប់អ៊ីម៉ាំ ឬអ្នកតំណាងរបស់គាត់
ក្នុងការថ្លែងឃុតហ្ពះ(ថ្លែងសុន្ទរកថា)មួយទៅកាន់ម

នុស្ស ដែលសមស្របនឹងស្ថានភាព ដោយពន្យល់នៅក្នុងយុតហ្គុះនោះនូវអ្វីដែលត្រូវបាន បញ្ញត្តិសម្រាប់អ្នកធ្វើហាជ្ជីនៅថ្ងៃនេះ និងថ្ងៃបន្ទាប់។ នៅក្នុងយុតហ្គុះនោះដែរ គាត់ត្រូវបង្គាប់ពួកគេឲ្យកោតខ្លាចអល់ឡោះតែម្នាក់គត់ និងមានភាពស្មោះត្រង់(អ៊ិខ្លើស)ចំពោះទ្រង់នៅក្នុងរាល់កិច្ចការងារទាំងអស់ ព្រមទាំងព្រមានពួកគេពីបម្រាមទាំងឡាយរបស់ទ្រង់ និងផ្តាំផ្ញើពួកគេឲ្យកាន់ខ្ជាប់នូវគម្ពីររបស់អល់ឡោះ និងស៊ុណ្ណះរបស់ព្យាការី ﷺ ហើយត្រូវកាត់សេចក្តីដោយគម្ពីរនិងស៊ុណ្ណះ និងត្រូវស្វែងរកការកាត់សេចក្តីពីគម្ពីរនិងស៊ុណ្ណះនៅក្នុងគ្រប់កិច្ចការទាំងអស់ ដើម្បីធ្វើត្រាប់តាមព្យាការី ﷺ នៅក្នុងរឿងទាំងអស់នោះ។ បន្ទាប់មក ពួកគេត្រូវសឡាតហ្ស៊ូហ៊្ួរ និងអាសើរ ដោយបង្រួម(កសើរ) និងផ្តុំ(ជម៉ក់តឹកទីម គឺយកសឡាតអាសើរមកសឡាតក្នុងពេលហ្ស៊ូហ៊្ួរ) ដោយអាហ្សានមួយ និងអ៊ិកកម៉ះពីរ ដូចដែលព្យាការី ﷺ បានប្រព្រឹត្ត។ រាយការណ៍ដោយមូស្លិម ពីហាំទីស្ហរបស់ជាពៀរ សូមអល់ឡោះពេញចិត្តដល់គាត់)។

បន្ទាប់មក គេត្រូវឈរនៅអារ៉ហ្វះ ហើយទីកន្លែងអារ៉ហ្វះទាំងមូលជាកន្លែងឈរ លើកលែងតែនៅ ហ្គាត់និល អ៊ូរ៉ណះ។ ហើយជាការល្អ

គឺត្រូវតម្រង់ទៅកាន់គីបឡាត់ និងភ្នំអាល់រ៉ស់ម៉ះ ប្រសិនបើអាចធ្វើបាន។ បើសិនមិនអាចតម្រង់ទៅកាន់ទាំងពីរបានទេ នោះគេត្រូវតម្រង់ទៅកាន់គីបឡាត់ ទោះបីជាមិនបានតម្រង់ទៅកាន់ភ្នំក៏ដោយ។ ហើយអ្នកធ្វើហាជ្ជីគួរតែព្យាយាមនៅកន្លែងឈរនេះ ក្នុងការសូត្រហ្ស៊ីកៀរចំពោះអល់ឡោះជាម្ចាស់ និងសុំទូអាដោយទទូចអង្វរករចំពោះទ្រង់ ហើយត្រូវលើកដៃទាំងពីរនៅពេលសុំទូអា។ ហើយប្រសិនបើគេពោលតាល់ពីយ៉ះ ឬសូត្រគម្ពីរគួរអានខ្លះៗ នោះក៏ជាការល្អដែរ។ ហើយជាស៊ុនណះដែលត្រូវពោលឱ្យបានច្រើននូវពាក្យថា៖ "لَا إِلَهَ إِلَّا اللَّهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ المُلْكُ وَلَهُ الحَمْدُ، يُحْيِي وَيُمِيتُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ" ព្រោះមានការរាយការណ៍ពីព្យាការី ﷺ ថា លោកបានមានប្រសាសន៍ថា៖

«خَيْرُ الدُّعَاءِ دُعَاءُ يَوْمِ عَرَفَةَ، وَأَفْضَلُ مَا قُلْتُ أَنَا وَالنَّبِيُّونَ مِنْ قَبْلِي: لَا إِلَهَ إِلَّا اللَّهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ المُلْكُ وَلَهُ الحَمْدُ، يُحْيِي وَيُمِيتُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ[1]».

ការបួងសួង(ទូអា)ដែលល្អជាងគេបំផុត គឺការបួងសួង(ទូអា)នៅថ្ងៃអារ៉ហ្វះ, ហើយពាក្យដែលល្អជាងគេបំផុតដែលខ្ញុំ និងបណ្ដាណាពីមុនខ្ញុំបានសូត្រគឺ៖

---

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ីៈ៣៥៨៥

ហើយមានភាពត្រឹមត្រូវពីព្យាការី ﷺ ដែលលោកបានមានប្រសាសន៍ថា៖

«أَحَبُّ الكَلَامِ إِلَى اللَّهِ أَرْبَعٌ: سُبْحَانَ اللَّهِ، وَالحَمْدُ لِلَّهِ، وَلَا إِلَهَ إِلَّا اللَّهُ، وَاللَّهُ أَكْبَرُ».

«ពាក្យពេចន៍ដែលអល់ឡោះជាម្ចាស់ស្រឡាញ់បំផុតគឺមានបួនឃ្លាគឺ៖ ស៊ុបហានុលឡោះ, វ៉ាល់ហាំទូលិលឡះ, វ៉ាឡាអ៊ីឡាហាអ៊ិលឡលឡោះ, និង វ៉ុលឡហ៊ូអឹកពើរ»[1]

ដូចនេះ គួរតែបង្កើននូវការហ្សីកៀរនេះ និងសូត្រវាឡើងវិញឲ្យបានច្រើនដោយភាពឱនលំទោន និងការផ្ចង់អារម្មណ៍។ ម្យ៉ាងទៀតក៏គួរតែបង្កើននូវការហ្សីកៀរ និងទូអាទាំងឡាយដែលមានចែងនៅក្នុងច្បាប់ឲ្យបានច្រើនផងដែរនៅគ្រប់ពេលវេលា ជាពិសេសនៅក្នុងទីកន្លែងនេះ ក្នុងថ្ងៃដ៏អស្ចារ្យនេះ។ ហើយត្រូវជ្រើសរើសយកនូវការហ្សីកៀរ និងទូអាដែលមានអត្ថន័យគ្រប់ជ្រុងជ្រោយ ដែលក្នុងចំណោមនោះគឺ៖

អល់ឡោះជាម្ចាស់ដ៏មហាបរិសុទ្ធ ហើយការសរសើរទាំងឡាយ គឺសម្រាប់ទ្រង់, អល់ឡោះជាម្ចាស់មហាបរិសុទ្ធ មហាធំធេង

﴿...لَا إِلَهَ إِلَّا أَنتَ سُبْحَانَكَ إِنِّي كُنتُ مِنَ الظَّالِمِينَ﴾

---

1 រាយការណ៍ដោយ មូស្លីម៖២១៣៧

គ្មានម្ចាស់ណាផ្សេងដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីទ្រង់ឡើយ។ ទ្រង់មហាស្អាតស្អំ។ ពិតប្រាកដណាស់ ខ្ញុំទេដែលស្ថិតក្នុងចំណោមអ្នកដែលបំពាននោះ។ [គម្ពីរគួរអាន ២១:៨៧]

គ្មានម្ចាស់ណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ ហើយពួកយើងមិនគោរពសក្ការៈចំពោះអ្នកណាផ្សេងក្រៅពីទ្រង់ឡើយ។ រាល់នៀកម៉ាត់(ការប្រោសប្រទាន)គឺជារបស់ទ្រង់ ហើយរាល់ការប្រទានឱ្យគឺជារបស់ទ្រង់ ហើយរាល់ការសរសើរដ៏ល្អប្រសើរគឺជារបស់ទ្រង់។ គ្មានម្ចាស់ណាដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដក្រៅពីអល់ឡោះឡើយ ដោយពួកយើងមានភាពស្មោះត្រង់ចំពោះទ្រង់នៅក្នុងសាសនា ទោះបីជាពួកដែលប្រឆាំងនឹងទ្រង់ស្អប់ខ្ពើម(នូវទង្វើនេះ)ក៏ដោយ។

គ្មានទេអំណាច និងឥទ្ធិពល គឺមានតែមកពីអល់ឡោះ[1]។

* ﴿...رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا عَذَابَ النَّارِ ﴿٢٠١﴾﴾

ឱព្រះជាម្ចាស់របស់យើង!

1 រាយការណ៍ដោយ មូស្លីមៈ៥៩៤

សូមទ្រង់មេត្តាប្រទានដល់យើងខ្ញុំនូវប្រការល្អក្នុងលោកិយ និងប្រការល្អនៅថ្ងៃបរលោក ព្រមទាំងការពារយើងខ្ញុំពីទណ្ឌកម្មនៃភ្លើងនរកផង។ [អាល់ហ្គាក៏រ៉ោះ៖ ២០១]

* اللَّهُمَّ أَصْلِحْ لِي دِينِيَ الَّذِي هُوَ عِصْمَةُ أَمْرِي، وَأَصْلِحْ لِي دُنْيَايَ الَّتِي فِيهَا مَعَاشِي، وَأَصْلِحْ لِي آخِرَتِي الَّتِي فِيهَا مَعَادِي، وَاجْعَلِ الحَيَاةَ زِيَادَةً لِي فِي كُلِّ خَيْرٍ، وَالمَوْتَ رَاحَةً لِي مِنْ كُلِّ شَرٍّ.

ឱអល់ឡោះ! សូមទ្រង់មេត្តាកែលម្អសាសនារបស់ខ្ញុំឱ្យបានល្អប្រសើរ ដែលវាគឺជាការការពារ (បង្អែក) នៃរាល់កិច្ចការងាររបស់ខ្ញុំ និងសូមទ្រង់មេត្តាកែលម្អលោកីយរបស់ខ្ញុំឱ្យបានល្អប្រសើរ ដែលវាគឺជាកន្លែងសម្រាប់ជីវភាពរស់នៅរបស់ខ្ញុំ និងសូមទ្រង់មេត្តាកែលម្អថ្ងៃខាងមុខ(អាឃីរ៉ាត់) របស់ខ្ញុំឱ្យបានល្អប្រសើរ ដែលវាគឺជាកន្លែងត្រឡប់ទៅវិញរបស់ខ្ញុំ និងសូមធ្វើឱ្យជីវិតរស់នៅនេះ ជាការបន្ថែមនូវរាល់អំពើល្អសម្រាប់ខ្ញុំ និងសូមធ្វើឱ្យសេចក្តីស្លាប់ ជាការសម្រាក (ភាពស្ងប់សុខ) សម្រាប់ខ្ញុំឱ្យផុតពីរាល់អំពើអាក្រក់ទាំងពួង។[1]

1 រាយការណ៍ដោយ មូស្លីម៖២៧២០

* أَعُوذُ بِاللَّهِ مِنْ جَهْدِ البَلَاءِ، وَدَرَكِ الشَّقَاءِ، وَسُوءِ القَضَاءِ، وَشَمَاتَةِ الأَعْدَاءِ.

ខ្ញុំសូមការពារពីទ្រង់ ឱ្យផុតពីភាពធ្ងន់ធ្ងរនៃទុក្ខវេទនា (ឬគ្រោះមហន្តរាយដែលលើសពីសមត្ថភាពនឹងទ្រាំទ្របាន) និង សូមការពារឱ្យផុតពីការធ្លាក់ទៅក្នុងសេចក្តីវិនាស ឬភាពអភ័ព្វក្នុងជីវិត និងសូមការពារឱ្យផុតពី ការសម្រេចវាសនាដ៏អាក្រក់ និងសូមការពារឱ្យផុតពី ការត្រេកអរ សើចចំអករបស់សត្រូវចំពោះទុក្ខសោករបស់ខ្ញុំ។[1]។

* اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنَ الهَمِّ وَالحَزَنِ، وَأَعُوذُ بِكَ مِنَ العَجْزِ وَالكَسَلِ، وَأَعُوذُ بِكَ مِنَ الجُبْنِ وَالبُخْلِ، وَمِنَ المَأْثَمِ وَالمَغْرَمِ، وَأَعُوذُ بِكَ مِنْ غَلَبَةِ الدَّيْنِ وَقَهْرِ الرِّجَالِ.

ឱអល់ឡោះ! ពិតប្រាកដណាស់ ទូលបង្គំសូមជ្រកកោននឹងទ្រង់ឱ្យរួចផុតពីការព្រួយបារម្ភ និងទុក្ខសោក។ ហើយទូលបង្គំសូមជ្រកកោននឹងទ្រង់ឱ្យរួចផុតពីភាពអសមត្ថភាព និងភាពខ្ជិលច្រអូស។ ហើយទូលបង្គំសូមជ្រកកោននឹងទ្រង់ឱ្យរួចផុតពីភាពកំសាក និងភាពកំណាញ់ និងពីអំពើបាប និងការជំពាក់បំណុល។ ហើយទូលបង្គំសូមជ្រកកោននឹងទ្រង់ឱ្យរួចផុតពីការជំពាក់បំណុលវ័ណ្ឌក

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ៦៣៤៧

និងការគាបសង្កត់ពីសំណាក់មនុស្សលោក[1]។

* اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنَ الْبَرَصِ وَالْجُنُونِ وَالْجُذَامِ وَمِنْ سَيِّئِ الأَسْقَامِ.

ឱអល់ឡោះ! ពិតប្រាកដណាស់ ខ្ញុំសូមការការពារពីទ្រង់ ឱ្យចៀសផុតពីជំងឺភឿក និងជំងឺ ឆ្កួតវង្វេង និង ជំងឺឃ្លង់និងឱ្យចៀសផុតពីជំងឺកាចសាហាវផ្សេងៗ)[2]។

ឱអល់ឡោះ! ពិតប្រាកដណាស់ខ្ញុំសុំពីទ្រង់នូវការអភ័យទោស និងសុខសុវត្ថិភាពទាំងនៅក្នុងលោកិយ និងថ្ងៃបរលោក។

ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវការអភ័យទោស និងភាពសុខសាន្ត ចំពោះសាសនារបស់ខ្ញុំ លោកិយរបស់ខ្ញុំ ក្រុមគ្រួសាររបស់ខ្ញុំ និងទ្រព្យសម្បត្តិរបស់ខ្ញុំ។

* اللَّهُمَّ اسْتُرْ عَوْرَتِي وَآمِنْ رَوْعَاتِي، اللَّهُمَّ احْفَظْنِي مِنْ بَيْنِ يَدَيَّ وَمِنْ خَلْفِي، وَعَنْ يَمِينِي وَعَنْ شِمَالِي، وَمِنْ فَوْقِي، وَأَعُوذُ بِعَظَمَتِكَ أَنْ أُغْتَالَ مِنْ تَحْتِي.

ឱអល់ឡោះ សូមទ្រង់បិទបាំងនូវកំហុសឆ្គងរបស់ខ្ញុំ និងសូមទ្រង់ធ្វើឲ្យខ្ញុំមានសុវត្ថិភាពពីការភ័យខ្លាចរបស់ខ្ញុំ។ ឱអល់ឡោះ សូមទ្រង់ការពារខ្ញុំពីខាងមុខខ្ញុំ និងពីខាងក្រោយខ្ញុំ និងពីខាងស្តាំខ្ញុំ

1 រាយការណ៍ដោយ អាពូហ្ទើរ៉ូទ ដោយប្រើពាក្យពេចន៍នេះពី អាពូអ៊ូម៉ាម៉ះ អាល់អាន់សរី ដោយមិនមានពាក្យថា (វ៉ាមីណាល់ម៉ាក់សាំ វ៉ាល់មើរ៉ុម) ៖១៥៥៤

2 រាយការណ៍ដោយ អាពូហ្ទើរ៉ូទ៖១៥៥៤

និងពីខាងឆ្វេងខ្ញុំ និងពីខាងលើខ្ញុំ។ ហើយខ្ញុំសូមជ្រកកោននឹងភាពមហិមារបស់ទ្រង់ពីការត្រូវគេធ្វើឃាតពីខាងក្រោមខ្ញុំ[1]។

* اللَّهُمَّ اغْفِرْ لِي جِدِّي وَهَزْلِي، وَخَطَئِي وَعَمْدِي، وَكُلَّ ذَلِكَ عِنْدِي، اللَّهُمَّ اغْفِرْ لِي مَا قَدَّمْتُ وَمَا أَخَّرْتُ، وَمَا أَسْرَرْتُ وَمَا أَعْلَنْتُ، وَمَا أَنْتَ أَعْلَمُ بِهِ مِنِّي، أَنْتَ الْمُقَدِّمُ وَأَنْتَ الْمُؤَخِّرُ، وَأَنْتَ عَلَى كُلِّ شَيْءٍ قَدِيرٌ.

ឱអល់ឡោះ សូមទ្រង់មេត្តាអភ័យទោសឱ្យខ្ញុំបាទនូវទង្វើដែលខ្ញុំបាទបានធ្វើដោយពិតប្រាកដ និងដោយលេងសើច និងកំហុសឆ្គងរបស់ខ្ញុំបាទ និងដោយចេតនា ហើយទាំងអស់នោះគឺមាននៅក្នុងខ្លួនខ្ញុំបាទ។ ឱអល់ឡោះ សូមទ្រង់មេត្តាអភ័យទោសឱ្យខ្ញុំបាទនូវអ្វីដែលខ្ញុំបាទបានប្រព្រឹត្តកន្លងមក និងអ្វីដែលខ្ញុំបាទនឹងប្រព្រឹត្តទៅថ្ងៃមុខ និងអ្វីដែលខ្ញុំបាទបានលាក់បាំង និងអ្វីដែលខ្ញុំបាទបានបង្ហាញឱ្យគេឃើញ និងអ្វីដែលទ្រង់ដឹងច្បាស់អំពីវាជាងខ្ញុំបាទទៅទៀត។ ទ្រង់គឺជាអ្នកដែលធ្វើឱ្យទៅមុន និងជាអ្នកដែលធ្វើឱ្យទៅក្រោយ ហើយទ្រង់គឺជាអ្នកដែលមានសមត្ថភាពលើអ្វីៗទាំងអស់។[2]

---

1 រាយការណ៍ដោយ អាពូហ៊្មើរ៉ូទះ៥០៧៤

2 ផ្នែកមួយនៃហាទីស្ហដែលរាយការណ៍ដោយអ៊ីម៉ាំមូស្លីម តាមរយៈអាពូ មូសា អាល់អាស្អអារី (សូមអល់ឡោះពេញចិត្តដល់គាត់) ៖២៧១៩។

* اللَّهُمَّ إِنِّي أَسْأَلُكَ الثَّبَاتَ فِي الأَمْرِ وَالعَزِيمَةَ عَلَى الرُّشْدِ، وَأَسْأَلُكَ شُكْرَ نِعْمَتِكَ وَحُسْنَ عِبَادَتِكَ، وَأَسْأَلُكَ قَلْبًا سَلِيمًا وَلِسَانًا صَادِقًا، وَأَسْأَلُكَ مِنْ خَيْرِ مَا تَعْلَمُ، وَأَعُوذُ بِكَ مِنْ شَرِّ مَا تَعْلَمُ، وَأَسْتَغْفِرُكَ لِمَا تَعْلَمُ، إِنَّكَ عَلَّامُ الغُيُوبِ.

ឱអល់ឡោះ! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវភាពរឹងមាំនៅក្នុងកិច្ចការ និងការប្តេជ្ញាចិត្តលើភាពត្រឹមត្រូវ។ ហើយខ្ញុំសុំពីទ្រង់នូវការដឹងគុណចំពោះនៀកម៉ាត់របស់ទ្រង់ និងការធ្វើអ៊ីហ្ពាទាត់(គោរពសក្ការៈ)ចំពោះទ្រង់ដ៏ល្អប្រសើរ។ ហើយខ្ញុំសុំពីទ្រង់នូវបេះដូងមួយដែលស្អាតស្អំ និងអណ្តាតមួយដែលពោលពាក្យពិត។ ហើយខ្ញុំសុំសូមពីទ្រង់នូវរាល់អំពើល្អដែលទ្រង់បានដឹង ហើយខ្ញុំសូមជ្រកកោននឹងទ្រង់ឱ្យរួចផុតពីអំពើអាក្រក់ទាំងឡាយដែលទ្រង់បានដឹង ហើយខ្ញុំសុំអភ័យទោសពីទ្រង់ចំពោះអ្វីដែលទ្រង់បានដឹង។ ពិតប្រាកដណាស់ ទ្រង់គឺជាអ្នកដែលដឹងបំផុតនូវរឿងរ៉ាវអាថ៌កំបាំងទាំងឡាយ។[1]

* اللَّهُمَّ رَبَّ النَّبِيِّ مُحَمَّدٍ عَلَيْهِ الصَّلَاةُ وَالسَّلَامُ، اغْفِرْ لِي ذَنْبِي، وَأَذْهِبْ غَيْظَ قَلْبِي وَأَجِرْنِي مِنْ مُضِلَّاتِ الفِتَنِ مَا أَحْيَيْتَنَا.

ឱអល់ឡោះ! ជាម្ចាស់នៃព្យាការីមូហាំម៉ាត់

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី ពី សាដាដ កូន អោស សូមអល់ឡោះទ្រង់ពេញចិត្តដល់គាត់៖៣៤០៧

សូមសុខសន្តិភាព និងពរជ័យកើតមានដល់គាត់ សូមទ្រង់មេត្តាអភ័យទោសដល់កំហុសរបស់ខ្ញុំបាទ និងសូមទ្រង់បំបាត់នូវកំហឹងចេញពីក្នុងបេះដូងរបស់ខ្ញុំបាទ ហើយសូមទ្រង់ការពារខ្ញុំបាទឱ្យរួចផុតពីការល្បួងទាំងឡាយដែលនាំឱ្យវង្វេង ដរាបណាទ្រង់នៅតែបន្តឱ្យពួកយើងមានជីវិតរស់នៅ[1]។

* اللَّهُمَّ رَبَّ السَّمَاوَاتِ وَرَبَّ الأَرْضِ وَرَبَّ العَرْشِ العَظِيمِ، رَبَّنَا وَرَبَّ كُلِّ شَيْءٍ، فَالِقَ الحَبِّ وَالنَّوَى، وَمُنْزِلَ التَّوْرَاةِ وَالإِنْجِيلِ وَالفُرْقَانِ، أَعُوذُ بِكَ مِنْ شَرِّ كُلِّ شَيْءٍ أَنْتَ آخِذٌ بِنَاصِيَتِهِ، اللَّهُمَّ أَنْتَ الأَوَّلُ فَلَيْسَ قَبْلَكَ شَيْءٌ، وَأَنْتَ الآخِرُ فَلَيْسَ بَعْدَكَ شَيْءٌ، وَأَنْتَ الظَّاهِرُ فَلَيْسَ فَوْقَكَ شَيْءٌ، وَأَنْتَ البَاطِنُ فَلَيْسَ دُونَكَ شَيْءٌ، اقْضِ عَنَّا الدَّيْنَ وَأَغْنِنَا مِنَ الفَقْرِ.

ឱអល់ឡោះជាម្ចាស់! ទ្រង់ម្ចាស់នៃមេឃ ម្ចាស់នៃផែនដី និងម្ចាស់នៃអារ៉ស្ហដ៏អស្ចារ្យ ម្ចាស់របស់យើង និងម្ចាស់នៃអ្វីៗគ្រប់យ៉ាង អ្នកដែលបំបែកគ្រាប់រុក្ខជាតិ ធ្វើឲ្យបណ្ដូលដុះចេញជារុក្ខជាតិ អ្នកដែលបញ្ចុះគម្ពីរតៅរ៉ត និងគម្ពីរអ៊ីញជីល និងគម្ពីរហ្វួរកន ខ្ញុំទ្រង់ការពារខ្ញុំពីអំពើអាក្រក់នៃអ្វីៗគ្រប់យ៉ាងដែល

---

1 រាយការណ៍ដោយ អ៊ីម៉ាំអះម៉ាត់ ពីហាទីស្ហរបស់អ៊ុំមូសាឡាម៉ះ សូមអល់ឡោះពេញចិត្តដល់អ្នកស្រី (៦/៣០១)

ទ្រង់គ្រប់គ្រងវា ឱអល់ឡោះជាម្ចាស់!
ទ្រង់គឺជាដើមដំបូង គ្មានអ្វីមុនទ្រង់
ហើយទ្រង់គឺជាចុងក្រោយ គ្មានអ្វីក្រោយទ្រង់
ហើយទ្រង់គឺជាអ្នកខាងលើ គ្មានអ្វីនៅលើទ្រង់
ហើយទ្រង់គឺជាអ្នកខាងក្នុង គ្មានអ្វីក្រៅពីទ្រង់
សូមលុបបំណុលយើង
និងធ្វើឱ្យយើងចាកផុតពីភាពក្រីក្រផង។[1]

* اللَّهُمَّ أَعْطِ نَفْسِي تَقْوَاهَا، وَزَكِّهَا أَنْتَ خَيْرُ مَنْ زَكَّاهَا، أَنْتَ وَلِيُّهَا وَمَوْلَاهَا، اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنَ العَجْزِ وَالكَسَلِ، وَأَعُوذُ بِكَ مِنَ الجُبْنِ وَالهَرَمِ وَالبُخْلِ، وَأَعُوذُ بِكَ مِنْ عَذَابِ القَبْرِ.

ឱអល់ឡោះជាម្ចាស់!
សូមប្រទានឱ្យខ្លួនខ្ញុំនូវការកោតខ្លាចដល់ទ្រង់
ហើយសូមសម្អាតវាផង
ព្រោះទ្រង់គឺជាអ្នកសម្អាតដ៏ល្អបំផុត
ហើយទ្រង់គឺជាម្ចាស់និងជាអ្នកថែរក្សាវា។
ឱអល់ឡោះជាម្ចាស់!
ខ្ញុំសូមទ្រង់មេត្តាការពារពីភាពទន់ខ្សោយ
និងភាពខ្ជិល ហើយសូមទ្រង់ការពារខ្ញុំពីភាពកំសាក
ភាពចាស់ជរា និងភាពកំណាញ់
ព្រមទាំងពីទណ្ឌកម្មនៃផ្នូរផង។[2]

* اللَّهُمَّ لَكَ أَسْلَمْتُ، وَبِكَ آمَنْتُ، وَعَلَيْكَ تَوَكَّلْتُ، وَإِلَيْكَ أَنَبْتُ، وَبِكَ خَاصَمْتُ،

---

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម ពីអាហ៊ូរ៉ាយរ៉ោះ៖២៧១៣

2 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម៖២៧២២

أَعُوذُ بِعِزَّتِكَ أَنْ تُضِلَّنِي، لَا إِلَهَ إِلَّا أَنْتَ، أَنْتَ الحَيُّ الَّذِي لَا يَمُوتُ، وَالجِنُّ وَالإِنْسُ يَمُوتُونَ.

អល់ឡោះជាម្ចាស់! ខ្ញុំបានប្រគល់ខ្លួនចំពោះទ្រង់ ហើយខ្ញុំបានជឿលើទ្រង់ ហើយខ្ញុំបានប្រគល់ការទុកចិត្តចំពោះទ្រង់ ហើយខ្ញុំបានវិលត្រឡប់ទៅរកទ្រង់ ហើយដោយសារទ្រង់ ខ្ញុំបានតតាំង (ប្រឆាំងនឹងសត្រូវ)។ ខ្ញុំសូមជ្រកកោននឹងភាពខ្លាំងពូកែរបស់ទ្រង់ កុំឲ្យទ្រង់ធ្វើឲ្យខ្ញុំវង្វេង។ គ្មានព្រះជាម្ចាស់ណាដែលត្រូវគោរពសក្ការៈពិតប្រាកដ ក្រៅពីទ្រង់ឡើយ។ ទ្រង់គឺជាអ្នកដែលរស់រានជានិច្ច ដែលមិនស្លាប់ ហើយជិន និងមនុស្សលោកគឺត្រូវស្លាប់[1]។

* اللَّهُمَّ إِنِّي أَعُوذُ بِكَ مِنْ عِلْمٍ لَا يَنْفَعُ، وَمِنْ قَلْبٍ لَا يَخْشَعُ، وَمِنْ نَفْسٍ لَا تَشْبَعُ، وَمِنْ دَعْوَةٍ لَا يُسْتَجَابُ لَهَا.

ឱអល់ឡោះជាម្ចាស់! សូមទ្រង់បញ្ចៀសខ្ញុំពីចំណេះដឹងដែលគ្មានប្រយោជន៍ ពីចិត្តដែលមិនកោតខ្លាច ពីខ្លួនប្រាណដែលមិនចេះគ្រប់គ្រាន់

1 រាយការណ៍ដោយ មូស្លីម៖២៧១៧

និងពីការទូអាដែលមិនត្រូវបានឆ្លើយតបផង[1]។

* اللَّهُمَّ جَنِّبْنِي مُنْكَرَاتِ الأَخْلَاقِ وَالأَعْمَالِ وَالأَهْوَاءِ وَالأَدْوَاءِ.

ឱអល់ឡោះ! សូមទ្រង់មេត្តាឱ្យខ្ញុំជៀសឆ្ងាយផុតពីរាល់សីលធម៌ និងមារយាទដ៏អាក្រក់ទាំងឡាយ និងរាល់សកម្មភាពទាំងឡាយដែលអាក្រក់ និងរាល់តណ្ហាដែលនាំឱ្យវង្វេង និងរាល់ជំងឺដង្កាត់ទាំងឡាយ ទាំងជំងឺផ្លូវកាយ និងជំងឺផ្លូវចិត្ត[2]។

* اللَّهُمَّ أَلْهِمْنِي رُشْدِي، وَأَعِذْنِي مِنْ شَرِّ نَفْسِي.

ឱអល់ឡោះ! សូមទ្រង់មេត្តាបំផុសនូវមាគ៌ាដ៏ត្រឹមត្រូវដល់ខ្ញុំ ហើយសូមការពារខ្ញុំឱ្យរួចផុតពីភាពអាក្រក់នៃខ្លួនខ្ញុំផង[3]។

* اللَّهُمَّ اكْفِنِي بِحَلَالِكَ عَنْ حَرَامِكَ، وَأَغْنِنِي بِفَضْلِكَ عَمَّنْ سِوَاكَ.

ឱអល់ឡោះ! សូមទ្រង់មេត្តាប្រទានភាពគ្រប់គ្រាន់ដល់ខ្ញុំបាននូវអ្វីដែលជាការអនុញ្ញាត(ហឡាល)របស់ទ្រង់

---

1 នេះគឺជាផ្នែកមួយនៃហាទីស្ហរបស់ ហ្សេត កូន អើរកម (សូមអល់ឡោះពេញចិត្តចំពោះគាត់) ដែលបានបញ្ជាក់ប្រភពរួចហើយៈ២៧២២។

2 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ីៈ៣៥៩១

3 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី ពីលោក អ៊ិមរ៉ន កូន ហ៊ូសេន សូមអល់ឡោះពេញចិត្តដល់គាត់ ៖៣៤៨៣

ជំនួសឱ្យអ្វីដែលជាការហាមឃាត់(ហារ៉ម)របស់ទ្រង់។ ហើយសូមទ្រង់មេត្តាធ្វើឱ្យខ្ញុំបាទមានបាន តាមរយៈការប្រោសប្រទានរបស់ទ្រង់ ដោយមិនពឹងពាក់ទៅលើអ្នកណាម្នាក់ក្រៅពីទ្រង់ឡើយ[1]។

* اللَّهُمَّ إِنِّي أَسْأَلُكَ الهُدَى وَالتُّقَى وَالعَفَافَ وَالغِنَى.

ឱអល់ឡោះ! ពិតប្រាកដណាស់ ខ្ញុំសូមពីទ្រង់នូវការចង្អុលបង្ហាញ ភាពកោតខ្លាច ភាពស្អាតស្អំ និងភាពមានបាន[2]។

* اللَّهُمَّ إِنِّي أَسْأَلُكَ الهُدَى وَالسَّدَادَ.

ឱអល់ឡោះ ពិតប្រាកដណាស់ខ្ញុំបាទសូមពីទ្រង់នូវការចង្អុលបង្ហាញ និងភាពត្រឹមត្រូវ[3]។

* اللَّهُمَّ إِنِّي أَسْأَلُكَ مِنَ الخَيْرِ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، وَأَعُوذُ بِكَ مِنَ الشَّرِّ كُلِّهِ، عَاجِلِهِ وَآجِلِهِ، مَا عَلِمْتُ مِنْهُ وَمَا لَمْ أَعْلَمْ، وَأَسْأَلُكَ مِنْ خَيْرِ مَا سَأَلَكَ مِنْهُ عَبْدُكَ وَنَبِيُّكَ مُحَمَّدٌ ﷺ، وَأَعُوذُ بِكَ مِنْ شَرِّ مَا اسْتَعَاذَ مِنْهُ عَبْدُكَ وَنَبِيُّكَ مُحَمَّدٌ ﷺ، اللَّهُمَّ إِنِّي أَسْأَلُكَ الجَنَّةَ وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَعُوذُ بِكَ مِنَ النَّارِ وَمَا قَرَّبَ إِلَيْهَا مِنْ قَوْلٍ أَوْ عَمَلٍ، وَأَسْأَلُكَ أَنْ تَجْعَلَ كُلَّ قَضَاءٍ قَضَيْتَهُ لِي خَيْرًا.

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី៖៣៥៦៣

2 រាយការណ៍ដោយ មូស្លីម៖២៧២១

3 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម៖២៧២៥

(ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវរាល់ប្រការល្អទាំងអស់ ទាំងបច្ចុប្បន្ន ទាំងអនាគត ទាំងអ្វីដែលខ្ញុំដឹង ទាំងអ្វីដែលខ្ញុំមិនដឹង ហើយខ្ញុំសុំពីទ្រង់បញ្ចៀសនូវរាល់ប្រការអាក្រក់ទាំងអស់ ទាំងបច្ចុប្បន្ន ទាំងអនាគត ទាំងអ្វីដែលខ្ញុំដឹង ទាំងអ្វីដែលខ្ញុំមិនដឹង។ ហើយខ្ញុំសុំពីទ្រង់នូវប្រការល្អដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់ មូហាំម៉ាត់ ﷺ បានសុំពីទ្រង់ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីប្រការអាក្រក់ដូចអ្វីដែលខ្ញុំបម្រើរបស់ទ្រង់ និងណាពីរបស់ទ្រង់ មូហាំម៉ាត់ ﷺ បានសុំការបញ្ចៀសអំពីវា។ ឱអល់ឡោះជាម្ចាស់! ពិតប្រាកដណាស់ ខ្ញុំសុំពីទ្រង់នូវឋានសួគ៌ និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្តី និងទង្វើ ហើយខ្ញុំសុំពីទ្រង់បញ្ចៀសពីឋាននរក និងអ្វីដែលនាំឱ្យខ្ញុំខិតជិតវា ទាំងពាក្យសម្តី និងទង្វើ។ ហើយខ្ញុំសុំពីទ្រង់ សូមទ្រង់មេត្តាធ្វើឲ្យរាល់ការកំណត់ទាំងឡាយដែលទ្រង់បានកំណត់សម្រាប់ខ្ញុំនោះ គឺជាប្រការល្អផង)។[1]

* لَا إِلَهَ إِلَّا اللَّهُ وَحْدَهُ لَا شَرِيكَ لَهُ، لَهُ المُلْكُ وَلَهُ الحَمْدُ، يُحْيِي وَيُمِيتُ بِيَدِهِ الخَيْرُ وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ، سُبْحَانَ اللَّهِ، وَالحَمْدُ لِلَّهِ، وَلَا إِلَهَ إِلَّا اللَّهُ، وَاللَّهُ أَكْبَرُ، وَلَا حَوْلَ وَلَا قُوَّةَ إِلَّا بِاللَّهِ العَلِيِّ العَظِيمِ.

1 រាយការណ៍ដោយ អ៊ិបនូម៉ាជះ៖៣៨៤៦

គ្មានព្រះជាម្ចាស់ណាផ្សេងក្រៅពីអល់ឡោះឡើយ ទ្រង់តែមួយអង្គគត់ គ្មានដៃគូសម្រាប់ទ្រង់ឡើយ។ ទ្រង់ជាម្ចាស់គ្រប់គ្រងលើអ្វីៗទាំងអស់ ហើយរាល់ការសរសើរគឺសម្រាប់ទ្រង់។ ទ្រង់ប្រទានជីវិត និងដកយកជីវិត នៅក្នុងដៃរបស់ទ្រង់គឺរាល់អំពើល្អ ហើយទ្រង់មានអានុភាពលើអ្វីៗទាំងអស់។ អល់ឡោះមហាស្អាតស្អំ ហើយរាល់ការសរសើរគឺសម្រាប់អល់ឡោះ ហើយគ្មានព្រះជាម្ចាស់ណាផ្សេងក្រៅពីអល់ឡោះឡើយ ហើយអល់ឡោះមហាធំធេង។ ហើយគ្មានអំណាច និងកម្លាំងអ្វីឡើយ លើកលែងតែដោយមានការអនុញ្ញាតពីអល់ឡោះ ដែលទ្រង់មហាខ្ពង់ខ្ពស់ មហាអស្ចារ្យ។[1]

* اللَّهُمَّ صَلِّ عَلَى مُحَمَّدٍ، وَعَلَى آلِ مُحَمَّدٍ، كَمَا صَلَّيْتَ عَلَى إِبْرَاهِيمَ، وَعَلَى آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ، وَبَارِكْ عَلَى مُحَمَّدٍ، وَعَلَى آلِ مُحَمَّدٍ، كَمَا بَارَكْتَ عَلَى إِبْرَاهِيمَ، وَعَلَى آلِ إِبْرَاهِيمَ، إِنَّكَ حَمِيدٌ مَجِيدٌ.

ឱអល់ឡោះជាម្ចាស់! សូមទ្រង់សឡាវ៉ាត(លើកសរសើរ)ទៅចំពោះមូហាំម៉ាត់ និងក្រុមគ្រួសារមូហាំម៉ាត់ ដូចដែលទ្រង់បានសឡាវ៉ាតទៅចំពោះអ៊ីព្រហ៊ីម និងក្រុមគ្រួសាររបស់អ៊ីព្រហ៊ីមផង។ ពិតណាស់ ទ្រង់គឺជាអ្នកដែលត្រូវគេកោតសរសើរ

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរី៖១១៥៤

និងលើកតម្កើង។
ហើយសូមទ្រង់ប្រទានពរជ័យដល់មូហាំម៉ាត់ និងក្រុមគ្រួសាររបស់មូហាំម៉ាត់ ដូចដែលទ្រង់បានប្រទានពរជ័យដល់អ៊ីព្រហ៊ីម និងក្រុមគ្រួសាររបស់អ៊ីព្រហ៊ីមផង។ ពិតណាស់ ទ្រង់គឺជាអ្នកដែលត្រូវគេកោតសរសើរ និងលើកតម្កើង។[1]

* ﴿...رَبَّنَا آتِنَا فِي الدُّنْيَا حَسَنَةً وَفِي الْآخِرَةِ حَسَنَةً وَقِنَا عَذَابَ النَّارِ ﴿٢٠١﴾﴾

ឱព្រះជាម្ចាស់របស់យើងខ្ញុំ! សូមទ្រង់មេត្តាប្រទានដល់យើងខ្ញុំនូវប្រការល្អក្នុងលោកិយ និងប្រការល្អនៅថ្ងៃបរលោក ព្រមទាំងការពារយើងខ្ញុំពីទណ្ឌកម្មនៃភ្លើងនរកផង។

[គម្ពីរគួរអាន ២:២០១]

ហើយស៊ូណាត់នៅកន្លែងដ៏មហិមានេះ ឲ្យគេធ្វើឡើងវិញនូវការហ្ស៊ីកៀរ និងការទូអាដែលបានរៀបរាប់រួចមកហើយ ព្រមទាំងអ្វីដែលមានអត្ថន័យស្រដៀងគ្នា ដូចជាការហ្ស៊ីកៀរ ការសុំទូអា និងការសឡាវ៉ាតទៅលើព្យាការី ﷺ។ ហើយគេត្រូវសុំទូអាប្រកបដោយការទទូចអង្វរករ ហើយសុំពីអល់ឡោះជាម្ចាស់របស់គេនូវភាពល្អប្រសើរ ទាំងក្នុងលោកិយនិងបរលោក។ ហើយព្យាការី ﷺ

---

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ៣៣៧០

នៅពេលដែលលោកសុំទូអា គឺលោកតែងតែធ្វើទូអានោះឡើងវិញបីដង។ ដូច្នេះ គេគប្បីធ្វើត្រាប់តាមលោក ﷺ ក្នុងរឿងនេះ។

នៅក្នុងស្ថានការណ៍នេះ ជនមូស្លីមត្រូវបន្ទាបខ្លួនចុះចាញ់ និងទន់ជ្រាយនៅចំពោះម្ចាស់របស់គេ ដោយសង្ឃឹមនូវក្តីមេត្តាករុណា និងការអភ័យទោសរបស់ទ្រង់ ហើយនិងភ័យខ្លាចនូវទណ្ឌកម្ម និងការខឹងក្រោធរបស់ទ្រង់។ គេត្រូវត្រួតពិនិត្យខ្លួនឯង ហើយត្រូវកែប្រែខ្លួនដោយស្មោះត្រង់ជាថ្មី។ ព្រោះថានេះគឺជាថ្ងៃដ៏មហិមា និងជាការប្រមូលផ្តុំដ៏ធំមួយ ដែលនៅក្នុងថ្ងៃនោះ អល់ឡោះទ្រង់ប្រទានដោយសប្បុរសចំពោះខ្ញុំបម្រើទាំងឡាយរបស់ទ្រង់ ហើយទ្រង់មានមោទនភាពចំពោះពួកគេនៅចំពោះមុខម៉ាឡាអ៊ីកាត់របស់ទ្រង់ ព្រមទាំងរំដោះពួកគេឲ្យរួចផុតពីភ្លើងនរកយ៉ាងច្រើនទៀតផង។ ហើយគេមិនដែលឃើញស្ហៃតននៅថ្ងៃណាមួយដែលវានៅក្នុងសភាពបរាជ័យ តូចតាច និងទាបថោកបំផុត ជាងថ្ងៃអារ៉ហ្វះឡើយ លើកលែងតែអ្វីដែលគេបានឃើញវានៅថ្ងៃបាក់ឌើរ។ នោះគឺដោយសារតែវាបានឃើញនូវភាពសប្បុរសរបស់អល់ឡោះចំពោះខ្ញុំបម្រើរបស់ទ្រង់

និងការធ្វើល្អរបស់ទ្រង់ចំពោះពួកគេ ហើយនិងការរំដោះឲ្យរួចផុតពីភ្លើងនរក និងការអភ័យទោសដ៏ច្រើនលើសលប់របស់ទ្រង់។

ហើយនៅក្នុង ហាទីស្ហ សហេស مسلم، អំពី អាអ៊ីស្ហះ رضي الله عنها، ពិតណាស់ ព្យាការី ﷺ លោកបានមានប្រសាសន៍ថាៈ

«مَا مِنْ يَوْمٍ أَكْثَرَ مِنْ أَنْ يُعْتِقَ اللَّهُ فِيهِ عَبْدًا مِنَ النَّارِ مِنْ يَوْمِ عَرَفَةَ، وَإِنَّهُ لَيَدْنُو ثُمَّ يُبَاهِي بِهِمُ الْمَلَائِكَةَ، فَيَقُولُ: مَا أَرَادَ هَؤُلَاءِ؟».

“គ្មានថ្ងៃណាមួយដែលអល់ឡោះទ្រង់រំដោះទាសករ (មនុស្ស) ឱ្យរួចផុតពីភ្លើងនរក ច្រើនជាងថ្ងៃអារ៉ាហ្វះនោះឡើយ ហើយពិតប្រាកដណាស់ ទ្រង់នឹងស្ថិតនៅកៀកដោយកិត្តិយសរបស់ទ្រង់ បន្ទាប់មកទ្រង់មានមោទនភាពចំពោះពួកគេ (អ្នកសាងបុណ្យ) នៅចំពោះមុខពួកម៉ាឡាអ៊ីកាត់ រួចទ្រង់មានបន្ទូលសួរថាៈ "តើពួកទាំងនេះ (អ្នកសាងបុណ្យ) ចង់បានអ្វី (ទើបពួកគេមកប្រមូលផ្តុំគ្នាយ៉ាងដូច្នេះ)?"[1]។

ហេតុនេះ សមគួរហើយសម្រាប់បណ្តាអ្នកមុស្លីមក្នុងការបង្ហាញនូវទង្វើល្អរបស់ខ្លួនទៅកាន់អល់ឡោះ ហើយធ្វើឲ្យសត្រូវរបស់ពួកគេគឺស្ហៃតនទទួលនូវភាព

1 រាយការណ៍ដោយ អ៊ីម៉ាំមូស្លីមៈ១៣៤៨

អាម៉ាស់ និងកើតទុក្ខ តាមរយៈការរំលឹកដល់អល់ឡោះ និងការបួងសួងឲ្យបានច្រើន ព្រមទាំងប្រកាន់ខ្ជាប់នូវការសារភាពកំហុស និងការសុំអភ័យទោសពីគ្រប់បាបកម្ម និងកំហុសឆ្គងទាំងអស់។ ហើយបណ្ដាហាជ្ជី(អ្នកធ្វើហាជ្ជី)នៅតែបន្ដស្ថិតនៅក្នុងទីតាំងនេះ ដោយរវល់ជាមួយនឹងការរំលឹកដល់អល់ឡោះ ការបួងសួង និងការបន្ទាបខ្លួនអង្វរករ រហូតដល់ពេលថ្ងៃលិច។ នៅពេលដែលថ្ងៃបានលិចហើយ ពួកគេត្រូវធ្វើដំណើរទៅកាន់មូហ្សដាលីហ្វះដោយភាពស្ងប់ស្ងាត់និងថ្លៃថ្នូរ ព្រមទាំងបន្លឺសំឡេងតាល់ពីយ៉ះឲ្យបានច្រើន ហើយត្រូវពន្លឿនដំណើរនៅកន្លែងដែលធំទូលាយ ដើម្បីអនុវត្តតាមទង្វើរបស់ព្យាការី ﷺ។ ហើយវាមិនត្រូវបានអនុញ្ញាតឲ្យចាកចេញមុនពេលថ្ងៃលិចឡើយ ពីព្រោះព្យាការី ﷺ បានឈររហូតទាល់តែព្រះអាទិត្យបានលិច ហើយគាត់បានមានប្រសាសន៍ថា៖

«خُذُوا عَنِّي مَنَاسِكَكُمْ».

“ចូរអ្នករាល់គ្នា យកគំរូ ពីខ្ញុំ”នូវរាល់វិន័យ និងកិច្ចការសាងបុណ្យ (ហាជ្ជី និងអ៊ុំរ៉ោះ)

របស់អ្នករាល់គ្នា”។[1]

ហើយនៅពេលទៅដល់មុហ្សទើលីហ្វះ គេត្រូវសឡាតម៉ាហ្គ្រិបបីរ៉ក្អាត់ និងអ៊ីស្ហាពីររ៉ក្អាត់ ដោយផ្តុំសឡាត(ជម៉ក់) ជាមួយនឹងអ៉ាហ្សានមួយ និងអ៊ីក៏ម៉ាត់ពីរដង ភ្លាមៗនៅពេលទៅដល់ទីនោះ ដើម្បីអនុវត្តតាមព្យាការីមូហាំម៉ាត់ ﷺ នោះបីជាគេទៅដល់មុហ្សទើលីហ្វះនៅក្នុងម៉ោងសឡាតម៉ាហ្គ្រិប ឬក្រោយពេលចូលម៉ោងសឡាតអ៊ីសាក៏ដោយ។

រីឯទង្វើរបស់មនុស្សទូទៅមួយចំនួនដែលបានរើសគ្រាប់ក្រួសសម្រាប់គប់គោលតាំងពីពេលទៅដល់មូហ្សទើលីហ្វះមុនពេលធ្វើសឡាត និងការជឿរបស់ពួកគេជាច្រើនថាទង្វើបែបនេះគឺជាកិច្ចការដែលត្រឹមត្រូវតាមច្បាប់សាសនា គឺវាជាការខុសឆ្គងមួយដែលគ្មានមូលដ្ឋានគ្រឹះឡើយ។ ដ្បិតព្យាការី ﷺ មិនបានបញ្ជាឱ្យរើសគ្រាប់ក្រួសឲ្យលោកឡើយ លុះត្រាតែលោកបានចាកចេញពីអាល់មិស្អើរ(នៅមូហ្សទើលីហ្វះ)ទៅកាន់មីណាសិន។ ហើយការរើសគ្រាប់ក្រួសពីទីកន្លែងណាក៏ដោយគឺវាគ្រប់គ្រាន់ហើយ ដោយមិនបានតម្រូវជាដាច់ខាតឱ្យរើសចេញពីមូហ្សទើលីហ្វះនោះទេ

---

1 បានបញ្ជាក់ប្រភពរួចហើយ។

ផ្ទុយទៅវិញគេអាចរើសពីមីណាបានដែរ។
ហើយតាមស៊ុណ្ណះ គឺត្រូវរើសប្រាំពីរគ្រាប់នាថ្ងៃនេះ ដើម្បីយកទៅគប់គោលអាក៏ហ្គះ តាមការអនុវត្តរបស់ព្យាការី ﷺ។ រីឯនៅថ្ងៃទាំងបីបន្ទាប់ គឺត្រូវរើសពីមីណានូវគ្រាប់ក្រួសចំនួនម្ភៃមួយគ្រាប់ជារៀងរាល់ថ្ងៃ ដើម្បីយកទៅគប់គោលទាំងបី។

មិនគប្បីលាងគ្រាប់ក្រួសឡើយ ផ្ទុយទៅវិញ គេត្រូវយកវាទៅគប់ដោយមិនបាច់លាងសម្អាតវាឡើយ។ ពីព្រោះទង្វើបែបនោះ (ការលាងគ្រាប់គ្រួស) មិនមានការរៀបរាប់តៗគ្នាពីលោកព្យាការី ﷺ និងបណ្ដាសហាហ្ពាត់របស់លោកឡើយ។ ហើយក៏មិនត្រូវយកគ្រាប់គ្រួសណាដែលគេធ្លាប់យកទៅគប់រួចហើយ (គ្រាប់គ្រួសចាស់ដែលរើសចេញពីកន្លែងគប់) យកមកគប់ម្ដងទៀតដែរ។

ហើយអ្នកធ្វើហាជ្ជីត្រូវស្នាក់នៅ (សម្រាក) ក្នុងយប់នោះ (យប់ថ្ងៃទី ១០ ហ្ស៊ុលហិជ្ជះ) នៅតំបន់មុហ្សទើលីហ្វះ។ ប៉ុន្តែវាត្រូវបានអនុញ្ញាតសម្រាប់អ្នកដែលទន់ខ្សោយ ដូចជាស្ត្រី ក្មេងៗ និងអ្នកដែលមានសភាពស្រដៀងគ្នា ក្នុងការចាកចេញឆ្ពោះទៅកាន់តំបន់មីណា នៅចុងបញ្ចប់នៃយប់នោះ (ក្រោយពាក់កណ្ដាលអធ្រាត្រ)។

ចំណែកឯបណ្ដាអ្នកធ្វើហាជ្ជីដទៃទៀត គឺតម្រូវឲ្យពួកគេស្នាក់នៅទីនោះរហូតទាល់តែបានប្រតិបត្តិសឡាតហ្វាជើរ។ បន្ទាប់មកត្រូវឈរនៅត្រង់ម៉ាស្អារីលហារ៉ម ដោយតម្រង់ទៅកាន់គិបឡាត់ ហើយត្រូវធ្វើការហ្ស៊ីកៀររំឭកដល់អល់ឡោះ តាក់អាឡា និងទូអាពីរចំពោះទ្រង់ និងសុំទូអាឲ្យបានច្រើន រហូតដល់ពេលព្រឹកព្រាងច្បាស់។ យោងតាមហាទីស្ហរបស់អ្នកស្រី អៃអ៊ីស្ហះ និងអ្នកស្រី អ៊ុម្មូ សាឡាម៉ះ និងអ្នកផ្សេងទៀតក្រៅពីពួកគាត់។ ហើយស៊ូណាត់ឱ្យលើកដៃទាំងសងខាងនៅទីនេះ (មុហ្សទើលីហ្វះ) ក្នុងកំឡុងពេលបួងសួង។ ហើយមិនថាពួកគេឈប់សម្រាកនៅត្រង់កន្លែងណានៃតំបន់មុហ្សទើលីហ្វះនោះទេ ក៏វាត្រូវបានចាត់ទុកថាត្រឹមត្រូវ (គ្រប់គ្រាន់) សម្រាប់ពួកគេដែរ។ ហើយវាមិនមែនជាកាតព្វកិច្ច (វ៉ាជិប) លើពួកគេក្នុងការទៅឱ្យកៀកនឹងភ្នំ "អាល់ម៉ាស្អារអាល់ ហារ៉ាំ" ឬឡើងលើភ្នំនោះឡើយ។ យោងតាមប្រសាសន៍របស់ព្យាការី ﷺ

«وَقَفْتُ هَاهُنَا - يَعْنِي عَلَى المَشْعَرِ الحَرَامِ - وَجَمْعٌ كُلُّهَا مَوْقِفٌ».

«ខ្ញុំបានឈរ (បួងសួង) នៅត្រង់ទីនេះ គឺនៅលើភ្នំអាល់ម៉ាស្អារអាល់ ហារ៉ាំ" ក្នុងតំបន់មុហ្សដាលីហ្វះ ប៉ុន្តែតំបន់ "ជាំអ៊ុ" (ឈ្មោះម្យ៉ាងទៀតរបស់មុហ្សទើលីហ្វះ) ទាំងមូល

គឺជាកន្លែងសម្រាប់ឈរ (ស្នាក់នៅ) ដូចគ្នា។»[1] រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម នៅក្នុងសៀវភៅសហេសរបស់គាត់៖ ហើយ ជាំអ៊ុ គឺជាមូហ្សទើលីហ្វះ។

ដូច្នេះ នៅពេលដែលមេឃចាប់ផ្តើមភ្លឺខ្លាំង (ជិតព្រះអាទិត្យរះ) ពួកគេត្រូវចាកចេញឆ្ពោះទៅកាន់តំបន់មីណា មុនពេលព្រះអាទិត្យរះ។ ហើយពួកគេត្រូវបង្កើនការសូត្រ "តាល់ប៊ីយ៉ះ" ក្នុងកំឡុងពេលធ្វើដំណើររបស់ពួកគេ។ ហើយនៅពេលដែលពួកគេធ្វើដំណើរទៅដល់វាល "មូហាស់សៀរ" ស៊ូណាត់ ឱ្យបង្កើនល្បឿននៃការដើរ (ឬបើកបរ) បន្តិច។

ដូច្នេះ នៅពេលដែលអ្នកធ្វើហាជ្ជីទៅដល់តំបន់មីណា ពួកគេត្រូវបញ្ឈប់ការសូត្រ "តាល់ពីយ៉ះ" នៅត្រង់កន្លែងគប់គោល អាក៏ហ្ពះ បន្ទាប់មក ពួកគេត្រូវគប់វាភ្លាមៗនៅពេលទៅដល់ នូវគ្រាប់គ្រួសចំនួន ៧ គ្រាប់ ដោយគប់ម្តងមួយគ្រាប់ៗជាបន្តបន្ទាប់គ្នា។ គេត្រូវលើកដៃឡើងនៅពេលគប់គ្រាប់គ្រួសនីមួយៗ ហើយសូត្រពាក្យ "អល់ឡោះហ៊ូអឹកពើរ"។ ហើយស៊ុណាត់ឱ្យគេគប់វាពីផ្នែកកណ្តាលនៃជ្រលងភ្នំ

---

1 រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម ពីហាទីស្ហរបស់លោក ជាពៀរ (សូមអល់ឡោះពេញចិត្តដល់គាត់) លេខ ១២១៨

ដោយទុកឱ្យកាក់ពះស្ថិតនៅខាងឆ្វេងដៃ
និងតំបន់មិណាស្ថិតនៅខាងស្តាំដៃរបស់គេ។
នេះគឺជាការអនុវត្តតាមទង្វើរបស់លោកព្យាការី ﷺ
ប៉ុន្តែប្រសិនបើគេគប់វាពីទិសដៅផ្សេងៗទៀត
ក៏វាត្រូវបានចាត់ទុកថាត្រឹមត្រូវដែរ
ឱ្យតែគ្រាប់គ្រួសនោះធ្លាក់ចូលទៅក្នុងអាង (រង្វង់)
សម្រាប់គប់។
ហើយវាមិនមែនជាលក្ខខណ្ឌដែលគ្រាប់គ្រួសត្រូវតែស្ថិតនៅក្នុងអាងនោះរហូតឡើយ
អ្វីដែលជាលក្ខខណ្ឌសំខាន់
គឺឱ្យតែវាបានធ្លាក់ចូលទៅក្នុងអាងនោះ
(ទោះវាខ្ទាតចេញមកវិញក៏ដោយ)។ ដូច្នេះ
ប្រសិនបើគ្រាប់គ្រួសធ្លាក់ចូលក្នុងអាងគប់ហើយ
បន្ទាប់មកវាខ្ទាតចេញមកក្រៅវិញ
គឺវាត្រូវបានចាត់ទុកថាត្រឹមត្រូវ (គ្រប់គ្រាន់)
យោងតាមសម្តីច្បាស់លាស់របស់អ្នកប្រាជ្ញឥស្លាម។
ហើយក្នុងចំណោមអ្នកប្រាជ្ញដែលបានបញ្ជាក់ច្បាស់ពីចំណុចនេះ គឺ អ៊ីមុាំ អាន់នូវ៉ាវី
(សូមអល់ឡោះមេត្តាដល់រូបគាត់) នៅក្នុងសៀវភៅ
"សារ៉ស អាល់-មូហាស់ហ្សាប"។
ហើយទំហំនៃគ្រាប់គ្រួសសម្រាប់គប់នោះ
គឺត្រូវមានទំហំប៉ុនគ្រាប់ដីឥដ្ឋតូចៗ
ពោលគឺវាធំជាងគ្រាប់សណ្តែកបាយបន្តិចប៉ុណ្ណោះ។
បន្ទាប់មក ក្រោយពីការគប់ដុំគោលហើយ
គឺត្រូវសម្លេះសត្វជំនូនរបស់គេ។

ហើយស៊ូណាត់ឲ្យគេសូត្រនៅពេលដែលគេសម្លេះវាថា:

"بِسْمِ اللهِ وَاللهُ أَكْبَرُ، اللَّهُمَّ هَذَا مِنْكَ وَلَكَ"

(ក្នុងនាមអល់ឡោះ ហើយអល់ឡោះមហាធំធេង ឱអល់ឡោះជាម្ចាស់! សត្វជំនូននេះគឺមកពីទ្រង់ ហើយគឺសម្រាប់ទ្រង់)

ហើយគេត្រូវដាក់វាឲ្យបែរមុខទៅកាន់ទិសគិបឡាត់។ ហើយស៊ូណាត់ គឺត្រូវសម្លេះសត្វអូដ្ឋក្នុងសភាពដែលវាឈរដោយចងជើងខាងឆ្វេងរបស់វា ហើយសម្លេះសត្វគោ និងសត្វពពែដោយឲ្យវាដេកផ្អៀងទៅខាងឆ្វេង។ ហើយប្រសិនបើគេសម្លេះដោយមិនបែរមុខទៅកាន់ទិសគិបឡាត់ គឺគេបានបោះបង់ចោលនូវស៊ុណ្ណះ ក៏ប៉ុន្តែការសម្លេះរបស់គេនោះគឺអាចយកជាការបាន ពីព្រោះថា ការដាក់សត្វឲ្យបែរមុខទៅកាន់ទិសគិបឡាត់នៅពេលសម្លេះ គឺជាស៊ូណាត់ ហើយមិនមែនជាវ៉ាជិប(កាតព្វកិច្ច)នោះឡើយ។ ហើយស៊ូណាត់ឲ្យគេបរិភោគសាច់សត្វជំនូនរបស់គេខ្លះ ជូនជាអំណោយខ្លះ និងបរិច្ចាគខ្លះ ដូចដែលទ្រង់(អល់ឡោះ)បានមានបន្ទូលថា:

﴿...فَكُلُوا مِنْهَا وَأَطْعِمُوا الْبَائِسَ الْفَقِيرَ﴾

ដូច្នេះ ចូរពួកអ្នកបរិភោគអំពីវា(សត្វដែលបានសំឡេះ)ទាំងនេះ ហើយចូរបរិច្ចាគទៅដល់អ្នកដែលក្រលំបាក។

[គម្ពីរគួរអាន ២២:២៨], ហើយពេលវេលានៃការសំឡេះគឺបន្តរហូតដល់ថ្ងៃលិច នៃថ្ងៃទីបីនៃថ្ងៃតាស្រ៊ិក យោងតាមទស្សនៈដែលត្រឹមត្រូវជាងគេរបស់អ្នកប្រាជ្ញឥស្លាម។ ដូចនេះរយៈពេលនៃការសំឡេះគឺថ្ងៃណះរ៍ និងបីថ្ងៃបន្ទាប់ពីនោះ។

បន្ទាប់ពីបានសំឡេះសត្វជំនូនរួច គេត្រូវកោរ ឬកាត់សក់របស់គេ ដោយការកោរគឺប្រសើរជាង ពីព្រោះព្យាការី ﷺ លោកបានបួងសួងសុំការប្រោសប្រណី និងការអភ័យទោសឱ្យអ្នកដែលកោរសក់ (ចំនួនបីដង) និងអ្នកដែលកាត់សក់តែមួយដង។ ហើយការកាត់សក់ត្រឹមតែមួយផ្នែកនៃក្បាលគឺមិនគ្រប់គ្រាន់ឡើយ តែត្រូវតែកាត់ឱ្យសព្វពេញក្បាលដូចទៅនឹងការកោរដែរ។ ចំណែកឯស្ត្រីវិញ គឺត្រូវកាត់ចុងសក់ពីគ្រប់ផ្នែករបស់នាងប្រវែងមួយថ្នាំងដៃ ឬតិចជាងនេះ។

បន្ទាប់ពីគប់គោលអាក៏ហ្ពះ និងកោរឬកាត់សក់រួច រាល់បម្រាមទាំងអស់នៅក្នុងការអៀហរ៉ម ត្រូវបានអនុញ្ញាតឡើងវិញសម្រាប់គេ លើកលែងតែស្ត្រី។ ហើយការតាហាល់លុលនេះត្រូវបានគេហៅថាៈ តាហាល់លុលលើកទីមួយ។ ហើយជាស៊ុណ្ណះសម្រាប់គេ

បន្ទាប់ពីការគាហាល់លុលនេះ គឺត្រូវលាបទឹកអប់ និងធ្វើដំណើរទៅកាន់ម៉ាក្កះ ដើម្បីតវ៉ាហ្វអ៊ីហ្វាហ្គោះ យោងតាមហាទីស្តរបស់លោកស្រី អាអ៊ីស្សះ ដែលបានមានប្រសាសន៍ថា៖

«كُنْتُ أُطَيِّبُ رَسُولَ اللَّهِ ﷺ لِإِحْرَامِهِ قَبْلَ أَنْ يُحْرِمَ، وَلِحِلِّهِ قَبْلَ أَنْ يَطُوفَ بِالبَيْتِ».

«ខ្ញុំធ្លាប់បានលាបទឹកអប់ឱ្យអ្នកនាំសាររបស់អល់ឡោះ ﷺ សម្រាប់អៀហរ៉ាមរបស់លោក មុនពេលដែលលោកគ្រងអៀហរ៉ាម, និងសម្រាប់ការបញ្ចប់អៀហរ៉ាមរបស់លោក មុនពេលដែលលោកធ្វើតាវ៉ាហ្វអ៊ីហ្វាហ្គោះនៅកាក់ហ្ពះ)»[1] រាយការណ៍ដោយ អ៊ីម៉ាំពូខរី និងមូស្លីម។

តវ៉ាហ្វនេះត្រូវបានគេហៅថា៖ តវ៉ាហ្វអ៊ីហ្វាហ្គោះ និង តវ៉ាហ្វហ្ស៊ីយ៉ារ៉ោះ ហើយវាគឺជាសសរស្តម្ភ(គ្រឹះ)មួយនៃហាជ្ជី ដែលហាជ្ជីមិនត្រឹមត្រូវទេបើគ្មានវា ហើយវាគឺជាអ្វីដែលត្រូវបានចង់សំដៅនៅក្នុងព្រះបន្ទូលរបស់ទ្រង់ដ៏ខ្ពង់ខ្ពស់ថា៖

﴿ثُمَّ لْيَقْضُوا تَفَثَهُمْ وَلْيُوفُوا نُذُورَهُمْ وَلْيَطَّوَّفُوا بِالْبَيْتِ الْعَتِيقِ ۝٢٩﴾

បន្ទាប់មក ចូរឲ្យពួកគេបំពេញនូវកិច្ចការហាជ្ជីរបស់ពួកគេ(ដែល

---

1 រាយការណ៍ដោយ អ៊ីម៉ាំ ពូខរី៖១៥៣៩, មូស្លីម៖១១៨៩

នៅសេលសល់)
ហើយចូរឲ្យពួកគេបំពេញនូវពាក្យសច្ចារបស់ខ្លួន
និងចូរឲ្យពួកគេតវ៉ាហ្វជុំវិញពៃតុលឡោះ។
[គម្ពីរគួរអាន ២២:២៩]

បន្ទាប់ពីតវ៉ាហ្វ
និងសទ្បាតនៅខាងក្រោយម៉ាកូមរួចរាល់
គេត្រូវសាអ៊ីរវាងភ្នំសហ្វានិងមារវ៉ះ
ប្រសិនបើគេធ្វើហាជ្ជីតាម៉ាត់តួក។
ការសាអ៊ីនេះគឺសម្រាប់ហាជ្ជីរបស់គេ
រីឯការសាអ៊ីដំបូងគឺសម្រាប់អ៊ុំរ៉ោះរបស់គេ។

ហើយការសាអ៊ីតែមួយដងគឺមិនគ្រប់គ្រាន់ឡើយ
យោងតាមទស្សនៈដែលត្រឹមត្រូវបំផុតរបស់បណ្ដាអ្នកប្រាជ្ញអ៊ីស្លាម ដោយផ្អែកលើហាទីស្ហរបស់អាអ៊ីស្ហះ رضي الله عنها ដែលបាននិយាយថា៖
«ពួកយើងបានចេញដំណើរជាមួយរ៉ស៊ូលុលឡោះ ﷺ»
រួចមកនាងក៏បានរៀបរាប់ហាទីស្ហនោះ
ហើយនៅក្នុងនោះ លោកបានមានប្រសាសន៍ថា៖

«وَمَنْ كَانَ مَعَهُ هَدْيٌ فَلْيُهِلَّ بِالحَجِّ مَعَ العُمْرَةِ ثُمَّ لَا يَحِلُّ حَتَّى يَحِلَّ مِنْهُمَا جَمِيعًا».

«ហើយអ្នកណាដែលនាំសត្វជំនូនមកជាមួយ
(តាំងពីក្រៅតំបន់ហារ៉ាំ
នោះចូរឱ្យគេបន្លឺសំឡេងធ្វើហាជ្ជី
រួមជាមួយអ៊ុំរ៉ោះតែម្ដង (ហៅថា ហាជ្ជីបែបគីរ៉ន
បន្ទាប់មក គេមិនត្រូវដោះអៀហរ៉ម (តាហាលុល)
ឡើយ រហូតទាល់តែគេបានបញ្ចប់កិច្ចការទាំងពីរ

(ហាជ្ជី និងអ៊ុំរ៉ោះ) ជាមួយគ្នា (នៅថ្ងៃរ៉យ៉ា)» រហូតដល់សម្ដីរបសអ្នកស្រី

«فَطَافَ الَّذِينَ أَهَلُّوا بِالعُمْرَةِ بِالبَيْتِ وَبِالصَّفَا وَالمَرْوَةِ ثُمَّ حَلُّوا ثُمَّ طَافُوا طَوَافًا آخَرَ بَعْدَ أَنْ رَجَعُوا مِنْ مِنًى لِحَجِّهِمْ».

«ហើយបណ្ដាអ្នកដែលបានធ្វើអ៊ុំរ៉ោះ ក៏បានតវ៉ាហ្វជុំវិញកាក់ហ្ពះ និងបានសាអ៊ីរវាងភ្នំសហ្វា និងភ្នំម៉ារវ៉ះ រួចពួកគេបានតាហាល់លុល។ បន្ទាប់មកពួកគេបានធ្វើតវ៉ាហ្វមួយលើកផ្សេងទៀត ក្រោយពីពួកគេបានត្រឡប់ពីមីណាវិញ សម្រាប់ហាជ្ជីរបស់ពួកគេ»[1] រាយការណ៍ដោយ អ៊ីម៉ាំពូខរី និងមូស្លីម។

ហើយចំពោះសម្ដីរបស់អ្នកស្រីអាអ៊ីស្ស៊ះដែលសំដៅលើអ្នកដែលបាននិយតធ្វើអ៊ុំរ៉ោះ ដែលថា៖ បន្ទាប់មកពួកគេបានដើរតវ៉ាហ្វមួយផ្សេងទៀត (តវ៉ាហ្វទីពីរ) បន្ទាប់ពីពួកគេបានត្រឡប់មកពីតំបន់មីណាវិញ សម្រាប់កិច្ចការហាជ្ជីរបស់ពួកគេ។ អត្ថន័យដែលអ្នកស្រីចង់សំដៅនោះគឺ៖ ការដើររវាងភ្នំសហ្វា ទៅភ្នំម៉ារវ៉ះ នេះបើផ្អែកតាមទស្សនៈដែលត្រឹមត្រូវបំផុតក្នុងការបកស្រាយហាទីស្លនេះ ចំពោះមតិដែលលើកឡើងថា៖ អ្នកស្រីចង់សំដៅលើ "តវ៉ាហ្វអ៊ីហ្វាហ្ោះ" នោះ គឺមិនត្រឹមត្រូវឡើយ។ ពីព្រោះតវ៉ាហ្វអ៊ីហ្វាហ្ោះ

1 រាយការណ៍ដោយ អ៊ីម៉ាំ ពូខរី៖១៥៥៦, មូស្លីម៖១២១១

គឺជាមូលដ្ឋានគ្រឹះ(រ៉ូកុន) សម្រាប់អ្នកធ្វើហាជ្ជីគ្រប់រូប (ទាំងហាជ្ជីគិរ៉ន មូហ្វរិដ និងតាម៉ាត់ត្អុក) ហើយពួកគេទាំងអស់សុទ្ធតែបានអនុវត្តវារួចរាល់ហើយ ប៉ុន្តែអ្វីដែលអ្នកស្រីចង់សំដៅពិតប្រាកដនោះគឺៈ អ្វីដែលជាលក្ខណៈពិសេសសម្រាប់តែអ្នកធ្វើហាជ្ជី "មុតៈម៉ាត់ទី" ប៉ុណ្ណោះ ពោលគឺ ការដើរសាអ៊ីរវាងភ្នំសហ្វា និងម៉ារវ៉ះ ជាលើកទីពីរ បន្ទាប់ពីត្រឡប់មកពីមីណាវិញ ដើម្បីបង្គ្រប់កិច្ចការហជ្ជរបស់គេឱ្យពេញលេញ។ ហើយចំណុចនេះគឺច្បាស់លាស់ណាស់ (អាល់ហាំទូលិលឡោះ) ហើយវាក៏ជាទស្សនៈរបស់អ្នកប្រាជ្ញភាគច្រើនផងដែរ ។

ហើយអ្វីដែលបញ្ជាក់ពីភាពត្រឹមត្រូវនៃរឿងនេះផងដែរ គឺការរាយការណ៍របស់អ៊ីមុាំអាល់ខពូរីនៅក្នុងសៀវភៅសហ៊ើសរបស់លោក ជាការរាយការណ៍ដែលលោកបានបញ្ជាក់ពីភាពត្រឹមត្រូវរបស់វាដោយមិនភ្ជាប់ខ្សែសង្វាក់អ្នករាយការណ៍ អំពី អ៊ិពនូអាប់ហ្គាស رضي الله عنهما ថា នៅពេលដែលគេបានសួរគាត់អំពី មុតអៈនៃហាជ្ជី គាត់ក៏បាននិយាយថាៈ ក្រុមមូហាជីរីន ក្រុមអាន់ស័រ និងភរិយាទាំងឡាយរបស់ណាពី ﷺ បានបន្លឺសម្លេង(នៀត)ចូលអៀហរ៉មនៅក្នុងអំឡុងពេលនៃហាជ្ជីវ៉ាហ្ទាក(ហាជ្ជីចុងក្រោយ) ហើយពួកយើង

(អ្នកស្រីអែអ៊ិស្សះ និងអ្នកដទៃ) ក៏បាននៀតអៀហរ៉ាមដែរ លុះដល់ពេលពួកយើងបានមកដល់ទីក្រុងម៉ាក្កះ លោកសាស្ដ្រាចារ្យអល់ឡោះ ﷺ បានមានប្រសាសន៍ថា៖ "ចូរពួកអ្នកប្ដូរការនៀតហាជ្ជីរបស់ពួកអ្នក ឱ្យទៅជាអ៊ុំរ៉ោះវិញចុះ លើកលែងតែអ្នកណាដែលបានបំពាក់សញ្ញាលើសត្វពលិកម្ម (នាំសត្វមកជាមួយ) ប៉ុណ្ណោះ បន្ទាប់មក ពួកយើងក៏បានដើរតវ៉ាហ្វជុំវិញកាក់ពះ និងដើរសាអ៊ីរវាងភ្នំសហ្វា និងម៉ារវ៉ះ (រួចក៏ដោះអៀហរ៉ាម) ហើយពួកយើងក៏បានរួមរស់ជាមួយភរិយា និងបានស្លៀកពាក់សម្លៀកបំពាក់ធម្មតាវិញ ហើយព្យាការី ﷺ បានមានប្រសាសន៍ទៀតថា៖ "អ្នកណាដែលបាននាំសត្វជំនូនមកជាមួយ គេមិនត្រូវដោះអៀហរ៉ាមឡើយ រហូតទាល់តែសត្វជំនូននោះទៅដល់កន្លែងសម្លាប់របស់វា (នៅថ្ងៃរ៉ោយ៉ា) បន្ទាប់មក នៅល្ងាចនៃថ្ងៃតារវីយ៉ះ (ថ្ងៃទី ៨ ហ្ស៊ុលហិជ្ជះ) ព្យាការី ﷺ បានបញ្ជាឱ្យពួកយើងនៀតអៀហរ៉ាមសម្រាប់ធ្វើហាជ្ជីម្ដងទៀត ហើយនៅពេលដែលពួកយើងបានបញ្ចប់កិច្ចការហាជ្ជីទាំងឡាយ (នៅមីណា និងអារ៉ាហ្វះ) រួចរាល់ហើយ ពួកយើងក៏បានមកកាន់កាក់ពះ ដើម្បីដើរតវ៉ាហ្វ និងដើរសាអ៊ី វាងភ្នំសហ្វា និងម៉ារវ៉ះ ជាលើកទីពីរ

សម្រាប់ហាជ្ជី។[1] ចប់ខ្លឹមសារដែលចង់ដកស្រង់ ហើយវាបញ្ជាក់យ៉ាងច្បាស់អំពីការសាអីរបស់អ្នកធ្វើហាជ្ជីតាម៉ាត់តួកចំនួនពីរដង ហើយអល់ឡោះជាអ្នកដឹងបំផុត។

ចំណែកឯសេចក្តីរាយការណ៍ របស់អ៊ីម៉ាំមូស្លីមអំពី ជើពៀរ رضي الله عنه៖ "ព្យាការី ﷺ និងបណ្តាសហ្ហាត់របស់លោក (ដែលមានសភាពដូចលោក) មិនបានដើរតវ៉ាហ្វ..និងរវាងភ្នំសហ្វា និងម៉ារ៉ោះ ក្រៅតែពីការដើរតវ៉ាហ្វ តែមួយដងគត់។[2] ការដើរតវ៉ាហ្វ លើកដំបូងរបស់ពួកគេ ដែលរៀបរាប់ក្នុងហាទីស្ហជ្ជាពៀរ គឺត្រូវបានសំដៅទៅលើបណ្តាសហាហ្ហាត់ទាំងឡាយណា ដែលបាននាំសត្វជំនូនមកជាមួយ។ ពីព្រោះពួកគេបានបន្តស្ថិតក្នុងសភាពអៀហរ៉មរបស់ពួកគេជាមួយលោកព្យាការី ﷺ រហូតទាល់តែពួកគេបានដោះអៀហរ៉ម (តាហាលុល) ពីកិច្ចការហាជ្ជីនិងអ៊ុំរ៉ោះជាមួយគ្នាតែម្តង (នៅរ៉យ៉ា) ហើយព្យាការី ﷺ បាននៀតអៀហរ៉មសម្រាប់ទាំងហាជ្ជី និងអ៊ុំរ៉ោះ (បែបគីរ៉ន) ហើយលោកក៏បានបញ្ជាដល់អ្នកណាដែលនាំសត្វជំនូនមកជាមួយ ឱ្យនៀតអៀហរ៉មសម្រាប់ទាំងហាជ្ជី

1 រាយការណ៍ដោយ អ៊ីម៉ាំពូខរីៈ១៥៧២

2 រាយការណ៍ដោយ មូស្លីមៈ១២១៥

និងអ៊ុំរ៉ោះរួមគ្នាដែរ និងលោកបានបញ្ជា មិនឱ្យពួកគេដោះអៀហរ៉មឡើយ រហូតទាល់តែពួកគេបានបញ្ចប់កិច្ចការទាំងពីរ (ហាជ្ជី និងអ៊ុំរ៉ោះ) ជាមួយគ្នា។ ហើយអ្នកដែលរួមបញ្ចូលគ្នារវាងហាជ្ជី និងអ៊ុំរ៉ោះ គ្មានកាតព្វកិច្ចលើគាត់ក្រៅពីការធ្វើសាអ៊ីតែមួយដងឡើយ ដូចដែលបានបញ្ជាក់នៅក្នុងហាទីសរបស់ហ្ជាពៀរដែលបានរៀបរាប់ និងហាទីស្ហត្រឹមត្រូវ(សហើស) ដទៃទៀត។

ដូចគ្នានេះដែរ អ្នកដែលធ្វើហាជ្ជីអ៊ីហ្វរ៉ាទ ហើយបន្តស្ថិតនៅក្នុងអៀហរ៉មរបស់ខ្លួនរហូតដល់ថ្ងៃរ៉យ៉ា គឺគេត្រូវធ្វើសាអ៊ីតែមួយប៉ុណ្ណោះ។ ដូច្នេះ ប្រសិនបើអ្នកធ្វើហាជ្ជីគីរ៉ាន និងអ៊ីហ្វរ៉ាទ បានសាអ៊ីបន្ទាប់ពីតវ៉ាហ្វគូទូមរួច នោះវាគ្រប់គ្រាន់សម្រាប់គេ ដោយមិនចាំបាច់សាអ៊ីម្តងទៀតបន្ទាប់ពីតវ៉ាហ្វអ៊ីហ្វាហ្ោះឡើយ។ ហើយនេះគឺជាការបូកបញ្ចូលគ្នារវាងហាទីស្ហទាំងពីររបស់លោកស្រីអាអ៊ីស្ហះ និងលោកអ៊ីបនូអាហ្គាស់ ជាមួយនឹងហាទីស្ហរបស់លោកហ្ជាពៀរដែលបានរៀបរាប់។ ដោយធ្វើបែបនេះ ភាពផ្ទុយគ្នាត្រូវបានបំបាត់ ហើយគេអាចយកហាទីស្ហទាំងអស់ទៅអនុវត្តបាន។

ហើយអ្វីដែលគាំទ្រដល់ការបកស្រាយរួមគ្នានេះ គឺថា ហាទីស្ហរបស់អ្នកស្រី អាអ៊ីស្យះ និងលោក អ៊ីបនូ

អាប់ហ្គាស់
សូមអល់ឡោះពេញចិត្តដល់ពួកគាត់ទាំងពីរ
គឺជាហាទីស្ហសហើសទាំងពីរ
ដែលបានបញ្ជាក់អំពីការសាអុ៊ីលើកទីពីរចំពោះអ្នក
ធ្វើហាជ្ជីប្រភេទតាំម៉ាត់តួក។
រីឯអត្ថន័យច្បាស់របស់ហាទីស្ហ ហ្វាពៀរ
បានបដិសេធចំពោះបញ្ហានេះ
ហើយភស្តុតាងដែលបញ្ជាក់គឺត្រូវមានអាទិភាពជាង
ភស្តុតាងដែលបដិសេធ
ដូចដែលមានចែងនៅក្នុងវិជ្ជាគោលការណ៍គ្រឹះ
(អ៊ូសូល) និងវិជ្ជាផ្នែកហាទីស (ម៉ូស្តឡាហ៍
អាល់ហាទីស)។ ហើយអល់ឡោះ ស៊ុបហានាហ៊ូ វ៉ាតាអាឡា
ជាអ្នកប្រទានឱ្យមានភាពត្រឹមត្រូវ
ហើយគ្មានអានុភាព និងកម្លាំងអ្វីឡើយ
លើកលែងតែដោយសារទ្រង់ប៉ុណ្ណោះ។

## ជំពូក

## បញ្ជាក់ពីឧត្តមភាពនៃទង្វើដែលអ្នកធ្វើហាជ្ជីអនុវត្តនៅថ្ងៃណះរ៍(ថ្ងៃរ៍យ៉ាសំឡេះសត្វ)។

អ្វីដែលល្អបំផុតសម្រាប់អ្នកធ្វើហាជ្ជីគឺ
ត្រូវរៀបចំកិច្ចការទាំងបួនយ៉ាងនេះនៅថ្ងៃបុណ្យហាជ្ជី
តាមលំដាប់លំដោយដូចដែលបានរៀបរាប់៖
ដោយត្រូវចាប់ផ្តើមដំបូងគេដោយការគប់គោលអាក៏
ហ្គះ បន្ទាប់មកធ្វើគើរពាន បន្ទាប់មកកោរ
ឬកាត់សក់ រួចតវ៉ាហ្វ និងសាអ៊ីបន្ទាប់ពីនោះ

សម្រាប់អ្នកធ្វើហាជ្ជីតាម៉ាត់តួក ហើយដូចគ្នានេះដែរសម្រាប់អ្នកធ្វើហាជ្ជីអ៊ីហ្វរ៉ទ និងហាជ្ជីគីរ៉នប្រសិនបើពួកគេទាំងពីរមិនទាន់បានសាអ៊ីក្រោយពីតវ៉ាហ្វគូទូម។

ប្រសិនបើគេធ្វើកិច្ចការទាំងនេះមិនតាមលំដាប់លំដោយ នោះគឺអនុញ្ញាតសម្រាប់គេហើយ ដោយសារតែការអនុញ្ញាតត្រូវបានបញ្ជាក់ពីព្យាការី ﷺ នៅក្នុងរឿងនេះ។

ហើយក្នុងនោះរួមបញ្ចូលទាំងការធ្វើសាអ៊ីមុនការតវ៉ាហ្វផងដែរ ពីព្រោះវាគឺជាកិច្ចការមួយដែលគេត្រូវធ្វើនៅថ្ងៃបុណ្យហាជ្ជី។ ដូចនេះ វាស្ថិតនៅក្នុងសង្កឌីរបស់សហហ្ពាះដែលបានពោលថា៖ «នៅថ្ងៃនោះ លោកមិនត្រូវបានគេសួរអំពីអ្វីមួយដែលត្រូវបានគេធ្វើមុន ឬក្រោយ(លំដាប់របស់វា)ឡើយ លើកលែងតែលោកបានមានប្រសាសន៍ថា...»

«افْعَلْ وَلَا حَرَجَ».

"ចូរអ្នកធ្វើចុះ គ្មានបញ្ហាអ្វីឡើយ",[1] ហើយដោយសារតែរឿងនោះ គឺជាអ្វីដែលកើតមាននូវការភ្លេចភ្លាំង

1 រាយការណ៍ដោយ អាល់ពូខរីៈ៨៣, មូស្លីមៈ១៣០៦

និងការមិនដឹង ទើបគេតម្រូវឲ្យបញ្ចូលវាទៅក្នុងគោលការណ៍រួមនេះ ដោយសារតែវាជាការផ្តល់ភាពងាយស្រួល និងការសម្រួល។

មានភាពត្រឹមត្រូវពីព្យាការី ﷺ ថា លោកត្រូវបានគេសួរអំពីអ្នកដែលបានធ្វើសាអុិមុន ពេលធ្វើតវ៉ាហ្វ ហើយលោកបានមានប្រសាសន៍ថា៖

«لَا حَرَجَ».

“គ្មានទោសកំហុសទេ”[1] រាយការណ៍ដោយ អាពូហ្ទើរ៉ូទ តាមរយៈហាទីស្ទរបស់ អូសាម៉ះ កូន ស្ហ៊ារីក ដោយបណ្តាញរាយការណ៍ត្រឹមត្រូវ៖ ហេតុនេះ វាបានបញ្ជាក់យ៉ាងច្បាស់ថា វាស្ថិតក្នុងន័យទូទៅដោយគ្មានការសង្ស័យ ហើយអល់ឡោះជាអ្នកប្រទានភាពជោគជ័យ។

កិច្ចការដែលនាំឱ្យអ្នកធ្វើហាជ្ជីបានបញ្ចប់តំណម អៀហរ៉មទាំងស្រុងនោះគឺមានបីយ៉ាង៖ ការគប់គោលអាក៏ហ្ពះ, ការកោរសក់ឬកាត់សក់, និងការតវ៉ាហ្វអ៊ីហ្វាហ្ទោះ ព្រមទាំងការសាអុីបន្ទាប់ពីនោះ។ នៅពេលដែលគេបានបំពេញកិច្ចការទាំងបីនេះរួច គឺអ្វីគ្រប់យ៉ាងដែលត្រូវបានហាមឃាត់លើគេដោយសារអៀហរ៉ម គឺត្រូវបានអនុញ្ញាតសម្រាប់គេវិញ រួមមាន ការរួមមេត្រី ទឹកអប់ និងផ្សេងៗទៀត។

[1] រាយការណ៍ដោយ អាពូហ្ទាវូទ៖២០១៥

ហើយអ្នកដែលបានបំពេញត្រឹមតែពីរក្នុងចំណោមនោះ
គឺអ្វីគ្រប់យ៉ាងដែលត្រូវបានហាមឃាត់លើគេដោយសារអៀហរ៉ម គឺត្រូវបានអនុញ្ញាតសម្រាប់គេវិញ លើកលែងតែការរួមមេត្រីប៉ុណ្ណោះ
ហើយនេះត្រូវបានគេហៅថា ៖ ការបញ្ចប់តំណមអៀហរ៉មដំបូង។

ហើយស៊ូណាត់សម្រាប់អ្នកធ្វើហាជ្ជី គឺត្រូវពិសាទឹកហ្សំហ្សំឲ្យបានឆ្អែត និងសុំទូអាដែលមានប្រយោជន៍តាមដែលគេអាចធ្វើបាន ហើយ...

«مَاءُ زَمْزَمَ لِمَا شُرِبَ لَهُ».

"ទឹកហ្សំហ្សំ គឺសម្រាប់គោលបំណងដែលគេបានផឹកវា" (៨៦)[1] ដូចដែលបានរ៉ាយការណ៍អំពីព្យាការី ﷺ នៅក្នុងសហើសមូស្លីម អំពី អាពូហ្សើរ ថា ពិតណាស់ ព្យាការី ﷺ លោកបានមានប្រសាសន៍ស្ដីអំពីទឹកហ្សំហ្សំមថា៖

«إِنَّهُ طَعَامُ طُعْمٍ».

«ពិតប្រាកដណាស់ វាជាអាហារដែលធ្វើឲ្យឆ្អែត»[2] បន្ថែមដោយ អាពូហ្ើរូទ៖

---

1 រាយការណ៍ដោយ អ៊ីបនូម៉ាជះ អំពី ហ្គាពៀរ កូន អាប់ទុលឡោះ رضي الله عنه ៖៣០៦២

2 រាយការណ៍ដោយមូស្លីម លេខ (2473)។

«وَشِفَاءُ سُقْمٍ».

និងជាការធ្វើឱ្យជាសះស្បើយពីជំងឺ។[1]

បន្ទាប់ពីតវ៉ាហ្វអ៊ីហ្វាខោះ និងសាអីសម្រាប់អ្នកដែលត្រូវធ្វើសាអីរួច បណ្តាអ្នកធ្វើហាជ្ជីត្រូវត្រឡប់ទៅកាន់មីណាវិញ ហើយស្នាក់នៅទីនោះរយៈពេលបីថ្ងៃបីយប់ ដោយត្រូវគប់គោលទាំងបីក្នុងថ្ងៃនីមួយៗនៃថ្ងៃទាំងបីនោះបន្ទាប់ពីថ្ងៃជ្រេ ហើយវ៉ាជិប(ចាំបាច់)ត្រូវគប់តាមលំដាប់លំដោយ។

គេត្រូវចាប់ផ្តើមនៅគោលទីមួយ ដែលជាគោលស្ថិតនៅក្បែរម៉ាស្ជិត អាល់ខៃហ្វ៍ ដោយគប់វាចំនួនប្រាំពីរគ្រាប់គ្រួសបន្តបន្ទាប់គ្នា និងលើកដៃរាល់ពេលគប់គ្រាប់គ្រួសនីមួយៗ។ តាមស៊ុណ្ណះ គឺត្រូវឈានទៅមុខបន្តិចដោយទុកឲ្យគោលនោះនៅខាងឆ្វេងដៃ រួចតម្រង់ទៅកាន់គិបឡាត់ លើកដៃទាំងពីរ ហើយសុំទូអា និងទទួចអង្វរករឲ្យបានច្រើន។

បន្ទាប់មក គេត្រូវគប់គោលទីពីរដូចគោលទីមួយដែរ។ ក្រោយមក គេគប្បីដើរទៅមុខបន្តិច

1 គឺចង់សំដៅលើ អាពូហ្ពើរូទ អាត់តយ្យាលីស៊ី ដែលគាត់បានកត់ត្រាវានៅក្នុងហាទីស្តរឿងរ៉ាវអំពីការចូលសាសនាឥស្លាមរបស់អាពូហ្ស៊ើរ សូមអល់ឡោះពេញចិត្តដល់គាត់។ សូមមើល មូសណាត់ អាពូហ្ពើរូទ អាត់តយ្យាលីស៊ីុះ៤៥៩។

ដោយដាក់គោលនោះនៅខាងស្តាំដៃ
រួចតម្រង់មុខទៅកាន់គិបឡាត់
ហើយលើកដៃទាំងពីរឡើងដើម្បីសុំទូអាឲ្យបានច្រើន។
បន្ទាប់មក គេត្រូវគប់គោលទីបី
ហើយមិនត្រូវឈរនៅទីនោះឡើយ។
ហើយនៅថ្ងៃទីពីរនៃថ្ងៃតាស្រិក
គេត្រូវគប់គោលបន្ទាប់ពីថ្ងៃជ្រេ
ដូចដែលបានគប់នៅថ្ងៃដំបូងដែរ
ហើយគេត្រូវធ្វើនៅត្រង់គោលទីមួយនិងគោលទីពីរ
ដូចដែលបានធ្វើនៅថ្ងៃដំបូងដែរ
ដើម្បីត្រាប់តាមព្យាការី ﷺ។
ការគប់គោលនៅពីរថ្ងៃដំបូងនៃថ្ងៃតាស្រិក
គឺជាវ៉ាជិបមួយនៃវ៉ាជិបរបស់ពិធីហាជ្ជី
ហើយការស្នាក់នៅមីណានៅយប់ទីមួយនិងយប់ទីពីរ
ក៏ជាវ៉ាជិបដែរ លើកលែងតែចំពោះអ្នកផ្តល់ទឹក
អ្នកគង្វាល
និងអ្នកដែលមានករណីស្រដៀងនឹងពួកគេ
គឺមិនវ៉ាជិបឡើយ
បន្ទាប់ពីគប់គោលនៅថ្ងៃទាំងពីរនោះរួចហើយ
អ្នកណាដែលចង់ប្រញាប់ចាកចេញពីមីណា
គឺអាចធ្វើបាន ដោយត្រូវចាកចេញមុនពេលថ្ងៃលិច។
ចំណែកឯអ្នកដែលពន្យារពេលដោយស្នាក់នៅនាយប់
ទី១៣មួយយប់ទៀត ហើយគប់គោលនៅថ្ងៃទី១៣
នោះគឺល្អប្រសើរ និងមានផលបុណ្យមហាសាលជាង។
ដូចដែលអល់ឡោះជាម្ចាស់ដ៏ខ្ពង់ខ្ពស់បានមានបន្ទូល

ថា:

﴿وَاذْكُرُوا اللَّهَ فِي أَيَّامٍ مَعْدُودَاتٍ فَمَنْ تَعَجَّلَ فِي يَوْمَيْنِ فَلَا إِثْمَ عَلَيْهِ وَمَنْ تَأَخَّرَ فَلَا إِثْمَ عَلَيْهِ لِمَنِ اتَّقَى...﴾

ហើយចូរពួកអ្នករំឭកទៅចំពោះអល់ឡោះក្នុងបណ្តាថ្ងៃដែលត្រូវបានកំណត់ ។ ដូច្នេះ ជនណាដែលមានការប្រញាប់(ចង់ចាកចេញពីតំបន់មីណា)ក្នុងថ្ងៃទីពីរ គឺគ្មានទោសពៃរ៍អ្វីឡើយចំពោះគេ ហើយជនណាដែលចង់ពន្យារ(ដោយបន្តស្នាក់នៅរហូតដល់ថ្ងៃទីបី) ក៏គ្មានទោសពៃរ៍អ្វីចំពោះគេដែរសម្រាប់អ្នកដែលកោតខ្លាច(អល់ឡោះ)... [គម្ពីរគួរអាន ២:២០៣] ព្រោះថា ព្យាការីមូហាំម៉ាត់ ﷺ លោកបានអនុញ្ញាតឱ្យមនុស្សទូទៅអាចប្រញាប់ចាកចេញបាន ប៉ុន្តែលោកផ្ទាល់មិនបានប្រញាប់ចាកចេញនោះទេ ផ្ទុយទៅវិញលោកបានស្នាក់នៅមីណារហូតដល់លោកបានគប់គោលនាថ្ងៃទី១៣ បន្ទាប់ពីថ្ងៃជ្រេ។ បន្ទាប់មកលោកក៏បានធ្វើដំណើរចាកចេញមុនពេលលោកសឡាតហ្ស៊ូហ៊្ស។

ហើយអាណាព្យាបាលរបស់ក្មេងប្រុសដែលគ្មានលទ្ធភាពគប់ដោយខ្លួនឯង គឺអាចគប់ជំនួសគាត់នៅជំរ៉ាតុលអាក៏ហ្ពះ និងបណ្តាហ្ជាម៉ារ៉ាតដែលនៅសល់

បន្ទាប់ពីខ្លួនបានគប់សម្រាប់ខ្លួនឯងរួច។ ហើយដូចគ្នានេះដែរ ក្មេងស្រីតូចដែលគ្មានលទ្ធភាពគប់ គឺអាណាព្យាបាលរបស់នាងជាអ្នកគប់ជំនួស ដោយផ្អែកលើហាទីស្ហរបស់ហ្ចាពៀរ សូមអល់ឡោះពេញចិត្តដល់គាត់ ដែលគាត់បានមានប្រសាសន៍ថា:

«حَجَجْنَا مَعَ رَسُولِ اللَّهِ ﷺ، وَمَعَنَا النِّسَاءُ وَالصِّبْيَانُ، فَلَبَّيْنَا عَنِ الصِّبْيَانِ وَرَمَيْنَا عَنْهُمْ».

“ពួកយើងបានធ្វើហាជ្ជីជាមួយរ៉សូលុលឡោះ ﷺ ហើយមានស្ត្រីនិងកុមារនៅជាមួយពួកយើងផងដែរ។ ពេលនោះ ពួកយើងបានសូត្រតាល់ពីយ៉ះជំនួសឲ្យកុមារ ហើយបានគប់ដុំថ្មជំនួសពួកគេ”។[1] រាយការណ៍ដោយអ៊ីបនូម៉ាហ្ជះ

ហើយត្រូវបានអនុញ្ញាតឱ្យអ្នកដែលអសមត្ថភាពក្នុងការគប់គោល ដោយសារជំងឺ ឬចាស់ជរា ឬមានផ្ទៃពោះ ចាត់តាំងអ្នកផ្សេងឱ្យគប់គោលជំនួស ដោយយោងតាមព្រះបន្ទូលរបស់អល់ឡោះជាម្ចាស់៖

﴿فَاتَّقُوا اللَّهَ مَا اسْتَطَعْتُمْ...﴾

ដូច្នេះ ចូរពួកអ្នកកោតខ្លាចអល់ឡោះតាមលទ្ធភាពរបស់ពួ

1 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី៖៩២៧

កអ្នក... [គម្ពីរគួរអាន ៦៤:១៦]. ហើយពួកគេទាំងនេះមិនអាចប្រជ្រៀតជាមួយហ្វូង មនុស្សនៅកន្លែងគប់គ្រួស(ជុំរ៉េាះ)បានទេ ហើយពេលវេលានៃការគប់គ្រួសក៏នឹងកន្លងផុតទៅ ដោយមិនត្រូវបានអនុញ្ញាតឱ្យពួកគេធ្វើវានៅពេល ក្រោយឡើយ។ ហេតុដូច្នេះហើយ ទើបគេអនុញ្ញាតឱ្យពួកគេអាចចាត់តំណាងបាន ដែលនេះគឺផ្ទុយពីកិច្ចការហាជ្ជីផ្សេងៗទៀត។ ដូចនេះ អ្នកដែលស្ថិតក្នុងតំណមអៀហរ៉មមិនគួរចាត់តំណាង ឱ្យអ្នកដទៃធ្វើជំនួសខ្លួនឡើយ ទោះបីជាការធ្វើហាជ្ជីរបស់គាត់ជាប្រភេទស្ម័គ្រចិត្ត(ណាវ៉ាហ្វិល) ក៏ដោយ ពីព្រោះអ្នកដែលបានអៀហរ៉មសម្រាប់ហាជ្ជី ឬអ៊ុំរ៉េាះ ទោះបីជាវាទាំងពីរជាប្រភេទស្ម័គ្រចិត្ត(ណាវ៉ាហ្វិល)ក៏ ដោយ គឺតម្រូវឱ្យរូបគេត្រូវតែបំពេញវាទាំងពីរឱ្យបានពេញ លេញ ដោយយោងតាមព្រះតម្រាស់របស់អល់ឡោះជាម្ចាស់ដែលទ្រង់បានមានបន្ទូលថា:

﴿وَأَتِمُّوا الْحَجَّ وَالْعُمْرَةَ لِلَّهِ...﴾

ហើយចូរពួកអ្នកបំពេញនូវកាតព្វកិច្ចហាជ្ជី និងអ៊ុំរ៉េាះសម្រាប់អល់ឡោះ... [គម្ពីរគួរអាន ២:១៩៦]. ពេលវេលានៃការតវ៉ាហ្វ និងការសាអុី មិនកន្លងផុតទេ ផ្ទុយពីពេលវេលានៃការគប់គោល។

ចំណែកឯការស្នាក់នៅអារ៉ហ្វះ
និងការស្នាក់នៅមុហ្សទើលីហ្វះ និងមីណា
គឺពិតណាស់ថាពេលវេលារបស់វាត្រូវកន្លងផុតទៅ
ប៉ុន្តែការស្ថិតនៅរបស់អ្នកដែលគ្មានលទ្ធភាពនៅទីក
ន្លែងទាំងនេះគឺអាចទៅរួច
ទោះបីជាមានការលំបាកក៏ដោយ,
នេះគឺខុសពីការគប់គោល,
ពីព្រោះការគប់គោលមានការរាយការណ៍ពីអ្នកជំនាន់
មុនដ៏ល្អប្រសើរថាអាចតែងតាំងអ្នកតំណាងបានស
ម្រាប់អ្នកដែលមានឧបសគ្គ
មិនដូចសកម្មភាពដទៃទៀតទេ។

ការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)ត្រូវផ្អែកលើភស្តុតាង
គឺគ្មាននរណាម្នាក់អាចបង្កើតច្បាប់ណាមួយចេញពីវា
បានឡើយ លើកលែងតែមានភស្តុតាង។
ហើយគេអនុញ្ញាតឱ្យអ្នកតំណាងគប់គោលសម្រាប់ខ្លួ
នឯងជាមុន
បន្ទាប់មកគប់ជំនួសអ្នកដែលបានចាត់តាំងគាត់
នៅគោលនិមួយៗនៃគោលទាំងបី
ខណៈដែលគាត់ស្ថិតនៅកន្លែងតែមួយ។
ហើយមិនវ៉ាជិប(មិនចាំបាច់)លើគាត់ឡើយ
ដែលត្រូវគប់គោលទាំងបីសម្រាប់ខ្លួនឯងឱ្យចប់សព្វ
គ្រប់ជាមុនសិន
ទើបត្រឡប់ទៅគប់ជំនួសអ្នកដែលបានចាត់តាំងគា
ត់នោះទេ
យោងតាមទស្សនៈដែលត្រឹមត្រូវជាងគេក្នុងចំណោម

ទស្សនៈទាំងពីររបស់បណ្ដាអ្នកប្រាជ្ញ ដោយសារគ្មានភស្តុតាងដែលតម្រូវឱ្យធ្វើដូច្នេះ និងដោយសារតែមានភាពលំបាកលំបិននៅក្នុងនោះ ។ ហើយអល់ឡោះទ្រង់មានបន្ទូលថា:

﴿...وَمَا جَعَلَ عَلَيْكُمْ فِي الدِّينِ مِنْ حَرَجٍ...﴾

...ហើយទ្រង់មិនបានធ្វើឲ្យមានការលំបាកលើពួកអ្នកនៅក្នុងសាសនា(របស់ពួកអ្នក)នោះឡើយ... [គម្ពីរគួរអាន ២២:៧៨] ហើយព្យាការីមូហាំម៉ាត់ ﷺ ក៏បានមានប្រសាសន៍ថាៈ

«يَسِّرُوا وَلَا تُعَسِّرُوا».

“ចូរពួកអ្នកបង្កភាពងាយស្រួល ហើយកុំបង្កការលំបាក”។[1] ហើយក៏ព្រោះតែការណ៍នេះមិនត្រូវបានគេរាយការណ៍ពីពួកសហហាបីរបស់រ៉សូល ﷺ នៅពេលដែលពួកគេបានគប់(ដុំមរ៉ោះ)ជំនួសឲ្យកូនៗរបស់ពួកគេ និងអ្នកដែលគ្មានសមត្ថភាពក្នុងចំណោមពួកគេឡើយ។ ប្រសិនបើពួកគេបានធ្វើបែបនេះមែន នោះវាពិតជាត្រូវបានគេរាយការណ៍តៗគ្នាជាមិនខាន ព្រោះវាជារឿងដែលមនុស្សម្នាក់ខ្នះខ្នែងក្នុងការរាយការណ៍អំពីវា។ ហើយអល់ឡោះជាអ្នកដឹងបំផុត។

1 រាយការណ៍ដោយ អ៊ីមុាំពូខរីៈ៦៩

# ជំពូក
# កាតព្វកិច្ចនៃការសំឡេះសត្វជំនូនទៅលើអ្នកធ្វើហាជ្ជីបែបតាំម៉ាត់តួក និងគីរ៉ន។

ហើយចាំបាច់លើអ្នកធ្វើហាជ្ជីដែលធ្វើហាជ្ជីប្រភេទតាម៉ាត់តួក ឬ គីរ៉ន ហើយមិនមែនជាអ្នករស់នៅក្នុងបរិវេណម៉ាស្ជិទអ៊ីលហារ៉ម(ទឹកដីពិសិដ្ឋ) គឺតម្រូវឲ្យគាត់សម្លេះសត្វជំនូនដែលនោះគឺៈ សត្វពពែមួយក្បាល ឬមួយភាគប្រាំពីរនៃសត្វអូដ្ឋ ឬមួយភាគប្រាំពីរនៃសត្វគោ។ ហើយចាំបាច់ដែលសត្វជំនូននោះត្រូវតែបានមកពីប្រាក់កាសដែលស្របច្បាប់(ហាឡាល់) និងជាទ្រព្យសម្បត្តិដ៏ស្អាតស្អំ ពីព្រោះអល់ឡោះជាម្ចាស់ទ្រង់ស្អាតស្អំ។ ទ្រង់មិនទទួលយកឡើយ លើកលែងតែអ្វីដែលស្អាតស្អំ។

អ្នកមូស្លីមគួរតែចៀសវាងការសុំអ្នកដទៃ មិនថាជាអំណោយ ឬរបស់អ្វីផ្សេងនោះទេ ទោះបីពួកគេជាស្តេច ឬជាជនដទៃក៏ដោយ ប្រសិនបើអល់ឡោះជាម្ចាស់បានប្រទានឲ្យគេនូវទ្រព្យសម្បត្តិគ្រប់គ្រាន់ ដែលអាចឲ្យគេផ្តល់ជាអំណោយពីខ្លួនឯងបាន និងធ្វើឲ្យគេមិនត្រូវការអ្វីពីអ្នកដទៃ នោះក៏ដោយសារតែមានបញ្ញាក់នៅក្នុងហាទីស្ហជាច្រើ

នរបស់ព្យាការី ﷺ អំពីការបន្ទោស និងភាពអាប់ឱននៃការសុំ ហើយនិងការសរសើរចំពោះអ្នកដែលបានបោះបង់វា។

ប្រសិនបើអ្នកធ្វើហាជ្ជីតាម៉ាត់តួក និងអ្នកធ្វើហាជ្ជីគីរ៉ន គ្មានលទ្ធភាពសំឡេះសត្វជំនូនទេនោះ គឺតម្រូវឲ្យគេបួសចំនួនបីថ្ងៃនៅក្នុងអំឡុងពេលធ្វើហាជ្ជី និងប្រាំពីរថ្ងៃទៀតនៅពេលដែលគេវិលត្រឡប់ទៅកាន់គ្រួសាររបស់គេវិញ។ ហើយគេអាចជ្រើសរើសក្នុងការបួសបីថ្ងៃនោះ ដោយគេអាចបួសវាមុនថ្ងៃសំឡេះគួរហ្ពាន ឬក៏អាចបួសវានៅក្នុងបណ្ដាថ្ងៃតាសស្រិកទាំងបីថ្ងៃក៏បាន។ អល់ឡោះជ៏ខ្ពង់ខ្ពស់ទ្រង់បានមានបន្ទូលថាៈ

﴿...فَمَنْ تَمَتَّعَ بِالْعُمْرَةِ إِلَى الْحَجِّ فَمَا اسْتَيْسَرَ مِنَ الْهَدْيِ فَمَنْ لَمْ يَجِدْ فَصِيَامُ ثَلَاثَةِ أَيَّامٍ فِي الْحَجِّ وَسَبْعَةٍ إِذَا رَجَعْتُمْ تِلْكَ عَشَرَةٌ كَامِلَةٌ ذَلِكَ لِمَنْ لَمْ يَكُنْ أَهْلُهُ حَاضِرِي الْمَسْجِدِ الْحَرَامِ...﴾

ដូចនេះជនណាដែលធ្វើហាជ្ជី”អាត់តាម៉ាត់តួក” ដោយធ្វើអ៊ុមរ៉ោះភ្ជាប់ជាមួយនឹងហាជ្ជី គឺត្រូវសំឡេះសត្វជំនូនណាមួយដែលគេងាយរកបាន។ តែប្រសិនបើគេគ្មានលទ្ធភាព(សំឡេះសត្វ)ទេនោះ គឺត្រូវបួសចំនួនបីថ្ងៃក្នុងពេលធ្វើហាជ្ជី និងប្រាំពីរថ្ងៃទៀតនៅពេលដែលពួកអ្នកវិលត្រលប់ទៅ(កាន់គ្រួសារ)វិញ។ នោះគឺគ្រប់ចំនួនដប់ថ្ងៃពេញ។

វាគឺសម្រាប់អ្នកដែលមិនមែនជាអ្នករស់នៅក្នុងតំបន់ម៉ាស្ជិតអាល់ហារ៉ម។ (អាល់ហ្គាក៏រ៉ោះ៖១៩៦) វាក្យខណ្ឌ

ហើយនៅក្នុង សហ៊ើស អាល់ពូខរី, អំពី អាអ៊ីស្ហះ និង អ៊ីបនូ អូមើរ رضي الله عنهم គាត់ទាំងពីរបាននិយាយថា៖

«لَمْ يُرَخَّصْ فِي أَيَّامِ التَّشْرِيقِ أَنْ يُصَمْنَ إِلَّا لِمَنْ لَمْ يَجِدِ الهَدْيَ».

“ការតមអាហារនៅថ្ងៃតាស្ស៊ីរីក មិនត្រូវបានអនុញ្ញាតឡើយ លើកលែងតែសម្រាប់ជនណាដែលរកសត្វចំនួនមិនបាន”។[1] ហើយហ៊ូកុមនេះ គឺស្ថិតក្នុងឋានៈជាហ៊ូកុមដែលចេញពីណាពី ﷺ។ ការដែលប្រសើរបំផុតនោះ គឺត្រូវបួសបីថ្ងៃមុនថ្ងៃអារ៉ហ្វា៖ ដើម្បីឲ្យនៅថ្ងៃអារ៉ហ្វា៖នោះគេមិនបានបួស ពីព្រោះណាពី ﷺ លោកបានឈរនៅថ្ងៃអារ៉ហ្វា៖ក្នុងសភាពដែលលោកមិនបានបួស ហើយលោកបានហាមឃាត់មិនឲ្យបួសនៅថ្ងៃអារ៉ហ្វា៖ សម្រាប់អ្នកដែលកំពុងស្ថិតនៅអារ៉ហ្វា៖។ ម្យ៉ាងទៀត ការមិនបួសនៅថ្ងៃនេះ គឺធ្វើឲ្យគេមានកម្លាំងបន្ថែមទៀតក្នុងការរំឭកដល់អល់ឡោះ(ហ្ស៊ីរគៀរ) និងការបួងសួង(ឌូអា)។ គេអនុញ្ញាតឲ្យបួសរយៈពេលបីថ្ងៃដែលបានរៀបរាប់ខាងលើនោះ ដោយអាចបួសបន្តបន្ទាប់គ្នា

---

[1] រាយការណ៍ដោយ អាល់ពូខរី៖១៩៩៨

ឬដាច់ពីគ្នាបាន។ ដូចគ្នាដែរ ចំពោះការបួសប្រាំពីរថ្ងៃទៀត ក៏មិនតម្រូវឲ្យបួសបន្តបន្ទាប់គ្នាដែរ ពោលគឺគេអាចបួសបន្តបន្ទាប់គ្នា ឬដាច់ពីគ្នាបាន ពីព្រោះអល់ឡោះជាម្ចាស់ ទ្រង់មិនបានដាក់លក្ខខណ្ឌឲ្យមានការបួសបន្តបន្ទាប់គ្នានោះទេ ហើយរ៉សូលរបស់ទ្រង់ ﷺ ក៏ដូច្នោះដែរ។ ហើយការដែលប្រសើរបំផុត គឺត្រូវពន្យារការបួសប្រាំពីរថ្ងៃនោះ រហូតដល់គេបានត្រឡប់ទៅកាន់គ្រួសាររបស់គេវិញ ដោយសារតែព្រះបន្ទូលរបស់ទ្រង់ជាម្ចាស់ដែលថា៖

﴿...وَسَبْعَةٍ إِذَا رَجَعْتُمْ...﴾

...ប្រាំពីរថ្ងៃទៀតនៅពេលដែលពួកអ្នកវិលត្រលប់ទៅ... [គម្ពីរគួរអាន ២:១៩៦]

ហើយការបួសសម្រាប់អ្នកដែលគ្មានលទ្ធភាពសំឡេះសត្វជំនួស គឺប្រសើរជាងការសុំសត្វជំនួសពីបណ្ដាមេដឹកនាំនិងអ្នកដទៃទៀតដើម្បីយកមកសំឡេះជំនួសខ្លួន។ ហើយចំពោះអ្នកដែលត្រូវបានគេផ្ដល់ឲ្យនូវសត្វជំនួស ឬអ្វីផ្សេងទៀត ដោយមិនបានសុំ ហើយក៏មិនមានចិត្តលោភលន់ចង់បានដែរ គឺគ្មានបញ្ហាអ្វីឡើយក្នុងការទទួលយកវា ទោះបីជារូបគេកំពុងធ្វើហាជ្ជីជំនួសអ្នកដទៃក៏ដោយ

ពោលគឺ
ប្រសិនបើអ្នកដែលបានពឹងពាក់គេ(ឲ្យធ្វើហាជ្ជីជំនួស
)
មិនបានដាក់លក្ខខណ្ឌឲ្យរូបគេទិញសត្វជំនួនពីថវិកា
ដែលបានផ្តល់ឲ្យនោះទេ។
ចំណែកឯទង្វើរបស់មនុស្សមួយចំនួន
ដែលសុំសត្វជំនួនពីរដ្ឋាភិបាលឬអ្នកដទៃ
ដោយប្រើឈ្មោះអ្នកដទៃដែលខ្លួនបានលើកឡើង
ទាំងដែលខ្លួនជាអ្នកកុហកនោះ
ការធ្វើបែបនេះគឺគ្មានការសង្ស័យឡើយចំពោះការហា
មឃាត់របស់វា
ព្រោះវាជាការរកស៊ីដោយការភូតកុហក។
សូមអល់ឡោះការពារពួកយើងនិងបណ្តាអ្នកមូស្លីមឲ្យរួ
ចផុតពីអំពើបែបនេះ។

## ជំពូក
## វ៉ាជិប(ចាំចាច់)លើបណ្តាអ្នកធ្វើហាជ្ជី និងអ្នកផ្សេងទៀត ត្រូវបង្គាប់ប្រើគ្នាឱ្យធ្វើអំពើល្អ។

ហើយក្នុងចំណោមកាតព្វកិច្ចដ៏ធំធេងបំផុតសម្រាប់បណ្តាអ្នកធ្វើហាជ្ជី និងអ្នកដទៃទៀតនោះគឺការត្រាស់បង្គាប់ឱ្យធ្វើអំពើល្អ
និងការហាមឃាត់ពីអំពើអាក្រក់
និងការថែរក្សាលើការសឡាតទាំងប្រាំពេលជាលក្ខណៈរួមគ្នា

ដូចដែលអល់ឡោះជាម្ចាស់បានបង្គាប់ប្រើនៅក្នុងគម្ពីររបស់ទ្រង់ និងតាមរយៈអ្នកនាំសាររបស់ទ្រង់ ﷺ។

ចំណែកឯអ្វីដែលមនុស្សជាច្រើនបានប្រព្រឹត្តក្នុងចំណោមអ្នករស់នៅទីក្រុងម៉ាក្កះ និងទីក្រុងផ្សេងៗទៀត ដូចជាការសឡាតនៅក្នុងផ្ទះ និងការទុកម៉ាស្ជិតចោល គឺជាកំហុសមួយដែលបំពាននឹងច្បាប់ឥស្លាម។ ដូច្នេះ គឺត្រូវតែហាមឃាត់នូវទង្វើនេះ និងបង្គាប់ប្រើមនុស្សទាំងឡាយឲ្យថែរក្សាការសឡាតនៅតាមម៉ាស្ជិត ដោយសារអ្វីដែលត្រូវបានបញ្ជាក់ពីណាពី ﷺ ថាលោកបានមានប្រសាសន៍ទៅកាន់លោក អ៊ិបនិ អ៊ុមមិ ម៉ាក់ទូម (សូមអល់ឡោះយល់ព្រមលើរូបគាត់) នៅពេលដែលគាត់បានសុំការអនុញ្ញាតពីលោកដើម្បីសឡាតនៅក្នុងផ្ទះរបស់គាត់ ដោយសារតែគាត់ជាមនុស្សពិការភ្នែក ហើយផ្ទះរបស់គាត់នៅឆ្ងាយពីម៉ាស្ជិត៖

«هَلْ تَسْمَعُ النِّدَاءَ بِالصَّلَاةِ؟ قَالَ: نَعَمْ، قَالَ: فَأَجِبْ».

“តើអ្នកឮការអាហ្សានទេ? គាត់បានឆ្លើយថា៖ បាទ, លោកបានមានប្រសាសន៍ថា៖ បើដូច្នេះ ចូរអ្នកឆ្លើយតប”[1]។

ហើយនៅក្នុងការនិទានមួយទៀត៖

1 រាយការណ៍ដោយ អាល់ពូខរី៖២៤២០, មូស្លីម៖៦៥១

«لَا أَجِدُ لَكَ رُخْصَةً».

“ខ្ញុំមិនឃើញមានការអនុញ្ញាតសម្រាប់អ្នកឡើយ”,[1] លោកបានមានប្រសាសន៍ទៀតថា៖

«لَقَدْ هَمَمْتُ أَنْ آمُرَ بِالصَّلَاةِ فَتُقَامَ، ثُمَّ آمُرَ رَجُلًا فَيُؤُمَّ النَّاسَ، ثُمَّ أَنْطَلِقَ إِلَى رِجَالٍ لَا يَشْهَدُونَ الصَّلَاةَ فَأُحَرِّقَ عَلَيْهِمْ بُيُوتَهُمْ بِالنَّارِ».

“ជាការពិតណាស់ ខ្ញុំពិតជាចង់ប្រើនរណាម្នាក់ឲ្យគេអ៊ីកំម៉ះសឡាត។ បន្ទាប់មក ខ្ញុំប្រើនរណាម្នាក់ឲ្យធ្វើជាអ៊ីម៉ាំដឹកនាំមនុស្សសឡាត។ បន្ទាប់មកទៀត ខ្ញុំក៏ចេញទៅសំដៅទៅកាន់ក្រុមដែលមិនមកចូលរួមសឡាត រួចដុតផ្ទះរបស់ពួកគេចោល”[2], ហើយនៅក្នុងសៀវភៅស៊ូណាន់អ៊ិពនូម៉ាជះ និងផ្សេងទៀត ដោយខ្សែបន្តនិទានហាសាន់, អំពីអ៊ិពនូអាប់ហ្គាស رضي الله عنهما, ពិតណាស់ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ سَمِعَ النِّدَاءَ فَلَمْ يَأْتِ فَلَا صَلَاةَ لَهُ إِلَّا مِنْ عُذْرٍ».

“អ្នកណាដែលបានឮសំឡេងអាហ្សាន ហើយមិនបានមក គឺគ្មានសឡាតសម្រាប់គេឡើយ

---

1 រាយការណ៍ដោយ មូស្លីម៖៦៥៣

2 រាយការណ៍ដោយ អាពូហ្ទាវូទ ពី អាប់ឌុលឡោះ ប៊ីន អ៊ីម៉ាក់ទូម៖៥៥២

លើកលែងតែមានមូលហេតុស្របច្បាប់”[1]،
ហើយនៅក្នុងសហ៊ីហមូស្លីម, អំពី អ៊ិពនូម៉ាស្អ៊ូទ رضي الله عنه បាននិយាយថា៖ «បុគ្គលណាដែលពេញចិត្តនឹងជួបអល់ឡោះជាម្ចាស់នៅថ្ងៃស្អែក(ថ្ងៃបរលោក)ក្នុងសភាពជាអ្នកមូស្លីម ចូរឲ្យគាត់រក្សានូវការសឡាតទាំងនេះនៅកន្លែងដែលគេប្រកាសហៅ(ម៉ាស្ជិត)។ ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ញត្តិសម្រាប់ណាពីរបស់ពួកអ្នកនូវគំរូទាំងឡាយនៃការចង្អុលបង្ហាញ។ ហើយពិតប្រាកដណាស់ វា(ការសឡាតរួមគ្នា)គឺស្ថិតក្នុងចំណោមគំរូនៃការចង្អុលបង្ហាញ។ ហើយប្រសិនបើពួកអ្នកសឡាតនៅក្នុងផ្ទះរបស់ពួកអ្នក ដូចដែលអ្នកដែលមិនទៅម៉ាស្ជិតនេះសឡាតនៅក្នុងផ្ទះរបស់គេ នោះពួកអ្នកពិតជាបានបោះបង់ចោលនូវគំរូ(ស៊ូណះ)របស់ណាពីរបស់ពួកអ្នកហើយ។ ហើយប្រសិនបើពួកអ្នកបោះបង់ចោលនូវគំរូ(ស៊ូណះ)របស់ណាពីរបស់ពួកអ្នក នោះពួកអ្នកពិតជានឹងវង្វេង។ ហើយគ្មានបុរសណាម្នាក់ដែលគេសម្អាតខ្លួន(យកវូហ្ពុ) ហើយគេសម្អាតខ្លួននោះបានយ៉ាងល្អប្រសើរ

---

1 រាយការណ៍ដោយ មូស្លីម៖៦៥៤

បន្ទាប់មក
គេឆ្ពោះទៅកាន់ម៉ាស្ជិតណាមួយក្នុងចំណោមម៉ាស្ជិតទាំងនេះ
លើកលែងតែអល់ឡោះជាម្ចាស់នឹងកត់ត្រាឲ្យគេនូវអំពើល្អមួយសម្រាប់គ្រប់ជំហានដែលគេបានដើរ
ហើយទ្រង់នឹងលើកតម្កើងឋានៈរបស់គេមួយកម្រិត
ហើយទ្រង់នឹងលុបបំបាត់ចោលនូវកំហុសឆ្គង(បាបកម្ម)របស់គេមួយ។ ហើយពិតប្រាកដណាស់ ពួកយើងបានឃើញហើយ
គឺគ្មាននរណាម្នាក់ដែលបោះបង់ចោលវាឡើយ
លើកលែងតែពួកពុតត្បុត(មូណាហ្វិក)ដែលគេស្គាល់ច្បាស់ពីភាពពុតត្បុតរបស់គេ។
ហើយពិតប្រាកដណាស់
បុរសម្នាក់ត្រូវបានគេនាំខ្លួនមកដោយមានបុរសពីរនាក់គ្រាហ៍
រហូតដល់គេបានដាក់ឲ្យគាត់ឈរនៅក្នុងជួរ(សាហ្វ)»[1]។

ចាំបាច់លើបណ្ដាអ្នកធ្វើហាជ្ជី
និងអ្នកផ្សេងទៀតត្រូវចៀសវាងពីបម្រាមទាំងឡាយរបស់អល់ឡោះជាម្ចាស់ដ៏ខ្ពង់ខ្ពស់
និងត្រូវប្រុងប្រយ័ត្នពីការប្រព្រឹត្តវា ដូចជាៈ ការរួមភេទខុសច្បាប់(ហ្ស៊ីណា),
ការរួមភេទរវាងបុរសនិងបុរស, ការលួចប្លន់,

1 រាយការណ៍ដោយ អាពូហ្ទៅវូទ៖៥៥១

ការយកការប្រាក់, ការយកទ្រព្យសម្បត្តិរបស់ក្មេងកំព្រា, ការបោកប្រាស់ក្នុងកិច្ចការជំនួញ, ការក្បត់នឹងការទុកចិត្ត(អាម៉ាណះ), ការសេពគ្រឿងស្រវឹង, ការជក់បារី, ការស្លៀកសម្លៀកបំពាក់អួសដី, ភាពក្រអឺតក្រទម, ការច្រណែនឈ្នានីស, ការអួតបង្អាញ(រីយ៉ាក់), ការនិយាយដើមគេ, ការញុះញង់, ការចំអកឡកឡឺយចំពោះបណ្ដាអ្នកមូស្លីម, ការប្រើប្រាស់ឧបករណ៍ភ្លេងកម្សាន្ត ដូចជាឌីសចម្រៀង ឧបករណ៍តន្ត្រី(អ៊ូត រ៉បាប) ខ្លុយ និងឧបករណ៍ស្រដៀងគ្នានេះ, ការស្ដាប់ចម្រៀង និងឧបករណ៍ភ្លេងចេញពីវិទ្យុ និងឧបករណ៍ផ្សេងៗទៀត, ការលេងគ្រាប់ឡុកឡាក់ និងអុក, ការទាក់ទងនឹងល្បែងស៊ីសង(ម៉ៃស៊ីរ) - ដែលជាការភ្នាល់ - ការបង្កើតរូបភាពនៃវត្ថុមានព្រលឹងពីក្នុងចំណោមមនុស្សនិងសត្វ ព្រមទាំងការយល់ស្របនឹងទង្វើនេះ។ ពិតណាស់ ទង្វើទាំងអស់នេះគឺស្ថិតក្នុងចំណោមទង្វើអាក្រក់ដែលអល់ឡោះទ្រង់បានហាមឃាត់ចំពោះខ្ញុំបម្រើរបស់ទ្រង់នៅគ្រប់ពេលវេលា និងទីកន្លែង។ ហេតុនេះ ចាំបាច់ដែលបណ្ដាអ្នកធ្វើហាជ្ជី និងអ្នកដែលរស់នៅក្នុងទឹកដីពៃតុលឡោះអាល់ហារ៉មត្រូវប្រុងប្រយ័ត្នចំពោះវាឱ្យបានច្រើនជាងអ្នកផ្សេង

ទៀត ពីព្រោះថាអំពើបាបកម្មនៅក្នុងទឹកដីដ៏សុខសាន្តមួយនេះ បាបរបស់វាកាន់តែធ្ងន់ធ្ងរ ហើយទណ្ឌកម្មរបស់វាក៏កាន់តែធំធេង។

អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលៈ

﴿...وَمَنْ يُرِدْ فِيهِ بِإِلْحَادٍ بِظُلْمٍ نُذِقْهُ مِنْ عَذَابٍ أَلِيمٍ ﴿٢٥﴾﴾

ហើយជនណាដែលមានបំណងងាករេ(ចេញពីសេចក្តីពិត)ដោយបំពាននៅទីនោះ យើងនឹងឲ្យរូបគេភ្លក្សនូវទណ្ឌកម្មដ៏សែនឈឺចាប់បំផុត។ [គម្ពីរគួរអាន ២២:២៥]، ប្រសិនបើអល់ឡោះជាម្ចាស់បានសន្យាព្រមានចំពោះអ្នកដែលគ្រាន់តែមានបំណងចង់ប្រព្រឹត្តអំពើបំពាននៅក្នុងដែនដីហារ៉ម នោះតើទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តវានោះនឹងទៅជាយ៉ាងណាទៅ?! គឺគ្មានការសង្ស័យឡើយថា វាពិតជារឹតតែធ្ងន់ធ្ងរ និងខ្លាំងក្លាជាងទៅទៀត។ ហេតុនេះ តម្រូវឲ្យមានការប្រុងប្រយ័ត្នចំពោះទង្វើបែបនោះ ក៏ដូចជារាល់អំពើល្មើសទាំងឡាយផងដែរ។

ហើយបណ្តាអ្នកធ្វើហាជ្ជីនឹងមិនទទួលបាននូវហាជ្ជីដែលគេទទួលយក និងការអភ័យទោសចំពោះបាបកម្មឡើយ លុះត្រាតែពួកគេប្រុងប្រយ័ត្នពីអំពើល្មើសទាំងនេះ

និងអំពើផ្សេងៗទៀតដែលអល់ឡោះបានហាមឃាត់ពួកគេ ដូចដែលណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ حَجَّ فَلَمْ يَرْفُثْ وَلَمْ يَفْسُقْ رَجَعَ كَيَوْمِ وَلَدَتْهُ أُمُّهُ».

"ជនណាដែលបានធ្វើធម្មយាត្រាហាជ្ជី ហើយគេមិនបានរួមមេត្រី(ជាមួយភរិយា) និងមិនបានល្មើសនឹងបទបញ្ញាផ្សេងៗរបស់អល់ឡោះជាម្ចាស់ទេនោះ គេនឹងវិលត្រឡប់មកវិញដូចជាថ្ងៃដែលគេប្រសូត្រពីផ្ទៃម្ដាយរបស់ខ្លួនដូច្នោះដែរ(ពោលគឺជ្រះស្អាតពីបាបកម្ម)"។[1]

ហើយអ្វីដែលជាអំពើគួរឱ្យស្អប់ខ្ពើមដែលធ្ងន់ធ្ងរ និងធំជាងនេះទៅទៀតនោះគឺ៖ ការទូអាសុំពីអ្នកស្លាប់ ការសុំជំនួយសង្គ្រោះពីពួកគេ ការស្បថចំពោះពួកគេ និងការសំឡះសត្វសម្រាប់ពួកគេ ដោយសង្ឃឹមថាពួកគេនឹងជួយអង្វរករជំនួសអ្នកដែលបួងសួងសុំពីពួកគេនៅចំពោះអល់ឡោះ ឬព្យាបាលអ្នកជំងឺរបស់គេឱ្យជាសះស្បើយ ឬធ្វើឱ្យអ្នកដែលបាត់ខ្លួនរបស់គេត្រលប់មកវិញ និងអ្វីៗផ្សេងទៀត។

ហើយនេះគឺជាប្រការនៃស្ហ៊ីរិកធំដែលអល់ឡោះបានហាមឃាត់ ហើយវាគឺជាសាសនារបស់ពួកអ្នកធ្វើស្ហ៊ីរិកនាសម័យ

---

1 រាយការណ៍ដោយ អាល់ពូខរី៖១៥២១, មូស្លីម៖១៣៥០

យ៉ាហ៊ុលីយ៉ះ។ ហើយពិតណាស់ អល់ឡោះជាម្ចាស់ទ្រង់បានបញ្ជូនបណ្ដារ៉សូល និងបានបញ្ចុះបណ្ដាគម្ពីរ ដើម្បីបដិសេធ និងហាមឃាត់នូវប្រការនេះ។

ដូច្នេះ ចាំបាច់លើបុគ្គលគ្រប់រូប ទាំងអ្នកដែលធ្វើហាជ្ជី និងអ្នកផ្សេងទៀត ត្រូវប្រុងប្រយ័ត្នចំពោះវា ហើយត្រូវសារភាពកំហុស(តាវហ្ពាត់)ចំពោះអល់ឡោះពីអ្វីដែលបានប្រព្រឹត្តកន្លងមក ប្រសិនបើធ្លាប់មាន ហើយត្រូវចាប់ផ្ដើមធ្វើហាជ្ជីជាថ្មី បន្ទាប់ពីបានសារភាពកំហុសពីអំពើនោះរួច។ ព្រោះថាស្ហ៊ីរិកធំ ធ្វើឲ្យរាល់ទង្វើទាំងអស់ក្លាយជាអសារបង់ ដូចដែលអល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

﴿...وَلَوْ أَشْرَكُوا لَحَبِطَ عَنْهُم مَّا كَانُوا يَعْمَلُونَ ﴿٨٨﴾﴾

តែប្រសិនបើពួកគេ(បណ្ដាព្យាការី)បានធ្វើស្ហ៊ីរិកវិញនោះ ទង្វើ(កុសល)ទាំងឡាយដែលពួកគេធ្លាប់បានសាងនឹងត្រូវចាត់ទុកជាអសារបង់ជាមិនខាន។

[គម្ពីរគួរអាន ៦:៨៨]

ក្នុងចំណោមប្រភេទនៃស្ហ៊ីរិកតូចគឺ៖ ការស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ ដូចជាការស្បថនឹងព្យាការី ﷺ, កាក់ហ្ពះ និងភាពទៀងត្រង់ជាដើម។

ហើយក្នុងចំណោមនោះរួមមាន៖ រីយ៉ាក់ និងស៊ុមអះ, និងការនិយាយថា៖ “អ្វីដែលអល់ឡោះ និងអ្នកមានចេតនា(វានឹងកើតឡើង)”, “ប្រសិនបើគ្មានអល់ឡោះ និងអ្នកទេនោះ” និង “នេះគឺមកពីអល់ឡោះ និងមកពីអ្នក”, ព្រមទាំងប្រការផ្សេងៗដែលស្រដៀងគ្នានេះ។

ហេតុនេះ ត្រូវតែប្រុងប្រយ័ត្នពីទង្វើអបាយមុខដែលជាអំពើស្ ីរិកទាំងនេះ និងផ្តាំផ្ញើគ្នាឲ្យបោះបង់វា ព្រោះណាពី ﷺ បានមានប្រសាសន៍ថា៖

«مَنْ حَلَفَ بِغَيْرِ اللهِ فَقَدْ كَفَرَ أَوْ أَشْرَكَ».

“ជនណាដែលបានស្បថនឹងអ្វីផ្សេងក្រៅពីអល់ឡោះ គេពិតជាក្លាយបានបោះបង់ជំនឿ (កាហ្វៀរ) ឬបានធ្វើស្ ីរិកហើយ”។[1] រាយការណ៍ដោយ អះម៉ាត់, អាពូទើវូទ និងអាត់តៀរមីហ្ស៊ី តាមខ្សែរាយការណ៍ដែលត្រឹមត្រូវ។

រីឯនៅក្នុងសេចក្តីរាយការណ៍ដែលត្រឹមត្រូវវិញ អ៊ូមើរ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ كَانَ حَالِفًا فَلْيَحْلِفْ بِاللهِ أَوْ لِيَصْمُتْ».

“ជនណាដែលស្បថ ចូរឲ្យគេស្បថនឹងអល់ឡោះ

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖៣២៥១

ឬនៅស្មៀម"[1]។ ហើយព្យាការី ﷺ ក៏បានមានប្រសាសន៍ថា៖

«مَنْ حَلَفَ بِالأَمَانَةِ فَلَيْسَ مِنَّا».

"បុគ្គលណាស្បថនឹងភាពទៀងត្រង់(អាម៉ាណះ) គឺមិនមែនជាក្រុមរបស់យើងឡើយ"[2]។ រាយការណ៍ដោយ អាពូហ្ទើវូទ។

លោកបានមានប្រសាសន៍ទៀតថា៖

«أَخْوَفُ مَا أَخَافُ عَلَيْكُمُ الشِّرْكُ الأَصْغَرُ، فَسُئِلَ عَنْهُ فَقَالَ: الرِّيَاءُ».

«អ្វីដែលខ្ញុំខ្លាចបំផុតចំពោះពួកអ្នកគឺស្ហ៊ីរិកតូច, ហើយនៅពេលលោកត្រូវបានគេសួរអំពីវា លោកបានឆ្លើយថា៖ គឺរីយ៉ាក»[3]

លោកបានមានប្រសាសន៍ទៀតថា៖

«لَا تَقُولُوا: مَا شَاءَ اللهُ وَشَاءَ فُلَانٌ، وَلَكِنْ قُولُوا مَا شَاءَ اللهُ ثُمَّ شَاءَ فُلَانٌ».

"ចូរពួកអ្នកកុំនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា និងបុគ្គលនោះមានចេតនា(វានឹងកើតឡើង)។ ក៏ប៉ុន្តែពួកអ្នកត្រូវនិយាយថា៖ អ្វីដែលអល់ឡោះមានចេតនា(វានឹងកើតឡើង)។ បន្ទាប់មក ទើបបុគ្គលនោះមានចេតនា"[4]។ ហើយ

---

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖៣២៥៣

2 រាយការណ៍ដោយ អាល់ពូខរី៖2679, មូស្លីម៖1646

3 រាយការណ៍ដោយអះម៉ាត់៖៥/៤២៨

4 រាយការណ៍ដោយ អាពូហ្ទាវូទ៖៤៩៨០

អានណាសាអុី បានរាយការណ៍អំពី អុីបនូអាប់ហ្ពាស رضي الله عنهما ថា មានបុរសម្នាក់បាននិយាយថា៖ ឱរ៉សូលលុលឡោះអើយ! អ្វីដែលអល់ឡោះមានចេតនា និងលោកមានចេតនា(វានឹងកើតឡើង)។ ពេលនោះ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«أَجَعَلْتَنِي لِلَّهِ نِدًّا، بَلْ مَا شَاءَ اللهُ وَحْدَهُ».

តើអ្នកបានចាត់ទុកខ្ញុំជាដៃគូប្រជែងនឹងអល់ឡោះឬ? ផ្ទុយទៅវិញ គឺអ្វីដែលអល់ឡោះតែមួយអង្គគត់បានកំណត់។[1]

បណ្ដាហាទីស្ទទាំងនេះបង្ហាញអំពីការថែរក្សាការពាររបស់ព្យាការី ﷺ ទៅលើគោលការណ៍តាវហ៊ីទ, ការព្រមានរបស់លោកចំពោះសហគមន៍របស់លោកពីអំពើស្ទីរិកធំនិងស្ទីរិកតូច, ព្រមទាំងការយកចិត្តទុកដាក់របស់លោកចំពោះភាពត្រឹមត្រូវនៃជំនឿរបស់ពួកគេ និងការសង្គ្រោះពួកគេឱ្យរួចផុតពីទារុណកម្មរបស់អល់ឡោះ និងមូលហេតុដែលនាំឱ្យទ្រង់ខ្ញាល់។ ដូចនេះ សូមអល់ឡោះទ្រង់តបស្នងដល់លោកនូវផលទានដ៏ល្អប្រសើរបំផុត។ ពិតណាស់ លោកបានផ្សព្វផ្សាយនិងបានព្រមានដាស់តឿន ហើយបានផ្ដល់ដំបូន្មានដោយស្មោះត្រង់ដើម្បីអល់ឡោះ និងដើម្បីខ្ញុំបម្រើទាំងឡាយរបស់ទ្រង់។

---

1 រាយការណ៍ដោយ អុីបនូ ម៉ាហ្ជះ៖២១១៧

សូមអល់ឡោះទ្រង់ប្រទានពរជ័យ
និងសេចក្តីសុខសន្តិភាពដល់លោកជានិច្ចនិរន្តរ៍រហូតដល់ថ្ងៃជំនុំជំរះ។
ហើយប្រការចាំបាច់លើអ្នកចេះដឹងក្នុងចំណោមអ្នកធ្វើធម្មយាត្រាហាជ្ជី
និងអ្នកដែលរស់នៅក្នុងទឹកដីដ៏សុខសាន្តរបស់អល់ឡោះ(ម៉ាក្កះ)
និងទីក្រុងនៃអ្នកនាំសារដ៏ឧត្តុង្គឧត្តមរបស់ទ្រង់ ﷺ (ម៉ាឌីណះ)
គឺត្រូវបង្រៀនមនុស្សលោកនូវអ្វីដែលអល់ឡោះបានបញ្ញត្តិសម្រាប់ពួកគេ
និងដាស់តឿនព្រមានពួកគេពីអ្វីដែលអល់ឡោះបានហាមឃាត់លើពួកគេ
ពីគ្រប់ទម្រង់នៃការធ្វើស្ហ៊ីរិក(ការធ្លុបធ្លងនឹងទ្រង់)
និងអំពើបាបផ្សេងៗ
ហើយត្រូវពន្យល់បកស្រាយរឿងនោះដោយភ្ជាប់ជាមួយភស្តុតាងរបស់វា និងបញ្ជាក់វាឲ្យបានច្បាស់លាស់
និងគ្រប់គ្រាន់
ដើម្បីឲ្យពួកគេអាចនាំមនុស្សលោកចេញពីភាពងងឹតសូន្យសុងទៅកាន់ពន្លឺ(នៃជំនឿ)
ហើយដើម្បីឲ្យពួកគេអាចបំពេញនូវអ្វីដែលអល់ឡោះបានតម្រូវឲ្យចាំបាច់លើពួកគេ អំពីការផ្សព្វផ្សាយ
និងការបកស្រាយបញ្ជាក់។
អល់ឡោះជាម្ចាស់ដ៏មហាបរិសុទ្ធបានមានបន្ទូលថា:

﴿وَإِذْ أَخَذَ اللَّهُ مِيثَاقَ الَّذِينَ أُوتُوا الْكِتَابَ لَتُبَيِّنُنَّهُ لِلنَّاسِ وَلَا تَكْتُمُونَهُ...﴾

ហើយចូរអ្នក(ឱព្យាការីមូហាំម៉ាត់)នឹកឃើញ នៅពេលដែលអល់ឡោះទ្រង់បានដាក់កិច្ចសន្យាដ៏មុឺងម៉ាត់ទៅលើពួកដែលគេផ្តល់គម្ពីរឲ្យថា ពួកអ្នកត្រូវតែបកស្រាយបំភ្លឺវា(គម្ពីររបស់អល់ឡោះ) ដល់មនុស្សលោក ហើយពួកអ្នកមិនត្រូវលាក់បាំងវានោះឡើយ... [គម្ពីរគួរអាន ៣:១៨៧]

គោលបំណងនៃចំណុចនេះគឺ៖ ដាស់តឿនព្រមានដល់បណ្តាអ្នកប្រាជ្ញនៅក្នុងសហគមន៍នេះ ពីការដើរតាមមាគ៌ារបស់ជនបំពានទាំងឡាយនៃពួកអះលិគីតាប(ពួកដែលគេផ្តល់គម្ពីរឲ្យ) ដែលពួកគេបានលាក់បាំងសេចក្តីពិត ដោយសារតែការផ្តល់អាទិភាពឲ្យផលប្រយោជន៍លោកិយ ជាងផលប្រយោជន៍នាថ្ងៃបរលោក។ ហើយទ្រង់ដ៏ខ្ពង់ខ្ពស់បានមានបន្ទូលថា:

﴿إِنَّ الَّذِينَ يَكْتُمُونَ مَا أَنْزَلْنَا مِنَ الْبَيِّنَاتِ وَالْهُدَى مِنْ بَعْدِ مَا بَيَّنَّاهُ لِلنَّاسِ فِي الْكِتَابِ أُولَٰئِكَ يَلْعَنُهُمُ اللَّهُ وَيَلْعَنُهُمُ اللَّاعِنُونَ ﴿١٥٩﴾ إِلَّا الَّذِينَ تَابُوا وَأَصْلَحُوا وَبَيَّنُوا فَأُولَٰئِكَ أَتُوبُ عَلَيْهِمْ وَأَنَا التَّوَّابُ الرَّحِيمُ ﴿١٦٠﴾﴾

ជាការពិតណាស់ ពួកដែលបានលាក់បាំងនូវអ្វីដែលយើងបានបញ្ចុះមកនៃសញ្ញាភស្តុតាង និងការចង្អុលបង្ហាញ

ក្រោយពីយើងបានបញ្ជាក់វា(ភាពជាព្យាការីរបស់មូហាំម៉ាត់)ដល់មនុស្សលោកនៅក្នុងគម្ពីរ(របស់ពួកគេ) ហើយនោះ
ពួកទាំងនោះហើយជាពួកដែលត្រូវបានអល់ឡោះដាក់បណ្ដាសា
និងបណ្ដាអ្នកដែលដាក់បណ្ដាសាទាំងឡាយ(ម៉ាឡាអ៊ីកាត់ ព្យាការី និងមនុស្សលោក)ក៏បានដាក់បណ្ដាសាពួកគេផងដែរ។

លើកលែងតែបណ្ដាអ្នកដែលបានសារភាពកំហុស ហើយបានកែលម្អ(ទង្វើរបស់ពួកគេ) ព្រមទាំងបានបញ្ជាក់(អំពីការលាក់បាំងរបស់ពួកគេ) ប៉ុណ្ណោះ។ ពិតណាស់ អ្នកទាំងនោះ គឺយើង(អល់ឡោះ)នឹងទទួលយកការសារភាពកំហុសរបស់ពួកគេ
ហើយយើងគឺជាអ្នកដែលទទួលយកការសារភាពកំហុស ជាអ្នកអាណិតស្រលាញ់បំផុត។ 160 [គម្ពីរគួរអាន ២:១៥៩-១៦០] ជាការពិតណាស់
បណ្ដាអាយ៉ាត់នៃគម្ពីរគួរអាន
និងបណ្ដាហាទីស្ហរបស់ព្យាការីបានបង្ហាញឲ្យដឹងថា ការអំពាវនាវទៅកាន់អល់ឡោះជាម្ចាស់
និងការណែនាំបណ្ដាខ្ញុំបម្រើរបស់ទ្រង់ទៅកាន់គោលបំណងដែលពួកគេត្រូវបានគេបង្កើតឡើង
គឺជាកិច្ចការដ៏ប្រសើរបំផុតមួយ
និងជាកាតព្វកិច្ចដ៏សំខាន់បំផុត

ហើយក៏ជាមាគ៌ារបស់បណ្ដាអ្នកនាំសារ និងអ្នកដែលដើរតាមពួកគេរហូតដល់ថ្ងៃបរលោកផងដែរ។ ដូចដែលព្រះ
អល់ឡោះជាម្ចាស់ទ្រង់បានមានបន្ទូលថា៖

﴿وَمَنْ أَحْسَنُ قَوْلًا مِمَّنْ دَعَا إِلَى اللَّهِ وَعَمِلَ صَالِحًا وَقَالَ إِنَّنِي مِنَ الْمُسْلِمِينَ ۝٣٣﴾

ហើយគ្មាននរណាម្នាក់ដែលមានពាក្យសម្ដីល្អប្រសើរជាងអ្នកដែលអំពាវនាវទៅកាន់អល់ឡោះ និងបានសាងទង្វើកុសល ព្រមទាំងបាននិយាយថា៖ ពិតប្រាកដណាស់ រូបខ្ញុំគឺស្ថិតក្នុងចំណោមអ្នកដែលប្រគល់ខ្លួន(ជាជនមូស្លីម)នោះឡើយ។ [គម្ពីរគួរអាន ៤១:៣៣]، ទ្រង់បានមានបន្ទូលទៀតថា៖

﴿قُلْ هَذِهِ سَبِيلِي أَدْعُو إِلَى اللَّهِ عَلَى بَصِيرَةٍ أَنَا وَمَنِ اتَّبَعَنِي وَسُبْحَانَ اللَّهِ وَمَا أَنَا مِنَ الْمُشْرِكِينَ ۝١٠٨﴾

ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ នេះគឺជាមាគ៌ារបស់ខ្ញុំដែលខ្ញុំកំពុងតែអំពាវនាវទៅកាន់អល់ឡោះ ដែល(មាគ៌ានេះ)ស្ថិតនៅលើភស្តុតាងយ៉ាងច្បាស់លាស់ដែលរូបខ្ញុំផ្ទាល់ ព្រមទាំងអ្នកដែលដើរតាមខ្ញុំ(ក៏អំពាវនាវទៅកាន់វា)ដែរ។ អល់ឡោះជាម្ចាស់មហាស្អាតស្អំ។ ហើយខ្ញុំមិនមែនស្ថិតក្នុងចំណោមពួកដែលធ្វើស្ហ៊ីរិកនោះឡើយ។ [គម្ពីរគួរអាន ១២:១០៨]

ហើយព្យាការី ﷺ ក៏បានមានប្រសាសន៍ថាៈ

«مَنْ دَلَّ عَلَى خَيْرٍ فَلَهُ مِثْلُ أَجْرِ فَاعِلِهِ».

“បុគ្គលណាដែលបានណែនាំទៅកាន់អំពើល្អ គឺរូបគេនឹងទទួលបានផលបុណ្យប្រៀបដូចនឹងអ្នកដែលប្រព្រឹត្តអំពើនោះដែរ”[1]

«لَأَنْ يَهْدِيَ اللهُ بِكَ رَجُلًا وَاحِدًا خَيْرٌ لَكَ مِنْ حُمْرِ النَّعَمِ».

“ការដែលអល់ឡោះចង្អុលបង្ហាញដល់មនុស្សម្នាក់តាមរយៈអ្នក គឺល្អប្រសើរសម្រាប់អ្នកជាងអូដ្ឋក្រហម”[2] ហើយវាក្យខណ្ឌគួរអាន និងសេចក្តីរាយការណ៍នៅក្នុងអត្ថន័យនេះគឺមានយ៉ាងច្រើន។

ដូច្នេះហើយ គឺពិតជាចាំបាច់សម្រាប់អ្នកចេះដឹង និងអ្នកមានជំនឿក្នុងការបង្កើនការខិតខំប្រឹងប្រែងរបស់ពួកគេឲ្យកាន់តែខ្លាំងក្លាឡើងក្នុងការអំពាវនាវទៅកាន់អល់ឡោះស៊ូបហានៈហ៊ូ, និងណែនាំបណ្តាខ្ញុំបម្រើ(របស់ទ្រង់)ទៅកាន់មធ្យោបាយនៃការព្យាររួចផុត(ពីការដាក់ទណ្ឌកម្ម), និងដាស់តឿនព្រមានពួកគេពីមូលហេតុនៃសេចក្តីវិនាសអន្តរាយ, ជាពិសេសនៅក្នុងសម័យកាលនេះ ដែលចំណង់តណ្ហាបានគ្របដណ្តប់

---

1 រាយការណ៍ដោយ មូស្លីមៈ១៨៩៣

2 រាយការណ៍ដោយ អាល់ពូខរីៈ៣០០៩, មូស្លីមៈ២៤០៦

ហើយគោលការណ៍ដែលបំផ្លិចបំផ្លាញ
និងពាក្យស្លោកដែលនាំឲ្យវង្វេងបានរីករាលដាល,
ហើយអ្នកដែលអំពាវនាវទៅកាន់ការចង្អុលបង្ហាញដ៏ត្រឹមត្រូវមានចំនួនតិចតួច
រីឯអ្នកដែលអំពាវនាវទៅកាន់ការមិនជឿលើអត្ថិភាពរបស់ព្រះជាម្ចាស់
និងភាពដែលចាត់ទុកគ្រប់យ៉ាងគឺអនុញ្ញាត(ដែលខុសនឹងបទបញ្ញត្តិសាសនា)
បានកើនឡើងយ៉ាងច្រើន។ ដូចនេះ
គឺអល់ឡោះតែមួយអង្គគត់ដែលជាទីសុំជំនួយ,
ហើយគ្មានអានុភាព និងគ្មានកម្លាំងអ្វីឡើយ
លើកលែងតែដោយ(ការអនុញ្ញាតពី)អល់ឡោះដ៏ខ្ពង់ខ្ពស់ មហាអស្ចារ្យបំផុត។

## ជំពូក
## ស្ដីពីការបន្ទន់សម្លេងអំពើល្អឱ្យបានច្រើន។

វាជាការគប្បីសម្រាប់បណ្ដាអ្នកដែលធ្វើហាជ្ជីឲ្យប្រកាន់ខ្ជាប់នូវការហ្សិកៀវចំពោះអល់ឡោះ
ការគោរពប្រតិបត្តិចំពោះទ្រង់
និងការសាងទង្វើកុសល ព្រមទាំងបង្កើនការសឡាត
និងការដើរតវ៉ាហ្វជុំវិញកាក់ហ្ពះឲ្យបានច្រើន
ក្នុងអំឡុងពេលដែលពួកគេស្នាក់នៅទីក្រុងម៉ាក្កះ
ព្រោះផលបុណ្យនៅក្នុងទឹកដីហារ៉មត្រូវបានគេបង្កើនទ្វេដង
ហើយអំពើបាបនៅក្នុងនោះក៏មានទម្ងន់ធ្ងន់ធ្ងរណា

ស់ដែរ។ ដូចគ្នានេះដែរ វាជាការគប្បីសម្រាប់ពួកគេក្នុងការបង្កើនការសូត្រសឡាវ៉ាត និងសឡាមទៅលើរ៉សូលរបស់អល់ឡោះ ﷺ។

នៅពេលដែលបណ្ដាអ្នកធ្វើហាជ្ជីមានបំណងចាកចេញពីក្រុងម៉ាក្កះ គឺតម្រូវឱ្យពួកគេធ្វើតវ៉ាហ្វលា ដើម្បីឱ្យវាជាសកម្មភាពចុងក្រោយរបស់ពួកគេនៅពៃតុលឡោះ លើកលែងចំពោះស្ត្រីដែលមានរដូវ និងស្ត្រីក្រោយពេលសម្រាលកូន គឺមិនត្រូវតវ៉ាហ្វលាលើពួកគេឡើយ ដោយផ្អែកលើហាទីស្ហរបស់ អ៊ិបនូ អាប់ហ្ពាស់ (សូមអល់ឡោះប្រទាននូវការពេញចិត្តលើគាត់ទាំងពីរ) បានមានប្រសាសន៍ថា៖

«أُمِرَ النَّاسُ أَنْ يَكُونَ آخِرُ عَهْدِهِمْ بِالبَيْتِ، إِلَّا أَنَّهُ خُفِّفَ عَنِ المَرْأَةِ الحَائِضِ».

«មនុស្សទាំងឡាយត្រូវបានបញ្ជាឱ្យធ្វើការតវ៉ាហ្វវីហ្ទើក (តវ៉ាហ្វចុងក្រោយ)របស់ពួកគេជុំវិញពៃតុលឡោះ លើកលែងតែស្ត្រីដែលមានរដូវ ដែលត្រូវបានបន្ធូរបន្ថយសម្រាប់នាង»[1]។

នៅពេលដែលគេបានបញ្ចប់ការលាផ្ទះកាក់បះ ហើយមានបំណងចាកចេញពីម៉ាស្ជិទ គេត្រូវដើរទៅមុខរហូតដល់ចេញផុត។

---

1 រាយការណ៍ដោយ អាល់ពូខរី៖១៧៥៥, មូស្លីម៖១៣២៨

គេមិនគួរដើរថយក្រោយឡើយ
ព្រោះរឿងនោះមិនមានការរាយការណ៍ពីព្យាការី(សូម
សុខសន្តិភាពមានដល់លោក)
ហើយក៏មិនមានពីសាវ័ករបស់លោកដែរ។ ផ្ទុយទៅវិញ
វាគឺជារឿងបង្កើតថ្មី(ប៊ីទ្អះ)ក្នុងសាសនា។
ហើយព្យាការី(សូមសុខសន្តិភាពមានដល់លោក)បាន
មានប្រសាសន៍ថា៖

«مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ».

"បុគ្គលណាដែលធ្វើទង្វើ(អាម៉ាល់)អ្វីមួយ
ដោយវាពុំមែនជាកិច្ចការដែលយើងបានប្រើទេនោះ
វានឹងត្រូវគេបដិសេធចោល"[1]។
លោកបានមានប្រសាសន៍ទៀតថា៖

«إِيَّاكُمْ وَمُحْدَثَاتِ الأُمُورِ، فَإِنَّ كُلَّ مُحْدَثَةٍ بِدْعَةٌ، وَكُلَّ بِدْعَةٍ ضَلاَلَةٌ».

“ចូរប្រុងប្រយ័ត្នចំពោះប្រការទាំងឡាយដែលគេបង្កើតថ្មី(នៅក្នុងសាសនា)
ព្រោះរាល់ប្រការដែលគេបង្កើតថ្មី គឺជាប្រការពិតអះ
ហើយរាល់ប្រការពិតអះទាំងអស់ គឺសុទ្ធតែវង្វេង”[2]។
យើងខ្ញុំសូមពីអល់ឡោះនូវជំហរនឹងនរនៅលើសាសនារបស់ទ្រង់
និងសុវត្ថិភាពពីអ្វីដែលផ្ទុយនឹងសាសនានោះ។

---

1 បានបញ្ជាក់ប្រភពរួចហើយ។

2 រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម ពី ហ្ជាពៀរ កូន អាប់ទុលឡោះ (សូមអល់ឡោះពេញចិត្តដល់គាត់) លេខ ៨៦៧

ពិតណាស់ ទ្រង់ជាម្ចាស់ដ៏សប្បុរស និងឧត្តមឧត្តមបំផុត។

## ជំពូក
## អំពីក្បួនច្បាប់ និងសុជីវធម៌នៃការទស្សនកិច្ច

ជាស៊ូណាត់ឲ្យទៅទស្សនកិច្ចម៉ាស្ជិតរបស់ណាពី ﷺ នៅមុន ឬក្រោយពេលធ្វើហាជ្ជី ដោយយោងទៅតាមអ្វីដែលបានបញ្ជាក់នៅក្នុងសហីទាំងពីរ អំពីអាពីហ៊ូរ៉ យរ៉ោះ រ៉ឌីយ៉ាល់ឡោះអាន់ហ៊ូ បាននិយាយថា៖ រ៉សូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖

«صَلَاةٌ فِي مَسْجِدِي هَذَا خَيْرٌ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ إِلَّا الْمَسْجِدَ الْحَرَامَ».

“សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះ(ម៉ាស្ជិតណាហ្គាវី)មួយដង គឺល្អជាងសឡាតនៅម៉ាស្ជិតដទៃចំនួនមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉ មប៉ុណ្ណោះ”។[1] អំពីអ៊ីបនូអ៊ូម៉ើរ رضي الله عنهما ពិតណាស់ ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«صَلَاةٌ فِي مَسْجِدِي هَذَا أَفْضَلُ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ إِلَّا الْمَسْجِدَ الْحَرَامَ».

“សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះមួយដង គឺល្អជាងសឡាតនៅក្នុងម៉ាស្ជិតផ្សេងមួយពាន់ដង

1 រាយការណ៍ដោយ អាល់ពូខរី៖១១៩០, មូស្លីម៖១៣៩៤

លើកលែងតែម៉ាស្ជិតអាល់ហារ៉មប៉ុណ្ណោះ”[1] [មូស្លីម] អំពី អាប់ទុលឡោះ កូន ហ្ស៊ូបៃរ៍ رضي الله عنه បាននិយាយថា៖ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«صَلَاةٌ فِي مَسْجِدِي هَذَا أَفْضَلُ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ إِلَّا المَسْجِدَ الحَرَامَ، وَصَلَاةٌ فِي المَسْجِدِ الحَرَامِ أَفْضَلُ مِنْ مِائَةِ صَلَاةٍ فِي مَسْجِدِي هَذَا».

“សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះមួយដង គឺល្អជាងសឡាតនៅម៉ាស្ជិតដទៃចំនួនមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉មប៉ុណ្ណោះ, ហើយសឡាតនៅក្នុងម៉ាស្ជិតអាល់ហារ៉មមួយដង គឺល្អប្រសើរជាងសឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះចំនួនមួយរយដង”។[2] រាយការណ៍ដោយ អះម៉ាត់, អ៊ិបនូឃូហ្សៃម៉ះ និង អ៊ិបនូហ៊ិបប្ហាន

អំពី ហ្ជាពៀរ رضي الله عنه ពិតណាស់ រ៉សូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«صَلَاةٌ فِي مَسْجِدِي هَذَا أَفْضَلُ مِنْ أَلْفِ صَلَاةٍ فِيمَا سِوَاهُ، إِلَّا المَسْجِدَ الحَرَامَ، وَصَلَاةٌ فِي المَسْجِدِ الحَرَامِ أَفْضَلُ مِنْ مِائَةِ أَلْفِ صَلَاةٍ فِيمَا سِوَاهُ».

“សឡាតនៅក្នុងម៉ាស្ជិតរបស់ខ្ញុំនេះមួយដង គឺល្អជាងសឡាតនៅម៉ាស្ជិតដទៃទៀតចំនួនមួយពាន់ដង លើកលែងតែម៉ាស្ជិតអាល់ហារ៉មប៉ុណ្ណោះ, ហើយសឡាតនៅក្នុងម៉ាស្ជិតអាល់ហារ៉មមួយដង

---

1 រាយការណ៍ដោយ មូស្លីម៖១៣៩៥

2 រាយការណ៍ដោយអះម៉ាត់៖៤/៥

គឺល្អជាងសឡាតនៅម៉ាស្ជិតដទៃទៀតចំនួនមួយរយពាន់ដង"។[1] រាយការណ៍ដោយ អះម៉ាត់ និងអ៊ីបនូម៉ាហ្ជះ។ ហើយបណ្ដាហាទីស្ហដែលមានខ្លឹមសារក្នុងន័យនេះគឺមានជាច្រើន។

នៅពេលដែលគេបានទៅដល់ម៉ាស្ជិត ស៊ូណាត់ឲ្យគេឈានជើងស្ដាំចូលមុន ហើយសូត្រថា៖

بِسْمِ اللهِ، وَالصَّلَاةُ وَالسَّلَامُ عَلَى رَسُولِ اللهِ، أَعُوذُ بِاللهِ الْعَظِيمِ وَبِوَجْهِهِ الْكَرِيمِ وَسُلْطَانِهِ الْقَدِيمِ مِنَ الشَّيْطَانِ الرَّجِيمِ، اللَّهُمَّ افْتَحْ لِي أَبْوَابَ رَحْمَتِكَ

គេត្រូវសូត្រទូអាដូចគ្នានឹងពេលចូលម៉ាស្ជិតដទៃទៀតដែរ ហើយគ្មានហ្ស៊ិកៀរជាពិសេសសម្រាប់ការចូលម៉ាស្ជិតរបស់លោក ﷺ ឡើយ។ បន្ទាប់មក គេត្រូវសឡាតពីររ៉ក្អាត់ ហើយសុំទូអាពីអល់ឡោះនៅក្នុងសឡាតនោះនូវអ្វីដែលគេចង់បានពីភាពល្អប្រសើរនៃលោកិយ និងបរលោក។ ហើយប្រសិនបើគេសឡាតនៅក្នុងរ៉ាវហ្ទោះ នោះគឺប្រសើរជាង ព្រោះលោក ﷺ បានមានប្រសាសន៍ថា ៖

«مَا بَيْنَ بَيْتِي وَمِنْبَرِي رَوْضَةٌ مِنْ رِيَاضِ الْجَنَّةِ».

1 រាយការណ៍ដោយ អ៊ីបនូ ម៉ាយ៉ះ៖១៤០៦

(កន្លែងមួយដែលនៅចន្លោះមីមពើរនិងផ្ទះរបស់ខ្ញុំគឺជាសួនឧទ្យានមួយនៃសួនឧទ្យានឋានសួគ៌)[1]។

ក្រោយមក បន្ទាប់ពីសឡាតរួច គេត្រូវទៅទស្សនកិច្ចផ្នូរណាពី ﷺ និងផ្នូររបស់សហាហ្ពាត់ទាំងពីរៈ គឺអាពូហ្ពាកើរ និងអ៊ូមើរ សូមអល់ឡោះពេញចិត្តដល់គាត់ទាំងពីរ។ គេត្រូវឈរនៅទិសខាងមុខផ្នូរណាពី ﷺ ប្រកបដោយសុជីវធម៌ និងមិនត្រូវតម្លើងសំឡេងឡើយ រួចត្រូវឱ្យសាឡាមទៅចំពោះលោក ﷺ ដោយពោលថាៈ "السَّلَامُ عَلَيْكَ يَا رَسُول اللهِ وَرَحْمَةُ اللهِ وَبَرَكَاتُهُ" យោងតាមអ្វីដែលមាននៅក្នុងសៀវភៅស៊ូណាន់របស់អាពី ហ្ទើវូដ ជាមួយនឹងបណ្តាញរាយការណ៍ល្អ (ហាសាន់) ដែលរាយការណ៍ពីអាពូហ៊ូរ៉យរ៉ោះ សូមអល់ឡោះពេញចិត្តដល់គាត់ គាត់បានមានប្រសាសន៍ថា ព្យាការី ﷺ បានមានប្រសាសន៍ថាៈ

«مَا مِنْ أَحَدٍ يُسَلِّمُ عَلَيَّ إِلَّا رَدَّ اللهُ عَلَيَّ رُوحِي حَتَّى أَرُدَّ عَلَيْهِ السَّلَامَ».

“ជនណាម្នាក់ដែលបានឲ្យសាឡាមមកកាន់ខ្ញុំ អល់ឡោះជាម្ចាស់នឹងបង្វិលព្រលឹងរបស់ខ្ញុំមកកាន់ខ្ញុំវិញដើម្បីឲ្យខ្ញុំតបសាឡាមចំពោះគេ”។[2]។

ហើយបើសិនជាអ្នកទៅទស្សនកិច្ចពោលនៅក្នុងការ

---

1 រាយការណ៍ដោយ អាល់ពូខរីៈ១១៩៥, មូស្លីមៈ១៣៩០

2 រាយការណ៍ដោយ អាពូហ្ទើវូទៈ២០៤១

ឱ្យសាឡាមរបស់គេថា៖

السَّلَامُ عَلَيْكَ يَا نَبِيَّ اللَّهِ، السَّلَامُ عَلَيْكَ يَا خِيَرَةَ اللَّهِ مِنْ خَلْقِهِ، السَّلَامُ عَلَيْكَ يَا سَيِّدَ الْمُرْسَلِينَ وَإِمَامَ الْمُتَّقِينَ، أَشْهَدُ أَنَّكَ قَدْ بَلَّغْتَ الرِّسَالَةَ، وَأَدَّيْتَ الْأَمَانَةَ، وَنَصَحْتَ الْأُمَّةَ، وَجَاهَدْتَ فِي اللَّهِ حَقَّ جِهَادِهِ

គឺគ្មានបញ្ហាឡើយ, ពីព្រោះថា ទាំងអស់នេះគឺជាលក្ខណៈសម្បត្តិរបស់លោក ﷺ, ហើយគេត្រូវសឡាវ៉ាតលើលោក ﷺ និងបួងសួងឱ្យលោក, ដោយយោងទៅតាមអ្វីដែលត្រូវបានបញ្ញត្តិនៅក្នុងច្បាប់ឥស្លាម អំពីការអនុញ្ញាតឲ្យមានការរួមបញ្ចូលគ្នារវាងការសឡាវ៉ាត និងការឱ្យសាឡាមទៅលើលោក, ដោយអនុវត្តតាមព្រះបន្ទូលរបស់ទ្រង់ដ៏ខ្ពង់ខ្ពស់៖

﴿إِنَّ اللَّهَ وَمَلَائِكَتَهُ يُصَلُّونَ عَلَى النَّبِيِّ يَا أَيُّهَا الَّذِينَ آمَنُوا صَلُّوا عَلَيْهِ وَسَلِّمُوا تَسْلِيمًا ٥٦﴾

ពិតប្រាកដណាស់ អល់ឡោះជាម្ចាស់ និងម៉ាឡាអ៊ីកាត់ទាំងឡាយរបស់ទ្រង់សឡាវ៉ាតលើព្យាការី(មូហាំម៉ាត់)។ ឱបណ្ដាអ្នកដែលមានជំនឿ! ចូរពួកអ្នកសឡាវ៉ាត និងឲ្យសាឡាមទៅលើគាត់ចុះ។ [គម្ពីរគួរអាន ៣៣:៥៦] បន្ទាប់មកត្រូវឲ្យសាឡាមទៅកាន់អាពូហ្គាកើរ និងអូមើរ សូមអល់ឡោះពេញចិត្តដល់គាត់ទាំងពីរហើយសុំឌូអា និងសុំការពេញចិត្តចំពោះលោកទាំងពីរ។

អ៊ីបនូ អ៊ូមើរ

សូមអល់ឡោះពេញចិត្តដល់គាត់ទាំងពីរ នៅពេលដែលគាត់ឲ្យសាឡាមទៅកាន់ណាពី ﷺ និងសហាហ្ពាត់ទាំងពីរ (គឺអាពូហ្គាកើរ និងអ៊ូមើរ)៖ គឺគាត់មិនដែលពោលពាក្យលើសពីពាក្យថា៖ "សូមសេចក្ដីសុខកើតមានដល់លោក ឱអ្នកនាំសាររបស់អល់ឡោះ, សូមសេចក្ដីសុខកើតមានដល់លោក ឱអាពូហ្គាកើត, សូមសេចក្ដីសុខកើតមានដល់លោក ឱឪពុករបស់ខ្ញុំ" បន្ទាប់មក គេក៏ចាកចេញទៅ។

ហើយការទស្សនកិច្ចនេះ គឺអនុញ្ញាតសម្រាប់តែបុរសប៉ុណ្ណោះ ចំណែកឯស្រ្តីវិញ គឺមិនអនុញ្ញាតឱ្យពួកនាងទៅទស្សនកិច្ចផ្នូរណាមួយឡើយ ដូចដែលមានការបញ្ជាក់ពីណាពី ﷺ ថា

«لَعَنَ زُوَّارَاتِ الْقُبُورِ مِنَ النِّسَاءِ وَالْمُتَّخِذِينَ عَلَيْهَا الْمَسَاجِدَ وَالسُّرُجَ».

“ទ្រង់បានដាក់បណ្ដាសាចំពោះបណ្ដាស្រ្តីដែលឧស្សាហ៍ទៅសួរសុខទុក្ខផ្នូរ និងអ្នកទាំងឡាយដែលយកផ្នូរធ្វើជាម៉ាស្ជិត និងដុតចង្កៀងនៅលើវា”។[1]

ចំណែកឯគោលបំណងទៅកាន់ទីក្រុងម៉ាឌីណះ ដើម្បីប្រតិបត្តិសឡាតនៅក្នុងម៉ាស្ជិតរបស់រ៉សូល ﷺ និងបួងសួងនៅទីនោះ ព្រមទាំងទង្វើផ្សេងៗទៀតដែលត្រូវបានដាក់បញ្ញត្តិ

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖៣២៣៦

ឲ្យធ្វើនៅតាមបណ្តាម៉ាស្ជិតដទៃទៀត គឺវាត្រូវបានដាក់បញ្ញត្តិសម្រាប់មនុស្សគ្រប់រូប ដោយយោងតាមបណ្តាហាទីស្ទដែលបានរៀបរាប់រួចមកហើយអំពីរឿងនេះ។

ស៊ូណាត់ឲ្យអ្នកទស្សនកិច្ចធ្វើសឡាតប្រាំពេលនៅក្នុងម៉ាស្ជិតរបស់រ៉ស៊ូល ﷺ ព្រមទាំងឧស្សាហ៍ធ្វើការហ្ស៊ីកៀរបួងសួងសុំទូអា និងសឡាតស៊ូណាត់នៅក្នុងនោះដើម្បីឆ្លៀតយកនូវផលបុណ្យដ៏ធំធេង។

ប្រការស៊ូណាត់ត្រូវសឡាតស៊ូណិតឱ្យបានច្រើននៅក្នុងរ៉ាវហ្ទោះដ៏ពិសិដ្ឋ ដោយយោងតាមអ្វីដែលបានរៀបរាប់រួចមកហើយនៅក្នុងហាទីសសហោះអំពីឧត្តមភាពរបស់វា ដែលជាប្រសាសន៍របស់ណាពី ﷺ ៖

«مَا بَيْنَ بَيْتِي وَمِنْبَرِي رَوْضَةٌ مِنْ رِيَاضِ الجَنَّةِ».

«កន្លែងមួយដែលនៅចន្លោះមីមពើរនិងផ្ទះរបស់ខ្ញុំគឺជាសួនឧទ្យានមួយនៃសួនឧទ្យានឋានសួគ៌»[1]។

រីឯការសឡាតហ្វើរឌូវិញ គប្បីសម្រាប់អ្នកមកទស្សនកិច្ច និងអ្នកដទៃទៀតត្រូវរួសរាន់ទៅខាងមុខ ហើយរក្សាជួរទីមួយតាមលទ្ធភាពដែលអាចធ្វើទៅបាន

1 ប្រភពរបស់វាត្រូវបានបញ្ជាក់រួចមកហើយ។

ទោះបីជានៅត្រង់កន្លែងពង្រីកបន្ថែមខាងមុខក៏ដោយ
ដោយសារតែមានហាទីស្ហសហើសជាច្រើនពីព្យាការី ﷺ បានជំរុញ និងលើកទឹកចិត្តអំពីជួរទីមួយ ដូចជាពាក្យសម្តីរបស់លោក ﷺ ៖

«لَوْ يَعْلَمُ النَّاسُ مَا فِي النِّدَاءِ وَالصَّفِّ الأَوَّلِ ثُمَّ لَمْ يَجِدُوا إِلَّا أَنْ يَسْتَهِمُوا عَلَيْهِ لَاسْتَهَمُوا».

"ប្រសិនបើមនុស្សបានដឹងនូវអ្វីដែលមាននៅក្នុងការអាហ្សាននិងការសឡាតនៅជួរទីមួយ ក្រោយមកពួកគេគ្មានមធ្យោបាយអ្វីដើម្បីធ្វើដូច្នោះក្រៅតែពីការចាប់ឆ្នោត នោះពួកគេនឹងធ្វើការចាប់ឆ្នោតជាមិនខាន"។[1]
រាយការណ៍ដោយអ៊ីម៉ាំ ពូខរី និងមូស្លីម , និងដូចជាប្រសាសន៍របស់ណាពី ﷺ ទៅកាន់សហាហ្គាត់របស់លោកថា៖

«تَقَدَّمُوا فَأْتَمُّوا بِي وَلْيَأْتَمَّ بِكُمْ مَنْ بَعْدَكُمْ، وَلَا يَزَالُ الرَّجُلُ يَتَأَخَّرُ عَنِ الصَّلَاةِ حَتَّى يُؤَخِّرَهُ اللهُ».

"ចូរអ្នករាល់គ្នាឈានមកខាងមុខ រួចធ្វើការថ្វាយបង្គំតាមខ្ញុំ (យកខ្ញុំជាអ៊ីម៉ាំ)ហើយចូរឱ្យអ្នកដែលនៅពីក្រោយអ្នក

1 រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម តាមរយៈ អាពី សៃអ៊ីត អាល់ឃុទ្រី (សូមអល់ឡោះស្ទប់ស្ទល់ចំពោះគាត់) លេខ ៤៣៨

រាល់គ្នា ធ្វើការថ្វាយបង្គំតាមអ្នករាល់គ្នា (មើលតាមជួរមុខ) ហើយចូរឱ្យអ្នកដែលនៅពីក្រោយអ្នករាល់គ្នា ធ្វើការថ្វាយបង្គំតាមអ្នករាល់គ្នា (មើលតាមជួរមុខ)រហូតទាល់តែអល់ឡោះនឹងធ្វើឱ្យគេយឺតយ៉ាវ (ក្នុងរឿងល្អៗ ឬយឺតយ៉ាវក្នុងការចូលឋានសួគ៌) ដែរ។ ”[1] រាយការណ៍ដោយ មូស្លីម

អាពូ ហ៊ើរ៉ូដ បានរាយការណ៍អំពី អាអ៊ីស្ហះ رضي الله عنها ជាមួយនឹងសាណាត់ហាសាន់ ថា ណាពី ﷺ លោកបានមានប្រសាសន៍ថា៖

«لَا يَزَالُ الرَّجُلُ يَتَأَخَّرُ عَنِ الصَّفِّ المُقَدَّمِ حَتَّى يُؤَخِّرَهُ اللهُ فِي النَّارِ».

“បុរសម្នាក់នៅតែយឺតយ៉ាវពីជួរទីមួយ រហូតដល់អល់ឡោះពន្យាររូបគេក្នុងភ្លើងនរក។”[2] ហើយមានការបញ្ជាក់យ៉ាងត្រឹមត្រូវពីណាពី ﷺ ថា លោកបានមានប្រសាសន៍ទៅកាន់សហាហ្ពាត់របស់លោកថា៖

«أَلَا تَصُفُّونَ كَمَا تَصُفُّ المَلَائِكَةُ عِنْدَ رَبِّهَا؟ قَالُوا: يَا رَسُولَ اللهِ، وَكَيْفَ تَصُفُّ المَلَائِكَةُ عِنْدَ رَبِّهَا؟ قَالَ: يُتِمُّونَ الصُّفُوفَ الأُوَلَ، وَيَتَرَاصُّونَ فِي الصَّفِّ».

«តើពួកអ្នកមិនតម្រៀបជួរដូចដែលបណ្តាម៉ាឡាអ៊ីកា

1 រាយការណ៍ដោយ អាល់ពូខរី៖៦១៥, មូស្លីម៖៤៣៧

2 រាយការណ៍ដោយ មូស្លីម តាមរយៈ ហ្ជាពៀរ កូន សាមូ៉រ៉ោះ៖៤៣០

ត់តម្រៀបជួរនៅជិតម្ចាស់របស់ពួកគេទេឬ?»
ពួកគេបានពោលថា: «ឱអ្នកនាំសាររបស់អល់ឡោះ! ហើយតើបណ្ដាម៉ាឡាអ៊ីកាត់តម្រៀបជួរនៅជិតម្ចាស់របស់ពួកគេយ៉ាងដូចម្ដេចទៅ?»
លោកបានមានប្រសាសន៍ថា: «ពួកគេបំពេញជួរដំបូងៗឲ្យពេញ ហើយពួកគេឈរតម្រៀបគ្នាស្អិតរមួតនៅក្នុងជួរ»។[1] [មូស្លីម]

បណ្ដាហាទីស្ទដែលមានអត្ថន័យនេះមានជាច្រើន ហើយវាគ្របដណ្ដប់ទាំងទៅលើម៉ាស្ជិទរបស់លោក ﷺ និងម៉ាស្ជិទផ្សេងៗទៀត ទាំងមុន និងក្រោយពេលពង្រីក។ ហើយមានភស្តុតាងត្រឹមត្រូវពីណាពី ﷺ ថា លោកធ្លាប់បានជំរុញបណ្ដាសហាហ្ពាត់របស់លោកឲ្យឈរនៅផ្នែកខាងស្ដាំនៃជួរសឡាត។ ហើយជាការពិតដែលគេដឹងថា ផ្នែកខាងស្ដាំនៃជួរនៅក្នុងម៉ាស្ជិទដំបូងរបស់លោកគឺនៅក្រៅរ៉ៅហ្ទោះ។ ដូចនេះ គេបានដឹងតាមរយៈភស្តុតាងនេះថា ការយកចិត្តទុកដាក់ទៅលើបណ្ដាជួរខាងមុខ និងផ្នែកខាងស្ដាំនៃជួរ

---

1 រាយការណ៍ដោយ អាពូហ្ទើវូទ:៦៧៩ ដែលមានខ្លឹមសារថា: «មនុស្សមួយក្រុមនឹងនៅតែយឺតយ៉ាវពីជួរទីមួយ រហូតដល់អល់ឡោះនឹងធ្វើឱ្យពួកគេយឺតយ៉ាវ ហើយដាក់ពួកគេក្នុងភ្លើងនរក»។

គឺមានអាទិភាពជាងការយកចិត្តទុកដាក់ទៅលើរ៉ៅហ្មោះដ៏មានកិត្តិយស
ហើយថាការថែរក្សាវាទាំងពីរគឺប្រសើរជាងការថែរក្សាការសឡាតនៅក្នុងរ៉ៅហ្មោះ។ ហើយបញ្ហានេះគឺពិតជាច្បាស់លាស់ណាស់សម្រាប់អ្នកដែលបានពិចារណានូវបណ្ដាហាឌីសដែលបានរៀបរាប់នៅក្នុងបញ្ហានេះ។
ហើយអល់ឡោះជាម្ចាស់ជាអ្នកប្រទាននូវភាពជោគជ័យ។

ហើយមិនត្រូវបានអនុញ្ញាតសម្រាប់នរណាម្នាក់ឱ្យធ្វើការស្ទាបប៉ះផ្នូរណាពី ឬថើបវា ឬដើរតវ៉ាហ្វជុំវិញវានោះឡើយ
ព្រោះរឿងនោះមិនមានថែងពីក្រុមសាឡាហ្វជំនាន់មុនឡើយ ផ្ទុយទៅវិញ
វាគឺជាប្រការបង្កើតថ្មីក្នុងសាសនាដ៏គួរឱ្យស្អប់ខ្ពើម។

ហើយមិនត្រូវបានអនុញ្ញាតសម្រាប់នរណាម្នាក់ក្នុងការទូអាសុំទៅកាន់ណាពី ﷺ
ដើម្បីជួយបំពេញតម្រូវការ ឬបំបាត់ទុក្ខកង្វល់ ឬឱ្យបានជាសះស្បើយពីជំងឺ
និងផ្សេងៗទៀតនោះឡើយ ព្រោះការសុំទាំងអស់នោះគឺត្រូវសុំពីអល់ឡោះតែមួយគត់។
ហើយការសុំពីអ្នកដែលបានស្លាប់
គឺជាប្រការស្ហ៊ីរិកចំពោះអល់ឡោះ
និងជាការគោរពសក្ការៈ(អ៊ីហ្ពាហ្ទាត់)ចំពោះអ្នកផ្សេងក្រៅពីទ្រង់

ហើយសាសនាឥស្លាមគឺត្រូវបានកសាងឡើងនៅលើគោលការណ៍គ្រឹះចំនួនពីរ៖

ទីមួយ៖ មិនត្រូវគោរពសក្ការៈចំពោះអ្វីផ្សេងក្រៅពីអល់ឡោះតែមួយគត់ឡើយ។

ទីពីរ៖ ត្រូវគោរពសក្ការៈស្របទៅតាមច្បាប់បញ្ញត្តិរបស់រ៉សូលរបស់ទ្រង់។

នេះហើយជាអត្ថន័យនៃពាក្យសក្ខីកម្មថា គ្មានទេម្ចាស់ដែលត្រូវគោរពសក្ការៈដ៏ពិតប្រាកដ លើកលែងតែអល់ឡោះតែមួយគត់ ហើយព្យាការីមូហាំម៉ាត់ គឺជាអ្នកនាំសាររបស់អល់ឡោះ។

យ៉ាងដូច្នេះដែរ មិនត្រូវបានអនុញ្ញាតឲ្យនរណាម្នាក់សុំការជួយអន្តរាគមន៍ពីណាពី ﷺ ឡើយ ព្រោះវាគឺជាកម្មសិទ្ធិរបស់អល់ឡោះជាម្ចាស់ ហេតុនេះត្រូវតែសុំពីទ្រង់តែមួយគត់ ដូចដែលទ្រង់មានបន្ទូលថា:

﴿قُلْ لِلَّهِ الشَّفَاعَةُ جَمِيعًا...﴾

ចូរអ្នក(ឱអ្នកនាំសារមូហាំម៉ាត់)ពោលថា៖ ការជួយអន្តរាគមន៍ទាំងអស់ គឺជាកម្មសិទ្ធិរបស់អល់ឡោះ(តែមួយគត់)... [គម្ពីរគួរអាន ៣៩:៤៤] ដូចនេះ អ្នកត្រូវបួងសួងថា: “ឱអល់ឡោះ!

សូមទ្រង់ទទួលយកការជួយអន្តរាគមន៍របស់ព្យាការី ទ្រង់ចំពោះរូបខ្ញុំ ឱអល់ឡោះ! សូមទ្រង់ទទួលយកការជួយអន្តរាគមន៍របស់ម៉ាឡាអ៊ីកាត់របស់ទ្រង់ និងបាវបម្រើរបស់ទ្រង់ជាអ្នកមានជំនឿ ឱអល់ឡោះ! សូមទ្រង់ទទួលយកការជួយអន្តរាគមន៍ពីកូនៗដែលបានស្លាប់មុនរបស់ខ្ញុំ” និងការបួងសួងប្រហាក់ប្រហែលគ្នានេះជាដើម។ ចំណែកឯអ្នកដែលបានស្លាប់ទៅហើយ គឺគេមិនត្រូវសុំអ្វីពីពួកគេនោះឡើយ មិនថាជាការជួយអន្តរាគមន៍ ឬប្រការផ្សេងទៀតក៏ដោយ ទោះបីជាពួកគេជាព្យាការី ឬមិនមែនជាព្យាការីក៏ដោយ ព្រោះថាប្រការនោះ គឺមិនត្រូវបានបញ្ញត្តិឡើងនៅក្នុងសាសនានោះឡើយ ហើយព្រោះតែអ្នកដែលស្លាប់ទៅហើយ គឺទង្វើរបស់គេត្រូវបានកាត់ផ្តាច់ លើកលែងតែអ្វីដែលអ្នកបញ្ញត្តិ(អល់ឡោះ)បានលើកលែងឲ្យប៉ុណ្ណោះ។

នៅក្នុងសហ៊ីសមូស្លីម, អំពី អាពូហ៊ូរ៉យរ៉ោះ رضي الله عنه បាននិយាយថាៈ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថាៈ

«إِذَا مَاتَ ابْنُ آدَمَ انْقَطَعَ عَمَلُهُ إِلَّا مِنْ ثَلَاثٍ: صَدَقَةٍ جَارِيَةٍ، أَوْ عِلْمٍ يُنْتَفَعُ بِهِ، أَوْ وَلَدٍ صَالِحٍ يَدْعُو لَهُ».

“នៅពេលដែលកូនចៅអាដាំ (មនុស្ស) ស្លាប់បាត់បង់ជីវិតទៅ រាល់សកម្មភាព (បុណ្យកុសល) របស់គេត្រូវបានកាត់ផ្តាច់ លើកលែងតែពីប្រភពបីយ៉ាងប៉ុណ្ណោះ (ដែលបុណ្យនៅតែបន្តហូរទៅរកគេ) ការធ្វើទានដែលនៅបន្តផ្តល់ផលប្រយោជន៍ (សទើកោះ ជារីយ៉ះ) ឬចំណេះដឹងដែលត្រូវបានគេយកទៅប្រើប្រាស់ជាប្រយោជន៍ឬកូនចៅដ៏ល្អត្រឹមត្រូវ ដែលតែងតែបួងសួង (ទូអា) ឱ្យរូបគេ៖”[1]។

ការដែលគេអនុញ្ញាតឲ្យសុំការអន្តរាគមន៍ពីណាពី ﷺ នៅក្នុងជីវិតរបស់លោក និងនៅថ្ងៃបរលោក គឺដោយសារតែលោកមានសមត្ថភាពធ្វើបែបនេះបាន ព្រោះថាលោកអាចឈានទៅមុខហើយសុំពីម្ចាស់របស់លោកឲ្យអ្នកដែលសុំ។ ចំណែកឯ(ការសុំបែបនេះ)នៅក្នុងលោកិយវិញ គឺជារឿងដែលគេដឹងហើយ។ ហើយរឿងនេះមិនមែនជាការពិសេសសម្រាប់តែលោកម្នាក់ឯងនោះទេ ផ្ទុយទៅវិញ វាគឺជារឿងទូទៅសម្រាប់លោក និងអ្នកដទៃទៀត។ ហេតុនេះ

---

1 រាយការណ៍ដោយ អ៊ីម៉ាំ មូស្លីម ពី អ៊ាប៊ូហ៊ូរ៉យរ៉ោះ សូមអល់ឡោះពេញចិត្តដល់គាត់ លេខ ១៦៣១

គឺអនុញ្ញាតឲ្យអ្នកមូស្លិមនិយាយទៅកាន់បងប្អូនរបស់គាត់ថា «សូមជួយអន្តរាគមន៍ឲ្យខ្ញុំផងទៅកាន់ម្ចាស់របស់ខ្ញុំក្នុងរឿងនេះ ឬរឿងនោះ» ដែលមានន័យថា «សូមបួងសួងសុំពីអល់ឡោះឲ្យខ្ញុំផង»។ ហើយក៏អនុញ្ញាតឲ្យអ្នកដែលត្រូវបានគេសុំនោះ សុំពីអល់ឡោះ និងជួយអន្តរាគមន៍ឲ្យបងប្អូនរបស់គាត់ ប្រសិនបើអ្វីដែលគេសុំនោះ គឺជាប្រការដែលអល់ឡោះបានអនុញ្ញាតឲ្យសុំ។

ចំណែកឯនៅថ្ងៃបរលោកវិញ គឺគ្មាននរណាម្នាក់អាចជួយអន្តរាគមន៍បានឡើយ លើកលែងតែបន្ទាប់ពីមានការអនុញ្ញាតពីអល់ឡោះប៉ុណ្ណោះ៖ ដូចដែលទ្រង់បានមានបន្ទូលថា:

﴿...مَنْ ذَا الَّذِى يَشْفَعُ عِنْدَهُ إِلَّا بِإِذْنِهِ...﴾

គ្មានបុគ្គលណាម្នាក់ហ៊ានធ្វើអន្តរាគមន៍នៅចំពោះមុខទ្រង់ឡើយ លើកលែងតែដោយមានការអនុញ្ញាតពីទ្រង់ប៉ុណ្ណោះ។ [អាល់បាការ៉ោះ:២៥៥]

ចំណែកឯស្ថានភាពនៃការស្លាប់វិញ គឺវាជាស្ថានភាពពិសេសមួយដែលមិនត្រូវបានអនុញ្ញាតឲ្យប្រដូចវាទៅនឹងស្ថានភាពរបស់មនុស្សមុនពេលស្លាប់

ហើយក៏មិនត្រូវប្រដូចទៅនឹងស្ថានភាពរបស់គេបន្ទាប់ពីការរស់ឡើងវិញដែរ
ព្រោះថាទង្វើកុសលរបស់អ្នកដែលបានស្លាប់ត្រូវបានកាត់ផ្តាច់
ហើយរូបគេត្រូវបានជាប់ទាក់ទងនឹងអ្វីដែលគេបានសាង
លើកលែងតែអ្វីដែលអ្នកដាក់បញ្ញត្តិ(អល់ឡោះ)បានលើកលែងឲ្យប៉ុណ្ណោះ។
ហើយការសុំការសន្តោសប្រោស(ស្ហាហ្វាអាត)ពីអ្នកដែលបានស្លាប់
មិនមែនជាអ្វីដែលអ្នកដាក់បញ្ញត្តិ(អល់ឡោះ)បានលើកលែងឲ្យនោះឡើយ។ ដូចនេះ វាមិនត្រូវបានអនុញ្ញាតឲ្យបញ្ចូលវាទៅក្នុងរឿងនោះឡើយ។ គ្មានការសង្ស័យឡើយថា ណាពី ﷺ បន្ទាប់ពីលោកបានទទួលមរណភាព
គឺលោកមានជីវិតក្នុងផ្នូរដ៏ពេញលេញជាងជីវិតរបស់បណ្តាអ្នកស្លាប់ក្នុងសមរភូមិសាសនា(ស្ហាហ៊ីត)ទៅទៀត
ប៉ុន្តែវាមិនមែនជាប្រភេទជីវិតដូចជីវិតរបស់លោកមុនពេលស្លាប់
ហើយក៏មិនមែនជាប្រភេទជីវិតដូចជីវិតរបស់លោកនៅថ្ងៃបរលោកដែរ។ ផ្ទុយទៅវិញ វាគឺជាជីវិតដែលគ្មាននរណាម្នាក់ដឹងពីធាតុពិត និងលក្ខណៈរបស់វាឡើយ
លើកលែងតែអល់ឡោះតែមួយគត់។

ដោយហេតុនេះហើយ ទើបមានការរៀបរាប់នៅក្នុងហាទីស្ហនូវប្រសាសន៍របស់លោក ﷺ ថា៖

«مَا مِنْ أَحَدٍ يُسَلِّمُ عَلَيَّ إِلَّا رَدَّ اللهُ عَلَيَّ رُوحِي حَتَّى أَرُدَّ عَلَيْهِ السَّلَامَ».

“ជនណាម្នាក់ដែលបានឲ្យសាឡាមមកកាន់ខ្ញុំ អល់ឡោះជាម្ចាស់នឹងបង្វិលព្រលឹងរបស់ខ្ញុំមកកាន់ខ្ញុំវិញដើម្បីឲ្យខ្ញុំតបសាឡាមចំពោះគេ”។[1]

ហេតុនេះ វាគឺជាភស្តុតាងដែលបញ្ជាក់ថាលោកពិតជាបានទទួលមរណភាពហើយ ហើយព្រលឹងរបស់លោកបានឃ្លាតឆ្ងាយចេញពីរូបកាយរបស់លោក។ ក៏ប៉ុន្តែព្រលឹងនោះត្រូវបានគេត្រឡប់មកកាន់លោកវិញនៅពេលមានការឲ្យសាឡាមទៅកាន់លោក។ ហើយអត្ថបទភស្តុតាងទាំងឡាយពីគម្ពីរគួរអាន និងស៊ុណ្ណះដែលបញ្ជាក់ពីមរណភាពរបស់ណាពី ﷺ គឺត្រូវបានគេដឹងយ៉ាងច្បាស់លាស់ ហើយវាគឺជារឿងមួយដែលបណ្ដាអ្នកប្រាជ្ញបានឯកភាពគ្នាទៅលើវា។ ក៏ប៉ុន្តែរឿងនោះមិនបានរារាំងនូវជីវិតនៅក្នុងផ្នូររបស់លោកឡើយ ដូចដែលមរណភាពរបស់បណ្ដាសាហ៊ីទក៏មិនបានរារាំងនូវជីវិតនៅក្នុងផ្នូររបស់ពួកគេដែរ

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖២០៤១

ដែលមានចែងនៅក្នុងបន្ទូលរបស់អល់ឡោះជាម្ចាស់ ដែលទ្រង់បានមានបន្ទូលថាៈ

﴿وَلَا تَحْسَبَنَّ الَّذِينَ قُتِلُوا فِي سَبِيلِ اللَّهِ أَمْوَاتًا بَلْ أَحْيَاءٌ عِنْدَ رَبِّهِمْ يُرْزَقُونَ ١٦٩﴾

ហើយចូរអ្នក(ព្យាការីមូហាំម៉ាត់)កុំគិតស្មានថា បណ្តាអ្នកដែលត្រូវបានគេសម្លាប់(ពលីជីវិត)ក្នុងមាគ៌ារបស់អល់ឡោះនោះជាមនុស្សស្លាប់ឱ្យសោះ។ ផ្ទុយទៅវិញ ពួកគេមានជីវិតរស់នៅឯព្រះជាម្ចាស់របស់ពួកគេដោយពួកគេត្រូវបានប្រទានឲ្យនូវលាភសក្ការៈ(ជាច្រើនប្រភេទ)។ [គម្ពីរគួរអាន ៣:១៦៩]

ហើយយើងបានពន្យល់បកស្រាយយ៉ាងក្បោះក្បាយនៅក្នុងបញ្ហានេះ ដោយសារតែភាពចាំបាច់របស់វា ព្រោះតែមានអ្នកជាច្រើនដែលបង្កភាពមន្ទិលសង្ស័យក្នុងរឿងនេះ ហើយអំពាវនាវទៅកាន់អំពើស៊ីរិក និងការគោរពសក្ការៈអ្នកដែលបានស្លាប់ក្រៅពីអល់ឡោះ។ ដូច្នេះ យើងសូមបួងសួងដល់អល់ឡោះ ដើម្បីពួកយើង និងមូស្លីមទាំងអស់គ្នាមានសុវត្ថិភាពពីគ្រប់រឿងរ៉ាវដែលផ្ទុយនឹងច្បាប់របស់ទ្រង់។ ហើយអល់ឡោះជាអ្នកដឹងបំផុត។

ហើយរីឯអ្វីដែលអ្នកទស្សនកិច្ចធ្វើអំពីការតម្លើងសំឡេងខ្លាំងៗនៅឯផ្នូរណាពី ﷺ និងឈរនៅទីនោះយូរនោះ គឺវាជាប្រការដែលផ្ទុយពីច្បាប់ឥស្លាម។

ព្រោះតែអល់ឡោះបានហាមឃាត់អ្នកអ៊ីស្លាមអំពីការតម្លើងសំឡេងរបស់ពួកគេឱ្យខ្លាំងជាងសំឡេងរបស់ណាពី ﷺ និងការនិយាយខ្លាំងៗទៅកាន់គាត់ដូចជាការដែលពួកគេនិយាយខ្លាំងៗទៅកាន់គ្នាទៅវិញទៅមក
ហើយទ្រង់បានជំរុញពួកគេឱ្យបន្ថយសំឡេងនៅចំពោះមុខគាត់ នៅក្នុងបន្ទូលរបស់ទ្រង់ដែលថា៖

﴿يَا أَيُّهَا الَّذِينَ آمَنُوا لَا تَرْفَعُوا أَصْوَاتَكُمْ فَوْقَ صَوْتِ النَّبِيِّ وَلَا تَجْهَرُوا لَهُ بِالْقَوْلِ كَجَهْرِ بَعْضِكُمْ لِبَعْضٍ أَنْ تَحْبَطَ أَعْمَالُكُمْ وَأَنْتُمْ لَا تَشْعُرُونَ ۝٢ إِنَّ الَّذِينَ يَغُضُّونَ أَصْوَاتَهُمْ عِنْدَ رَسُولِ اللَّهِ أُولَٰئِكَ الَّذِينَ امْتَحَنَ اللَّهُ قُلُوبَهُمْ لِلتَّقْوَىٰ لَهُمْ مَغْفِرَةٌ وَأَجْرٌ عَظِيمٌ ۝٣﴾

ឱបណ្តាអ្នកដែលមានជំនឿ! ចូរពួកអ្នកកុំដំឡើងសំឡេងរបស់ពួកអ្នកខ្លាំងជាងសំឡេងរបស់ព្យាការី និងកុំហៅគាត់ខ្លាំងៗដូចពួកអ្នកហៅគ្នាឯងនោះឲ្យសោះ ខ្លាចក្រែងទង្វើកុសលរបស់ពួកអ្នកក្លាយជាអសារបង់ទាំងដែលពួកអ្នកមិនដឹងខ្លួន។

ពិតប្រាកដណាស់ បណ្តាអ្នកដែលថ្នមសំឡេងរបស់ពួកគេនៅចំពោះមុខអ្នកនាំសាររបស់អល់ឡោះ អ្នកទាំងនោះហើយជាអ្នកដែលអល់ឡោះទ្រង់សាកល្បងចិត្តរបស់ពួកគេដើម្បីឱ្យពួកគេកោតខ្លាច(ទ្រង់)។ សម្រាប់ពួកគេនឹងទទួលបាននូវការអភ័យទោស

និងផលបុណ្យដ៏ធំធេង។ (អាល់ហ្ជីរ៉តៈ ២-៣)។

ព្រោះតែការដែលឈរនៅយូរនៅឯផ្នូរណាពី ﷺ ហើយឱ្យសាឡាមច្រើនដងនោះ នឹងបណ្តាលឱ្យមានការកកស្ទះ និងមានជាការតម្លើងសម្លេងនៅឯផ្នូររបស់គាត់ ដែលវាជាទង្វើដែលផ្ទុយពីអ្វីដែលអល់ឡោះ បានបង្គាប់ប្រើមកចំពោះអ្នកអ៊ីស្លាមនៅក្នុងអាយ៉ាត់នេះ។ ណាពី ﷺ ត្រូវបានគេគោរពទាំងពេលនៅរស់ និងពេលស្លាប់។ ដូច្នេះ ចាំបាច់លើអ្នកមានជំនឿមិនត្រូវធ្វើអ្វីនៅឯកន្លែងផ្នូរដែលផ្ទុយពីសុជីវធម៌នៅក្នុងច្បាប់ឥស្លាមឡើយ។

ក៏ដូចគ្នាដែរ អ្វីដែលអ្នកទស្សនកិច្ច និងអ្នកផ្សេងទៀតធ្វើអំពីការព្យាយាមទូអាដោយលើកដៃទាំងពីរបែរមុខទៅផ្នូរណាពី ﷺ ទាំងនេះគឺផ្ទុយពីអ្នកជំនាន់មុនអំពីសាឡាហ្វ និងអ្នកបន្ទាប់ពីពួកគាត់នៃពួកតាពីអ៊ីនដ៏ល្អប្រសើរ ដែលវាគឺជាទង្វើពិទអះ(បង្កើតថ្មីនៅក្នុងសាសនាឥស្លាម), ហើយណាពី ﷺ បានមានប្រសាសន៍ថា៖

«فَعَلَيْكُمْ بِسُنَّتِي وَسُنَّةِ الْخُلَفَاءِ الرَّاشِدِينَ الْمَهْدِيِّينَ مِنْ بَعْدِي، تَمَسَّكُوا بِهَا وَعَضُّوا عَلَيْهَا بِالنَّوَاجِذِ، وَإِيَّاكُمْ وَمُحْدَثَاتِ الأُمُورِ، فَإِنَّ كُلَّ مُحْدَثَةٍ بِدْعَةٌ وَكُلَّ بِدْعَةٍ ضَلَالَةٌ».

“ហេតុនេះ ចូរពួកអ្នកប្រកាន់ខ្ជាប់នូវមាគ៌ា(ស៊ុណ្ណះ)របស់ខ្ញុំ

និងមាគ៌ារបស់អ្នកគ្រប់គ្រងដ៏ឈ្លាសវៃដែលត្រូវបាន គេចង្អុលបង្ហាញផ្លូវឲ្យបន្ទាប់ពីខ្ញុំ(យូឡាហ្វាកអើរ៉ស៊ីទីន),
ចូរពួកអ្នកប្រកាន់ខ្ជាប់នូវវាហើយខាំវានឹងធ្មេញថ្គាម។
ហើយចូរប្រុងប្រយ័ត្នចំពោះប្រការទាំងឡាយដែលគេ បង្កើតថ្មី(នៅក្នុងសាសនា)
ព្រោះរាល់ប្រការដែលគេបង្កើតថ្មីគឺជាប្រការពិតអះ ហើយរាល់ប្រការពិតអះគឺសុទ្ធតែវង្វេង»[1]។

លោកបានមានប្រសាសន៍ទៀតថា៖

«مَنْ أَحْدَثَ فِي أَمْرِنَا هَذَا مَا لَيْسَ مِنْهُ فَهُوَ رَدٌّ».

“បុគ្គលណាបង្កើតអ្វីមួយថ្មីនៅក្នុងកិច្ចការសាសនារបស់យើង
ហើយប្រការនោះពុំមែនជាកិច្ចការសាសនាពីយើងទេ នោះ វានឹងត្រូវគេបដិសេធចោល”[2]។

«مَنْ عَمِلَ عَمَلًا لَيْسَ عَلَيْهِ أَمْرُنَا فَهُوَ رَدٌّ».

“បុគ្គលណាធ្វើទង្វើអ្វីមួយ(ក្នុងការគោរពសក្ការៈ)ដែល មិនមែនជាកិច្ចការសាសនារបស់យើងទេនោះ វានឹងត្រូវគេបដិសេធចោល”។[3]

---

1 រាយការណ៍ដោយ អាពូហ្ទើវូទ៖៤៦០៧

2 ប្រភពរបស់វាត្រូវបានបញ្ជាក់រួចហើយ។

3 ប្រភពរបស់វាត្រូវបានបញ្ជាក់រួចហើយ។

អាលី កូន អាល់ហ៊ូសេន ហៀនូលអាពីឌីន رضي الله عنهما
បានឃើញបុរសម្នាក់កំពុងបួងសួងនៅក្បែរផ្នូររបស់ណាពី ﷺ គាត់ក៏បានហាមឃាត់បុរសនោះ ហើយបាននិយាយថា៖
តើឲ្យខ្ញុំនិយាយប្រាប់អ្នកនូវហាទីស្ហមួយទេ ដែលខ្ញុំបានឮអំពីឪពុករបស់ខ្ញុំ អំពីជីតារបស់ខ្ញុំ អំពីរ៉ស៊ូលុលឡោះ ﷺ ថា លោកបានមានប្រសាសន៍ថា៖

«لَا تَتَّخِذُوا قَبْرِي عِيدًا، وَلَا بُيُوتَكُمْ قُبُورًا، وَصَلُّوا عَلَيَّ، فَإِنَّ تَسْلِيمَكُمْ يَبْلُغُنِي أَيْنَمَا كُنْتُمْ».

“ចូរពួកអ្នកកុំយកផ្នូររបស់ខ្ញុំធ្វើជាកន្លែងធ្វើបុណ្យ ហើយកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ។ ប៉ុន្តែចូរពួកអ្នកសឡាវ៉ាតមកចំពោះខ្ញុំចុះ ព្រោះការតាស្លីមរបស់ពួកអ្នកនឹងមកដល់ខ្ញុំ ទោះជាពួកអ្នកស្ថិតនៅទីណាក៏ដោយ”[1]។

ក៏ដូចគ្នាដែរ អ្វីដែលអ្នកទស្សនកិច្ចធ្វើនៅពេលឱ្យសាឡាមទៅកាន់ណាពី ﷺ

1 សេចក្តីរាយការណ៍របស់លោក ស៊ែណាល់អាពីឌីន ត្រូវបានអ្នកនិពន្ធយោងទៅលើភស្តុតាងរបស់លោក អាល់ហាហ្វិស អាល់មឹកឌីស៊ី ដែលលោកបានដកស្រង់យកតែខ្លឹមសារបច្ចេកទេសនៃហាទីសមកបង្ហាញ ដោយកាត់ចេញនូវសាច់រឿងវែងឆ្ងាយដែលពាក់ព័ន្ធ។ ជាមួយគ្នានេះដែរ ហាទីស្ហនេះក៏មានវត្តមាននៅក្នុងសៀវភៅ "មូស្នាត់" របស់អ៊ីម៉ាំ អាះម៉ាត់ផងដែរ។ (២/៣៦៧)។

ដោយការដាក់ដៃស្តាំលើដៃឆ្វេងលើទ្រូងឬក្រោមទ្រូង ដូចគ្នាទៅនឹងពេលសឡាតនោះ គឺមិនត្រូវបានអនុញ្ញាតឡើយនៅពេលឱ្យសាឡាមទៅកាន់ណាពី ﷺ ហើយក៏មិនត្រូវបានអនុញ្ញាតនៅពេលឱ្យសាឡាមទៅកាន់អ្នកផ្សេងទៀតដែរ ដូចជាពួកស្តេច ពួកមេដឹកនាំ និងអ្នកដទៃទៀត ព្រោះការធ្វើបែបនេះ វាជារូបភាពនៃការឱនលំទោនបន្ទាបខ្លួន និងគោរពសក្ការៈ ដែលវាមិនគប្បីឡើយលើកលែងតែសម្រាប់អល់ឡោះ ដូចដែល អ៊ីបនូហាជើរ បានលើកឡើងនៅក្នុងសៀវភៅ الفتح عن العلماء ហើយបញ្ហានេះគឺពិតជាច្បាស់លាស់ណាស់សម្រាប់អ្នកដែលបានពិចារណា ហើយគោលបំណងរបស់គាត់គឺដើម្បីធ្វើតាមការណែនាំរបស់អ្នកជំនាន់មុនអំពីសាឡាហ្វ។

ចំណែកឯអ្នកដែលត្រូវបានគ្របដណ្តប់ដោយការនិយមជ្រុល ចំណង់ចំណូលចិត្ត ការធ្វើត្រាប់តាមដោយងងឹតងងល់ និងការគិតអាក្រក់ទៅលើអ្នកអំពាវនាវទៅកាន់មាគ៌ានៃបុព្វការីជនដ៏ល្អត្រឹមត្រូវ គឺរឿងរបស់គេប្រគល់ទៅចំពោះអល់ឡោះ។ ហើយយើងសូមបួងសួងដល់អល់ឡោះ សូមទ្រង់ប្រទានដល់យើង និងគេនូវការចង្អុលបង្ហាញ និងការសម្រួល ដើម្បីឱ្យបានជ្រើសយកសេចក្តីពិតជាងអ្វីៗផ្សេងទៀ

ត។ ពិតប្រាកដណាស់ ទ្រង់មហាវិសុទ្ធ គឺជាម្ចាស់ដ៏ប្រសើរបំផុតដែលត្រូវបួងសួងសុំ។

ក៏ដូចគ្នាដែរ អ្វីដែលមនុស្សមួយចំនួនធ្វើអំពីការបែរមុខទៅកាន់ផ្នូរណាពី ﷺ ពីចម្ងាយ ហើយធ្វើចលនាបបូរមាត់ដោយឱ្យសាឡាម ឬទូអា ទាំងអស់នេះគឺស្ថិតនៅក្នុងប្រភេទនៃទង្វើពិទអះដូចគ្នា។ ហើយមិនគប្បីសម្រាប់អ្នកមុស្លីមក្នុងការបង្កើតថ្មីនៅក្នុងសាសនារបស់គាត់នូវអ្វីដែលអល់ឡោះមិនបានអនុញ្ញាតនោះឡើយ។ ហើយតាមរយៈទង្វើនេះ គឺកាន់តែជិតទៅនឹងការបែរខ្នងចេញ ជាជាងការស្រឡាញ់រាប់អាន និងភាពស្មោះត្រង់។ ហើយអ៊ីមុាំម៉ាលិកបានបដិសេធនូវទង្វើនេះ និងទង្វើដែលស្រដៀងនឹងវា ហើយគាត់បាននិយាយថាៈ "អ្នកជំនាន់ក្រោយនៃប្រជាជាតិនេះ នឹងមិនអាចល្អប្រសើរបានឡើយ ក្រៅពីអ្វីដែលបានធ្វើឱ្យអ្នកជំនាន់មុនរបស់ខ្លួនល្អប្រសើរនោះទេ"[1]។

គេដឹងច្បាស់ហើយថា អ្វីដែលបានធ្វើឱ្យប្រជាជាតិជំនាន់ដំបូងនេះមានភា

[1] ដកស្រង់ចេញពីសៀវភៅ ការជួយសង្គ្រោះដល់អ្នកដែលកំពុងវង្វេង និងមានទុក្ខព្រួយ ឱ្យរួចផុតពីអន្ទាក់ទាំងឡាយរបស់ស្ហៃតន (១/៣៦៣)។

ពត្រឹមត្រូវ គឺការដើរតាមមាគ៌ារបស់ណាពី ﷺ យូឡាហ្វាកអើររ៉ស៊ីទីន សហាហ្គាត់របស់លោក និងអ្នកដែលដើរតាមពួកគេដោយល្អត្រឹមត្រូវ ហើយប្រជាជាតិជំនាន់ចុងក្រោយនេះ ក៏នឹងមិនមានភាពត្រឹមត្រូវឡើយ លុះត្រាតែពួកគេប្រកាន់ខ្ជាប់ និងដើរតាមមាគ៌ានោះ។

សូមអល់ឡោះមេត្តាផ្តល់ភាពជោគជ័យដល់មូស្លីមទាំងឡាយ ក្នុងកិច្ចការទាំងឡាយណាដែលផ្តល់នូវការសង្គ្រោះ សុភមង្គល និងកិត្តិយសដល់ពួកគេ ទាំងក្នុងលោកិយ និងបរលោក។ ពិតប្រាកដណាស់ ទ្រង់គឺជាម្ចាស់ដែលមហាសប្បុរស និងឧត្តុង្គឧត្តមបំផុត។

## ការព្រមាន
## ហ៊ូកុមនៃការទស្សនកិច្ចផ្នូររបស់ណាពី ﷺ

ការទស្សនកិច្ចផ្នូររបស់ណាពី ﷺ មិនមែនជាកាតព្វកិច្ច ឬជាលក្ខខណ្ឌក្នុងការធ្វើហាជ្ជី ដូចដែលមនុស្សទូទៅមួយចំនួនគិតនោះឡើយ តែវាជាប្រការគប្បីចំពោះអ្នកដែលបានទៅទស្សនកិច្ចម៉ាស្ជិតរបស់រ៉សូល ﷺ ឬស្ថិតនៅក្បែរនោះ។

ចំណែកឯអ្នកដែលនៅឆ្ងាយពីទីក្រុងម៉ាឌីណះ គឺមិនអនុញ្ញាតឱ្យព្យាយាមធ្វើដំណើរក្នុងគោលបំណងដើម្បីទៅទស្សនកិច្ចផ្នូរឡើយ។

ប៉ុន្តែគេត្រូវបានណែនាំឱ្យព្យាយាមធ្វើដំណើរក្នុងគោលបំណងទៅកាន់ម៉ាស្ជិតដ៏មានកិត្តិយស (ម៉ាស្ជិតណាពី)។ ហើយនៅពេលដែលគេទៅដល់ទីនោះ គេអាចទៅទស្សនកិច្ចផ្នូរដ៏មានកិត្តិយស (របស់ណាពី ﷺ) និងផ្នូររបស់សហាហ្ពាត់ទាំងពីរ។ ដូច្នេះ ការទស្សនកិច្ចផ្នូររបស់លោក ﷺ និងផ្នូររបស់សហាហ្ពាត់ទាំងពីរ គឺគ្រាន់តែជាផ្នែកមួយនៃការទស្សនកិច្ចទៅកាន់ម៉ាស្ជិតរបស់លោក ﷺ ប៉ុណ្ណោះ។ នេះគឺដោយសារតែមានបញ្ជាក់នៅក្នុងសៀវភៅសហើសទាំងពីរថា ព្យាការី ﷺ លោកបានមានប្រសាសន៍ថា៖

«لَا تُشَدُّ الرِّحَالُ إِلَّا إِلَى ثَلَاثَةِ مَسَاجِدَ: المَسْجِدِ الحَرَامِ، وَمَسْجِدِي هَذَا، وَالمَسْجِدِ الأَقْصَى».

“ចូរពួកអ្នកកុំព្យាយាមធ្វើដំណើរ លើកលែងតែទៅកាន់ម៉ាស្ជិតបីប៉ុណ្ណោះ គឺម៉ាស្ជិតអាល់ហារ៉ម ម៉ាស្ជិតណាហ្ពាវី និងម៉ាស្ជិតអាល់អឹកស”[1]។

ប្រសិនបើការព្យាយាមធ្វើដំណើរនៅក្នុងគោលបំណងដើម្បីទៅទស្សនកិច្ចផ្នូររបស់លោក ﷺ ឬផ្នូររបស់អ្នកដទៃត្រូវបានអនុញ្ញាតពិតណាស់លោកនឹងបង្ហាញប្រាប់ដល់សហគមន៍អ៊ីស្លាមអំពីវា

1 រាយការណ៍ដោយ អាល់ពូខរី៖១១៨៩, មូស្លីម៖១៣៩៧

ហើយនឹងណែនាំពួកគេទៅកាន់ភាពប្រសើររបស់វា។ ព្រោះថាលោកជាអ្នកដែលស្មោះត្រង់បំផុតចំពោះមនុស្ស ជាអ្នកដែលដឹងច្បាស់បំផុតអំពីអល់ឡោះ និងជាអ្នកដែលកោតខ្លាចទ្រង់ជាងគេបំផុត។ ហើយជាការពិតណាស់លោកបានផ្សព្វផ្សាយសារលិខិតយ៉ាងច្បាស់លាស់ ហើយបានបង្ហាញប្រាប់ប្រជាជាតិរបស់លោកទៅកាន់រាល់អំពើល្អទាំងអស់ និងបានព្រមានពួកគេពីគ្រប់អំពើអាក្រក់ទាំងអស់។ តើវាយ៉ាងដូចម្ដេចទៅ បើលោកបានព្រមានរួចហើយពីការព្យាយាមធ្វើដំណើរទៅកាន់កន្លែងផ្សេងក្រៅពីម៉ាស្ជិតទាំងបី ហើយលោកបានមានប្រសាសន៍ថា៖

«لَا تَتَّخِذُوا قَبْرِي عِيدًا، وَلَا بُيُوتَكُمْ قُبُورًا، وَصَلُّوا عَلَيَّ، فَإِنَّ صَلَاتَكُمْ تَبْلُغُنِي حَيْثُ كُنتُمْ».

“ចូរពួកអ្នកកុំយកផ្នូររបស់ខ្ញុំធ្វើជាកន្លែងធ្វើបុណ្យ ហើយកុំចាត់ទុកផ្ទះរបស់ពួកអ្នកជាផ្នូរ។ ប៉ុន្តែចូរពួកអ្នកសឡាវ៉ាតមកចំពោះខ្ញុំចុះ ព្រោះការសឡាវ៉ាតរបស់ពួកអ្នកនឹងមកដល់ខ្ញុំ ទោះជាពួកអ្នកស្ថិតនៅទីណាក៏ដោយ”[1]

ហើយការយល់ឃើញថា ការព្យាយាមធ្វើដំណើរដើម្បីទៅមើលផ្នូររបស់លោក ﷺ

1 បានបញ្ជាក់ប្រភពរួចហើយ។

គឺជារឿងដែលអនុញ្ញាត
វានឹងនាំទៅរកការយកវាធ្វើជាបុណ្យ
និងនាំឲ្យកើតមាននូវរឿងដែលត្រូវហាមឃាត់ដែល
ណាពី ﷺ បានព្រួយបារម្ភ នោះគឺការលើកតម្កើងជ្រុល
និងការសរសើរលើសលប់។
ដូចដែលមនុស្សជាច្រើនបានធ្លាក់ចូលទៅក្នុងរឿង
នោះ
ក៏ដោយសារតែការជឿរបស់ពួកគេអំពីការអនុញ្ញាត
ឱ្យព្យាយាមធ្វើដំណើរដើម្បីទៅមើលផ្នូររបស់លោក ﷺ
ដែរ។

ចំណែកឯហាទីស្អដែលត្រូវបានគេរាយការណ៍នៅក្នុងរឿងនេះ
ដែលត្រូវបានគេយកមកធ្វើជាភស្តុតាងដោយអ្នកដែលនិយាយអំពីការអនុញ្ញាតឱ្យព្យាយាមធ្វើដំណើរទៅកាន់ផ្នូររបស់លោក ﷺ នោះ
គឺវាជាហាទីស្អដែលមានសាណាត់ខ្សោយ
ថែមទាំងជាហាទីស្អប្រឌិតទៀតផង
ដូចដែលក្រុមហាហ្វិសបានបញ្ជាក់ពីភាពខ្សោយរបស់វា ដូចជា អាល់ហ្គើរ៉កុដនី អាល់ពៃហាគី និងអាល់ហាហ្វិស អ៊ិបនូហាជើរ និងអ្នកផ្សេងទៀត។
ដូចនេះ
មិនអនុញ្ញាតឱ្យយកហាទីស្អទាំងនោះមកប្រឆាំងនឹងហាទីសដែលត្រឹមត្រូវ
ដែលបញ្ជាក់អំពីការហាមឃាត់ការព្យាយាមធ្វើដំណើរទៅកាន់កន្លែងផ្សេងក្រៅពីម៉ាស្ជិតទាំងបីឡើយ។

អ្នកអានជាទីគោរព ខាងក្រោមនេះគឺជាហាទីស្ហដែលប្រឌិតមួយចំនួនក្នុងរឿងនេះ ដើម្បីឱ្យអ្នកបានស្គាល់វា និងប្រយ័ត្នអំពីវាៈ

ទីមួយៈ (អ្នកណាដែលមកធ្វើហាជ្ជីហើយមិនបានមកទស្សនកិច្ចខ្ញុំទេនោះ មានន័យថា គេមិនអើពើនឹងខ្ញុំឡើយ)។

ទីពីរៈ (អ្នកណាដែលមកទស្សនកិច្ចខ្ញុំបន្ទាប់ពីខ្ញុំស្លាប់នោះ គឺដូចជាគេបានមកទស្សនកិច្ចខ្ញុំនៅពេលនៅរស់ដែរ)។

ទីបីៈ (អ្នកណាដែលមកទស្សនកិច្ចខ្ញុំ និងឪពុករបស់ខ្ញុំនៅឆ្នាំតែមួយ នោះខ្ញុំនឹងធានានូវឋានសួគ៌ពីអល់ឡោះជូនគេ)។

ទីបួនៈ (អ្នកណាដែលមកទស្សនកិច្ចផ្នូររបស់ខ្ញុំ គឺគេនឹងត្រូវទទួលបានការស្ហាហ្វាអាត់(ជួយអន្តរាគមន៍)ពីខ្ញុំ)។

ហាទីសទាំងនេះ និងហាទីស្ហស្រដៀងគ្នាមួយចំនួនទៀត គឺគ្មានការបញ្ជាក់ពីណាពី ﷺ ឡើយ។

អាល់ហាហ្វីស អ៊ិបនូហាជើរ បាននិយាយនៅក្នុងសៀវភៅ التلخيص ថាៈ បន្ទាប់ពីបានរៀបរាប់ជាច្រើននៃរីវ៉ាយ៉ាត់ គឺសាណាត់ទាំងអស់នៃហាទីស្ហនេះគឺខ្សោយ។

អាល់ហាហ្វីស អាល់អាគីលី បាននិយាយថាៈ គ្មានអ្វីដែលត្រឹមត្រូវក្នុងរឿងនេះទេ។

ស្ហាបាត់ឥស្លាម អ៊ិពនូតៃមីយ៉ះ រ៉ហ៊ីម៉ាហ៊ុលឡោះ បានអះអាងយ៉ាងម៉ឺងម៉ាត់ថា ហាទីស្ហទាំងអស់នេះសុទ្ធតែជាហាទីស្ហប្រឌិត។ ហើយចំណេះដឹង ការចងចាំ និងការយល់ដឹងដ៏ទូលំទូលាយរបស់គាត់គឺគ្រប់គ្រាន់ហើយ។

ប្រសិនបើមានរឿងណាមួយក្នុងចំណោមនោះដែលត្រូវបានបញ្ជាក់ច្បាស់លាស់មែននោះ បណ្ដាសហាហ្ពាត់ رضي الله عنهم ពិតជាអ្នកដែលនាំមុខគេក្នុងការប្រតិបត្តិវា និងបញ្ជាក់បកស្រាយវាដល់សហគមន៍ឥស្លាម ហើយនិងអំពាវនាវពួកគេទៅកាន់វា។ ព្រោះថាពួកគាត់គឺជាមនុស្សល្អបំផុតបន្ទាប់ពីបណ្ដាព្យាការី ហើយជាអ្នកដែលមានចំណេះដឹងបំផុតអំពីព្រំដែនកំណត់របស់អល់ឡោះ និងអំពីអ្វីដែលទ្រង់បានបញ្ញត្តិសម្រាប់ខ្ញុំបម្រើរបស់ទ្រង់ និងជាអ្នកដែលស្មោះត្រង់បំផុតចំពោះអល់ឡោះ និងចំពោះភារៈរបស់ទ្រង់។ ហេតុដូច្នេះហើយ នៅពេលដែលគ្មានអ្វីមួយក្នុងចំណោមរឿងនោះត្រូវបានគេរាយការណ៍ពីពួកគាត់សោះ នោះវាបានបង្ហាញឱ្យឃើញថា រឿងនោះគឺមិនត្រូវបានបញ្ញត្តិឡើងឡើយ។

ហើយទោះបីជាមានខ្លះក្នុងចំណោមនោះដែលត្រឹមត្រូវក៏ដោយ ក៏ចាំបាច់ត្រូវយល់ថា នោះគឺជាការទស្សនកិច្ចដែលស្របនឹងច្បាប់ឥស្លាម

ដែលគ្មានការព្យាយាមធ្វើដំណើរក្នុងគោលបំណងទៅកាន់ផ្លូវតែមួយគត់នោះទេ
ដើម្បីបង្រួបបង្រួមរវាងហាទីស្ទទាំងឡាយ។
ហើយអល់ឡោះជាម្ចាស់ទ្រង់ជ្រាបច្បាស់បំផុត។

## ជំពូក

## អំពីការស៊ូណាត់នៃការទស្សនកិច្ចម៉ាស្ជិតគូហ្បាក និងការទៅមើលអាល់ហ្បាគៀក

ស៊ូណាត់ឲ្យអ្នកដែលទៅទស្សនកិច្ចម៉ាទីណះទៅទស្សនកិច្ចម៉ាស្ជិតគូហ្បាក់ និងសឡាតនៅទីនោះព្រោះមាននៅក្នុងសហើសទាំងពីរពីហាទីស្ទរបស់អុិបនូអូមើរ رضي الله عنهما លោកបាននិយាយថា៖

«كَانَ النَّبِيُّ ﷺ يَزُورُ مَسْجِدَ قُبَاءٍ رَاكِبًا وَمَاشِيًا وَيُصَلِّي فِيهِ رَكْعَتَيْنِ».

«ណាពី ﷺ លោកបានទៅទស្សនកិច្ចម៉ាស្ជិតគូហ្បាក់ដោយថ្មើរជើង និងដោយយានជំនិះ ហើយបានសឡាតនៅទីនោះពីររ៉ក្អាត់»។[1]

ហើយអំពី សះល៍ កូន ហ៊ូណៃហ្វ៍ رضي الله عنه បាននិយាយថា៖ រ៉ស៊ូលុលឡោះ ﷺ លោកបានមានប្រសាសន៍ថា៖

«مَنْ تَطَهَّرَ فِي بَيْتِهِ ثُمَّ أَتَى مَسْجِدَ قُبَاءٍ فَصَلَّى فِيهِ صَلَاةً كَانَ لَهُ كَأَجْرِ عُمْرَةٍ».

“ជនណាដែលបានយកទឹកវូហ្កុពីផ្ទះរបស់ខ្លួន

---

1 រាយការណ៍ដោយ អាល់ពូខរី៖១១៩៣, មូស្លីម៖១៣៩៩

ហើយបានធ្វើដំណើរទៅម៉ាស្ជិតគូហ្ពាក់ ហើយបានសឡាតនៅក្នុងវា នោះគេទទួលបានផលបុណ្យស្មើនឹងការធ្វើអ៊ុំរ៉ោះ”1។

គេប្រើស៊ូណិតឲ្យទៅទស្សនកិច្ចទីបញ្ចុះសពអាល់ហ្គាកៀក និងផ្នូររបស់អ្នកដែលបានស្លាប់ស្ហាហ៊ីទ និងផ្នូរហាំហ្សះ رضي الله عنه ព្រោះព្យាការី ﷺ លោកធ្លាប់ទៅទស្សនកិច្ចផ្នូរពួកគេ និងបួងសួងសុំទូអាឲ្យពួកគេ ហើយរ៉ស៊ូលុលឡោះ ﷺ បានមានប្រសាសន៍ថា៖

«زُورُوا القُبُورَ فَإِنَّهَا تُذَكِّرُكُمْ بِالآخِرَةِ».

«ចូរពួកអ្នកទៅមើលផ្នូរ ព្រោះវាធ្វើឱ្យពួកអ្នកនឹកដល់ថ្ងៃបរលោក»2។ រាយការណ៍ដោយ មូស្លីម

ណាពី ﷺ លោកតែងបង្រៀនសហាហ្ពាត់របស់លោក នៅពេលដែលពួកគេទៅទស្សនកិច្ចផ្នូរ ឲ្យសូត្រថា៖

«السَّلَامُ عَلَيْكُمْ أَهْلَ الدِّيَارِ مِنَ المُؤْمِنِينَ وَالمُسْلِمِينَ، وَإِنَّا إِنْ شَاءَ اللهُ بِكُمْ لَاحِقُونَ، نَسْأَلُ اللهَ لَنَا وَلَكُمُ العَافِيَةَ».

«សូមសេចក្តីសុខកើតមានដល់ពួកអ្នក ដែលជាអ្នករស់នៅក្នុងលំនៅដ្ឋាន(ផ្នូរ)នេះ ពីក្នុងចំណោមអ្នកមានជំនឿ និងអ្នកមូស្លីម។ ហើយពិតណាស់ពួកយើង

---

1 រាយការណ៍ដោយ អ៊ិបនូ ម៉ាចាស់៖១៤១២

2 កត់ត្រាដោយមូស្លីម លេខ (976)។

ប្រសិនបើអល់ឡោះទ្រង់មានចេតនា
គឺពិតជានឹងទៅតាមក្រោយពួកអ្នក។
ពួកយើងសូមបួងសួងដល់អល់ឡោះ
សូមទ្រង់ប្រទាននូវសុខសុវត្ថិភាពសម្រាប់ពួកយើង
និងសម្រាប់ពួកអ្នកផងដែរ»[1]។ រាយការណ៍ដោយ អ៊ីម៉ាំមូស្លីម ពីហាទីស្ហរបស់ ស៊ូឡៃម៉ាន កូន ពូរ៉ៃដះ ពីឪពុករបស់គាត់។

ហើយ អាត់-ទើមីហ្ស៊ី បានរាយការណ៍អំពី អ៊ិពនូអាប់ហ្ពាស رضي الله عنهما បាននិយាយថា៖ ណាពី ﷺ លោកបានដើរកាត់ផ្នូរទាំងឡាយនៅទីក្រុងម៉ាឌីណះ។ ពេលនោះ លោកបានបែរមុខទៅរកផ្នូរទាំងនោះ ហើយបានមានប្រសាសន៍ថា៖

«السَّلَامُ عَلَيْكُمْ يَا أَهْلَ القُبُورِ، يَغْفِرُ اللهُ لَنَا وَلَكُمْ، أَنْتُمْ سَلَفُنَا وَنَحْنُ بِالأَثَرِ».

«សូមសុខសន្តិភាពកើតមានដល់ពួកអ្នក ឱ! បណ្ដាអ្នកនៅក្នុងផ្នូរ
សូមអល់ឡោះអភ័យទោសឱ្យពួកយើង និងពួកអ្នក។
ពួកអ្នកបានទៅមុនពួកយើង
ហើយពួកយើងនឹងទៅតាមក្រោយ»[2]។

ហើយតាមរយ:ហាទីស្ហទាំងនេះ គេបានដឹងថា គោលបំណងនៃការទៅមើលផ្នូរដែលស្របតាមច្បាប់

---

1 រាយការណ៍ដោយ មូស្លីម៖៩៧៥

2 រាយការណ៍ដោយ អាត់តៀរមីហ្ស៊ី៖១០៣៥

សាសនា គឺការរំលឹកអំពីថ្ងៃបរលោក៖ ការផ្ញើល្អទៅកាន់អ្នកដែលស្លាប់៖ ការទូអាបួងសួងសម្រាប់ពួកគេ និងការសុំសេចក្ដីមេត្ដាករុណាសម្រាប់ពួកគេ។

ហើយរីឯការទស្សនកិច្ចដើម្បីធ្វើការទូអាបួងសួងនៅឯផ្នូររបស់ពួកគេ ឬការសម្ងំនៅទីនោះ ឬសុំជំនួយពីពួកគេ ឬសុំឱ្យជាសះស្បើយពីជំងឺ ឬសុំអល់ឡោះតាមរយៈពួកគេ ឬតាមស្ថានភាពរបស់ពួកគេ ឬផ្សេងទៀតនោះ គឺជាប្រការពិទអះដែលត្រូវបានហាមឃាត់ និងមិនត្រូវបានអល់ឡោះ និងរ៉សូលរបស់ទ្រង់បង្គាប់ប្រើនោះឡើយ ហើយអ្នកសាឡាហ្វជំនាន់មុន ដែលអល់ឡោះទ្រង់សព្វព្រះហឫទ័យនឹងពួកគេ ក៏មិនបានធ្វើដែរ។ ផ្ទុយទៅវិញ វាគឺជាការឃ្លាតចាកដែលរ៉សូល ﷺ បានហាមឃាត់ ដោយលោកបានមានប្រសាសន៍ថា៖

«زُورُوا الْقُبُورَ، وَلَا تَقُولُوا هُجْرًا».

“ចូរពួកអ្នកទៅទស្សនកិច្ចផ្នូរ និងកុំពោលពាក្យអាក្រក់”។[1]

ហើយកិច្ចការទាំងឡាយដែលបានរៀបរាប់នេះគឺសុទ្ធតែជាប្រការពិទអះ ប៉ុន្តែវាមានកម្រិតខុសៗគ្នា។ ក្នុងនោះ ខ្លះជាប្រការពិទអះ

1 រាយការណ៍ដោយមូស្លីម៖៩៧៧

តែមិនមែនជាអំពើស៊ីរិក
ដូចជាការទូអាបួងសួងសុំពីអល់ឡោះនៅឯផ្នូរទាំងឡាយ និងការសុំពីទ្រង់តាមរយៈសិទ្ធិរបស់អ្នកស្លាប់ និងឋានៈរបស់ពួកគេ
និងអ្វីផ្សេងទៀតដែលស្រដៀងគ្នានេះ។
ហើយខ្លះទៀតគឺជាប្រការស្ហ៊ីរិកធំ
ដូចជាការទូអាបួងសួងសុំពីអ្នកស្លាប់
និងការសុំជំនួយពីពួកគេ
និងអ្វីផ្សេងទៀតដែលស្រដៀងគ្នានេះ។

ហើយការពន្យល់បកស្រាយអំពីរឿងនេះ ត្រូវបានគេលើកឡើងយ៉ាងលម្អិតរួចមកហើយកាលពីមុន។ ដូច្នេះ ចូរអ្នកយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន ហើយចូរអ្នកសុំពីម្ចាស់របស់អ្នកនូវការផ្ដល់ភាពងាយស្រួល និងការចង្អុលបង្ហាញទៅកាន់សេចក្ដីពិត។ ពីព្រោះពិតណាស់
ទ្រង់គឺជាអ្នកដែលផ្ដល់ភាពងាយស្រួល
និងជាអ្នកចង្អុលបង្ហាញ
គ្មានព្រះណាផ្សេងដែលត្រូវគោរពសក្ការៈក្រៅពីទ្រង់ឡើយ ហើយក៏គ្មានម្ចាស់ណាផ្សេងក្រៅពីទ្រង់ដែរ។

នេះគឺជាការបញ្ចប់នៃអ្វីដែលយើងមានបំណងចង់បរិយាយ
ហើយការសរសើរទាំងឡាយគឺសម្រាប់អល់ឡោះទាំងដំបូងនិងចុងក្រោយ។
សូមអល់ឡោះប្រទានពរជ័យដល់ខ្ញុំបម្រើរបស់ទ្រង់ អ្នកនាំសាររបស់ទ្រង់

និងជាជម្រើសដ៏ឆ្នើមរបស់ទ្រង់ក្នុងចំណោមសត្វលោក គឺមូហាំម៉ាត់ ព្រមទាំងក្រុមគ្រួសារ និងបណ្ដាសហាហ្គាត់របស់គាត់ និងបណ្ដាអ្នកដែលបានដើរតាមពួកគេដោយសេចក្ដីល្អរហូតដល់ថ្ងៃជំនុំជំរះ។

❋❋❋

# Index


អារម្ភកថា អ្នកនិពន្ធ........2
ជំពូក........5
ភស្តុតាងនានានៃការដាក់កាតព្វធ្វើកិច្ចហាជ្ជី និងអ៊ុំរ៉ោះ និងការរួសរាន់ក្នុងការបំពេញអ៊ីហ្គាទាត់ទាំងពីរនេះ។........5
ជំពូក........12
កាតព្វកិច្ចត្រូវសារភាពកំហុសពីអំពើ និងបាបទាំងឡាយ និងការដោះស្រាយរាល់អំពើអយុត្តិធម៌ដែលបានប្រព្រឹត្តលើអ្នកដទៃ........12
ជំពូក........24
កិច្ចការរបស់អ្នកធ្វើហាជ្ជី នៅពេលពួកគេទៅដល់មីកត........24
ជំពូក........35
ស្តីពីទីតាំងកំណត់ (មីកត) និងការកំណត់ព្រំដែននៃទីតាំងទាំងនោះ........35
ជំពូក........43
ក្បួនច្បាប់ចំពោះអ្នកទៅដល់មីកតនៅក្រៅខែហាជ្ជី........43
ជំពូក........48
នៅក្នុងហ៊ូកុម(ច្បាប់) នៃការធ្វើហាជ្ជីរបស់កុមារតូច តើវាគ្រប់គ្រាន់សម្រាប់គាត់ជំនួសឱ្យហាជ្ជីនៃឥស្លាមដែរឬទេ?48
ជំពូក........54
ការបកស្រាយអំពីបម្រាមទាំងឡាយនៃអៀហរ៉ម និងកិច្ចការដែលអនុញ្ញាតសម្រាប់អ្នកអៀហរ៉ម........54
ជំពូក........68
អំពីកិច្ចការដែលអ្នកធ្វើហាជ្ជីត្រូវធ្វើនៅពេលចូលក្រុងម៉ាក្កះ និងការបកស្រាយអំពីអ្វីដែលត្រូវធ្វើបន្ទាប់ពីចូលក្នុងម៉ាស្ជិតហារ៉ម អំពីការតវ៉ាហ្វ និងរបៀបរបស់វា។........68
ជំពូក........83

ស្តីពីហ៊ូកុមនៃការនៀតអៀហរ៉មហាជ្ជីនៅថ្ងៃទីប្រាំបីនៃខែហ្ស៊ូលហ៊ិជ្ជះ និងការចាកចេញទៅកាន់មីណា ........................................ 83
ជំពូក ........................................................................................................ 120
បញ្ជាក់ពីឧត្តមភាពនៃទង្វើដែលអ្នកធ្វើហាជ្ជីអនុវត្តនៅថ្ងៃណះរ៍(ថ្ងៃរ៉យ៉ាសំឡេះសត្វ)។ ........................................................................ 120
ជំពូក ........................................................................................................ 131
កាតព្វកិច្ចនៃការសំឡេះសត្វជំនូនទៅលើអ្នកធ្វើហាជ្ជីបែបតាំម៉ាត់តួក និងគីរ៉ន។ ........................................................................ 131
ជំពូក ........................................................................................................ 135
វ៉ាជិប(ចាំបាច់)លើបណ្តាអ្នកធ្វើហាជ្ជី និងអ្នកផ្សេងទៀតត្រូវបង្គាប់ប្រើគ្នាឱ្យធ្វើអំ ពើល្អ។ .................................................... 135
ជំពូក ........................................................................................................ 152
ស៊ូណាត់សាងអំពើល្អឱ្យបានច្រើន។ ........................................ 152
ជំពូក ........................................................................................................ 155
អំពីក្បួនច្បាប់ និងសុជីវធម៌នៃការទស្សនកិច្ច ................... 155
ការព្រមាន .............................................................................................. 179
ហ៊ូកុមនៃការទស្សនកិច្ចផ្នូររបស់ណាពី ﷺ ................................ 179
ជំពូក ........................................................................................................ 185
អំពីការស៊ូណាត់នៃការទស្សនកិច្ចម៉ាស្ជិតគូហ្បាក និងការទៅមើលអាល់ហ្កាគៀក ...................................................... 185

***

km٣٩٦v٣,١ - ٠٦/٠٤/٢٠٢٦

رئاسة الشؤون الدينية
بالمسجد الحرام والمسجد النبوي

# رسالة الحرمين

# Message of The Two Holy Mosques

Guidance content for the visitors of the Holy Mosque and the Prophet's Mosque in languages.

978-603-517-247-9